Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា

ខែធ្នូ ឆ្នាំ២០២៤

THE WORLD BANK
IBRD • IDA | WORLD BANK GROUP
East Asia & Pacific

# ពីការស្ទុះងើបសេដ្ឋកិច្ចឡើងវិញឆ្ពោះទៅរកភាពធន់៖ ការប្រែក្លាយទេសចរណ៍និងពាណិជ្ជកម្មឱ្យទៅជាកត្តាជំរុញកំណើនសេដ្ឋកិច្ច

## អត្ថបទផ្តោតពិសេស

ឧបសគ្គរចនាសម្ព័ន្ធ ក្រុមហ៊ុន និងអាជីវកម្មចំពោះផលិតភាពការងារ



## បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា

ខែធ្នូ ឆ្នាំ២០២៤

# ពីការស្ទុះងើបសេដ្ឋកិច្ចឡើងវិញឆ្ពោះទៅរកភាពធន់៖ ការប្រែក្លាយទេសចរណ៍និងពាណិជ្ជកម្មឱ្យទៅជាកត្តាជំរុញកំណើនសេដ្ឋកិច្ច

## អត្ថបទផ្តោតពិសេស

ឧបសគ្គរចនាសម្ព័ន្ធ ក្រុមហ៊ុន
និងអាជីវកម្មចំពោះផលិតភាពការងារ

THE WORLD BANK
IBRD • IDA | WORLD BANK GROUP
East Asia & Pacific

# តារាងមាតិកា


**សេចក្តីថ្លែងអំណរគុណ** . . . . . . . . . . v
**អក្សរកាត់** . . . . . . . . . . vi
**សេចក្តីសង្ខេប** . . . . . . . . . . 1

**ផ្នែកទី១ ៖ ការវិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងចក្ខុវិស័យ** . . . . . . . . . . 7
- ការវិវឌ្ឍថ្មីៗ សកម្មភាពសេដ្ឋកិច្ចពិភពលោកស្ទុះងើបឡើងវិញ . . . . . . . . . . 8
- ក្នុងគ្រាដែលកត្តាខាងក្រៅមានភាពអំណោយផលសេដ្ឋកិច្ចរបស់កម្ពុជាមានភាពប្រសើរឡើងតិចតួច . . . . . . . . . . 10
- ភ្ញៀវទេសចរបរទេសដែលមកទស្សនា ខេត្តសៀមរាប នៅតែមានកម្រិតទាបខ្លាំងបើធៀបនឹងចំនួនភ្ញៀវទេចរក្នុងឆ្នាំ២០១៩ . . . . . . . . . . 11
- ការនាំចេញទំនិញបានកើនឡើង . . . . . . . . . . 11
- ការងារកម្មន្តសាលបានកើនឡើងដោយ សារកំណើននាំចេញសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងផលិតផលស្បែកជើង . . . . . . . . . . 12
- ចំណាប់អារម្មណ៍របស់វិនិយោគិនបានកើនឡើង . . . . . . . . . . 13
- ចំណាប់អារម្មណ៍ប្រកបដោយភាពទុទិដ្ឋិនិយមរបស់វិនិយោគិនក្នុងស្រុក ក្នុងការវិនិយោគលើវិស័យដែលអាចជួញដូរបាន . . . . . . . . . . 14
- ការធ្លាក់ចុះក្នុងវិស័យអចលនទ្រព្យបានបន្តកើតមាន . . . . . . . . . . 15
- ការនាំចូលដែកបានកើនឡើងយ៉ាងខ្លាំង ដែលត្រូវបានជំរុញដោយការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត . . . . . . . . . . 15
- ការនាំចេញទំនិញកសិកម្មបានថមថយ . . . . . . . . . . 16
- ការប្រើប្រាស់ឯកជនមានភាពប្រសើរឡើង . . . . . . . . . . 16
- អតិផរណានៅតែមានកម្រិតទាប . . . . . . . . . . 17
- ក្នុងពេលកំណើននាំចូលស្ទុះងើប ឡើងវិញ ឱនភាពគណនីចរន្តបានកើតមានសាជាថ្មី . . . . . . . . . . 19
- ប្រាក់រៀលឡើងថ្លៃតិចតួចធៀបទៅនឹងប្រាក់ដុល្លារអាមេរិក . . . . . . . . . . 19
- ការផ្គត់ផ្គង់សាច់ប្រាក់បន្តកើនឡើង . . . . . . . . . . 20
- អត្រាការប្រាក់ក្នុងស្រុកបានធ្លាក់ចុះ . . . . . . . . . . 20
- ឥណទានបានធ្លាក់ចុះខ្លាំង ខណៈដែល សកម្មភាពអភិវឌ្ឍន៍លំនៅឋាននៅទ្រឹង . . . . . . . . . . 21
- ការប្រមូលប្រាក់ចំណូលក្នុងស្រុកនៅតែយឺត . . . . . . . . . . 24
- កិច្ចប្រឹងប្រែងពង្រឹងថវិកាបានចាប់ផ្តើមទប់ស្កាត់ការចំណាយ . . . . . . . . . . 25
- ឱនភាពសារពើពន្ធជារួមបានធ្លាក់ចុះ . . . . . . . . . . 25
- ស្តុកបំណុលសាធារណៈបានកើនឡើង ដល់ ២៤,៤ភាគរយនៃ ផ.ស.ស . . . . . . . . . . 26
  - *ចក្ខុវិស័យ* . . . . . . . . . . *26*
  - *បញ្ហាប្រឈមនិងហានិភ័យ* . . . . . . . . . . *26*
  - *ជម្រើសគោលនយោបាយ* . . . . . . . . . . *28*

**ផ្នែកទី២ ៖ ឧបសគ្គរចនាសម្ព័ន្ធក្រុមហ៊ុន និងធុរកិច្ចចំពោះផលិតភាពការងារ** . . . . . . . . . . 29
- **I. សេចក្តីផ្តើម** . . . . . . . . . . 30
- **II. មូលដ្ឋានគ្រឹះរចនាសម្ព័ន្ធ និងផលិតភាពការងារកម្រិតក្រុមហ៊ុន** . . . . . . . . . . 30
- **III. ទិដ្ឋភាពទូទៅអំពីឧបសគ្គចំពោះការធ្វើអាជីវកម្ម** . . . . . . . . . . 34
- **IV. ឧបសគ្គខាងក្រៅចំពោះការធ្វើអាជីវកម្ម** . . . . . . . . . . 36
  - ក. ក្រុមហ៊ុនក្រៅផ្លូវការ . . . . . . . . . . 36
  - ខ. ហេដ្ឋារចនាសម្ព័ន្ធ . . . . . . . . . . 37
  - គ. លទ្ធភាពទទួលបានជំនាញ . . . . . . . . . . 38
  - ឃ. លទ្ធភាពទទួលបានហិរញ្ញវត្ថុ . . . . . . . . . . 39
- **V. ឧបសគ្គការិយាល័យធិបតេយ្យចំពោះការធ្វើអាជីវកម្ម** . . . . . . . . . . 41
  - ក. ពន្ធដារ . . . . . . . . . . 41
  - ខ. អំពើពុករលួយ . . . . . . . . . . 42
  - គ. តុលាការ . . . . . . . . . . 44
  - ឃ. ឯកសារអាជីវកម្មនិងដំណើរការ . . . . . . . . . . 44
- **VI. ភាពជំពាក់ជំពិនផ្នែកគោលនយោបាយនិងអនុសាសន៍** . . . . . . . . . . 45

**ឧបសម្ព័ន្ធ៖ កម្ពុជា-សូចនាករសំខាន់ៗ** . . . . . . . . . . 51
**គន្ថនិទ្ទេស** . . . . . . . . . . 53

# ប្រអប់


ប្រអប់ ១ ៖ ការស្វែងរកវិធីដោះស្រាយហានិភ័យនៃការធ្លាក់ចុះទីផ្សារអចលនទ្រព្យ . . . . . . . . . . . . . . . . . . . . . . . . . . 18
ប្រអប់ ២ ៖ ការកើនឡើងបំណុលគ្រួសារ. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 22
ប្រអប់ ៣ ៖ របាយការណ៍ Business-Ready ឆ្នាំ២០២៤ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 23


# រូបភាព


រូប ES១ ៖ សេចក្តីសង្ខេបអំពីការវិវឌ្ឍថ្មីៗរបស់កម្ពុជា. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 6
រូប ១ ៖ សន្ទស្សន៍ PMI រួមរបស់ពិភពលោក. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 8
រូប ២ ៖ ពាណិជ្ជកម្មទំនិញពិភពលោក. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 8
រូប ៣ ៖ សកម្មភាពសេដ្ឋកិច្ចមានភាពប្រសើរឡើងតិចតួច . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 10
រូប ៤ ៖ ការមកដល់របស់ភ្ញៀវទេសចរក្នុងរយៈពេល ៨ខែ និងប្រាក់ចំណូលពីវិស័យទេសចរណ៍ . . . . . . . . . . . . . . . . . *10*
រូប ៥ ៖ ប្រាក់ចំណូលពីការលក់សំបុត្រចូលទស្សនាតំបន់អង្គរ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 12
រូប ៦ ៖ ការចូលរួមចំណែកដល់កំណើននាំចេញតាមផលិតផល . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 12
រូប ៧ ៖ ការងារក្នុងវិស័យកម្មន្តសាល និងរោងចក្រ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 13
រូប ៨ ៖ តម្លៃគម្រោង QIP ដែលត្រូវបានអនុម័ត. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 13
រូប ៩ ៖ គម្រោងផ្តល់ហិរញ្ញប្បទានដោយ FDI ដែលត្រូវបានអនុម័តតាមវិស័យ. . . . . . . . . . . . . . . . . . . . . . . . . 14
រូប ១០ ៖ គម្រោងអចលនទ្រព្យដែលត្រូវបានអនុម័ត . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 14
រូប ១១ ៖ ការនាំចេញទំនិញកសិកម្ម . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 17
រូប ១២ ៖ ការនាំចូលទំនិញប្រើប្រាស់បានកើនឡើង. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 17
រូប B១.១ ៖ សន្ទស្សន៍តម្លៃអចលនទ្រព្យ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 19
រូប B១.២ ៖ ការវិនិយោគលើអចលនទ្រព្យនៅចិន និងលំហូរចូល FDI របស់ចិនចូលមកកាន់កម្ពុជា. . . . . . . . . . . . . . . . . 19
រូប ១៣ ៖ អតិផរណាបានធ្លាក់ចុះការចូលរួមចំណែកចំពោះអតិផរណាក្នុងរយៈពេល ១២ខែ. . . . . . . . . . . . . . . . . . . . 20
រូប ១៤ ៖ កំណើនរូបិយវត្ថុទូទៅបានស្ទុះងើបឡើងវិញការចូលរួមចំណែកចំពោះកំណើនរូបិយវត្ថុទូទៅ . . . . . . . . . . . . 20
រូប ១៥ ៖ អត្រាការប្រាក់នៅតែខ្ពស់ អត្រាការប្រាក់ក្នុងស្រុក . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 21
រូប ១៦ ៖ កំណើនឥណទានក្នុងស្រុកបានធ្លាក់ចុះ កំណើនឥណទាន . . . . . . . . . . . . . . . . . . . . . . . . . . . . . 21
រូប B២.១ ៖ បំណុលគ្រួសារមិនទាន់សងជាមធ្យម . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 23
រូប B២.២ ៖ ការទូទាត់សេវាបំណុល . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 23
រូប B.៣.១ ៖ លទ្ធផលរបស់កម្ពុជាតាមប្រធានបទនិងសរសរស្តម្ភ . . . . . . . . . . . . . . . . . . . . . . . . . . . . . . 23
រូប B.៣.២ ៖ ការប្រៀបធៀបក្នុងតំបន់ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 23
រូប ១៧ ៖ ការប្រមូលចំណូលក្នុងស្រុកមានភាពប្រសើរ ប្រាក់ចំណូលក្នុងស្រុករបស់រដ្ឋាភិបាលថ្នាក់កណ្តាល . . . . . . . . . . 24
រូប ១៨ ៖ ការចំណាយត្រូវបានទប់ស្កាត់ការចំណាយរបស់រដ្ឋាភិបាលថ្នាក់កណ្តាល. . . . . . . . . . . . . . . . . . . . . . . 24
រូប ១៩ ៖ ប្រតិបត្តិការរបស់រដ្ឋាភិបាលទូទៅ. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 25
រូប ២០ ៖ អតិរេក/ឱនភាពរបស់រដ្ឋាភិបាលទូទៅ និងការផ្តល់ហិរញ្ញប្បទាន. . . . . . . . . . . . . . . . . . . . . . . . . . . 25
រូប S.១ ៖ ផលិតភាពការងារក្នុងចំណោមក្រុមហ៊ុនកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់ តាមវិស័យ . . . . . . . . . . . . . . . . 31

រូប S.២ ៖ ភាពខុសគ្នានៃផលិតភាពការងារក្នុងចំណោមក្រុមហ៊ុនកម្ពុជាផ្អែកតាមលក្ខណៈក្រុមហ៊ុន តម្លៃបន្ថែមជាមធ្យមក្នុងនិយោជិតម្នាក់ (ដុល្លារអាមេរិក) ឆ្នាំ២០២៣. . . . . . . . . . . . . . . . . . . . . . . . . . . . . .31
រូប S.៣ ៖ ភាពខុសគ្នានៃផលិតភាពការងារក្នុងចំណោមក្រុមហ៊ុនកម្ពុជាផ្អែកតាមការអនុវត្ត . . . . . . . . . . . . . . . . . . . .32
រូប S.៤ ៖ ភាពខុសគ្នានៃផលិតភាពការងារក្នុងចំណោមក្រុមហ៊ុនកម្ពុជាផ្អែកតាមកម្រិតអនុវត្ត និងធៀបនឹងប្រទេសក្នុងតំបន់ . . .33
រូប S.៥ ៖ ចំណាត់ថ្នាក់ឧបសគ្គក្នុងការធ្វើអាជីវកម្មក្នុងប្រទេសកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់ . . . . . . . . . . . . . . . . . . .35
រូប S.៦ ៖ ចំណាត់ថ្នាក់ឧបសគ្គក្នុងការធ្វើអាជីវកម្មនៅកម្ពុជាផ្អែកតាមលក្ខណៈក្រុមហ៊ុន. . . . . . . . . . . . . . . . . . . . . . .36
រូប S.៧ ៖ ឧបសគ្គវិស័យក្រៅប្រព័ន្ធនៅកម្ពុជាផ្អែកតាមលក្ខណៈក្រុមហ៊ុន . . . . . . . . . . . . . . . . . . . . . . . . . . . . . . .37
រូប S.៨ ៖ ឧបសគ្គអគ្គិសនីនៅកម្ពុជាផ្អែកតាមលក្ខណៈក្រុមហ៊ុន . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .38
រូប S.៩ ៖ ឧបសគ្គជំនាញក្នុងចំណោមក្រុមហ៊ុនកម្ពុជាផ្អែកតាមលក្ខណៈក្រុមហ៊ុន. . . . . . . . . . . . . . . . . . . . . . . . . . .39
រូប S.១០ ៖ សង្ខេបអំពីលក្ខណៈអប់រំរបស់កម្លាំងពលកម្មក្នុងចំណោមក្រុមហ៊ុនកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់ . . . . . . . . . .39
រូប S.១១ ៖ ភាពខុសគ្នានៃលទ្ធភាពទទួលហិរញ្ញវត្ថុក្នុងចំណោមក្រុមហ៊ុនកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់ តាមវិស័យ . . . . . .40
រូប S.១២ ៖ ឧបសគ្គរដ្ឋបាលពន្ធដារក្នុងចំណោមក្រុមហ៊ុនកម្ពុជាផ្អែកតាមលក្ខណៈក្រុមហ៊ុន. . . . . . . . . . . . . . . . . . . . . . .41
រូប S.១៣ ៖ កត្តាបង្កឱ្យមានការព្រួយបារម្ភអំពីពន្ធក្នុងចំណោមក្រុមហ៊ុនកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់. . . . . . . . . . . . . . .42
រូប S.១៤ ៖ កត្តាជំរុញឱ្យមានការបារម្ភអំពីអំពើពុករលួយក្នុងចំណោមក្រុមហ៊ុនកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់ . . . . . . . . . .43
រូប S.១៥ ៖ ការកើតមានការចំណាយក្រៅផ្លូវការក្នុងចំណោមក្រុមហ៊ុនកម្ពុជាផ្អែកតាមលក្ខណៈក្រុមហ៊ុន . . . . . . . . . . . . . . .43
រូប S.១៦ ៖ ការយល់ឃើញអំពីឯករាជ្យភាពរបស់តុលាការក្នុងវិវាទពាណិជ្ជកម្មក្នុងចំណោមក្រុមហ៊ុនកម្ពុជា ធៀបនឹងប្រទេសក្នុងតំបន់ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .44
រូប S.១៧ ៖ ពេលវេលាផ្តល់សេវាកម្មអាជីវកម្មសម្រាប់ក្រុមហ៊ុនក្នុងប្រទេសកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់. . . . . . . . . . . . .45

# តារាង

តារាង ES១ ៖ ចក្ខុវិស័យម៉ាក្រូ (ភាគរយនៃ ផសស លុះត្រាតែមានការបង្ហាញផ្សេងពីនេះ) . . . . . . . . . . . . . . . . . . . . . . . . . .3
តារាង ២ ៖ ចក្ខុវិស័យម៉ាក្រូបង្ហាញពីភាពប្រសើរឡើងនៃសេដ្ឋកិច្ចជាបន្ត . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .27

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍ស្តីពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា (CEU) ខែធ្នូ ឆ្នាំ២០២៤ ត្រូវបានរៀបចំឡើងដោយលោក លី សូដេត និង Faya Hayati ដោយមានការចូលរួមចំណែកពី Samuel Christopher Hill, Hassan Noura, Aka Kyaw Min Maw, តុង គីមស៊ុន, ភឹម រុនស៊ីណារិទ្ធិ និង Tim L. De Vann។ ហ៊ាវ ចាន់កេសី ជាជំនួយការស្រាវជ្រាវ។ អ៊ុំ ស៊ីណា ជាជំនួយការផ្នែករដ្ឋបាល។ លោក ប៊ូ សារឿន ផ្តល់ជំនួយលើការងារផ្នែកផ្សព្វផ្សាយព័ត៌មាន ការងារបង្ហោះលើគេហទំព័រ និងកម្មវិធីផ្សព្វផ្សាយ។

ក្រុមការងារបានធ្វើការងារ ក្រោមការណែនាំរួមរបស់លោក Sebastian Eckardt។ ក្រុមការងារសូមថ្លែងអំណរគុណសម្រាប់ដំបូន្មាន និងយោបល់របស់ Lalita M. Moorty, Mariam Sherman និង Tania Meyer។ សូមថ្លែងអំណរគុណដល់សហសេវិកមួយចំនួនទៀតរួមទាំង Aaditya Mattoo និង Ergys Islamaj បានផ្តល់យោបល់សម្រាប់សេចក្តីព្រាងរបស់របាយការណ៍នេះ។

ក្រុមការងារសូមថ្លែងអំណរគុណចំពោះអាជ្ញាធរកម្ពុជា ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជាចំពោះកិច្ចសហការ និងការគាំទ្រ។ អាជ្ញាធរទើបតែកែប្រែមូលដ្ឋាន[1] សម្រាប់ការគណនាផលិតផលក្នុងស្រុកសរុប (ផ.ស.ស) របស់កម្ពុជា។ ទិន្នន័យ ផ.ស.ស ដែលផ្អែកលើមូលដ្ឋានថ្មីនេះប្រើប្រាស់ឆ្នាំ២០១៤ ធ្វើជាមូលដ្ឋាន ហើយមូលដ្ឋាននេះនឹងចាប់ផ្តើមប្រើប្រាស់ក្នុងរបាយការណ៍ស្តីពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២៤ នេះតទៅ។ របាយការណ៍នេះក៏ទទួលបានដំបូន្មាន មតិយោបល់ និងទស្សនៈរបស់ភាគីពាក់ព័ន្ធផ្សេងៗនៅក្នុងប្រទេសកម្ពុជា រួមទាំងអ្នកអាន និងអ្នករិះគន់ផងដែរ។

របាយការណ៍ ស្តីពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ដែលចេញផ្សាយពីរដងក្នុងមួយឆ្នាំ ផ្តល់ព័ត៌មានបច្ចុប្បន្នភាពអំពីការវិវឌ្ឍម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ របាយការណ៍នេះត្រូវបានចែកចាយ និងពិភាក្សាយ៉ាងទូលំទូលាយ រួមទាំងក្នុងចំណោមអាជ្ញាធរកម្ពុជា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ស្ថាប័នស្រាវជ្រាវនិងផ្តល់យោបល់ (Think tanks) អង្គការសង្គមស៊ីវិល និងក្រុមអ្នកសិក្សាជាន់ខ្ពស់ផងដែរ។

សម្រាប់ព័ត៌មានអំពីធនាគារពិភពលោក និងសកម្មភាពរបស់ធនាគារនៅក្នុងប្រទេសកម្ពុជា សូមចូលទៅកាន់គេហទំព័ររបស់យើងតាមរយៈ www.worldbank.org/cambodia។

ដើម្បីទទួលបានរបាយការណ៍ ស្តីពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា និងការបោះពុម្ពផ្សាយដែលពាក់ព័ន្ធផ្សេងទៀត សូមទាក់ទង អ៊ុំ ស៊ីណា (soum1@worldbank.org)។ សម្រាប់សំណួរពាក់ព័ន្ធនឹងខ្លឹមសាររបស់របាយការណ៍នេះ សូមទាក់ទងលោក ប៊ូ សារឿន (sbou@worldbank.org )។

លទ្ធផលរកឃើញ ការបកស្រាយ និងការសន្និដ្ឋាន ដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ មិនឆ្លុះបញ្ចាំងទស្សនៈរបស់នាយកប្រតិបត្តិធនាគារពិភពលោក ឬរដ្ឋាភិបាលដែលពួកគេតំណាងឱ្យនោះឡើយ។ ធនាគារពិភពលោកមិនធានានូវភាពត្រឹមត្រូវរបស់ទិន្នន័យ ដែលត្រូវបានរួមបញ្ចូលនៅក្នុងការងារនេះទេ។ ព្រំប្រទល់ ពណ៌ កំណត់សម្គាល់ និងព័ត៌មានផ្សេងទៀត ដែលត្រូវបានបង្ហាញនៅលើផែនទីណាមួយនៅក្នុងការងារនេះ មិនបានបញ្ជាក់ពីការវិនិច្ឆ័យណាមួយ របស់ធនាគារពិភពលោក ទាក់ទងនឹងស្ថានភាពផ្លូវច្បាប់របស់ដែនដីណាមួយ ឬការយល់ព្រម ឬការទទួលយកព្រំប្រទល់បែបនោះទេ។

1 ការកែប្រែមូលដ្ឋានសម្រាប់ការគណនា ផ.ស.ស មានការពាក់ព័ន្ធនឹងការជំនួសឆ្នាំមូលដ្ឋានចាស់ជាមួយនឹងឆ្នាំមូលដ្ឋានថ្មី ដើម្បីស្របតាមការវិវត្តនៃតម្លៃ។

# អក្សរកាត់

| | |
|---|---|
| **ASEAN** | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| **B-READY** | គម្រោងប្រមូលនិងវិភាគទិន្នន័យ Business Ready |
| **CEO** | ប្រធាននាយកប្រតិបត្តិ |
| **CEU** | បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា |
| **COVID-19** | ជំងឺវីរុសកូរ៉ូណាឆ្នាំ២០១៩ |
| **CPI** | សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ |
| **CSES** | ការអង្កេតសេដ្ឋកិច្ចកិច្ច-សង្គមកិច្ចកម្ពុជា |
| **DTI** | បំណុលធៀបនឹងប្រាក់ចំណូល |
| **EAP** | តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក |
| **EMDE** | ប្រទេសកំពុងអភិវឌ្ឍន៍ខ្លាំង និងប្រទេសកំពុងអភិវឌ្ឍន៍ |
| **EU** | សហភាពអឺរ៉ុប |
| **FDI** | ការវិនិយោគផ្ទាល់ពីបរទេស |
| **Fed** | ធនាគារកណ្តាលសហរដ្ឋអាមេរិក |
| **GDP** | ផលិតផលក្នុងស្រុកសរុប |
| **GTF** | សម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងផលិតផលស្បែងជើង |
| **MFI** | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| **PMI** | សន្ទស្សន៍អ្នកគ្រប់គ្រងការបញ្ជាទិញ |
| **QIP** | គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ |
| **SMEs** | សហគ្រាសធុនតូចនិងមធ្យម |
| **SDR** | ទ្រព្យបម្រុងអន្តរជាតិ SDR |
| **US$** | ដុល្លារសហរដ្ឋអាមេរិក |
| **USDA** | ក្រសួងកសិកម្មសហរដ្ឋអាមេរិក |
| **VAT** | ពន្ធលើតម្លៃបន្ថែម |
| **y/y** | ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន |

# សេចក្តីសង្ខេប

## *ការវិវឌ្ឍថ្មីៗ*

**សកម្មភាពសេដ្ឋកិច្ច មានស្ថិរភាពនៅក្នុងឆ្នាំ២០២៤ ប៉ុន្តែលទ្ធផលនៅតែមិនទាន់មានតុល្យភាពនៅទូទាំងវិស័យ។** ការស្ទុះងើបឡើងវិញនៃតម្រូវការ និងពាណិជ្ជកម្មខាងក្រៅ បានជំរុញឱ្យមានការស្ទុះងើបឡើងវិញនៃការនាំចេញទំនិញ និងសេវាកម្ម។ ក្នុងអំឡុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ការនាំចេញទំនិញបានកើនឡើង ១៣,៩ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (y/y) ដែលភាគច្រើនជំរុញដោយផលិតផលសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង (GTF)។ ទន្ទឹមនឹងនោះដែរ ការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិ បានបន្តកើនឡើងដោយកើនឡើងចំនួន ២២,៥ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដល់ ៤,៣លាននាក់។ បើទោះបីជាការចំណាយរបស់ភ្ញៀវទេសចរ មានភាពប្រសើរឡើង ដូចដែលបានបង្ហាញតាមរយៈការប្រមូលប្រាក់ចំណូល ពីការលក់សំបុត្រចូលទស្សនាតំបន់អង្គរ ដែលកើនឡើង ៣១,៤ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនក៏ដោយ ក៏ការចំណាយនេះមានកម្រិតទាបជាងចំនួនភ្ញៀវទេសចរដែលមកទស្សនា។ ទោះបីជារយៈពេលស្នាក់នៅជាមធ្យមសម្រាប់ភ្ញៀវទេសចរ បានកើនឡើងដល់ ៧,៦ថ្ងៃក្នុងឆ្នាំ២០២៣ ធៀបនឹង ៦,២ថ្ងៃ ក្នុងឆ្នាំ២០១៩ ក៏ដោយ ក៏ចំណូលពីវិស័យទេសចរណ៍សរុបដែលបានប៉ាន់ស្មានបានធ្លាក់ចុះពីចំនួន ៤,៩៣ពាន់លានដុល្លារអាមេរិកមកត្រឹមចំនួន ៣,០៨ពាន់លានដុល្លារអាមេរិក ដោយសារការថយចុះការចំណាយជាមធ្យមក្នុងភ្ញៀវទេសចរម្នាក់។

**លើសពីនេះ ការស្ទុះងើបឡើងវិញនៃការប្រើប្រាស់ឯកជនកំពុងជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកឱ្យមានភាពប្រសើរឡើង។** ក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ការនាំចូលទំនិញប្រើប្រាស់ រួមទាំងប្រេងម៉ាស៊ូត ឧបករណ៍អេឡិចត្រូនិក ប្រេងសាំង គ្រឿងឧបភោគបរិភោគ សម្លៀកបំពាក់ និងភេសជ្ជៈ បានកើនឡើង ២៣,៦ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ដោយបង្ហាញពីភាពប្រសើរឡើងនៃអារម្មណ៍របស់វិនិយោគិន ទឹកប្រាក់វិនិយោគ ដែលផ្តល់ហិរញ្ញប្បទានដោយការវិនិយោគផ្ទាល់ពីបរទេស (FDI) ដែលត្រូវបានអនុម័ត (នៅខាងក្រៅតំបន់សេដ្ឋកិច្ចពិសេស) ស្ថិតក្រោមគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) បានកើនឡើងដល់ ១,១២ពាន់លានដុល្លារអាមេរិក ពោលគឺកើនឡើង ២៤,៣ភាគរយក្នុងអំឡុងពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ការវិនិយោគស្ថិតក្រោមភាពជាដៃគូសាធារណៈ និងឯកជននៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធបរវន្តធំៗ ដូចជាផ្លូវថ្នល់ និងកំពង់ផែបានជំរុញសេវាកម្មសាងសង់។ ក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ការនាំចូលឧបករណ៍សំណង់ និងដែកថែបបានកើនឡើង ២០,១ភាគរយ និង ៥៩,២ភាគរយ រៀងគ្នា។

**ផ្ទុយទៅវិញ ការវិនិយោគលើវិស័យអចលនទ្រព្យនៅតែមានកម្រិតទាប។** ការធ្លាក់ចុះវិស័យអចលនទ្រព្យ បានបន្តឆ្លុះបញ្ចាំងឱ្យឃើញពីភាពលើសតម្រូវការនៅក្នុងទីផ្សារអចលនទ្រព្យ និងការបន្តធ្លាក់ចុះទីផ្សារលំនៅឋាន។ លិខិតអនុញ្ញាតអភិវឌ្ឍអចលនទ្រព្យឯកជនដែលត្រូវបានអនុម័ត បានធ្លាក់ចុះចំនួន ២៩,១ភាគរយគិតជាទឹកប្រាក់នៅក្នុងអំឡុងពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

**សមតុល្យគណនីចរន្ត ត្រូវបានព្យាករថានឹងមានភាពអវិជ្ជមាននៅឆ្នាំនេះ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីការស្ទុះងើបឡើងវិញ នៃតម្រូវការនាំចូលដែលត្រូវបានប៉ះប៉ូវមួយផ្នែកប៉ុណ្ណោះ ដោយការកើនឡើងប្រាក់បញ្ញើពីបរទេស និងប្រាក់ចំណូលពីវិស័យទេសចរណ៍។** ឱនភាពនេះនៅតែបន្តផ្តល់ហិរញ្ញប្បទានដោយលំហូរចូលមូលធន ប្រកបដោយនិរន្តរភាព។ ក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ការបន្តលំហូរចូលមូលធនដ៏រឹងមាំ ជាពិសេសការវិនិយោគផ្ទាល់ពីបរទេស បានជួយបន្ធូរបន្ថយសម្ពាធលើអត្រាប្តូរប្រាក់ និងបានជំរុញប្រាក់បម្រុងរូបិយប័ណ្ណអន្តរជាតិដុល ដែលបានកើនឡើងដល់ ២០,៧ពាន់លានដុល្លារអាមេរិក ពោលគឺកើនឡើង ១១,៣ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលមានសមត្ថភាពគ្របដណ្តប់ការចំណាយលើការនាំចូលបានប្រហែលប្រាំពីរខែ។

**អតិផរណានៅមានកម្រិតទាប ដោយសារតែការធ្លាក់ចុះតម្លៃស្បៀងអាហារ និងប្រេងឆៅ។** សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ (CPI) របស់ប្រទេសកម្ពុជា បានកើនឡើង ០,៣ភាគរយក្នុងខែសីហា ឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលជាកម្រិតទាបបំផុតក្នុងរយៈពេល ១៥ឆ្នាំ។ ការធ្លាក់ចុះតម្លៃម្ហូបអាហារ ជាពិសេសសាច់ ត្រី បន្លែ និងផ្លែឈើ បានកាត់បន្ថយអតិផរណា ដោយសារសមាសធាតុអាហារ (សន្ទស្សន៍រង) មានចំណែក ៤៣ភាគរយនៅក្នុងកញ្ចប់អតិផរណា។

**គោលនយោបាយរូបិយវត្ថុនៅតែមានលក្ខណៈសមរម្យ ដោយមានការកើនឡើងការផ្គត់ផ្គង់ប្រាក់នាពេលថ្មីៗនេះ។** ដោយឆ្លុះបញ្ចាំងពីការកើនឡើងលំហូរចូលមូលធន រូបិយវត្ថុទូទៅ (broad money) បានកើនឡើង ១៤,៣ភាគរយក្នុងរយៈពេល ១២ខែដែលបញ្ចប់ក្នុងខែសីហា ឆ្នាំ២០២៤ ពោលគឺកើនឡើងពី ១១ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៣ ដោយសារការកើនឡើងប្រាក់បញ្ញើរូបិយប័ណ្ណបរទេស។ ដោយសារថា សេដ្ឋកិច្ចកម្ពុជាប្រើប្រាស់ប្រាក់ដុល្លារអាមេរិកខ្ពស់

ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស បានរួមចំណែកយ៉ាងខ្លាំងដល់កំណើនរូបិយវត្ថុទូទៅ។

**សម្ពាធដែលកើនឡើងទៅលើអត្រាការប្រាក់ក្នុងស្រុកកំពុងចាប់ផ្តើមថមថយ ខណៈដែលសេដ្ឋកិច្ច ដែលប្រើប្រាស់ប្រាក់ដុល្លារច្រើនរបស់ប្រទេសកម្ពុជានាំចូលគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក ដែលបានចាប់ផ្តើមថមថយបន្ទាប់ពីធនាគារកណ្តាលអាមេរិក (Fed) កាត់បន្ថយអត្រាការប្រាក់មូលនិធិ Fed ចំនួន ៥០ពិន្ទុមូលដ្ឋានក្នុងខែកញ្ញា និង ២៥ពិន្ទុមូលដ្ឋានក្នុងខែវិច្ឆិកា ឆ្នាំ២០២៤ រៀងគ្នា។** ទោះបីយ៉ាងណាកាធ្លាក់ចុះគួរឱ្យកត់សម្គាល់នៃកំណើនឥណទានក្នុងស្រុក បានបន្តកើតមានក្នុងគ្រា ដែលតម្រូវការឥណទានខ្សោយដោយសារការធ្លាក់ចុះវិស័យអចលនទ្រព្យ ដោយឥណទានបានធ្លាក់ចុះយ៉ាងខ្លាំងដល់ ៣,៤ភាគរយ ដែលជាកម្រិតទាបបំផុតនៅក្នុងរយៈពេល ១៤ឆ្នាំកាលពីខែសីហា ឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ពោលគឺធ្លាក់ចុះពីអត្រា ៧,៧ភាគរយនៅក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៣។ ទន្ទឹមនឹងនេះដែរ អនុបាតប្រាក់កម្ចីមិនដំណើរការ ក្នុងប្រទេសកម្ពុជា បានកើនឡើងដល់ ៦,៨ភាគរយសម្រាប់វិស័យធនាគារ និង ៨,៣ភាគរយសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុគិតត្រឹមពាក់កណ្តាលឆ្នាំ២០២៤ ដែលកើនឡើងពីអត្រា ៥,៤ភាគរយ និង ៦,៧ភាគរយរៀងគ្នាក្នុងឆ្នាំ២០២៣។

**ក្នុងគ្រាដែលមានការធ្លាក់ចុះ វដ្តឥណទាន តារាងតុល្យការរបស់វិស័យធនាគារ កំពុងចុះខ្សោយ។** គិតត្រឹមពាក់កណ្តាលឆ្នាំ២០២៤ ការកើនឡើងអនុបាតកម្ចីមិនដំណើរការដល់ ៦,៨ភាគរយសម្រាប់វិស័យធនាគារ និង ៨,៣ភាគរយសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ បង្ហាញពីការចុះខ្សោយបន្ថែមទៀតនៃគុណភាពទ្រព្យសកម្ម ក្នុងគ្រាដែលមានការធ្លាក់ចុះជាបន្តនៅក្នុងវិស័យអចលនទ្រព្យ។ ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មនៃវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុបានធ្លាក់ចុះមកត្រឹម ០,៦ភាគរយ និង ១,៥ភាគរយរៀងគ្នាក្នុងឆ្នាំ២០២៣ ពីអត្រា ១,៩ភាគរយ និង ២,៨ភាគរយក្នុងឆ្នាំ២០១៩។ ដូចគ្នានេះដែរ ក្នុងរយៈពេលដូចគ្នានេះ ប្រាក់ចំណេញធៀបនឹងដើមទុនវិនិយោគបានធ្លាក់ចុះមកនៅត្រឹម ៣,៤ភាគរយ និង ៥,៩ភាគរយរៀងគ្នាពីអត្រា ៩,៨ភាគរយ និង ១៩,៨ភាគរយរៀងគ្នា។

**ខណៈពេលដែលសម្ពាធសារពើពន្ធនៅតែបន្ត ប្រាក់ចំណូលក្នុងស្រុកបានបង្ហាញពីភាពប្រសើរឡើងតិចតួច។** ក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ប្រាក់ចំណូលក្នុងស្រុករបស់រដ្ឋាភិបាលកណ្តាលបានកើនឡើង ៤,៥ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ពីអត្រា ០,៤ភាគរយក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣។ ភាពប្រសើរឡើងនេះត្រូវបានគាំទ្រដោយការស្ទុះងើបឡើងវិញនៃការប្រើប្រាស់ឯកជន ដែលបានជួយបង្កើនប្រាក់ចំណូលពន្ធលើទំនិញនិងសេវាកម្ម និងដោយសារពាណិជ្ជកម្មអន្តរជាតិ។ លើសពីនេះទៀត ការស្ទុះ ងើបឡើងវិញនៃសកម្មភាពទេសចរណ៍ បានចូលរួមចំណែកដល់ការកើនឡើងប្រាក់ចំណូលមិនមែនសារពើពន្ធ។

**ដើម្បីរក្សានិរន្តរភាពសារពើពន្ធ អាជ្ញាធរបានចាប់ផ្តើមទប់ស្កាត់ការចំណាយ ជាពិសេសការចំណាយមូលធន។** ក្នុងអំឡុងពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ការចំណាយរបស់រដ្ឋាភិបាលថ្នាក់កណ្តាលត្រូវបានទប់ស្កាត់ ដោយបានធ្លាក់ចុះដល់អត្រាអវិជ្ជមាន ០,៣ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ពីកំណើនវិជ្ជមាន ១៥,១ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៣។ ទោះជាយ៉ាងណា ប្រាក់បញ្ញើរបស់រដ្ឋាភិបាល (ទុនបម្រុងសារពើពន្ធ) នៅតែមានសុខភាពល្អដោយមានអត្រា ១១,៤ ភាគរយនៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស) នៅក្នុងខែសីហា ឆ្នាំ២០២៤ ហើយបំណុលសាធារណៈនៅតែមានកម្រិតទាបប្រហែល ២៧ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅក្នុងឆ្នាំ២០២៣។

**ការស្ទុះងើបឡើងវិញនៃការនាំចេញ បាននាំឱ្យស្ថានភាពទីផ្សារការងារមានភាពប្រសើរឡើង។** នៅក្នុងខែសីហា ឆ្នាំ២០២៤ ការងារនៅក្នុងវិស័យកម្មន្តសាលផ្លូវការដែលមានចំនួន១៩,៤ភាគរយនៃការងារមិនមែនកសិកម្ម បានកើនឡើង ៩,៥ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលគាំទ្រដល់ការប្រើប្រាស់គ្រួសារ និងជួយឱ្យធ្លាក់ចុះមួយផ្នែកមកវិញនៃភាពក្រីក្រ ដែលបានកើនឡើងដោយសារជំងឺរាតត្បាត។ រូប ES.១ បង្ហាញពីការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចនាពេលថ្មីៗ នេះរបស់កម្ពុជា។

## ចក្ខុវិស័យ

**ដោយប្រើប្រាស់មូលដ្ឋានថ្មី សម្រាប់ការគណនាទិន្នន័យគណនីជាតិ កំណើនសេដ្ឋកិច្ចនៅឆ្នាំនេះត្រូវបានព្យាករថានឹងកើនឡើងដល់ ៥,៣ភាគរយ (តារាង ES.1.) បើធៀបនឹងអត្រា ៥ភាគរយក្នុងឆ្នាំ២០២៣ ដែលជំរុញជាចម្បងដោយសារសេវាកម្ម និងការនាំចេញទំនិញ។** ការកើនឡើងការនាំចេញជាពិសេសការកើនឡើងការនាំចេញទំនិញសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងផលិតស្បែកជើង ការស្ទុះងើបឡើងវិញនៃឧស្សាហកម្មធ្វើដំណើរ និងទេសចរណ៍ និងលំហូរចូលជាបន្តនៃការវិនិយោគផ្ទាល់ពីបរទេស បានជួយទ្រទ្រង់ដល់ការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចនៅឆ្នាំនេះ។

**ក្នុងរយៈពេលខ្លី កំណើន ផ.ស.ស ពិតរបស់កម្ពុជា ត្រូវបានព្យាករថានឹងមានភាពប្រសើរឡើងបន្តិច ដោយនឹងកើនឡើងដល់ ៥,៥ភាគរយនៅឆ្នាំ២០២៥ និង២០២៦។** ទោះបីជាតម្រូវការក្នុងស្រុកត្រូវបានរំពឹងថា នឹងមានភាពប្រសើរឡើងបន្ថែមទៀតក្នុងរយៈពេលពីរឆ្នាំខាងមុខ ដែលគាំទ្រដោយភាពប្រសើរឡើងនៃទីផ្សារការងារ និងការរំពឹងទុកថាអតិផរណានឹងស្ថិតក្នុងអត្រា

ល្អក៏ដោយ ក៏ការស្ទុះងើបសេដ្ឋកិច្ចឡើងវិញនេះ នៅតែមិនមានភាពពេញលេញនោះទេ។ ការណ៍នេះគឺដោយសារតែការស្ទុះងើបឡើងវិញនៃការប្រើប្រាស់ក្នុងស្រុក ដែលមានចំណែកប្រហែល ២ ភាគ ៣ នៃផលិតផលក្នុងស្រុកសរុប នឹងត្រូវបានរងផលប៉ះពាល់ដោយសារការធ្លាក់ចុះកំណើនឥណទានក្នុងស្រុក ដែលបណ្តាលមកពីការអូសបន្លាយពេលយូរនៃការធ្លាក់ចុះវិស័យសំណង់ និងអចលនទ្រព្យ។ លើសពីនេះ ឥទ្ធិពលទ្រព្យសម្បត្តិអវិជ្ជមាននៃការធ្លាក់ចុះតម្លៃផ្ទះ និងជាពិសេសបំណុលគ្រួសារខ្ពស់ ដែលការទូទាត់សេវាបំណុលកើនឡើងជិតដល់ ៥០ភាគរយនៃប្រាក់ចំណូល ទំនងជានឹងរារាំងដល់ការប្រើប្រាស់បន្តទៅមុខ។

**សម្រាប់ផ្នែកផលិតកម្មវិញ ឧស្សាហកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ចទំនងជានឹងមានភាពប្រសើរឡើងបន្ថែមទៀត ដោយមានការព្យាករថានឹងមានការកើនឡើងចំនួនភ្ញៀវទេសចរអន្តរជាតិ។** ខណៈពេលដែលការនាំចេញទំនិញកម្មន្តសាលជាពិសេសទំនិញសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងផលិតផលស្បែកជើង នឹងនៅតែងាយរងគ្រោះទៅនឹងតម្រូវការខាងក្រៅ ផលិតកម្មកសិកម្មនិងឧស្សាហកម្មកែច្នៃ បន្តទទួលបានការជំរុញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគី។ ឧស្សាហកម្មធ្វើដំណើរ ដឹកជញ្ជូន និងឡូជិស្ទិក គួរតែទទួលបានអត្ថប្រយោជន៍ ពីការវិនិយោគឯកជនខ្លាំងនៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗមួយចំនួន ដូចជាផ្លូវល្បឿនលឿនដែលទើបសាងសង់ថ្មីតភ្ជាប់ពីរាជធានីភ្នំពេញទៅកាន់ខេត្តព្រះសីហនុ ជាទីកន្លែងដែលមានកំពង់ផែទឹកជ្រៅ គម្រោងអភិវឌ្ឍន៍កំពង់ផែពហុមុខងារ និងទីតាំងឡូជិស្ទិកថ្មីនៅក្នុងខេត្តកំពត និងរាជធានីភ្នំពេញ និងគម្រោងផ្លូវល្បឿនលឿនថ្មីមួយទៀតដែលនឹងតភ្ជាប់ពីរាជធានីភ្នំពេញទៅកាន់ទីក្រុងបាវិតនៅព្រំដែនប្រទេសកម្ពុជា-វៀតណាម និងគម្រោងផ្សេងៗទៀត។

**ជាមួយនឹង ការធ្លាក់ចុះការប្រើប្រាស់ឯកជនដោយសារតែការធ្លាក់ចុះរយៈពេលយូរ នៅក្នុងវិស័យអចលនទ្រព្យ អតុល្យភាពខាងក្រៅត្រូវបានរំពឹងថានឹងប្រសើរឡើងនៅក្នុងរយៈពេលខ្លីដល់រយៈពេលមធ្យម។** ខណៈពេលដែលប្រាក់បញ្ញើពីបរទេស និងប្រាក់ចំណូលពីវិស័យទេសចរណ៍ នឹងបន្តជំរុញប្រាក់ចំណូលសុទ្ធ និងសេវាកម្ម ការវិនិយោគផ្ទាល់ពីបរទេស គួរតែបន្តជួយផ្តល់ហិរញ្ញប្បទានដល់ឱនភាពគណនីចរន្ត ដែលត្រូវបានព្យាករថានឹងកើតមានតិចតួចបំផុតនាពេលខាងមុខ។ ក្នុងរយៈពេលខ្លីដល់មធ្យម កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរក្នុងការធ្វើឱ្យប្រសើរឡើងនូវការប្រមូលចំណូល អនុវត្តការពង្រឹងសារពើពន្ធ និងបង្កើនប្រសិទ្ធភាពចំណាយស្ថិតក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគួរតែជួយឱ្យឱនភាពសារពើពន្ធសរុបរួមតូច ដែលឱនភាពនេះត្រូវបានកំណត់ក្នុងបរិមាណស្មើ ឬក្រោម ៥ភាគរយនៃ ផ.ស.ស។

**តារាង ES១ ៖ ចង្កូវិស័យម៉ាក្រូ**
(ភាគរយនៃ ផសស លុះត្រាតែមានការបង្ហាញផ្សេងពីនេះ)

| | ការព្យាករ | | | ប្រែប្រួលធៀបនឹងខែមិថុនា ឆ្នាំ២០២៤ | | |
|---|---|---|---|---|---|---|
| | ២០២៤ | ២០២៥ | ២០២៦ | ២០២៤ | ២០២៥ | ២០២៦ |
| **កំណើនពិត** (ភាគរយ) | ៥,៣ | ៥,៥ | ៥,៥ | -០,៥ | -០,៦ | -០,៩ |
| **CPI** (រយៈពេលជាមធ្យម, ភាគរយ) | ២,២ | ២,២ | ២,២ | -០,៦ | -០,៥ | -០,៨ |
| **គណនីចរន្ត** | -១,០ | -១,៥ | -១,៨ | -៣,៧ | -៤,១ | -៣,៤ |
| **ឱនភាពសារពើពន្ធរួម** | -៣ | -៣,៣ | -៣,២ | ២,៥ | ១,១ | ១ |
| **បំណុលសាធារណៈ** | ២៦,៩ | ២៧,៤ | ២៧,៤ | -៨,៦ | -៨,១ | -៧,៤ |

*សម្គាល់៖ ១/* ការប្រៀបធៀបដែលបានបង្ហាញនៅក្នុងជួរឈរ “ការប្រែប្រួលធៀបនឹងខែមិថុនា ឆ្នាំ២០២៤” គឺគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ។ ការណ៍នេះគឺដោយសារតែទិន្នន័យនៅក្នុងជួរឈរ “ការព្យាករ” (លើកលែងតែទិន្នន័យ CPI) ដែលមានមូលដ្ឋានលើឆ្នាំមូលដ្ឋាន២០១៤ នៃទិន្នន័យគណនីជាតិមិនអាចប្រៀបធៀបបានដោយផ្ទាល់ទៅនឹងទិន្នន័យដែលបានចេញផ្សាយក្នុងខែមិថុនា ឆ្នាំ២០២៤ ដែលប្រើមូលដ្ឋានឆ្នាំ ២000 នៃទិន្នន័យគណនីជាតិឡើយ។

## បញ្ហាប្រឈមនិងហានិភ័យ

**ទោះបីជាសេដ្ឋកិច្ច បន្តមានភាពល្អប្រសើរក៏ដោយ ក៏សេដ្ឋកិច្ចកំពុងប្រឈមមុខនឹងហានិភ័យធ្លាក់ចុះ រួមទាំងការធ្លាក់ចុះជាងការរំពឹងទុកនៃតម្រូវការសកលលោក ក្នុងគ្រាដែលមានការកើនឡើងបំណុលនិងការចំណាយលើការខ្ចីប្រាក់ និងការថមថយសេដ្ឋកិច្ចខ្លាំងជាងការរំពឹងទុកក្នុងប្រទេសចិន។** សេដ្ឋកិច្ចដែលបើកចំហនិងមានទំហំតូចរបស់កម្ពុជា ដែលអនុបាតពាណិជ្ជកម្មធៀបនឹង ផ.ស.ស មានចំនួន ១១២ភាគរយក្នុងឆ្នាំ២០២៣ ប្រឈមនឹងហានិភ័យពីការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ច និងការកើនឡើងកិច្ចគាំពារនិយម។

**នៅក្នុងប្រទេសវិញ ការកើនឡើងលឿនជាងការរំពឹងទុកនៃកម្ចីមិនដំណើរការ អាចប៉ះពាល់ដល់ស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុនៅពេលដែលការធ្លាក់ចុះទីផ្សារលំនៅឋាននៅតែបន្ត។** ការធ្លាក់តម្លៃផ្ទះកំពុងជះឥទ្ធិពលអវិជ្ជមានដល់សុខភាព និងស្ថិរភាពនៃវិស័យធនាគារ តាមរយៈការបង្កើនហានិភ័យនៃការខកខានបង់សងប្រាក់កម្ចី និងការធ្លាក់ចុះតម្លៃទ្រព្យបញ្ចាំដែលកាន់កាប់ដោយធនាគារ។ ទោះជាយ៉ាងណា ការធ្លាក់ចុះទីផ្សារលំនៅឋានក៏អាចត្រូវបានមើលឃើញថាជាដំណើរធម្មតានៃវដ្តឥណទានផងដែរ ដែលអាចផ្តល់លទ្ធភាពឱ្យគ្រួសារពលរដ្ឋកម្ពុជា កាន់តែច្រើនមានលទ្ធភាពទិញលំនៅឋានក្នុងតម្លៃកាន់តែទាប។

## ជម្រើសគោលនយោបាយ

**ដោយផ្អែកលើការកែលម្អជាបន្តបន្ទាប់ក្នុងការគ្រប់គ្រងសារពើពន្ធក្រោយជំងឺរាតត្បាត កំណែទម្រង់សារពើពន្ធ ដើម្បីជំរុញការកៀរគរប្រាក់ចំណូលក្នុងស្រុក គួរតែជាអាទិភាពកំពូល។** ការពង្រឹងសារពើពន្ធដែលកំពុងដំណើរការ ដោយសារតែការថមថយការប្រមូលប្រាក់ចំណូល នឹងទំនងជាប៉ះពាល់ដល់ការចំណាយសម្រាប់សង្គម និងការអប់រំជាមូលដ្ឋាន និងសេវាសុខភាព លុះត្រាតែទំហំសារពើពន្ធត្រូវបានស្តារឡើងវិញក្នុងរយៈពេលខ្លី។ ទីមួយ ការធ្វើអន្តរាគមន៍សារពើពន្ធ និងការលើកទឹកចិត្តផ្នែកពន្ធដែលដាក់ចេញដោយសារជំងឺរាតត្បាត គួរតែត្រូវបានបញ្ឈប់។ ទីពីរ ការដាក់ចេញអភិបាលកិច្ចកាន់តែតឹងរ៉ឹងទៅលើវិធានការលើកទឹកចិត្តផ្នែកពន្ធ គួរតែជួយកាត់បន្ថយការខាតបង់ប្រាក់ចំណូលមិនចាំបាច់ ដែលវិធានការទាំងនោះអាចបង្កឡើង។ ក្នុងន័យនេះ ការអភិវឌ្ឍសមត្ថភាពតាមដានគ្រប់គ្រង និងត្រួតពិនិត្យមើលការចំណាយផ្នែកពន្ធដារ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តសារពើពន្ធ និងថវិការយៈពេលមធ្យមមានសារៈសំខាន់ខ្លាំង។ ទីបី ពន្ធលើទំនិញនិងសេវាកម្ម គួរតែត្រូវបានពង្រឹងតាមរយៈការពិនិត្យមើលឡើងវិញទៅលើអត្រាអាករលើតម្លៃបន្ថែម ការលើកលែងពន្ធ និងការកំណត់ពន្ធក្នុងអត្រាសូន្យ ខណៈពេលដែលដាក់ចេញវិធានការដំឡើងពន្ធគយប្រកបដោយមហ្សិតាលើគ្រឿងស្រវឹង និងថ្នាំជក់ ដោយកំណត់អត្រាពន្ធគយនេះធៀបទៅនឹងអត្រាពន្ធគយ ដែលអនុវត្តនៅក្នុងប្រទេសដែលមានចំណូលមធ្យមនានា។ ការដាក់ចេញវិធានការពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួន គួរតែជាគោលដៅរយៈពេលមធ្យមនៃយុទ្ធសាស្ត្រកៀរគរប្រាក់ចំណូលបន្ទាប់។ ទីបួន ខណៈពេលដែលអាជ្ញាធរកំពុងដាក់ចេញគោលនយោបាយពង្រឹងសារពើពន្ធសន្សឹមៗ ការពង្រឹងប្រសិទ្ធភាពចំណាយ ឬតម្លៃសាច់ប្រាក់គឺជាការងារចាំបាច់។

**ដើម្បីការពារស្ថិរភាពហិរញ្ញវត្ថុ ការផ្តោតការយកចិត្តទុកដាក់ជាបន្ទាន់ គួរតែធ្វើឡើងទៅការត្រួតពិនិត្យធនាគារកាន់តែខ្លាំង៖ ការធ្វើស្ត្រេសតេស្តរបស់គ្រឹះស្ថាននីមួយៗ ការត្រួតពិនិត្យនៅនឹងកន្លែងជាប្រព័ន្ធ ការបន្សីុបន្ថែមទៀតនៃក្របខ័ណ្ឌបទប្បញ្ញត្តិជាមួយនឹងស្តង់ដារអន្តរជាតិ និងការវាយតម្លៃយ៉ាងម៉ត់ចត់ទៅលើគុណភាពផលប័ត្រប្រាក់កម្ចី និងកិច្ចការផ្សេងៗទៀត។** ចំនួនគ្រឹះស្ថានហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា កំពុងកើនឡើងយ៉ាងឆាប់រហ័សរហូតដល់ឆ្នាំ២០២២។ ការពង្រឹងវិស័យហិរញ្ញវត្ថុតាមរយៈការច្របាច់បញ្ចូលគ្នា និងការទិញយក (M&A) គួរតែជួយរក្សាប្រាក់ចំណេញ តាមរយៈការកែលម្អប្រសិទ្ធភាព និងការបង្កើនចំណែកទីផ្សារ។ ដើម្បីត្រៀមខ្លួនសម្រាប់ការកើនឡើងកម្រិតឥណទានមិនដំណើរការ វាមានសារៈសំខាន់ណាស់ក្នុងការធានាថា ជម្រើសដំណោះស្រាយត្រូវត្រៀមរួចជាស្រេចដើម្បីដាក់ឱ្យប្រើប្រាស់តាមតម្រូវការ និងដើម្បីពង្រឹងរបបអសាធនភាពរបស់កម្ពុជា។ កិច្ចខិតខំប្រឹងប្រែងរៀបចំច្បាប់ស្តីពីការធានារ៉ាប់រងប្រាក់បញ្ញើ និងដំណោះស្រាយធនាគារត្រូវតែបន្តធ្វើទៀត។

**ជាចុងក្រោយ ដើម្បីបញ្ចៀសការថមថយកំណើនសេដ្ឋកិច្ចកម្ពុជាគួរតែផ្លាស់ប្តូរទៅរកគំរូកំណើនប្រកបដោយនិរន្តរភាពជាងនេះ តាមរយៈការធ្វើកំណែទម្រង់រចនាសម្ព័ន្ធបន្ថែមទៀត ដើម្បីជំរុញ និងធ្វើពិពិធកម្មការនាំចេញទំនិញ ជាពិសេសផលិតផលកម្មន្តសាល និងការកែច្នៃកសិផល ក៏ដូចជាសេវាកម្មជាពិសេសការធ្វើដំណើរ និងបដិសណ្ឋារកិច្ច។** កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតត្រូវធ្វើជាចាំបាច់ ដើម្បីពន្លឿនការធ្វើកំណែទម្រង់ភាពងាយស្រួលក្នុងការអាជីវកម្ម។ ដូចដែលមានបង្ហាញនៅក្នុងរបាយការណ៍ Business-Ready ឆ្នាំ២០២៤ បញ្ហាប្រឈមខ្លាំងបំផុតគឺថា ប្រទេសកម្ពុជាខ្វះសេវាកម្មសាធារណៈដែលមានគុណភាព ដើម្បីគាំទ្រដល់អាជីវកម្ម ជាពិសេសក្នុងវិស័យដូចជាអសាធនភាពអាជីវកម្ម ការប្រកួតប្រជែងទីផ្សារ និងការបង្កើតអាជីវកម្ម។ ដូច្នេះ ការពង្រឹងគ្រឹះស្ថានរបស់កម្ពុជា ដើម្បីធានាថា បទប្បញ្ញត្តិ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព នឹងជួយបង្កើតបរិយាកាសធុរកិច្ច ដែលអាចព្យាករបាន និងមានស្ថិរភាព ដែលមានសារៈសំខាន់សម្រាប់ការលើកកម្ពស់ពាណិជ្ជកម្ម និងការវិនិយោគ។ នោះគឺជាការផ្តោតសំខាន់នៃអត្ថបទពិសេស នៅក្នុងផ្នែកពិសេសនៃរបាយការណ៍នេះ។

## ឧបសគ្គរចនាសម្ព័ន្ធ ក្រុមហ៊ុន និងអាជីវកម្មចំពោះផលិតភាពការងារ

**ប្រទេសកម្ពុជា នឹងចាំបាច់ត្រូវកែលម្អដំណើរការផលិតភាពរបស់ខ្លួនឱ្យបានខ្លាំងនៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ខាងមុខ ដើម្បីរក្សាបាននូវអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ និងសម្រេចបានចក្ខុវិស័យរបស់ខ្លួន ក្នុងការក្លាយជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ឱ្យបានឆាប់រហ័ស។** កន្លងមក កំណើនផលិតភាពមិនមែនជាកត្តាដ៏សំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចឡើយ ហើយកម្រិតផលិតភាពការងាររបស់កម្ពុជាមានកម្រិតទាបខ្លាំង បើធៀបនឹងប្រទេសក្នុងតំបន់របស់ខ្លួន នៅគ្រប់វិស័យនៃសេដ្ឋកិច្ច។ ផ្នែកអត្ថបទផ្តោតពិសេសនៃរបាយការណ៍នេះ បង្ហាញវិស័យកំណែទម្រង់អាទិភាពចំនួនបួន ដើម្បីគាំទ្រដល់ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សឆ្ពោះទៅរកគំរូកំណើនដែលដឹកនាំដោយផលិតភាពកាន់តែខ្លាំងនៅក្នុងប្រទេសកម្ពុជា។

**ទីមួយ កម្ពុជាចាំបាច់ត្រូវពន្លឿនការផ្លាស់ប្តូររចនាសម្ព័ន្ធឆ្ពោះទៅរកផលិតផល ខ្សែច្រវាក់តម្លៃ និងសកម្មភាពតម្លៃបន្ថែម។** ផលិតភាពការងារក្នុងចំណោមក្រុមហ៊ុនកម្ពុជា មានភាពខុសគ្នាយ៉ាងខ្លាំងទាំងនៅក្នុងវិស័យ និងឆ្លងវិស័យ ដោយវិស័យ និងអនុវិស័យមួយចំនួន មានផលិតភាពច្រើនជាងវិស័យដទៃទៀត។ ការធ្វើឱ្យប្រសើរឡើងនូវដំណើរការផលិតភាពរបស់ប្រទេសកម្ពុជាទាមទារឱ្យមានការជំរុញ និងពន្លឿនការផ្លាស់ប្តូររចនាសម្ព័ន្ធរបស់ប្រទេសឆ្ពោះទៅរកសកម្មភាព និងក្រុមហ៊ុនបន្ថែមតម្លៃបន្ថែមទាំងក្នុងវិស័យនានា និងពីវិស័យផលិតភាពទាបឆ្ពោះទៅរកផលិតភាពខ្ពស់ និងពីតំបន់ជនបទទៅកាន់តំបន់ទីក្រុង។ ការណ៍នេះមានភាពស្របតាមតម្រូវការដ៏ទូលំទូលាយក្នុងការបន្តធ្វើពិពិធកម្មសេដ្ឋកិច្ចកាន់តែច្រើននៅក្នុងប្រទេសកម្ពុជា ដើម្បីកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងការប្រមូលផ្តុំខ្លាំងទៅលើតែផលិតផល និងទីផ្សារមួយចំនួន។ គំនិតគោលនយោបាយជាក់លាក់រួមមាន៖ ការបង្កើតឱ្យមានភាពកាន់តែងាយស្រួល និងរហ័ស សម្រាប់ការបើកដំណើរការរបស់ក្រុមហ៊ុនថ្មី និងសម្រាប់ការបិទក្រុមហ៊ុនដែលដំណើរការមិនល្អ និងការលើកទឹកចិត្តដល់ការអភិវឌ្ឍឧស្សាហកម្មថ្មី និងការបំប្លែងឧស្សាហកម្មដែលមានស្រាប់ទៅជាឧស្សាហកម្មបន្ថែមតម្លៃខ្ពស់។

**ទីពីរ កម្ពុជាចាំបាច់ត្រូវដោះស្រាយឧបសគ្គរចនាសម្ព័ន្ធជាក់លាក់ និង/ឬការមិនលើកទឹកចិត្តដែលប្រឈមដោយក្រុមហ៊ុនធុនមធ្យម ក្រុមហ៊ុនដែលមានទីតាំងនៅតំបន់ជនបទ និងក្រុមហ៊ុនឈានមុខគេ (frontier firms) របស់ខ្លួន។** ក្រុមហ៊ុនធុនមធ្យម និងក្រុមហ៊ុនដែលមានទីតាំងនៅតំបន់ភ្នំរបស់កម្ពុជា មានផលិតភាពការងារទាបជាង ហើយទំនងជាប្រឈមនឹងបរិយាកាសធុរកិច្ចកាន់តែលំបាក (ក្រុមហ៊ុននៅតំបន់បឹងទន្លេសាប មានស្ថានភាពធូរស្រាលជាង)។ ជាងនេះទៅទៀត ក្រុមហ៊ុនឈានមុខគេរបស់កម្ពុជា កំពុងស្ថិតនៅក្រោយគេឆ្ងាយធៀបនឹងប្រទេសក្នុងតំបន់ និងកំពុងប្រតិបត្តិការក្រោមកម្រិតផលិតភាពក្នុងតំបន់ខ្លាំង។ គំនិតគោលនយោបាយជាក់លាក់រួមមាន៖ ការគាំទ្ររបស់រដ្ឋាភិបាលកាន់តែខ្លាំងសម្រាប់ក្រុមហ៊ុនធុនមធ្យម ក្នុងការជម្នះឧបសគ្គអាជីវកម្ម និងកសាងសមត្ថភាពរបស់ពួកគេ កម្មវិធីពង្រីកការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មរបស់រដ្ឋាភិបាល ដែលបានកំណត់គោលដៅនៅតំបន់ជនបទ និងកំណែទម្រង់ដែលជួយបង្កើនការប្រកួតប្រជែង (ជាពិសេសក្នុងវិស័យសេវាកម្ម និងឌីជីថល) និងការលើកទឹកចិត្តក្រុមហ៊ុនឈានមុខគេ ឱ្យធ្វើការវិនិយោគលើបច្ចេកវិទ្យាទំនើប ការអភិវឌ្ឍជំនាញ និងបណ្តាញសកល។

**ទីបី កម្ពុជាគួរតែជំរុញការធ្វើទំនើបកម្ម និងឌីជីថលភាវូបនីយកម្មកាន់តែខ្លាំង និងកាន់តែលឿនដល់ក្រុមហ៊ុនរបស់ខ្លួន ក៏ដូចជាការផ្តោតលើទីផ្សារអន្តរជាតិឱ្យកាន់តែប្រសើរឡើង។** ក្រុមហ៊ុននៅកម្ពុជាដែលមានការអនុវត្តមុខងារបុគ្គលិក ទំនើបជាងមុន (ឧទាហរណ៍ នាយកប្រតិបត្តិដែលមានជំនាញវិជ្ជាជីវៈ ថ្នាក់គ្រប់គ្រងកាន់តែប្រសើរ ការផ្តល់កម្មវិធីបណ្តុះបណ្តាលបុគ្គលិកផ្លូវការ) និងក្រុមហ៊ុនដែលប្រើប្រាស់បច្ចេកវិទ្យា (ឧទាហរណ៍ មានគេហទំព័រ ប្រើការទូទាត់តាមអេឡិចត្រូនិក) ក៏ដូចជាក្រុមហ៊ុនដែលផ្តោតលើការនាំចេញ ជាធម្មតាមានផលិតភាពការងារខ្ពស់ជាង។ គំនិតគោលនយោបាយជាក់លាក់រួមមាន៖ (i) ផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនឱ្យធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការអភិវឌ្ឍស្ថាប័ន ការគ្រប់គ្រង និងកម្លាំងពលកម្មរបស់ពួកគេព្រមទាំងប្រើប្រាស់បច្ចេកវិទ្យាដើម្បីបង្កើនផលិតភាព និង (ii) ដោះស្រាយឧបសគ្គផ្នែកហេដ្ឋារចនាសម្ព័ន្ធចំពោះពាណិជ្ជកម្ម កាត់បន្ថយពេលវេលាបំពេញទម្រង់បែបបទបញ្ចេញទំនិញពីគយ និងកែលម្អសេវាកម្មដើម្បីជួយក្រុមហ៊ុនឱ្យទទួលបានទីផ្សារថ្មី។

**ទីបួន កម្ពុជាគួរតែកំណត់អាទិភាព និងដោះស្រាយឧបសគ្គធំបំផុតក្នុងការធ្វើអាជីវកម្ម ដែលលើកឡើងដោយក្រុមហ៊ុនរបស់ខ្លួន។** តម្រូវការបន្ទាន់បំផុតរួមមាន៖ (ក) ធានាថា អត្ថប្រយោជន៍ដែលទទួលបានពីការចុះឈ្មោះក្រុមហ៊ុនមានច្រើនជាងការចំណាយ ជាពិសេសសម្រាប់ក្រុមហ៊ុនធុនតូច ដោយកាត់បន្ថយការចំណាយលើការចុះឈ្មោះ និងបង្កើនអត្ថប្រយោជន៍ដែលពាក់ព័ន្ធ (ខ) កែលម្អហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងឡូជីស្ទិក (គ) លើកកម្ពស់ការវិនិយោគលើជំនាញនានា និងប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុទំនើប នៅក្នុងចំណោមក្រុមហ៊ុនទំនើបខ្លាំង (ឃ) បង្កើនប្រសិទ្ធភាពរបបរដ្ឋបាលពន្ធដារដែលស្មុគស្មាញ និងចំណាយខ្ពស់ (ង) កាត់បន្ថយអំពើពុករលួយ និងការចំណាយក្រៅផ្លូវការ (ជាពិសេសនៅក្នុងរដ្ឋបាលពន្ធដារ) តាមរយៈការវិនិយោគលើដំណើរការរុករកអំពើពុករលួយ និងការចំណាយក្រៅផ្លូវការ ដំណើរការបង្កើនការពិន័យ និងដំណើរការឌីជីថល (ច) លើកកម្ពស់ប្រសិទ្ធភាព និងភាពមិនលំអៀងនៃមជ្ឈត្តកម្មតុលាការ នៅក្នុងការដោះស្រាយបញ្ហាពាណិជ្ជកម្ម រួមទាំងតាមរយៈការបង្កើតតុលាការពាណិជ្ជកម្មឯកទេស និងការបង្កើនតម្លាភាព និងឌីជីថលនីយកម្ម និង (ឆ) កែលម្អការផ្តល់ និងប្រសិទ្ធភាពសេវាកម្មរបស់រដ្ឋាភិបាល ទាក់ទងនឹងការអនុញ្ញាតឱ្យធ្វើអាជីវកម្ម រួមទាំងតាមរយៈការធ្វើឌីជីថលពេញលេញទៅលើវិបផតថលចុះបញ្ជីអាជីវកម្ម និងការដាក់ដំណើរការ និងការអនុវត្តវិធីសាស្ត្រផ្អែកលើហានិភ័យក្នុងការផ្តល់អាជ្ញាប័ណ្ណ។

## **រូប ES១ ៖ សេចក្តីសង្ខេបអំពីការវិវឌ្ឍថ្មីៗរបស់កម្ពុជា**

**សកម្មភាពសេដ្ឋកិច្ចបន្តមានភាពប្រសើរ...**
*កំណើនពិត (ភាគរយ)*




**...គាំទ្រដោយការកើនឡើងវិញនូវការនាំចេញសេវាកម្ម...**
*ការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិ (លាននាក់)*




**...និងការស្ទុះងើបឡើងវិញនៃការនាំចេញទំនិញ...**
**ការនាំចេញទំនិញ (ពីដើមឆ្នាំមកដល់ពេលនេះ,**
*ប្រែប្រួលជាភាគរយ y/y )*




**...អតិផរណាបានធ្លាក់ចុះដល់ ០,៨ភាគរយក្នុងរយៈពេល ១២ខែគិតត្រឹមខែកញ្ញា ឆ្នាំ២០២៤ ដែលជាអត្រាទាបបំផុតក្នុងរយៈពេល ១៥ឆ្នាំ...**
*(ប្រែប្រួលជាភាគរយ y/y)*




**...កំណើនរូបិយវត្ថុទូទៅ (M2) បានកើនឡើង...**
*បំណុលរូបិយវត្ថុទូទៅ (ប្រែប្រួលជាភាគរយ y/y)*




**...ទោះជាមានភាពប្រសើរឡើងក៏ដោយ ក៏ប្រាក់ចំណូលក្នុងស្រុកនៅតែថមថយ...** *(ប្រែប្រួលជាភាគរយ y/y)*




*ប្រភព៖ អាជ្ញាធរកម្ពុជា,* ការព្យាកររបស់បុគ្គលិកធនាគារពិភពលោក
*សម្គាល់៖ e* = ការប៉ាន់ស្មាន, p = ការព្យាករ, y/y = ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន

# ផ្នែកទី១ ៖

## ការវិវឌ្ឍសេដ្ឋកិច្ចថ្មីៗ និងចក្ខុវិស័យ





# ការវិវឌ្ឍថ្មីៗ សកម្មភាពសេដ្ឋកិច្ចពិភពលោកស្ទុះងើបឡើងវិញ

**កំណើនសេដ្ឋកិច្ចសកល កំពុងមានស្ថិរភាព បន្ទាប់ពីបានធ្លាក់ចុះរយៈពេលបីឆ្នាំជាប់ៗគ្នា។** អតិផរណា បានធ្លាក់ចុះដល់កម្រិតទាបបំផុតនៅក្នុងរយៈពេលបីឆ្នាំ ហើយស្ថានភាពហិរញ្ញវត្ថុមានភាពល្អប្រសើរឡើង។ ជារួម សេដ្ឋកិច្ចពិភពលោកហាក់ដូចជាស្ថិតក្នុងដំណាក់កាលចុងក្រោយឆ្ពោះទៅរក "ការធ្វើឱ្យអតិផរណាធ្លាក់ចុះដោយមិនមានដំណើរថយក្រោយនៃសេដ្ឋកិច្ច ឬហៅថា soft landing"[2]។

**សកម្មភាពសេដ្ឋកិច្ចសកលនៅតែបន្តមានស្ថិរភាព បន្ទាប់ពីមានវិបត្តិជាច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ។** នៅក្នុងឆមាសទីមួយឆ្នាំ២០២៤ កំណើនសេដ្ឋកិច្ចពិភពលោកមានស្ថិរភាពដោយកើនឡើងប្រហែល ៣ភាគរយនៃអត្រាប្រចាំឆ្នាំ ហើយសូចនាករសកម្មភាពឈានមុខនានា ចង្អុលបង្ហាញឱ្យឃើញពីកំណើនប្រកបដោយស្ថិរភាពបន្ថែមទៀតនៅពេលខាងមុខ។ នៅក្នុងខែកញ្ញា សន្ទស្សន៍អ្នកគ្រប់គ្រងការទិញ (PMI) រួមរបស់ពិភពលោកនៅតែស្ថិតក្នុងតំបន់កំណើនពោលគឺមានតួលេខ ៥២ ទោះបីជាសេវាកម្មនិងកម្មន្តសាល (រូប ១) បន្តមានភាពខុសគ្នាក៏ដោយ។ បើទោះបីជាសន្ទស្សន៍ PMI ផ្នែកសេវាកម្មនៅតែមានភាពប្រសើរក៏ដោយ ក៏សន្ទស្សន៍ PMI ផ្នែកកម្មន្តសាលស្ថិតនៅក្នុងតំបន់ធ្លាក់ចុះក្នុងរយៈពេលបីខែជាប់ៗគ្នា។ ទោះបីជាទូទៅពាណិជ្ជកម្មពិភពលោក មានការកើនឡើងនៅឆ្នាំនេះក៏ដោយ ក៏កំណើននៅតែមិនមានតុល្យភាពនៅឡើយ (រូប ២)។ ពាណិជ្ជកម្មទំនិញ នៅប្រទេសកំពុងអភិវឌ្ឍន៍ខ្លាំង និងប្រទេសកំពុងអភិវឌ្ឍន៍ (EMDE) មានការកើនឡើងក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ ប៉ុន្តែផ្ទុយទៅវិញលើកលែងតែសហរដ្ឋអាមេរិក ពាណិជ្ជកម្មបានថមថយក្នុងប្រទេសមានសេដ្ឋកិច្ចជឿនលឿន ដែលមួយផ្នែកឆ្លុះបញ្ចាំងឱ្យឃើញពីសកម្មភាពខ្សោយនៅក្នុងតំបន់ប្រើប្រាស់ប្រាក់អឺរ៉ូ។

**ទោះជាយ៉ាងណា ក្នុងរយៈពេលជាងបួនឆ្នាំបន្ទាប់ពីកើតមានជំងឺរាតត្បាតកូវីដ-១៩ និងបញ្ហា ដែលកើតមាននៅលើពិភពលោកជាបន្តបន្ទាប់ មានការបង្ហាញយ៉ាងច្បាស់ថាពិភពលោក និងជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ មិនទាន់បានរកឃើញឡើងវិញនូវផ្លូវប្រកបដោយភាពអាចទុកចិត្តបានឆ្ពោះទៅកាន់វិបុលភាពនៅឡើយទេ។** ភាពមិនច្បាស់លាស់ផ្នែកគោលនយោបាយពាណិជ្ជកម្ម បានឈានដល់កម្រិតខ្ពស់បំផុតនៅសតវត្សរ៍នេះ ប្រសិនបើរាប់បញ្ចូលទាំងឆ្នាំដែលពាក់ព័ន្ធនឹងការបោះឆ្នោតសំខាន់ៗ។ ចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២៣ កំណើនវិនិយោគនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ជាមធ្យមបានធ្លាក់ចុះជាង ពាក់កណ្តាលបើធៀបនឹងពីការវិនិយោគ

**រូប ១ ៖ សន្ទស្សន៍ PMI រួមរបស់ពិភពលោក**




*ប្រភព៖ Haver,* ធនាគារពិភពលោក។
*សម្គាល់៖ បង្ហាញសន្ទស្សន៍* PMI រួម កម្មន្តសាល និងសេវាកម្មពិភពលោក។ តួលេខលើបន្ទាត់ផ្តេកត្រង់បង្ហាញពីការកើនឡើង ហើយតួលេខក្រោមបន្ទាត់ផ្តេកត្រង់បង្ហាញពីការធ្លាក់ចុះ។

**រូប ២ ៖ ពាណិជ្ជកម្មទំនិញពិភពលោក**




ប្រភព៖ ការិយាល័យវិភាគគោលនយោបាយសេដ្ឋកិច្ចហូឡង់ CPB។
ចំណាំ៖ រូបបង្ហាញពីការប្រែប្រួលជាភាគរយនៃបរិមាណពាណិជ្ជកម្មទំនិញធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ពាណិជ្ជកម្មទំនិញត្រូវបានវាស់វែងជាមធ្យមនៃបរិមាណនាំចេញ និងនាំចូល។ ការអង្កេតចុងក្រោយធ្វើឡើងនៅខែសីហា ឆ្នាំ២០២៤។

---

2 ធនាគារពិភពលោក ២០២៤a។

នៅទសវត្សរ៍ឆ្នាំ២០០០។ កំណើនសេដ្ឋកិច្ចពិភពលោកកំពុងមានស្ថិរភាព ដោយកើនឡើងក្នុងអត្រាមួយដែលមិនគ្រប់គ្រាន់សម្រាប់ធ្វើឱ្យមានវឌ្ឍនភាព ចំពោះគោលដៅអភិវឌ្ឍន៍សំខាន់ៗពោលគឺកើនឡើងជាមធ្យម ២,៧ភាគរយក្នុងមួយឆ្នាំរហូតដល់ឆ្នាំ២០២៦ ដែលទាបជាងមធ្យមភាគ ៣,១ភាគរយនៅក្នុងទសវត្សរ៍មុនពេលកើតមានជំងឺកូវីដ-១៩។ ដោយហេតុនេះ ស្ទើរតែពាក់កណ្ដាលនៃប្រទេសកំពុងអភិវឌ្ឍន៍ នឹងមើលឃើញការកើនឡើងគម្លាតប្រាក់ចំណូល ក្នុងមនុស្សម្នាក់របស់ប្រទេសទាំងនេះកាន់តែខ្លាំង បើធៀបនឹងប្រទេស ដែលមានសេដ្ឋកិច្ចជឿនលឿននៅក្នុងរយៈពេលពាក់កណ្ដាលទីមួយ នៃទសវត្សរ៍ឆ្នាំ២០២០ ដែលជាចំណែកខ្ពស់បំផុតគិតចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០មក។

**នៅថ្ងៃអនាគត កំណើនសេដ្ឋកិច្ចសកលត្រូវបានរំពឹងថានឹងនៅតែមានកម្រិតតិចតួចគឺ ២,៧ភាគរយក្នុងឆ្នាំ២០២៥ និងឆ្នាំ២០២៦។** កំណើននេះមានកម្រិតប្រហាក់ប្រហែលនឹងអត្រានៅឆ្នាំ២០២៤ ប៉ុន្តែទាបជាងជិត ០,៥ពិន្ទុភាគរយធៀបនឹងអត្រាកំណើនជាមធ្យម ដែលទទួលបានមុនពេលមានជំងឺរាតត្បាត ដែលឆ្លុះបញ្ចាំងឱ្យឃើញពីបញ្ហាប្រឈមជាច្រើនដែលរំពឹងថានឹងកើតមាន។ បញ្ហាប្រឈមទាំងនេះរួមមានទាំងផលប៉ះពាល់ ដែលមិនទាន់កើតមានភ្លាមៗ ពីការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ ការពង្រឹងសារពើពន្ធឡើងវិញ និងការថមថយកំណើនប្រើប្រាស់នៅគ្រា ដែលមានការធ្លាក់ចុះប្រាក់សន្សំ។ នៅទូទាំងពិភពលោក កំណើននៃការវិនិយោគក៏ត្រូវបានរំពឹងថា នឹងនៅតែថមថយផងដែរដោយសារការកើនឡើង អត្រាការប្រាក់ពិត និងភាពមិនច្បាស់លាស់ផ្នែកគោលនយោបាយនៅក្នុងគ្រាដែលមានការកើនឡើងភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ។ កំណើនពាណិជ្ជកម្ម ត្រូវបានរំពឹងថានឹងរឹងមាំដោយកើនឡើងដល់ ៣,៤ភាគរយនៅឆ្នាំ២០២៥ ស្របពេលដែលនឹងមានការកើនឡើងពាណិជ្ជកម្មនៅក្នុងតំបន់ប្រើប្រាស់ប្រាក់អឺរ៉ូ និងនៅប្រទេសកំពុងអភិវឌ្ឍន៍ខ្លាំង និងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ហើយនឹងនៅតែមានស្ថិរភាពនៅឆ្នាំ២០២៦។ ដោយសន្មតថា ជម្លោះបច្ចុប្បន្នមិនមានការកើនឡើង តម្លៃទំនិញត្រូវបានរំពឹងថានឹងថមថយ ដែលឆ្លុះបញ្ចាំងជាចម្បងឱ្យឃើញពីភាពប្រសើរឡើងនូវស្ថានភាពផ្គត់ផ្គង់ ប៉ុន្តែនៅតែល្អជាងកម្រិតមុនកើតមានជំងឺរាតត្បាត[3]។

**ទោះជាយ៉ាងនេះក្ដី សេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក (EAP) នៅបន្តមានដំណើរការល្អប្រសើរជាងសេដ្ឋកិច្ចរបស់ប្រទេសផ្សេងទៀតនៅក្នុងពិភពលោក។** កំណើនសេដ្ឋកិច្ចរបស់តំបន់នេះ ត្រូវបានព្យាករថានឹងកើនឡើងចំនួន ៤,៨ភាគរយនៅក្នុងឆ្នាំ២០២៤ ធៀបទៅនឹងកំណើនសេដ្ឋកិច្ចជាមធ្យម ៣,៣ភាគរយនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ខ្លាំង និងប្រទេសកំពុងអភិវឌ្ឍន៍ និង ១,៥ភាគរយនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍[4]។ នៅក្នុងប្រទេសក្នុងតំបន់អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក ការប្រើប្រាស់ឯកជននិងការនាំចេញសេវាកម្មបានជួយទ្រទ្រង់កំណើន ប៉ុន្តែការវិនិយោគឯកជន និងការនាំចេញទំនិញនៅតែខ្សោយ។

**កំណើនសេដ្ឋកិច្ចរបស់តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ត្រូវបានរំពឹងថានឹងថយចុះមកនៅត្រឹម ៤,៤ភាគរយនៅឆ្នាំ២០២៥។** ការថមថយនេះភាគច្រើនដោយសារថា កំណើនសេដ្ឋកិច្ចរបស់ប្រទេសចិន ដែលជាសេដ្ឋកិច្ចធំជាងគេក្នុងតំបន់ ត្រូវបានព្យាករថានឹងថមថយពី ៤,៨ភាគរយនៅឆ្នាំនេះមកនៅត្រឹម ៤,៣ភាគរយនៅឆ្នាំ២០២៥។ កំណើនសេដ្ឋកិច្ចរបស់ប្រទេសចិននៅឆ្នាំ២០២៤ ត្រូវបានគាំទ្រដោយការស្ទុះងើបឡើងវិញនៃការប្រើប្រាស់សេវាកម្ម និងការនាំចេញនៅដើមឆ្នាំ។ ប៉ុន្តែកំណើនសេដ្ឋកិច្ចត្រូវបានរំពឹងថានឹងថយចុះនៅឆ្នាំ២០២៥ ក្នុងគ្រាដែលមានការចុះខ្សោយទីផ្សារអចលនទ្រព្យរ៉ាំរ៉ៃ ទំនុកចិត្តរបស់អតិថិជននិងវិនិយោគិនទាប និងបញ្ហាប្រឈមផ្នែកភាពចាស់ជរារបស់ប្រជាជន និងភាពតានតឹងក្នុងពិភពលោក។ ការគាំទ្រផ្នែកសារពើពន្ធដែលបានដាក់ចេញនាពេលថ្មីៗនេះ អាចជួយជំរុញកំណើនសេដ្ឋកិច្ចក្នុងរយៈពេលខ្លី ប៉ុន្តែកំណើនសេដ្ឋកិច្ចរយៈពេលវែង នឹងពឹងផ្អែកលើកំណែទម្រង់រចនាសម្ព័ន្ធកាន់តែស៊ីជម្រៅ។ ប្រទេសផ្សេងទៀតក្នុងតំបន់អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក ត្រូវបានព្យាករថានឹងកើនឡើងក្នុងអត្រា ៤,៧ភាគរយនៅឆ្នាំ២០២៤ និង ៤,៩ភាគរយនៅឆ្នាំ២០២៥។ កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០២៤ ទទួលបានអត្ថប្រយោជន៍ពីការកើនឡើង នូវការប្រើប្រាស់ក្នុងស្រុក ការស្ទុះងើបឡើងវិញនៃការនាំចេញទំនិញ និងការស្ទុះងើបឡើងវិញនៃវិស័យទេសចរណ៍។ កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០២៥ ត្រូវបានរំពឹងថានឹងមាននិរន្តរភាព ដោយសារការស្ទុះងើបឡើងវិញជាបន្តនៃការនាំចេញ និងស្ថានភាពហិរញ្ញវត្ថុល្អជាងមុន។

**អស់រយៈពេលជាង ៣ទសវត្សរ៍មកហើយ ដែលប្រទេសចិនបានដឹកនាំកំណើនសេដ្ឋកិច្ចនៅក្នុងតំបន់ ប៉ុន្តែនៅឆ្នាំ២០២៥ សេដ្ឋកិច្ចរបស់ប្រទេសផ្សេងទៀតក្នុងតំបន់ ទំនងជានឹងកើនឡើងខ្ពស់ ជាងសេដ្ឋកិច្ចចិន។** ការវិភាគជាក់ស្តែងថ្មីមួយបង្ហាញថា កាលពីអតីតកាល កំណើនសេដ្ឋកិច្ចរបស់ប្រទេសផ្សេងទៀតក្នុងតំបន់អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក ទទួលបានអត្ថប្រយោជន៍ជាមធ្យមពីការកើនឡើងតម្រូវការនាំចូលរបស់ប្រទេសចិន ជាងការដែលរងផលប៉ះពាល់ដោយសារការកើនឡើងការប្រកួតប្រជែងទីផ្សារនាំចេញរបស់ប្រទេសចិន។ ទោះបីជាប្រទេសចិនមានកំណើនសេដ្ឋកិច្ចយឺតក៏ដោយ ក៏ប្រទេសកំពុងអភិវឌ្ឍន៍នៅតែទទួលបានការជំរុញជាវិជ្ជមាន ដែលត្រូវបានប៉ាន់ប្រមាណថាមានចន្លោះពី ០,៥ភាគរយទៅ ១ភាគរយ ដោយសារតែការកើនឡើងភាពស្រដៀងគ្នានៃការនាំចេញរបស់ប្រទេសទាំងនោះទៅនឹងគំរូតម្រូវការនាំចូលរបស់ប្រទេសចិន។

**ហានិភ័យចំពោះចក្ខុវិស័យសកល នៅតែមានទំនោរទៅរកការធ្លាក់ចុះ ក្នុងគ្រាដែលមានការកើនឡើងភាពមិនច្បាស់លាស់។**

3 ធនាគារពិភពលោក ឆ្នាំ២០២៤c។
4 ធនាគារពិភពលោក ឆ្នាំ២០២៤b។

ជម្លោះកាន់តែអាក្រក់ ជាពិសេសនៅតំបន់មជ្ឈិមបូព៌ា ឬការកើនឡើងភាពតានតឹងភូមិសាស្ត្រនយោបាយ អាចជះឥទ្ធិពលអាក្រក់ដល់កំណើនសេដ្ឋកិច្ចពិភពលោក តាមរយៈទីផ្សារទំនិញ ពាណិជ្ជកម្ម និងទំនាក់ទំនងហិរញ្ញវត្ថុ។ ក្នុងគ្រាដែលមានការកើនឡើងវិធានការគាំពារនិយមផ្នែកពាណិជ្ជកម្ម និងគោលនយោបាយឧស្សាហកម្មផ្តោតលើផ្ទៃក្នុង ការបែកបាក់ពាណិជ្ជកម្មបន្ថែមទៀតនាំមកនូវហានិភ័យ នៃការរំខានបន្ថែមទៀតដល់បណ្តាញពាណិជ្ជកម្ម ខ្សែច្រវាក់ផ្គត់ផ្គង់ និងសកម្មភាពសេដ្ឋកិច្ច។ ការកើនឡើងអតិផរណាស្ទួលរុំារ៉ៃ អាចរារាំងដល់ការបន្ធូរបន្ថយគោលនយោបាយរូបិយវត្ថុដែលរំពឹងថានឹងកើតមាន ការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុ រួមទាំងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ខ្លាំង និងប្រទេសកំពុងអភិវឌ្ឍន៍ និងបង្កផលប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចពិភពលោក។ កំណើនសេដ្ឋកិច្ច ដែលខ្សោយជាងការរំពឹងទុកនៅក្នុងប្រទេសចិន អាចបង្កផលប៉ះពាល់អវិជ្ជមានជាសកល តាមរយៈទីផ្សារទំនិញ និងបណ្តាញពាណិជ្ជកម្ម ខណៈដែលគ្រោះមហន្តរាយធម្មជាតិ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដែលកើតមានកាន់តែញឹកញាប់ បង្កហានិភ័យដល់កំណើនសេដ្ឋកិច្ចទាំងរយពេលខ្លី និងរយៈពេលវែង។ ជាកុសល កំណើនសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក អាចខ្លាំងជាងការរំពឹងទុក មួយផ្នែកដោយសារភាពស្វាហាប់ការបន្តនៃការផ្គត់ផ្គង់កម្លាំងពលកម្មដ៏រឹងមាំ ដែលគាំទ្រដោយការកើនឡើងចំនួនកម្លាំងពលកម្ម និងការស្រូបយកជនចំណាកស្រុកគ្រប់អាយុធ្វើការ។

**ផ្ទុយទៅវិញ ការថមថយកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសចិន អាចមានផលជះអវិជ្ជមានដល់សេដ្ឋកិច្ចរបស់កម្ពុជា។** ប្រទេសចិនគឺជាដៃគូពាណិជ្ជកម្មដ៏សំខាន់មួយរបស់កម្ពុជា ជាពិសេសសម្រាប់ការនាំចូលទំនិញពាក់កណ្តាលសម្រេច ដែលប្រើប្រាស់ក្នុងការផលិតសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងផលិតផលស្បែកជើងសម្រាប់ការនាំចេញ។ ជាងនេះទៅទៀត ប្រទេសចិនគឺជាប្រភពដ៏សំខាន់នៃការវិនិយោគផ្ទាល់ពីបរទេស និងប្រាក់ចំណូលទេសចរណ៍សម្រាប់កម្ពុជា។ ការវិនិយោគផ្ទាល់ពីបរទេសរបស់ប្រទេសចិន បន្តមានចំណែកប្រហែលពាក់កណ្តាលនៃលំហូរចូលការវិនិយោគផ្ទាល់ពីបរទេស ហើយមុនពេលកើតមានជំងឺរាតត្បាត ភ្ញៀវទេសចរចិនមានចំណែកមួយភាគបីនៃចំនួនភ្ញៀវទេសចរអន្តរជាតិសរុបដែលមកទស្សនាប្រទេសកម្ពុជា។

## ក្នុងគ្រាដែលកត្តាខាងក្រៅមានភាពអំណោយផលសេដ្ឋកិច្ចរបស់កម្ពុជាមានភាពប្រសើរឡើងតិចតួច

**សកម្មភាពសេដ្ឋកិច្ចនៅកម្ពុជា បានបង្ហាញពីភាពប្រសើរឡើងតិចតួច។** ភាពប្រសើរឡើងទាំងនេះភាគច្រើន ត្រូវបានជំរុញដោយការស្ទុះងើបឡើងវិញខាងវិស័យសេវាកម្ម និងការនាំចេញទំនិញ។ ដូចដែលបានបង្ហាញក្នុង (រូប ៣) ភាពប្រសើរឡើងជារួមនៅក្នុងវិស័យសេវាកម្ម ជាពិសេសវិស័យទេសចរណ៍ រួមជាមួយនឹង កំណើនរបស់វិស័យកាត់ដេរសម្លៀកបំពាក់ ទំនិញ ធ្វើដំណើរ និងផលិតផលស្បែកជើង បានបន្តជំរុញឱ្យសេដ្ឋកិច្ចមានភាពប្រសើរឡើង នៅឆ្នាំនេះ។ ការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិបានបន្តកើនឡើង ពោលគឺកើនឡើង ២៣,៤ភាគរយក្នុងរយៈពេលប្រាំបីខែដំបូងនៃឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនដល់ ៤,៣លាននាក់។ ចំនួននៃការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិ បានកើនឡើងដល់កម្រិតមុនពេលមានជំងឺរាតត្បាតកូវីដ-១៩ រួចហើយ (រូប ៤)។

**ដោយសារតែការផ្លាស់ប្តូរ សមាសភាពភ្ញៀវទេសចរ ការចំណាយរបស់ភ្ញៀវទេសចរបានថមថយ បើទោះបីជា ចំនួននៃការមកដល់របស់ភ្ញៀវទេសចរបានស្ទុះងើបឡើងវិញយ៉ាងឆាប់រហ័សក៏ដោយ។** ក្នុងឆ្នាំ២០២៣ ប្រាក់ចំណូលពីវិស័យទេសចរណ៍

**រូប ៣ ៖ សកម្មភាពសេដ្ឋកិច្ចមានភាពប្រសើរឡើងតិចតួច**

*ការរួមចំណែកចំពោះកំណើន ផ.ស.ស ពិត (ភាគរយ)*




*ប្រភព៖ អាជ្ញាធរកម្ពុជា* និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក

*សម្គាល់៖ GTI៖* សម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងផលិតផលស្បែកជើង,

p = ការព្យាករ។

**រូប ៤ ៖ ការមកដល់របស់ភ្ញៀវទេសចរក្នុងរយៈពេល ៨ខែ និងប្រាក់ចំណូលពីវិស័យទេសចរណ៍** *(ភាគរយ, ២០១៩ = ១០០)*




*ប្រភព៖ អាជ្ញាធរកម្ពុជា។*

*ប្រភព៖ m = ខែ។*

របស់កម្ពុជាត្រូវបានអាជ្ញាធរកម្ពុជាប៉ាន់ស្មានថា មានត្រឹមតែ ៦២,៩ភាគរយនៃប្រាក់ចំណូលដែលប្រមូលបានក្នុងឆ្នាំ២០១៩ប៉ុណ្ណោះ។ បើទោះបីជារយៈពេលស្នាក់នៅជាមធ្យមសម្រាប់ភ្ញៀវទេសចរ បានកើនឡើងដល់ ៧,៦ថ្ងៃក្នុងឆ្នាំ២០២៣ បើធៀបនឹង ៦,២ថ្ងៃក្នុងឆ្នាំ២០១៩ក៏ដោយ ក៏ប្រាក់ចំណូលទេសចរណ៍សរុបដែលត្រូវបានប៉ាន់ស្មាន បានធ្លាក់ចុះមកត្រឹមចំនួន ៣,០៨ ពាន់លានដុល្លារអាមេរិក ពោលគឺធ្លាក់ចុះពីចំនួន ៤,៩ពាន់លានដុល្លារអាមេរិក ដោយសារតែការថយចុះការចំណាយជាមធ្យមក្នុងភ្ញៀវទេសចរម្នាក់។ ក្នុងអំឡុងពេលមុនកើតមានជំងឺរាតត្បាត ការមកដល់របស់ភ្ញៀវទេសចរតាមផ្លូវអាកាស ដែលមានទំនោរជាប់ពាក់ព័ន្ធនឹងភ្ញៀវទេសចរចំណាយខ្ពស់ មានចំនួនពីរភាគបីនៃភ្ញៀវទេសចរសរុបដែលមកទស្សនាកម្ពុជា ខណៈពេលដែលភ្ញៀវទេសចរ ធ្វើដំណើរមកទស្សនាកម្ពុជាតាមផ្លូវគោកមានចំនួនមួយភាគបី។ ភាពផ្ទុយគ្នានេះពិតជាបានកើតមានឡើង នៅក្នុងរយៈពេលក្រោយវិបត្តិជំងឺកូវីដ-១៩ប្រាកដមែន។ ក្នុងអំឡុងពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិតាមផ្លូវគោកមានចំនួន ២,៨លាននាក់ ខណៈដែលការមកដល់តាមផ្លូវអាកាសមានចំនួន ១,៥លាននាក់។ បើក្រឡេកទៅមើលការប្រមូលប្រាក់ចំណូលពីការលក់សំបុត្រចូលទស្សនាតំបន់ប្រាសាទអង្គរដើម្បីវាស់វែងការចំណាយរបស់ភ្ញៀវទេសចរវិញ វាបានបង្ហាញឱ្យឃើញពីការស្ទុះងើបឡើងវិញយឺតនៃប្រាក់ចំណូលពីវិស័យទេសចរណ៍ផងដែរ។ ក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ការប្រមូលប្រាក់ចំណូលពីការលក់សំបុត្រចូលទស្សនាតំបន់ប្រាសាទអង្គរមានត្រឹមតែ ៤៣,៦ភាគរយនៃកម្រិតប្រាក់ចំណូលក្នុងឆ្នាំ២០១៩ប៉ុណ្ណោះ ទោះបីជាវាកើនឡើង ៣១,៤ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២៣ ដល់ចំនួន ៣០,៣លានដុល្លារអាមេរិកក្នុងអំឡុងពេល ៨ខែនេះក៏ដោយ[5]។

**លើសពីនេះ ចំណែកនៃភ្ញៀវទេសចរជនជាតិចិន ដែលជាក្រុមភ្ញៀវទេសចរច្រើនជាងគេក្នុងអំឡុងពេលមុនកើតមានជំងឺរាតត្បាត ស្មើនឹងជិត ៤០ភាគរយនៃចំនួនភ្ញៀវទេសចរអន្តរជាតិសរុប បានថយចុះមកនៅត្រឹម ១២ភាគរយ ដែលឥឡូវនេះជាប់ចំណាត់ថ្នាក់លេខ៣ បន្ទាប់ពីភ្ញៀវទេសចរជនជាតិថៃ និងវៀតណាម។** ភ្ញៀវទេសចរជនជាតិថៃឥឡូវនេះមានចំណែក ៣០,៧ភាគរយនៃចំនួនភ្ញៀវទេសចរអន្តរជាតិសរុប កើនឡើងពី ៥,៦ភាគរយក្នុងឆ្នាំ២០១៩ ខណៈដែលភ្ញៀវទេសចរជនជាតិវៀតណាម មានចំនួន ២០,២ភាគរយ កើនឡើងពី ១០ភាគរយក្នុងឆ្នាំ២០១៩។

**ការស្ទុះងើបឡើងវិញនៃភ្ញៀវទេសចរអន្តរជាតិនៅកម្ពុជាមានលក្ខណៈទូលំទូលាយបើប្រៀបធៀបទៅនឹងប្រទេសជិតខាង។** ក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិមកកាន់ប្រទេសកម្ពុជា វៀតណាម និងជនជាតិថៃ បានកើនឡើង ២៥,៦ភាគរយ ២៦,២ភាគរយ និង ៣១,៩ភាគរយរៀងគ្នា។ ទោះជាយ៉ាងណា កម្ពុជាមិនសូវទទួលបានជោគជ័យក្នុងការទាក់ទាញភ្ញៀវទេសចរចិនទេ។ បើគិតជាចំណែកនៃចំនួនភ្ញៀវទេសចរបរទេសសរុបនៅក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩ ការមកដល់របស់ភ្ញៀវទេសចរពីប្រទេសចិនមកកាន់កម្ពុជា វៀតណាម និងថៃមានចំនួន ៣១,៦ភាគរយ ៧២,៥ភាគរយ និង ៦៧,៨ភាគរយរៀងគ្នា។

## ភ្ញៀវទេសចរបរទេសដែលមកទស្សនាខេត្តសៀមរាប នៅតែមានកម្រិតទាបខ្លាំងបើធៀបនឹងចំនួនភ្ញៀវទេចរក្នុងឆ្នាំ២០១៩

**ការប្រែប្រួលសមាសភាពភ្ញៀវទេសចរបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការមកដល់របស់ភ្ញៀវទេសចរនៅខេត្តសៀមរាប ដែលជាតំបន់ទេសចរណ៍ធំជាងគេនៅកម្ពុជា។** នៅក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិសរុបមកកាន់ខេត្តសៀមរាបមានការថយចុះគួរឱ្យកត់សម្គាល់បើធៀបនឹងឆ្នាំ២០១៩ ដោយកើនឡើងដល់ត្រឹមតែ ២៣,២ភាគរយនៃចំនួនភ្ញៀវទេសចរក្នុងឆ្នាំ២០១៩ប៉ុណ្ណោះ។ ការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិមកកាន់ខេត្តសៀមរាបបានកើនឡើងដល់ ០,៤លាននាក់ ស្មើនឹង ៩ភាគរយនៃចំនួនភ្ញៀវទេសចរអន្តរជាតិសរុបក្នុងរយៈពេល ៨ខែដំបូងក្នុងឆ្នាំ ២០២៤ ធៀបនឹងចំនួន ១,៦៧លាន ឬ ៣៨,៥ភាគរយនៃចំនួនភ្ញៀវទេសចរអន្តរជាតិសរុប ក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

**បើគិតជាចំណែកនៃកម្រិតប្រាក់ចំណូលក្នុងឆ្នាំ២០១៩ ប្រាក់ចំណូលប្រចាំខែដែលទទួលបានពីការលក់សំបុត្រចូលប្រាសាទតំបន់អង្គរ បានកើនឡើងពី ២៩,៤ភាគរយក្នុងខែមករា ឆ្នាំ២០២៣ ឡើងដល់កម្រិតខ្ពស់បំផុត ៤៦ភាគរយក្នុងខែមីនា ឆ្នាំ២០២៣ ហើយបន្ទាប់មកបានធ្លាក់ចុះមកត្រឹម ៤៣,៧ភាគរយនៅក្នុងខែសីហា ឆ្នាំ២០២៤ (រូប ៥)។** ការធ្លាក់ចុះប្រាក់ចំណូល ពីទេសចរណ៍នេះ ឆ្លុះបញ្ចាំងឱ្យឃើញពីបញ្ហារចនាសម្ព័ន្ធ ពោលគឺការប្រែប្រួលសមាសភាពភ្ញៀវទេសចរជាជាងការប្រែប្រួលទៅតាមវដ្តទេសចរណ៍ ដែលទាមទារឱ្យមានការធ្វើកំណែទម្រង់ ជាចាំបាច់នៅក្នុងវិស័យទេសចរណ៍ដើម្បីបង្កើនប្រាក់ចំណូលបន្ថែម។

## ការនាំចេញទំនិញបានកើនឡើង

**ដោយត្រូវបានជំរុញដោយតម្រូវការខាងក្រៅកាន់តែខ្លាំង ការនាំចេញទំនិញរបស់កម្ពុជាបានកើនឡើងយ៉ាងខ្លាំង។** ក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ការនាំចេញទំនិញ (រួមទាំងមាស) បានកើនឡើង ១៣,៩ភាគរយធៀបនឹងរយៈពេល

5 គ្រឹះស្ថានអង្គរ ឆ្នាំ២០២៤។

ដូចគ្នាកាលពីឆ្នាំមុនដល់ ១៧,៨ពាន់លានដុល្លារ។ ការកើនឡើងការនាំចេញទំនិញនៅឆ្នាំនេះត្រូវបានជំរុញយ៉ាងខ្លាំងដោយការស្ទុះងើបឡើងវិញនៃការនាំចេញសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងផលិតផលស្បែកជើង (រូប ៦) ។ ក្នុងចំណោមផលិតផលមិនមែនសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងផលិតផលស្បែកជើង ទំនិញកសិកម្មនិងការនាំចេញផលិតកម្មឈើ បានបន្តមានភាពធន់។ ទោះជាយ៉ាងណាក៏ដោយ ការនាំចេញគ្រឿងអេឡិចត្រូនិកនិងគ្រឿងបរិក្ខារអគ្គិសនី កង់ និងបន្ទះថាមពលស្រូបពន្លឺព្រះអាទិត្យ បានថមថយ។ ការស្ទុះងើបឡើងវិញនៃការនាំចេញផលិតផលកាត់ដេរក៏ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញផងដែរ នៅក្នុងការស្ទុះងើបឡើងវិញនៃការនាំចូលទំនិញពាក់កណ្តាលសម្រេចចម្បងៗ ដែលត្រូវបានប្រើប្រាស់សម្រាប់ផលិតកផលិតផលសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងផលិតផលស្បែកជើងជាពិសេសក្រណាត់។ ការនាំចូលក្រណាត់បានកើនឡើង ២៤,៩ ភាគរយក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២៣ ដោយកើនឡើងពីកម្រិតអវិជ្ជមាន ១៦,៩ភាគរយនៅក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៣។

**កម្ពុជា បានជួបប្រទះនូវភាពប្រសើរឡើងក្នុងការនាំចេញទំនិញទៅកាន់ទីផ្សារធំៗទាំងអស់។** ក្នុងចំណោមកំណើននាំចេញទំនិញ ១៣,៩ភាគរយ សហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុប ដែលជាទីផ្សារធំជាងគេ និងធំទីបី និងបាននាំចូលជាចម្បងនូវផលិតផលសម្រេចសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងផលិតផលស្បែកជើង មានចំណែក ៤,១ពិន្ទុភាគរយ និង ២,៧ពិន្ទុភាគរយរៀងគ្នា។ ទីផ្សារអាស៊ាន ដែលជាទីផ្សារធំទីពីរ និងភាគច្រើននាំចូលទំនិញកសិកម្ម គ្រឿងបរិក្ខារអគ្គិសនី និងគ្រឿងបន្លាស់អេឡិចត្រូនិច មានចំណែក ២ពិន្ទុភាគរយនៃកំណើននាំចេញនេះ។ ទីផ្សារចិនដែលជាទីផ្សារធំជាងគេទីបួន និងភាគច្រើននាំចូលសម្លៀកបំពាក់រោមសត្វ ផលិតផលសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងផលិតផលស្បែកជើង ផលិតផលកសិកម្ម និងគ្រឿងបរិក្ខារអគ្គិសនីនិងយានយន្ត មានចំណែក ១,៣ពិន្ទុភាគរយនៃកំណើននាំចេញនេះ។ ទីផ្សារជប៉ុនដែលជាទីផ្សារធំទី៥ មានចំណែក ១ពិន្ទុភាគរយ។

**ក្នុងរយៈពេលប្រាំបីខែដំបូងនៅក្នុងឆ្នាំ២០២៤ ការនាំចេញទំនិញទៅកាន់សហរដ្ឋអាមេរិកបានកើនឡើងដល់ ៦,៧ពាន់លានដុល្លារ (ស្មើនឹង ៣៧,៨ភាគរយនៃការនាំចេញទំនិញសរុប)** ទៅអាស៊ានកើនឡើងដល់ ៣,៤ពាន់លានដុល្លារ (ស្មើនឹង ១៩,២ភាគរយ) ទៅសហភាពអឺរ៉ុបកើនឡើងដល់ ២,៩ពាន់លានដុល្លារ (ស្មើនឹង ១៦,៣ភាគរយ) ទៅប្រទេសចិនកើនឡើងដល់ ១,១ពាន់លានដុល្លារ (ស្មើនឹង ៦,៤ភាគរយ) និងទៅជប៉ុនកើនឡើង ០,៩ពាន់លានដុល្លារ (ស្មើនឹង ៥,២ភាគរយ)។

## ការងារកម្មន្តសាលបានកើនឡើងដោយសារកំណើននាំចេញសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងផលិតផលស្បែកជើង

**កំណើននាំចេញទំនិញ បាននាំឱ្យមានការកើនឡើងការងារក្នុងវិស័យកម្មន្តសាល។** បន្ទាប់ពីមានភាពធូរស្រាលខ្លះនៃលក្ខខណ្ឌទីផ្សារការងារ នៅក្នុងអំឡុងឆមាសទីមួយក្នុងឆ្នាំ២០២៣ ការងារកម្មន្តសាលបានចាប់ផ្តើមស្ទុះងើបឡើងវិញ។ វិស័យកម្មន្តសាលបានបន្ថែមការងារថ្មីចំនួន ៩៧.២២៩កន្លែងដល់ចំនួន ១,១២លានកន្លែង (ស្មើនឹង ១៩,៤ភាគរយនៃការងារមិនមែនកសិកម្ម

**រូប ៥ ៖ ប្រាក់ចំណូលពីការលក់សំបុត្រចូលទស្សនាតំបន់អង្គរ**
*(ចំណែក % នៃប្រាក់ចំណូលឆ្នាំ២០១៩, YTD)*




*ប្រភព៖ អាជ្ញាធរកម្ពុជា*
*សម្គាល់៖ YTD =* ចាប់ពីដើមឆ្នាំមកដល់ពេលនេះ

**រូប ៦ ៖ ការចូលរួមចំណែកដល់កំណើននាំចេញតាមផលិតផល**
*(YTD, ពិន្ទុភាគរយ)*




*ប្រភព៖ អាជ្ញាធរកម្ពុជា*
*សម្គាល់៖ GTF =* សម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងផលិតផលស្បែកជើង, YTD = ចាប់ពីដើមឆ្នាំមកដល់ពេលនេះ

ឬ ១២,៥ភាគរយនៃការងារសរុប)[6] នៅក្នុងខែសីហា ឆ្នាំ២០២៤ ពោលគឺកើនឡើង ៩,៥ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដោយសារការនាំចេញទំនិញបានកើនឡើង (រូប ៧)។ ក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ចំនួនការងារបានកើនឡើងនៅក្នុងឧស្សាហកម្មកម្មន្តសាលភាគច្រើន ពោលគឺជាឧស្សាហកម្មដែលកម្មករទទួលបានប្រាក់ឈ្នួលអប្បបរមា។ ប្រាក់ឈ្នួលអប្បបរមានៅតែបន្តកើនឡើងសន្សឹមៗ ដោយកើនឡើងដល់ ២០៤ដុល្លារអាមេរិកក្នុងមួយខែក្នុងឆ្នាំ២០២៤ កើនឡើងពី ១៨២ដុល្លារក្នុងមួយខែក្នុងឆ្នាំ២០១៩។ ការកើនឡើងនេះគួរតែជួយគាំទ្រដល់ការប្រើប្រាស់ឯកជន។

**លើសពីនេះ ផលិតភាពការងារក៏មានការកើនឡើងខ្លះផងដែរ ក្នុងឧស្សាហកម្មកាត់ដេរនៅកម្ពុជាមុននិងក្រោយកើតមានជំងឺរាតត្បាត។** ទោះបីជាការងារក្នុងឧស្សាហកម្មនេះបានធ្លាក់ចុះ ២៨,៩ភាគរយ ពោលគឺធ្លាក់ចុះមកនៅត្រឹមចំនួន ០,៦៤លាននាក់ក្នុងខែសីហា ឆ្នាំ២០២៤ ពីចំនួន ០,៩លាននាក់ក្នុងរយៈ ពេលដូចគ្នាក្នុងឆ្នាំ២០១៩ ក៏ដោយ ក៏តម្លៃនាំចេញសម្លៀកបំពាក់បានកើនឡើងចំនួន ១៤,៨ភាគរយដល់ចំនួន ៦,៤ពាន់លានដុល្លារអាមេរិក ពីចំនួន ៥,៦ពាន់លានដុល្លារក្នុងរយៈពេលដូចគ្នានេះ។

## ចំណាប់អារម្មណ៍របស់វិនិយោគិនបានកើនឡើង

**ខណៈពេលដែលសកម្មភាពសេដ្ឋកិច្ច មានភាពប្រសើរឡើង ចំណាប់អារម្មណ៍វិនិយោគក្នុងវិស័យពិតបានកើនឡើង ដែលបង្ហាញពីការកើនឡើងទំនុកចិត្តរបស់វិនិយោគិននៅក្នុងសេដ្ឋកិច្ច។** តម្លៃគម្រោងដែលបានអនុម័ត ដែលត្រូវបានចាត់ថ្នាក់ថា ជាគម្រោងវិនិយោគ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) បានកើនឡើងដល់ចំនួន ២,៤៤ពាន់លានដុល្លារអាមេរិក ពោលគឺកើនឡើង ៨៩,៤ភាគរយក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ កើនឡើងពីចំនួន ១,២៨ពាន់លានដុល្លារអាមេរិកក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣។ ក្នុងនោះ គម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត បានកើនឡើងដល់ចំនួន ១,១៣ពាន់លានដុល្លារអាមេរិក កើន២៤,៣ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ខណៈដែលតម្លៃវិនិយោគក្នុងស្រុកដែលបានអនុម័តបានកើនឡើងដល់ ១,៣១ពាន់លានដុល្លារអាមេរិក (រូប ៨) ពោលគឺកើនឡើង ២៤៤,៤ភាគរយ។

**ទោះជាយ៉ាងណា តម្លៃគម្រោងវិនិយោគដែលត្រូវបានអនុម័តនៅតែមានកម្រិតទាបជាងឆ្ងាយពីកម្រិតខ្ពស់បំផុតចំនួន ៥,៤ពាន់លានដុល្លារអាមេរិក ដែលបានកត់ត្រាក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩ ជាពេលដែលតម្លៃគម្រោងក្នុងស្រុកដែលបានអនុម័ត មានចំនួន ៣,៨ពាន់លានដុល្លារអាមេរិក និងតម្លៃគម្រោងដែលត្រូវបានផ្តល់ហិរញ្ញប្បទាន ដោយការវិនិយោគផ្ទាល់ពីបរទេស ដែលបានអនុម័តមានចំនួន ១,៥ពាន់លានដុល្លារអាមេរិក។** បើទោះជាមានភាពប្រសើរឡើងក៏ដោយ ក៏ចំណាប់អារម្មណ៍របស់វិនិយោគិនក្នុងស្រុកក្នុងការវិនិយោគលើវិស័យពិត នៅតែមានភាពទន់ខ្សោយក្នុងឆ្នាំ២០២៤។ តម្លៃគម្រោងវិនិយោគក្នុងស្រុកមានចំនួន ៥៣,៨ភាគរយនៃតម្លៃគម្រោងសរុបដែលបានអនុម័តនៅឆ្នាំ២០២៤ ពោលគឺធ្លាក់ចុះពី ៧១,៥ភាគរយក្នុងឆ្នាំ២០១៩។

**នៅក្នុងចំណោមទឹកប្រាក់វិនិយោគសរុបចំនួន ២,៤៤ពាន់លានដុល្លារអាមេរិក ឧស្សាហកម្មកាត់ដេរទទួលបានចំនួន ៣៦០លានដុល្លារអាមេរិក ស្មើនឹង ១៤,៧ភាគរយនៃចំនួនសរុបដែលមួយផ្នែកឆ្លុះបញ្ចាំងឱ្យឃើញពីការផ្លាស់ទីតាំងខ្សែច្រវាក់**

**រូប ៧ ៖ ការងារក្នុងវិស័យកម្មន្តសាល និងរោងចក្រ**




*ប្រភព៖ អាជ្ញាធរកម្ពុជា*

*សម្គាល់៖ RHS = ខាងស្តាំ*

**រូប ៨ ៖ តម្លៃគម្រោង QIP ដែលត្រូវបានអនុម័ត**

*(ពាន់លានដុល្លារអាមេរិក, ទ្រព្យសកម្មថេរ)*




*ប្រភព៖ អាជ្ញាធរកម្ពុជា*

*សម្គាល់៖ QIP = គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់*

6 ក្រសួងផែនការ ឆ្នាំ២០២១។

**ផ្តត់ផ្តង់ពីប្រទេសបង់ក្លាដែស។** វិស័យកសិកម្ម និងកសិកែច្នៃ ទទួលបានទឹកប្រាក់វិនិយោគចំនួន ១២១លានដុល្លារអាមេរិក ឬស្មើនឹង ៥ភាគរយនៃចំនួនសរុប ដោយសារតម្រូវការនាំចេញផលិតផលកសិកម្មកែច្នៃ កើនឡើង។ វិស័យកម្មន្តសាលមិនមែនកាត់ដេរមានចំនួន ១,៣៧ពាន់លានដុល្លារអាមេរិក ឬស្មើនឹង ៥៦,២ភាគរយនៃចំនួនសរុប ដែលមានគម្រោងវិនិយោគធំៗមួយចំនួនរួមទាំងគម្រោងថាមពលចំនួនពីរ គឺរោងចក្រវារីអគ្គិសនីតម្លៃ ៤៤១,៥លានដុល្លារអាមេរិក និងគម្រោងថាមពលពន្លឺព្រះអាទិត្យតម្លៃ ៦៥,៥ដុល្លារអាមេរិក ដែលឆ្លុះបញ្ចាំងឱ្យឃើញពីតម្រូវការជាបន្តនូវការវិនិយោគលើវិស័យថាមពល ដោយសារតែតម្លៃអគ្គិសនីនៅក្នុងប្រទេសនៅតែមានកម្រិតខ្ពស់នៅឡើយ។ លើសពីនេះ មានគម្រោងកែច្នៃដែក និងផលិតដែកបំពង់ទីបដែលមានតម្លៃសរុប ៤២លានដុល្លារអាមេរិក។ វិស័យអចលនទ្រព្យទទួលបានទឹកប្រាក់វិនិយោគដែលនៅសល់ពោលគឺចំនួន ០,៥៧ពាន់លានដុល្លារអាមេរិក ឬស្មើនឹង ២៤,១ភាគរយនៃចំនួនសរុប។

## ចំណាប់អារម្មណ៍ប្រកបដោយភាពទុទិដ្ឋិនិយមរបស់វិនិយោគិនក្នុងស្រុកក្នុងការវិនិយោគលើវិស័យដែលអាចជួញដូរបាន

**ការវិនិយោគដែលផ្តល់ហិរញ្ញប្បទានដោយការវិនិយោគផ្ទាល់ពីបរទេសនៅក្នុងវិស័យកាត់ដេរ មានចំនួន ៩៨,១ភាគរយ និងនៅក្នុងវិស័យកសិកម្ម និងកសិកែច្នៃមានចំនួន ៧០,១ភាគរយនៃការវិនិយោគសរុប។** កត្តានេះបញ្ជាក់ឱ្យឃើញថា ស្រដៀងគ្នាទៅនឹងការវិនិយោគ នៅក្នុងអំឡុងពេលមុនកើតមានជំងឺរាតត្បាតកូវីដ-១៩ ដែរ មានការចាប់អារម្មណ៍តិចតួចពីសំណាក់វិនិយោគិនក្នុងស្រុកកម្ពុជាក្នុងការវិនិយោគលើវិស័យនាំចេញចម្បង និងវិស័យកសិកម្មចម្បងដ៏សំខាន់នេះ។ កង្វះចំណាប់អារម្មណ៍នេះទំនងជាកើតមានឡើងដោយសារតែបញ្ហាប្រឈម នៅក្នុងភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម (សូមមើលផ្នែករូបិយវត្ថុខាងក្រោម)។

**ក្នុងចំណោមតម្លៃគម្រោង ដែលផ្តល់ហិរញ្ញប្បទានដោយការវិនិយោគផ្ទាល់ពីបរទេសចំនួន ១,៥៣ពាន់លានដុល្លារអាមេរិក ដែលបានកត់ត្រាក្នុងអំឡុងពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ឧស្សាហកម្មមិនមែនកាត់ដេរ និងឧស្សាហកម្មសេវាសាធារណៈ (Utilities) ទទួលបានការវិនិយោគចំនួន ៦០១,២លានដុល្លារអាមេរិក (៥៣,៣ភាគរយនៃចំនួនសរុប) (រូប ៩)។** ឧស្សាហកម្មកាត់ដេរទទួលបានការវិនិយោគចំនួន ៣៥៣,១លានដុល្លារអាមេរិក (៣១,៣ភាគរយ) ឧស្សាហកម្មទេសចរណ៍ទទួលបានការវិនិយោគចំនួន ៨៨,៩ លានដុល្លារ (៧,៩ភាគរយ) និងកសិកម្មនិងកែច្នៃអាហារ ទទួលបានការវិនិយោគ ចំនួន ៨៤,៨ លានដុល្លារ (៧,៥ភាគរយ)។ គម្រោងវិនិយោគដែលផ្តល់ហិរញ្ញប្បទាន ដោយប្រទេសចិន បានបន្តមានចំណែកភាគច្រើននៃតម្លៃគម្រោង ដែលផ្តល់ហិរញ្ញប្បទានដោយការវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តសរុប។ ក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ តម្លៃគម្រោងដែលផ្តល់ហិរញ្ញប្បទានប្រទេសចិន បើគិតជាចំណែកនៃតម្លៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តសរុប នៅតែមានកម្រិតខ្ពស់រហូតដល់ ៨៦,៣ភាគរយស្មើនឹង ៩៧៤លានដុល្លារអាមេរិក។ ចំនួននេះមានការកើនឡើងយ៉ាងច្រើនពីកម្រិតជាមធ្យម ៤០ភាគរយ

**រូប ៩ ៖ គម្រោងផ្តល់ហិរញ្ញប្បទានដោយ FDI ដែលត្រូវបានអនុម័តតាមវិស័យ**

*(លានដុល្លារ, ៨ខែក្នុងឆ្នាំ២០២៤)*




*ប្រភព៖ អាជ្ញាធរកម្ពុជា*

**រូប ១០ ៖ គម្រោងអចលនទ្រព្យដែលត្រូវបានអនុម័ត**

*(លានដុល្លារអាមេរិក)*




*ប្រភព៖ អាជ្ញាធរកម្ពុជា*

*សម្គាល់៖ RHS = ខាងស្តាំ, SHV = ខេត្តព្រះសីហនុ*

ក្នុងអំឡុងពេល ៥ឆ្នាំមុនកើតមានជំងឺរាតត្បាតកូវីដ-១៩ ដែលបង្ហាញពីការពឹងផ្អែកកាន់តែខ្លាំងលើការវិនិយោគផ្ទាល់ពីបរទេសរបស់ប្រទេសចិន។ ការសិក្សាមួយចំនួនបានចង្អុលបង្ហាញថា វិនិយោគិនជនជាតិចិនជាទូទៅមាននិន្នាការមិនសូវប្រថុយប្រថាន[7] ដែលអាចជាហេតុផលមួយសម្រាប់កម្ពុជាក្នុងការបន្តទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសពីប្រទេសចិន។ លើសពីនេះទៀត ការយល់ដឹងអំពីការវិនិយោគផ្ទាល់ពីបរទេសរបស់ចិន ទាមទារឱ្យមានការវិភាគលើអាទិភាពជាយុទ្ធសាស្ត្ររបស់ប្រទេសចិន។ ការគ្រប់គ្រងអំពើពុករលួយកាន់តែប្រសើរ នៅក្នុងប្រទេសជាទិសដៅវិនិយោគ ជួយជំរុញលំហូរវិនិយោគពីប្រទេសមិនសូវមានអំពើពុករលួយ ជាងពីប្រទេសដែលមានអំពើពុករលួយច្រើន[8]។

## ការធ្លាក់ចុះក្នុងវិស័យអចលនទ្រព្យបានបន្តកើតមាន

**ការវិនិយោគលើសតម្រូវការ នៅក្នុងវិស័យអចលនទ្រព្យបាននាំឱ្យមានការធ្លាក់ចុះជាបន្តបន្ទាប់នៅក្នុងទីផ្សារលំនៅឋាន។** ការណ៍នេះបានបណ្តាលឱ្យមាននិន្នាការធ្លាក់ចុះនៃតម្លៃលិខិតអនុញ្ញាតសាងសង់សម្រាប់គម្រោងអភិវឌ្ឍន៍អចលនទ្រព្យដែលត្រូវបានអនុម័ត។ នៅក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ តម្លៃគម្រោងអភិវឌ្ឍន៍អចលនទ្រព្យដែលបានអនុម័ត បានកើនឡើងដល់ចំនួន ៣,៣៣ពាន់លានដុល្លារអាមេរិក ធ្លាក់ចុះ ២៩,១ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (រូប ១០) ដែលជំរុញដោយការធ្លាក់ចុះការវិនិយោគលើអចលនទ្រព្យលំនៅឋាន។ ចំនួនផ្ទៃក្រឡាគិតជាម៉ែត្រការ៉េនៃគម្រោងអភិវឌ្ឍន៍អចលនទ្រព្យដែលត្រូវបានអនុម័តបានថយចុះយ៉ាងខ្លាំងមកនៅត្រឹម ៨លានម៉ែត្រការ៉េ ពោលគឺធ្លាក់ចុះ ៣០,១ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ដោយមិនគិតពីការធ្លាក់ចុះជារួមនៃការអនុញ្ញាតសាងសង់ សម្រាប់គម្រោងអភិវឌ្ឍន៍អចលនទ្រព្យ ផ្ទៃក្រឡាអគារឧស្សាហកម្មដែលត្រូវបានអនុម័ត កំពុងមាននិន្នាការកើនឡើង ហើយបច្ចុប្បន្ននេះមានចំណែកធំបំផុត។ ជាពិសេស ផ្ទៃក្រឡាអគារឧស្សាហកម្មដែលបានអនុម័ត បានកើនឡើងដល់ ៣លានម៉ែត្រការ៉េ ឬកើនឡើង ៧,១ភាគរយក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាកាលឆ្នាំមុនស្មើនឹង ៣៧,៥ភាគរយនៃផ្ទៃក្រឡាសរុបដែលត្រូវបានអនុម័ត។

**ទោះបើជាមានការធ្លាក់ចុះការវិនិយោគជារួមក៏ដោយ ក៏មានការចាប់អារម្មណ៍គួរឱ្យកត់សម្គាល់ចំពោះការវិនិយោគនៅក្នុងក្រុងព្រះសីហនុ ដែលជាទីក្រុងមាត់សមុទ្រ ដែលបានជួបប្រទះការរីកចម្រើនយ៉ាងខ្លាំងខាងផ្នែកសាងសង់ក្នុងអំឡុងពេលមុនកើតមានការរីករាលដាលនៃជំងឺរាតត្បាត។** នៅក្នុងចំណោមតម្លៃអនុញ្ញាតសាងសង់សរុប ដែលត្រូវបានអនុម័ត តម្លៃអនុញ្ញាតសម្រាប់គម្រោងអភិវឌ្ឍន៍អចលនទ្រព្យនានា ដែលបានអនុម័តនៅក្នុងខេត្តព្រះសីហនុមានចំនួន ៨៧៥,៥លានដុល្លារអាមេរិក ពោលគឺកើនឡើង ១៣២,៤ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ នៅក្នុងខែមករា ឆ្នាំ២០២៤ អាជ្ញាធរកម្ពុជាបានដាក់ចេញ "កម្មវិធីពិសេសដើម្បីជំរុញការវិនិយោគនៅក្នុងខេត្តព្រះសីហនុឆ្នាំ២០២៤"។ កម្មវិធីនេះអនុវត្តចំពោះ (i) អគារទាក់ទងនឹងគម្រោងដែលបានជាប់គាំង (ii) គម្រោងថ្មី និង (iii) ការពង្រីកគម្រោងវិនិយោគដែលមានស្រាប់ ដែលឆ្លើយតបទៅនឹងយុទ្ធសាស្ត្រ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការអនុវត្តផែនការមេ ដើម្បីប្រែក្លាយខេត្តព្រះសីហនុឱ្យទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង។ កម្មវិធីនេះផ្តល់ការលើកលែងពន្ធលើប្រាក់ចំណូល អាករលើតម្លៃបន្ថែម ពន្ធកាត់ទុក និងពន្ធលើអចលនទ្រព្យ ក្នុងចំណោមការលើកទឹកចិត្តផ្សេងទៀត[9]។ ដោយសារកម្មវិធីនេះ ការចាប់អារម្មណ៍ខ្លាំងកើតមានជាថ្មីនៅក្នុងតំបន់នេះ។ សូមមើលការពិភាក្សាបន្ថែមអំពីវិស័យអចលនទ្រព្យនៅក្នុងប្រអប់ទី១។

## ការនាំចូលដែកបានកើនឡើងយ៉ាងខ្លាំង ដែលត្រូវបានជំរុញដោយការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធបវរន្ត

**ទោះបីជាសកម្មភាពសាងសង់អចលនទ្រព្យដែលផ្តល់ហិរញ្ញប្បទានដោយឯកជននៅតែធ្លាក់ចុះក៏ដោយ ក៏ការវិនិយោគស្ថិតក្រោមភាពជាដៃគូសាធារណៈ និងឯកជននៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធបវរន្តធំៗដូចជាផ្លូវថ្នល់ ស្ពាន និងកំពង់ផែរួមទាំងព្រែកជីកតម្លៃ ១,៧៣ពាន់លានដុល្លារ បានជំរុញសេវាកម្មសាងសង់។** ការផ្លាស់ប្តូរឆ្ពោះទៅរកគម្រោងហេដ្ឋារចនាសម្ព័ន្ធនេះបង្ហាញពីការផ្តោតយកចិត្តទុកដាក់ជាយុទ្ធសាស្ត្រលើការលើកកម្ពស់ការតភ្ជាប់ និងការគាំទ្រសកម្មភាពសេដ្ឋកិច្ច តាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធ។ ជាលទ្ធផល ការនាំចូលសម្ភារៈសំណង់ជាមូលដ្ឋានបានកើនឡើង បន្ទាប់ពីបានជួបប្រទះការធ្លាក់ចុះយ៉ាងខ្លាំងក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះចាប់តាំងពីមានការរីករាលដាលជំងឺរាតត្បាត។

**នៅក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ការនាំចូលដែក ដែលប្រើប្រាស់សម្រាប់ឧស្សាហកម្មសំណង់គ្រប់ប្រភេទ**

7 "តើអ្វីជាកត្តាកំណត់ការវិនិយោគពីបរទេសរបស់ប្រទេសចិន?" https://www.sciencedirect.com/science/article/pii/S109095161000074X.
8 "តើអំពើពុករលួយមានសារៈសំខាន់ចំពោះប្រភពវិនិយោគផ្ទាល់ពីបរទេសមែនទេ?" ធនាគារអឺរ៉ុបសម្រាប់ការកសាងឡើងវិញនិងអភិវឌ្ឍន៍ https://www.ebrd.com/documents/oce/does-corruption-matter-for-sources-of-foreign-direct-investment.pdf.
9 កម្មវិធីជំរុញការវិនិយោគពិសេសនៅខេត្តព្រះសីហនុឆ្នាំ២០២៤ https://pressocm.gov.kh/en/archives/90596។

**បានកើនឡើង ៣១,៩ភាគរយ បើគិតពីតម្លៃ និងកើនឡើង ៥៨,៦ភាគរយបើគិតពីបរិមាណ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។** ការនាំចូលសម្ភារៈសំណង់ ក៏បានកើនឡើងយ៉ាងឆាប់រហ័សផងដែរ ពោលគឺកើនឡើង ២០,១ភាគរយបើគិតពីតម្លៃ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ទន្ទឹមនឹងនេះដែរ ការនាំចូលស៊ីម៉ង់ត៍បានធ្លាក់ចុះ ១៥,៤ភាគរយបើគិតពីតម្លៃ និងធ្លាក់ចុះ ១៤,៥ភាគរយបើគិតពីបរិមាណ ដែលទំនងជាដោយសារតែការកើនឡើងផលិតកម្មក្នុងស្រុក។ ការវិនិយោគស្ថិតក្រោមភាពជាដៃគូសាធារណៈ និងឯកជន និងការវិនិយោគឯកជនលើអចលនទ្រព្យពាណិជ្ជកម្ម និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជារោងចក្រ ការិយាល័យ ផ្លូវថ្នល់ ស្ពាន ភស្តុភារ និងហេដ្ឋារចនាសម្ព័ន្ធកំពង់ផែនៅតែបន្តធ្វើឡើង។ ការណ៍នេះបង្ហាញឱ្យឃើញតាមរយៈការកើនឡើង ការអនុញ្ញាតសាងសង់អគារឧស្សាហកម្ម និងគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មិនមែនកាត់ដេរ ដែលត្រូវបានផ្តល់ហិរញ្ញប្បទានដោយការវិនិយោគផ្ទាល់ពីបរទេស ដែលត្រូវបានអនុម័ត។

## ការនាំចេញទំនិញកសិកម្មបានថមថយ

**ប្រទេសកម្ពុជា បានបង្ហាញកំណើនគួរឱ្យកត់សម្គាល់ក្នុងការនាំចេញទំនិញកសិកម្មរបស់ខ្លួន ជាពិសេសការនាំចេញដំឡូងមី ស្វាយចន្ទី កៅស៊ូ និងអង្ករ។** ក្នុងរយៈពេលប្រាំបីខែដំបូងនៅក្នុងឆ្នាំ២០២៤ ការនាំចេញដំឡូងមីបានកើនឡើង ១៤,១ភាគរយដល់ ៥៥៧លានដុល្លារអាមេរិក។ ការនាំចេញគ្រាប់ស្វាយចន្ទីបានកើនឡើង ៣២,៦ភាគរយដល់ ៤៩១,៦លានដុល្លារអាមេរិក។ ការនាំចេញកៅស៊ូបានកើនឡើង ៥០ភាគរយដល់ ៣៤៨,៩លានដុល្លារអាមេរិក។ ការនាំចេញអង្ករបានកើនឡើង ៩ភាគរយដល់ ៣០៣,៨លានដុល្លារអាមេរិក។ រួមបញ្ចូលគ្នាការនាំចេញទំនិញសំខាន់ៗទាំងបួនមុខនេះមានតម្លៃ ១,៩ពាន់លានដុល្លារអាមេរិក ដែលឆ្លុះបញ្ចាំងឱ្យឃើញពីការកើនឡើង ២១,២ភាគរយ។ ការនាំចេញគ្រាប់ស្វាយចន្ទី បានកើនឡើងជាពិសេសដោយកើនឡើងក្នុងអត្រាប្រចាំឆ្នាំជាមធ្យម ៤០,៩ភាគរយក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ ដែលធ្វើឱ្យទំនិញនេះក្លាយជាការនាំចេញកសិផលធំទីពីរបន្ទាប់ពីដំឡូងមី។

**ដំបូងឡើយ ការនាំចេញកសិផលរបស់ប្រទេសកម្ពុជាភាគច្រើនជាអង្ករ និងកៅស៊ូ។** ទោះជាយ៉ាងណាក៏ដោយ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ កម្ពុជាបានធ្វើពិពិធកម្មការនាំចេញកសិផលរបស់ខ្លួនដោយរួមបញ្ចូលផលិតផលដំឡូងមីហើយថ្មីៗនេះ បន្ថែមគ្រាប់ស្វាយចន្ទីថែមទៀត។ ការធ្វើពិពិធកម្មនិងកំណើននាំចេញកសិផលនេះត្រូវបានគាំទ្រដោយកត្តាផ្សេងៗរួមទាំងតម្លៃដែលមានស្ថិរភាពសម្រាប់ស្រូវ និងដំណាំផ្សេងទៀតនិងការធ្វើឱ្យទំនាក់ទំនងពាណិជ្ជកម្ម ប្រសើរឡើង។ លើសពីនេះ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន (CCFTA) បានជួយសម្រួលដល់ការចូលទៅកាន់ ទីផ្សារចិនកាន់តែច្រើនដែលជំរុញការនាំចេញកសិផលបន្ថែមទៀត។ ទោះជាយ៉ាងណាការនាំចេញផលិតផលឈើ គ្រឿងសង្ហារិម និងផលិតផលកសិកម្មផ្សេងទៀតរបស់ប្រទេសកម្ពុជា បានថមថយ ដោយបានធ្លាក់ចុះ ៥៦,៧ភាគរយ។ ជាលទ្ធផល ការនាំចេញសរុបនៃទំនិញកសិកម្ម ផលិតផលឈើ គ្រឿងសង្ហារឹម និងការនាំចេញកសិផលផ្សេងទៀតបានធ្លាក់ចុះ ១១,៩ភាគរយ ក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (រូប ១១)។

**យោងតាមរបាយការណ៍ប្រចាំខែរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឱ្យដឹងថា ផ្ទៃដីដាំដុះស្រូវរដូវវស្សាបានកើនឡើងដល់ ២,៨៩លានហិកតាពោលគឺកើនឡើង ៤,៧ភាគរយក្នុងរយៈពេល ៩ខែដំបូងក្នុងឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។** ទោះជាយ៉ាងណា ការប្រមូលផលដំណាំស្រូវរដូវវស្សាដែលដាំដុះរយៈពេលខ្លីមានចំនួនត្រឹមតែ ២,៣លានតោនប៉ុណ្ណោះ ធ្លាក់ចុះ ៥,៧ភាគរយធៀបនឹងពេលដូចគ្នាកាលពីឆ្នាំមុន។

**រូប ១១ ៖ ការនាំចេញទំនិញកសិកម្ម**

*(ប្រែប្រួលជាភាគរយ y/y)*




*ប្រភព៖ អាជ្ញាធរកម្ពុជា*

*សម្គាល់៖ m = ខែ*

**រូប ១២ ៖ ការនាំចូលទំនិញប្រើប្រាស់បានកើនឡើង**

*(ប្រែប្រួលជាភាគរយ y/y )*




*ប្រភព៖ អាជ្ញាធរកម្ពុជា*

*សម្គាល់៖ y/y = ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន*

## ការប្រើប្រាស់ឯកជនមានភាពប្រសើរឡើង

**ការប្រើប្រាស់ឯកជន ដែលបានធ្លាក់ចុះខ្លាំងនៅក្នុងឆ្នាំ២០២៣ នៅពេលដែលតម្រូវការក្នុងស្រុកបានថមថយ បានស្ទុះងើបឡើងវិញខ្លះនៅក្នុងឆ្នាំ២០២៤ ដែលជំរុញដោយកត្តាជាច្រើន។** ការនាំចេញផ្នែកកម្មន្តសាល បានចាប់ផ្តើមស្ទុះងើបឡើងវិញនៅត្រីមាសទី៤ ឆ្នាំ២០២៣ ដោយបន្ថែមចំនួនការងារថ្មី និងបង្កើនប្រាក់ចំណូល។ វិស័យកម្មន្តសាលដែលរួមចំណែក ១៩,៨ភាគរយនៃការងារមិនមែនកសិកម្ម បានបង្កើតការងារថ្មីសុទ្ធចំនួន ៩៧.២២៩កន្លែង ឬកើនឡើង ៩,៥ភាគរយក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ការណ៍នេះបានជួយគាំទ្រដល់ការចំណាយរបស់អ្នកប្រើប្រាស់។ ដោយសារវិធានការគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាលសាច់ប្រាក់ងាយស្រួលក្នុងទីផ្សារមានភាពប្រសើរឡើង ទោះបីជាអត្រាការប្រាក់កើនឡើងក៏ដោយ (សូមមើលការពិភាក្សានៅផ្នែករូបិយវត្ថុខាងក្រោម)។ ការនាំចេញសេវាកម្មជាពិសេសប្រាក់ចំណូលពីវិស័យទេសចរណ៍ បានកើនឡើងនៅពេលដែលភ្ញៀវអន្តរជាតិស្ទុះងើប។ ប្រាក់បញ្ញើពីបរទេសរបស់ពលករក៏បានកើនឡើងផងដែរ។

**ការប្រើប្រាស់ក្នុងស្រុកមានប្រហែលពីរភាគបីនៃផលិតផលក្នុងស្រុកសរុប។** ការស្ទុះងើបឡើងវិញមួយផ្នែកនៃការប្រើប្រាស់ក្នុងស្រុក បានចាប់ផ្តើមគាំទ្រដល់សកម្មភាពលក់រាយនិងលក់ដុំដែលបានឆ្លុះបញ្ចាំងឱ្យឃើញ តាមរយៈការកើនឡើងការនាំចូលទំនិញប្រើប្រាស់។ ក្នុងអំឡុងពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ការនាំចូលទំនិញប្រើប្រាស់ដែលមានអាយុកាលខ្លីធំៗ បានកើនឡើងយ៉ាងខ្លាំង។ ការនាំចូលប្រេងម៉ាស៊ូតបានកើនឡើង ១៦,១ភាគរយ គ្រឿងអេឡិចត្រូនិកបានកើនឡើង ៣១,៩ភាគរយ ប្រេងសាំងបានកើនឡើង ២១,១ភាគរយ គ្រឿងឧបភោគបរិភោគបានកើនឡើង ១៤,៨ភាគរយ សម្លៀកបំពាក់បានកើនឡើង ២១,២ភាគរយ និងភេសជ្ជៈបានកើនឡើង ១៦,៦ភាគរយ (រូប ១២) ។ ដូចគ្នានេះដែរ ក្នុងអំឡុងពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ការនាំចូលទំនិញប្រើប្រាស់អាយុកាលវែងរួមមានម៉ូតូ រថយន្តដឹកអ្នកដំណើរ ឡានដឹកទំនិញ រថយន្តក្រុង ត្រាក់ទ័រ និងយានយន្តផ្សេងទៀតបានកើនឡើង ១៨ភាគរយ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ការកើនឡើងនៃការប្រើប្រាស់ឯកជន បាននាំឱ្យមានការកើនឡើងពន្ធលើទំនិញ និងសេវាកម្ម និងពន្ធលើពាណិជ្ជកម្មអន្តរជាតិ (សូមមើលការពិភាក្សាស្តីពីការប្រមូលចំណូលក្នុងវិស័យសារពើពន្ធខាងក្រោម)។

**ទោះយ៉ាងណា បញ្ហាប្រឈមក្នុងការរក្សានិរន្តរភាពតម្រូវការក្នុងស្រុកនៅតែមាន។** ការស្ទុះងើបឡើងវិញបឋមនៃតម្រូវការក្នុងស្រុក បានជួយជំរុញការនាំចូលទំនិញ ប៉ុន្តែទំនងជាមិនមាននិរន្តរភាពទេ ដោយសារតែការធ្លាក់ចុះគួរឱ្យកត់សម្គាល់នៃកំណើនឥណទានក្នុងស្រុក។ ការជំរុញកំណើនប្រាក់ចំណូលគ្រួសារ និងកំណើនប្រាក់ឈ្នួល ប្រឈមនឹងបញ្ហានានា។ ទោះបីជាមានការកើនឡើងការងារផ្នែកកម្មន្តសាលសមរម្យក៏ដោយ ក៏គ្រួសារនៅតែប្រឈមនឹងកំណើនប្រាក់ឈ្នួលយឺត ដោយប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យនាំចេញផលិតកម្មកើនឡើងត្រឹមតែ ២ភាគរយប៉ុណ្ណោះ។ កំណើនយឺតយ៉ាវក្នុងទីផ្សារការងារដែលមួយផ្នែកធំ បណ្តាលមកពីសកម្មភាពសំណង់ ដែលជាប់គាំង នៅតែជាក្តីបារម្ភបន្តជា។ ការវិភាគស៊ីជម្រៅមិនអាចធ្វើឡើងបានឡើយ ដោយសារមិនមានទិន្នន័យជាក់ស្តែង អំពីការចំណាយប្រើប្រាស់ផ្ទាល់ខ្លួនលើទំនិញប្រើប្រាស់អាយុកាលវែង និងអាយុកាលខ្លី និងសេវាកម្ម ជាពិសេសទិន្នន័យលក់រាយដើម្បីវាស់ស្ទង់តម្រូវការអ្នកប្រើប្រាស់ សម្រាប់ទំនិញផលិតផលសម្រេច។

## អតិផរណានៅតែមានកម្រិតទាប

**ទោះបីជាតម្រូវការក្នុងស្រុក មានភាពប្រសើរឡើងខ្លះក៏ដោយ ក៏សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ (CPI) របស់កម្ពុជានៅតែថមថយ ដោយបានធ្លាក់ចុះមកនៅត្រឹម ០,៣ភាគរយក្នុងខែសីហា ឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ពោលគឺធ្លាក់ចុះពីអត្រា ៣,២ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៣ (រូប ១៣)។** អតិផរណាបានចាប់ផ្តើមធ្លាក់ចុះបន្ទាប់ពីបានឡើងដល់អត្រា ៧,៨ភាគរយនៅក្នុងខែមិថុនា ឆ្នាំ២០២២ ពោលគឺជាកម្រិតខ្ពស់បំផុតក្នុងរយៈពេល ១៣ឆ្នាំ ដែលបង្កឡើងយ៉ាងខ្លាំងដោយសារវិបត្តិតម្លៃស្បៀងអាហារ និងប្រេងពិភពលោក។ ទោះបីជាតម្លៃអង្ករបានកើនឡើងក៏ដោយ ក៏តម្លៃសាច់និងត្រីជាមធ្យមបានធ្លាក់ចុះ ហើយតម្លៃបន្លែ និងផ្លែឈើជាមធ្យមបានធ្លាក់ចុះ ដែលនាំឱ្យមានការថយចុះសមាសធាតុអាហារ (សន្ទស្សន៍រង)។ កត្តានេះបានជួយធ្វើឱ្យអតិផរណារបស់កម្ពុជាធ្លាក់ចុះបន្ថែម ដោយហេតុថា សន្ទស្សន៍រងអាហារមានចំណែក ៤៣ភាគរយនៅក្នុងកញ្ចប់អតិផរណា។ បន្ថែមពីលើនេះទៀត តម្លៃផលិតផលប្រេង និងលំនៅឋាននិងសេវាសាធារណៈ ក៏ចាប់ផ្តើមធ្លាក់ចុះផងដែរ។ តម្លៃទំនិញក្នុងស្រុកមានភាពស្របគ្នាទៅនឹងតម្លៃទំនិញក្នុងពិភពលោក។ តម្លៃថាមពលសកលបានធ្លាក់ចុះ ៣,២ភាគរយនៅក្នុងខែសីហា ដែលនាំមុខដោយការធ្លាក់ចុះតម្លៃប្រេងឆៅ (-៦,២ភាគរយ) នេះបើយោងតាមឯកសារពណ៌ផ្កាឈូក (Pink Sheet) របស់ធនាគារពិភពលោក[10]។ តម្លៃទំនិញមិនមែនថាមពល បានធ្លាក់ចុះ ១,៩ភាគរយ។ តម្លៃទំនិញកសិកម្មបានធ្លាក់ចុះ ១,៤ភាគរយក្នុងខែសីហា។ តម្លៃអាហារបានធ្លាក់ចុះ ២,៣ភាគរយដែលជំរុញដោយប្រេង និងអាហារ (-៥,១ភាគរយ)។

10 ឯកសារពណ៌ផ្កាឈូក (Pink Sheet) របស់ធនាគារពិភពលោកផ្តល់ទិន្នន័យតម្លៃទំនិញ។

### ប្រអប់ ១ ៖ ការស្វែងរកវិធីដោះស្រាយហានិភ័យនៃការធ្លាក់ចុះទីផ្សារអចលនទ្រព្យ

**ក្នុងអំឡុងឆ្នាំ២០១១-២០១៩ ប្រទេសកម្ពុជាបានជួបប្រទះនូវកំណើន ផ.ស.ស ដ៏រឹងមាំ ដែលមានជាមធ្យមប្រមាណ ៨ភាគរយក្នុងមួយឆ្នាំ។** ទន្ទឹមនឹងវិស័យកាត់ដេរ កសិកម្ម និងទេសចរណ៍ វិស័យសំណង់និងអចលនទ្រព្យបានលេចចេញជាចំណែកដ៏សំខាន់ក្នុងកំណើនសេដ្ឋកិច្ច។ ការចូលរួមចំណែករបស់វិស័យសំណង់ និងអចលនទ្រព្យចំពោះកំណើន ផ.ស.ស បានកើនឡើងពី ០,៥ពិន្ទុភាគរយក្នុងឆ្នាំ២០១១ ដល់ ២,៥ពិន្ទុភាគរយ ដែលស្មើនឹង ៣០ភាគរយនៃកំណើនសេដ្ឋកិច្ចពិតក្នុងអំឡុងឆ្នាំ២០១៦-២០១៩។ ការណ៍នេះឆ្លុះបញ្ចាំងឱ្យឃើញពីដំណើរការនគូបនីយកម្មរបស់ប្រទេសកម្ពុជា និងការផ្លាស់ប្តូររចនាសម្ព័ន្ធកាន់តែទូលំទូលាយ។ កត្តានេះបានបង្កើតឱ្យមានការពឹងផ្អែកយ៉ាងខ្លាំងលើ (ដែលស្ទើរតែក្លាយជាការញៀននឹង) វិស័យអចលនទ្រព្យសម្រាប់កំណើនសេដ្ឋកិច្ច។

**ទោះជាយ៉ាងណា សន្ទុះកំណើនវិស័យសំណង់និងអចលនៈទ្រព្យ ត្រូវបានរំខានយ៉ាងធ្ងន់ធ្ងរដោយសារការចាប់ផ្តើមកើតមានជំងឺរាតត្បាតកូវីដ-១៩។** ក្នុងឆ្នាំ២០២០ វិស័យទាំងនេះមានការចូលរួមចំណែកអវិជ្ជមានចំពោះកំណើនសេដ្ឋកិច្ចពិត ១,២ពិន្ទុភាគរយជាលើកដំបូងគិតចាប់តាំងពីឆ្នាំ២០១០មក។ ការធ្លាក់ចុះនេះត្រូវបានជំរុញដោយការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក ដែលធ្វើឱ្យឥទ្ធិពលនៃជំងឺរាតត្បាតកាន់តែមានភាពធ្ងន់ធ្ងររហូតដល់សព្វថ្ងៃនេះ។

**នៅឆ្នាំ២០២៣ ចំណាប់អារម្មណ៍វិនិយោគក្នុងវិស័យសំណង់និងអចលនទ្រព្យ បានបង្ហាញសញ្ញាស្ទុះងើបឡើងវិញមួយចំនួនជាមួយនឹងការកើនឡើងតម្លៃអនុញ្ញាតសាងសង់ដែលត្រូវបានអនុម័ត។** ទោះជាយ៉ាងណា ការស្ទុះងើបឡើងវិញនេះមានរយៈពេលខ្លី។ នៅឆមាសទីមួយឆ្នាំ២០២៤ ចំណាប់អារម្មណ៍វិនិយោគបានធ្លាក់ចុះ ហើយតម្លៃអនុញ្ញាតសាងសង់បានធ្លាក់ចុះ ២០ភាគរយ។ ការថយចុះនេះបង្ហាញឱ្យឃើញយ៉ាងច្បាស់នៅក្នុងវិស័យសំណង់លំនៅឋាន បន្ទាប់មកវិស័យសំណង់ពាណិជ្ជកម្ម។ ទីផ្សារខុនដូក្នុងរាជធានីភ្នំពេញមានការសាងសង់បន្ថែមចំនួន ២.៤០០យូនីត ដោយមានការព្យាករថានឹងមានខុនដូថ្មីចំនួន ១៤.០០០យូនីតនៅដំណាច់ឆ្នាំនេះ។ ទន្ទឹមនឹងនេះ ទីផ្សារអចលនទ្រព្យដែលជាប់ដីបានផ្លាស់ប្តូរការផ្តោតរបស់ខ្លួនឆ្ពោះទៅរកការពង្រីកបន្ថែមជាជាងការបើកដំណើរការគម្រោងថ្មី ដោយសារការមានប្រុងប្រយ័ត្នកាន់តែខ្លាំងចំពោះតម្រូវការ។

**ដូចគ្នានេះដែរ សូចនាករតម្រូវការ ជាពិសេសនៅផ្នែកលំនៅឋានបានបង្ហាញពីការធ្លាក់ចុះ។** កម្ចីទិញផ្ទះបានថយចុះនៅក្នុងឆមាសទីមួយក្នុងឆ្នាំ២០២៤ ដែលបង្ហាញពីការធ្លាក់ចុះឆន្ទៈក្នុងការវិនិយោគក្នុងគ្រាដែលមានបរិយាកាសសេដ្ឋកិច្ចមិនល្អ។ និន្នាការតម្លៃបង្ហាញបន្ថែមទៀតឱ្យឃើញពីការធ្លាក់ចុះតម្រូវការកាន់តែខ្លាំង។ ក្រុមហ៊ុន Knight Frank ដែលជាក្រុមហ៊ុនប្រឹក្សាអចលនទ្រព្យលំដាប់ពិភពលោកបានរាយការណ៍ពីការធ្លាក់ចុះតម្លៃដីយ៉ាងខ្លាំង ដោយតម្លៃជាមធ្យមសម្រាប់អគារលំនៅឋាន និងការិយាល័យស្ថិតនៅទីតាំងល្អបានធ្លាក់ចុះ ៣៤,៥ភាគរយ និង ៣៥,៧ភាគរយរៀងគ្នាធៀបនឹងតម្លៃនៅត្រីមាសទី២ ឆ្នាំ២០២០ (រូប B.១.១)។ យោងតាមក្រុមហ៊ុន CBRE ដែលជាក្រុមហ៊ុននាំមុខគេមួយលើពិភពលោកខាងផ្នែកសេវាកម្មអចលនទ្រព្យពាណិជ្ជកម្មនិងការវិនិយោគបានឱ្យដឹងថា ផ្នែកសំខាន់ៗផ្សេងទៀតនៃវិស័យអចលនទ្រព្យដូចជាខុនដូ ការិយាល័យ និងការជួលលក់រាយ បានមើលឃើញការធ្លាក់ចុះតម្លៃជាបន្ត។

**វាហាក់ដូចជាមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងរវាងតម្លៃនៃការវិនិយោគទ្រព្យសកម្មថេរក្នុងវិស័យអចលនទ្រព្យនៅក្នុងប្រទេសចិន និងលំហូរវិនិយោគផ្ទាល់ពីបរទេសរបស់ចិនចូលមកកម្ពុជាក្នុងកំឡុងឆ្នាំ២០១៣-២០២០ (រូប B.១.២)។** ការណ៍នេះបង្ហាញថា ចំណាប់អារម្មណ៍វិនិយោគខ្លាំងរបស់វិនិយោគិនចិននៅក្នុងប្រទេសចិនបានចូលរួមចំណែកដល់ការកើនឡើងលំហូរវិនិយោគផ្ទាល់ពីបរទេសរបស់ចិនមកកាន់ប្រទេសកម្ពុជា ដែលផ្តល់ហិរញ្ញប្បទានជាចម្បងដល់វិស័យសំណង់ និងអចលនទ្រព្យ។ ក្នុងអំឡុងពេលនោះ ការវិនិយោគរបស់ចិនបានផ្លាស់ប្តូរទិដ្ឋភាពទីផ្សារសំណង់ កន្លែងស្នាក់នៅ និងអចលនទ្រព្យរបស់ប្រទេសកម្ពុជាយ៉ាងខ្លាំង ជាពិសេសនៅខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ។ ខណៈដែលលំហូរចូលនេះបានជំរុញឱ្យមានការរីកចំរើនខាងផ្នែកសំណង់ វាក៏បានបង្កើនការព្រួយបារម្ភអំពីការពឹងផ្អែកខ្លាំងលើមូលធនបរទេស និងអតុល្យភាពសេដ្ឋកិច្ចសង្គមផងដែរ។

**ទោះយ៉ាងណា ក្នុងអំឡុងឆ្នាំ២០២១-២០២៣ ទំនាក់ទំនងនេះបានថយចុះ។** ខណៈដែលតម្លៃនៃការវិនិយោគទ្រព្យសកម្មថេរក្នុងវិស័យអចលនទ្រព្យនៅប្រទេសចិនបានធ្លាក់ចុះ លំហូរចូលវិនិយោគផ្ទាល់ពីបរទេសរបស់ចិនចូលមកកម្ពុជាបានកើនឡើង។ ការណ៍នេះបង្ហាញថា លំហូរវិនិយោគផ្ទាល់ពីបរទេសរបស់ចិនចូលមកក្នុងប្រទេសកម្ពុជាត្រូវបានធ្វើពិពិធកម្មដោយបានផ្លាស់ប្តូរឆ្ងាយពីវិស័យសំណង់និងអចលនទ្រព្យទៅកាន់វិស័យកាត់ដេរ និងមិនមែនកាត់ដេរដូចដែលបានបង្ហាញក្នុងគម្រោងវិនិយោគដែលផ្តល់ហិរញ្ញប្បទានដោយវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័ត។

**កម្ពុជាកំពុងស្ថិតក្នុងហានិភ័យកើតមានវិបត្តិអចលនទ្រព្យ។** ការធ្លាក់ចុះតម្លៃអចលនទ្រព្យ រួមជាមួយនឹងការថយចុះការផ្តល់ប្រាក់កម្ចីដល់វិស័យអចលនទ្រព្យ និងតម្លៃអនុញ្ញាតសាងសង់ដែលត្រូវបានអនុម័ត បង្ហាញពីអស្ថិរភាពដែលអាចកើតមាននៅក្នុងទីផ្សារលំនៅឋាន។ ដើម្បីដោះស្រាយវិបត្តិនេះ បទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្តល់ប្រាក់កម្ចីកាន់តែតឹងរ៉ឹងត្រូវការជាចាំបាច់ដើម្បីទប់ស្កាត់ការខ្ចីប្រាក់ច្រើនហួសហេតុ និងលើកកម្ពស់ការអនុវត្តការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលស្របតាមការផ្គត់ផ្គង់ជាមួយនឹងតម្រូវការពិតប្រាកដ។ ការលើកកម្ពស់តម្លាភាពក្នុងប្រតិបត្តិការអចលនទ្រព្យនឹងបង្កើតទំនុកចិត្តរបស់វិនិយោគិន និងធានាឱ្យមានការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយការទទួលបានព័ត៌មានច្បាស់លាស់ ដែលនៅទីបំផុតជំរុញទីផ្សារអចលនទ្រព្យឱ្យកាន់តែមានភាពធន់។

**រូប B១.១ ៖ សន្ទស្សន៍តម្លៃអចលនទ្រព្យ**

*(មូលដ្ឋាន = ត្រីមាសទី១ ឆ្នាំ២០១៩)*




*ប្រភព៖ ក្រុមហ៊ុន* CBRE។

**រូប B១.២ ៖ ការវិនិយោគលើអចលនទ្រព្យនៅចិន និងលំហូរចូល FDI របស់ចិនចូលមកកាន់កម្ពុជា**




*ប្រភព៖ អាជ្ញាធរកម្ពុជា, ការិយាល័យស្ថិតិជាតិរបស់ប្រទេសចិន។*

# ក្នុងពេលកំណើននាំចូលស្ទុះងើបឡើងវិញ ឱនភាពគណនីចរន្តបានកើតមានសាជាថ្មី

**នៅក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ លំហូរចូលមូលធនដ៏រឹងមាំជាបន្ត ជាពិសេសការវិនិយោគផ្ទាល់ពីបរទេស** បានជួយបន្ធូរបន្ថយសម្ពាធលើអត្រាប្តូរប្រាក់ និងបានជួយជំរុញទុនបម្រុងរូបិយប័ណ្ណអន្តរជាតិដុល ដែលបានកើនឡើងដល់ចំនួន ២០,៧ពាន់លានដុល្លារអាមេរិក ពោលគឺកើនឡើង ១១,៣ ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលអាចមានលទ្ធភាពគ្របដណ្តប់លើការនាំចូលទំនិញបានប្រហែល ៧ខែ។ **ទោះបីជាប្រាក់បញ្ញើពីបរទេស បន្តមានភាពរឹងមាំ ដែលមានចំនួន ៦ភាគរយនៃផលិតផលក្នុងស្រុកសរុប និងជាប់ចំណាត់ថ្នាក់ទីពីរបន្ទាប់ពីប្រទេសហ្វីលីពីន (៩ភាគរយនៃផលិតផលក្នុងស្រុកសរុប) នៅក្នុងអាស៊ាន ហើយប្រាក់ចំណូលពីវិស័យទេសចរណ៍ បានស្ទុះងើបឡើងវិញមួយផ្នែកក៏ដោយ ក៏សមតុល្យគណនីចរន្តត្រូវបានព្យាករថានឹងបង្ហាញពីឱនភាពតិចតួចប្រហែល ១ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០២៤ ដែលផ្ទុយទៅនឹងអតិរេក ១,៣ភាគរយនៅឆ្នាំ២០២៣។** ឱនភាពនេះ នៅតែបន្តផ្តល់ហិរញ្ញប្បទានដោយលំហូរចូលមូលធនប្រកបដោយនិរន្តរភាព (សូមមើលការពិភាក្សាបន្ថែម អំពីការផ្តល់ហិរញ្ញប្បទានសម្បទាន និងការបញ្ចេញបំណុលនៅក្នុងផ្នែកសារពើពន្ធខាងក្រោម)។

# ប្រាក់រៀលឡើងថ្លៃតិចតួចធៀបទៅនឹងប្រាក់ដុល្លារអាមេរិក

**ការកើនឡើងសមតុល្យគណនីចរន្ត បានចូលរួមចំណែកដល់ការបន្ធូរបន្ថយសម្ពាធលើប្រាក់រៀល។** ជាលទ្ធផល អត្រាប្តូរប្រាក់រៀលនិងដុល្លារអាមេរិកបានឡើងថ្លៃក្នុងខែសីហា ឆ្នាំ២០២៤ ដោយកើនឡើងដល់ ៤.០៩១រៀលក្នុងមួយដុល្លារអាមេរិក ពី ៤.១៤០រៀលក្នុងមួយដុល្លារអាមេរិក ក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣។

**ទោះជាយ៉ាងនេះក្តី ប្រាក់រៀលបានចាប់ផ្តើមធ្លាក់ថ្លៃធៀបនឹងប្រាក់បាត និងប្រាក់យន់ ដោយធ្លាក់ចុះដល់ ១១៩រៀលក្នុងមួយបាត និង ៥៧១រៀលក្នុងមួយយន់ ក្នុងខែសីហា ឆ្នាំ ២០២៤ ធ្លាក់ចុះពី ១១៨រៀលក្នុងមួយបាត និង ៥៧០រៀលក្នុងមួយយន់ ក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២៣។** ផ្ទុយទៅវិញ ប្រាក់រៀល

ឡើងថ្លៃធៀបនឹងប្រាក់ដុង ដោយកើនឡើងដល់ ០,១៦៣រៀលក្នុងមួយដុង កើនឡើងពី ០,១៧២រៀលក្នុងមួយដុងក្នុងរយៈពេលដូចគ្នា។ ធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលរបស់ប្រទេសកម្ពុជា កំណត់អត្រាប្តូរប្រាក់រៀលនៅកម្រិត ៤.០០០ រៀលក្នុងមួយដុល្លារអាមេរិក។ គោលនយោបាយអត្រាប្តូរប្រាក់គឺជាធាតុសំខាន់មួយ នៃគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាល ដោយមានគោលបំណងសម្រេចបាននូវស្ថិរភាពថ្លៃ។ ដោយសារសេដ្ឋកិច្ចប្រើប្រាស់ប្រាក់ដុល្លារខ្ពស់ ការកំណត់គោលដៅស្ថិរភាពអត្រាប្តូរប្រាក់ជួយ រក្សាអំណាចទិញរបស់អ្នកដែលរកប្រាក់ចំណូលជាប្រាក់រៀល។

## ការផ្គត់ផ្គង់សាច់ប្រាក់បន្តកើនឡើង

**ដោយបង្ហាញពីភាពប្រសើរឡើងបន្ថែមទៀតនៃលំហូរចូលមូលធន ការកើនឡើងរូបិយវត្ថុទូទៅ បានបន្តកើតមាន។** រូបិយវត្ថុទូទៅបានកើនឡើងក្នុងអត្រា ១៤,៣ភាគរយក្នុងរយៈពេល ១២ខែដែលបញ្ចប់ក្នុងខែសីហា ឆ្នាំ២០២៤ ពី ១១ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៣ ដោយសារប្រាក់បញ្ញើរូបិយប័ណ្ណបរទេសមានភាពប្រសើរឡើង (រូប ១៤)។

**ដោយសារសេដ្ឋកិច្ចប្រើប្រាស់ប្រាក់ដុល្លារខ្ពស់ ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស បានរួមចំណែកច្រើនបំផុតដល់កំណើនរូបិយវត្ថុទូទៅ។** ក្នុងចំណោមកំណើនរូបិយវត្ថុទូទៅ ១៤,៣ភាគរយ ការរួមចំណែកនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស (និងប្រាក់បញ្ញើផ្សេងទៀត) មានចំណែក ១៣ពិន្ទុភាគរយ ប្រាក់បញ្ញើដែលអាចផ្ទេរបានមានចំណែក ១,៥ពិន្ទុភាគរយ និងរូបិយប័ណ្ណដែលកំពុងចរាចរមានចំណែកអវិជ្ជមាន ០,២ពិន្ទុភាគរយនៅក្នុងខែសីហា ឆ្នាំ២០២៤។ តួលេខទាំងនេះកើនឡើងពីចំណែក ១០,៨ពិន្ទុភាគរយ ចំណែកអវិជ្ជមាន ០,៥ពិន្ទុភាគរយ និងចំណែក ០,៨ពិន្ទុភាគរយរៀងគ្នាក្នុងរយៈពេលដូចគ្នា រយៈពេលក្នុងឆ្នាំ២០២៣។

**រូប ១៣ ៖ អតិផរណាបានធ្លាក់ចុះ**
**ការចូលរួមចំណែកចំពោះអតិផរណាក្នុងរយៈពេល ១២ខែ**
*(ពិន្ទុភាគរយ)*




*ប្រភព៖ អាជ្ញាធរកម្ពុជា។*

**នោះបីជាសេដ្ឋកិច្ច ដែលប្រើប្រាស់ប្រាក់ដុល្លារខ្ពស់របស់កម្ពុជា ដាក់កម្រិតលើសមត្ថភាពរបស់ធនាគារកណ្តាលរបស់ប្រទេសនេះ ក្នុងការជះឥទ្ធិពលលើសាច់ប្រាក់សរុបក៏ដោយ ក៏ការថយចុះអនុបាតទុនបម្រុងកាតព្វកិច្ច** ដែលជាឧបករណ៍គោលនយោបាយរូបិយវត្ថុមួយ ក្នុងចំណោមឧបករណ៍គោលនយោបាយរូបិយវត្ថុមួយចំនួន ដែលអាចប្រើប្រាស់ ដើម្បីជះឥទ្ធិពលលើការផ្គត់ផ្គង់សាច់ប្រាក់ ដែលបានដាក់ចេញកាលពីចុងឆ្នាំមុន អាចគាំទ្រមួយផ្នែកដល់សន្ទនីយភាពទីផ្សារ[11]។

## អត្រាការប្រាក់ក្នុងស្រុកបានធ្លាក់ចុះ

**អត្រាប្រាក់បញ្ញើជាដុល្លារអាមេរិកនៅក្នុងស្រុកបានចាប់ផ្តើមធ្លាក់ចុះក្នុងខែមករា ឆ្នាំ២០២៤។** នៅពេលដែលតម្រូវការឥណទានក្នុងស្រុក បានធ្លាក់ចុះក្នុងគ្រាដែលមានការធ្លាក់ចុះវិស័យអចលនទ្រព្យ អត្រាប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិកក្នុងស្រុក បានធ្លាក់ចុះមកត្រឹម ៥,១៥ភាគរយក្នុងមួយឆ្នាំក្នុងខែសីហា ឆ្នាំ២០២៤ ពី ៥,៧១ភាគរយក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ (រូប ១៥)។ ទោះជាយ៉ាងណា ការកើនឡើងសម្ពាធលើ អត្រាការប្រាក់ប្រាក់កម្ចីជាប្រាក់ដុល្លារអាមេរិកនៅតែមាន។ អត្រាការប្រាក់កម្ចីជាដុល្លារអាមេរិកនៅប្រទេសកម្ពុជាបានកើនឡើងដល់ ១០,៨២ភាគរយក្នុងមួយឆ្នាំ ពី ៩,៨៨ភាគរយក្នុងអំឡុងពេលដូចគ្នានេះ។

**ប្រទេសកម្ពុជា «នាំចូល» គោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក យ៉ាងមានប្រសិទ្ធភាព ដោយសារសេដ្ឋកិច្ចប្រើប្រាស់ប្រាក់ដុល្លារខ្ពស់។** ការកើនឡើងការចំណាយលើការខ្ចីប្រាក់ បានកាត់បន្ថយប្រាក់ចំណេញរបស់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។ ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មសម្រាប់វិស័យធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI) បានធ្លាក់ចុះពាក់កណ្តាលមកត្រឹម ០,៧ភាគរយ និង

**រូប ១៤ ៖ កំណើនរូបិយវត្ថុទូទៅបានស្ទុះងើបឡើងវិញ**
**ការចូលរួមចំណែកចំពោះកំណើនរូបិយវត្ថុទូទៅ**
*(ពិន្ទុភាគរយ)*




*ប្រភព៖ អាជ្ញាធរកម្ពុជា។*

11 ធនាគារជាតិនៃកម្ពុជា ឆ្នាំ២០២៣។

១,៥ភាគរយរៀងគ្នាក្នុងឆ្នាំ២០២៣ ដោយធ្លាក់ចុះពី ១,៤ភាគរយ និង ៣ភាគរយរៀងគ្នាក្នុងឆ្នាំ២០២២។ ដូចគ្នានេះដែរ ប្រាក់ចំណេញធៀបនឹងដើមទុនវិនិយោគសម្រាប់វិស័យធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានធ្លាក់ចុះមកនៅត្រឹម ៣,៨ភាគរយ និង ៦ភាគរយរៀងគ្នាក្នុងឆ្នាំ២០២៣ ដោយធ្លាក់ចុះពី ៧ភាគរយ និង ១៣,៦ភាគរយក្នុងឆ្នាំ២០២២។ នៅពាក់កណ្តាលឆ្នាំ២០២៤ អនុបាតប្រាក់កម្ចីមិនដំណើរការនៅកម្ពុជាបានកើនឡើងដល់ ៦,៨ភាគរយសម្រាប់វិស័យធនាគារ និង ៨,៣ភាគរយសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ពោលគឺកើនឡើងពី ៥,៤ភាគរយ និង ៦,៧ភាគរយរៀងគ្នាក្នុងឆ្នាំ២០២៣។

**សម្ពាធ ដែលកើនឡើងទៅលើអត្រាការប្រាក់ក្នុងស្រុកកំពុងចាប់ផ្តើមថយចុះ ខណៈពេលដែលសេដ្ឋកិច្ចដែលប្រើប្រាស់ប្រាក់ដុល្លារខ្ពស់ របស់ប្រទេសកម្ពុជា នាំចូលគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក ដែលបានចាប់ផ្តើមធូរស្រាលបន្ទាប់ពីធនាគារកណ្តាលអាមេរិក (Fed) បានកាត់បន្ថយអត្រាការប្រាក់របស់ខ្លួនចំនួន ៥០ពិន្ទុមូលដ្ឋាននៅក្នុងខែកញ្ញា និង ២៥ពិន្ទុមូលដ្ឋាននៅក្នុងវិច្ឆិកា ឆ្នាំ២០២៤[12]។** ផលជះអវិជ្ជមានទៅលើសកម្មភាពសេដ្ឋកិច្ច ដែលបណ្តាលមកពីរដ្តនៃការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុគួរតែចាប់ផ្តើមធូរស្រាល។

## ឥណទានបានធ្លាក់ចុះខ្លាំង ខណៈដែលសកម្មភាពអភិវឌ្ឍន៍លំនៅឋាននៅទ្រឹង

**កំណើនឥណទានក្នុងស្រុក បានជួបប្រទះនឹងការថយចុះគួរឱ្យកត់សម្គាល់ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០២៣មកបន្ទាប់ពីកើនឡើងក្នុងរយៈពេលវែង។** បើទោះបីជាការរឹតបន្តឹងលក្ខខណ្ឌឥណទានក៏អាចបណ្តាលមកពីការកើនឡើង អត្រាការប្រាក់កម្ចីពិភពលោកផងដែរនោះ ការធ្លាក់ចុះតម្រូវការឥណទានទំនងជាកត្តាចម្បង ដែលបណ្តាលឱ្យមានការធ្លាក់ចុះកំណើនឥណទាននេះ។ ទីមួយ តម្រូវការឥណទានក្នុងស្រុកពីសំណាក់វិស័យអចលនទ្រព្យ និងសំណង់បានធ្លាក់ចុះ។ ទីពីរ ការកើនឡើងអត្រាការប្រាក់ និងទំនុកចិត្តអ្នកប្រើប្រាស់ទាប អាចរួមចំណែកបង្កឱ្យមានតម្រូវការឥណទានខ្សោយពីគ្រួសារ និងក្រុមហ៊ុន (ប្រអប់ ២)។ ជាលទ្ធផល ឥណទានបានថយចុះយ៉ាងខ្លាំងដល់កម្រិតទាបបំផុតក្នុងរយៈពេល ១៤ឆ្នាំមកនៅត្រឹម ៣,៤ភាគរយក្នុងខែសីហា ឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ពោលគឺធ្លាក់ចុះពី ៧,៧ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៣ (រូប ១៦)។ ការថយថមកំណើនឥណទានបាននាំឱ្យមានការថយចុះអនុបាតឥណទាន ធៀបនឹងផលិតផលក្នុងស្រុកសរុប ដែលបានធ្លាក់ចុះមកត្រឹម ១២៦,៧ភាគរយនៅក្នុងខែសីហា ឆ្នាំ២០២៤ ពី ១៣៣,៣ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៣។

**កំណើនប្រាក់បញ្ញើរបស់វិស័យឯកជន បានកើនឡើងដល់ ១៥,៨ភាគរយក្នុងខែសីហា ឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដោយកើនឡើងពី ១១,១ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៣ បើទោះបីជាមានការធ្លាក់ចុះអត្រាការប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិក មកនៅត្រឹម ៥,១៥ភាគរយក្នុងមួយឆ្នាំក្នុងខែសីហា ឆ្នាំ២០២៤ ពីចំនួន ៥,៧១ភាគរយក្នុងមួយឆ្នាំក្នុងខែសីហា ឆ្នាំ២០២៣ ក៏ដោយ។** ដូចដែលបានពិភាក្សានៅក្នុងផ្នែកវិនិយោគ ចំណាប់អារម្មណ៍របស់វិនិយោគិនក្នុងស្រុកក្នុងការវិនិយោគលើវិស័យដែលអាចជួញដូរបាន

**រូប ១៥ ៖ អត្រាការប្រាក់នៅតែខ្ពស់**
**អត្រាការប្រាក់ក្នុងស្រុក**
*(ភាគរយក្នុងមួយឆ្នាំ)*




*ប្រភព៖ អាជ្ញាធរកម្ពុជា, ធនាគារកណ្តាលសហរដ្ឋអាមេរិក*

*សម្គាល់៖ RHS= ខាងស្តាំ*

**រូប ១៦ ៖ កំណើនឥណទានក្នុងស្រុកបានធ្លាក់ចុះ**
**កំណើនឥណទាន**
*(ប្រែប្រួលជាភាគរយ y/y)*




ប្រភព៖ អាជ្ញាធរកម្ពុជា

សម្គាល់៖ CRM= សំណង់ អចលនទ្រព្យ និងកម្ចីទិញផ្ទះ

12 ធនាគារកណ្តាលអាមេរិកចេញសេចក្តីប្រកាសព័ត៌មាន FOMC នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៤ https://www.federalreserve.gov/newsevents/pressreleases/monetary20241107a.htm

### ប្រអប់ ២ ៖ ការកើនឡើងបំណុលគ្រួសារ

**ក្នុងកំឡុងឆ្នាំ២០០៩-២០២១ កម្ពុជាបានជួបប្រទះកំណើនឥណទានក្នុងស្រុកយ៉ាងឆាប់រហ័ស ដែលមានកំណើនជាមធ្យម ២៧,២ភាគរយជារៀងរាល់ឆ្នាំដែលត្រូវបានជំរុញយ៉ាងខ្លាំងដោយសកម្មភាពសេដ្ឋកិច្ច។** ទោះជាយ៉ាងណា ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០២៣ មក កំណើនឥណទានក្នុងស្រុកមានការថមថយយ៉ាងខ្លាំងដោយបានធ្លាក់ចុះមកត្រឹម ៣,៨ភាគរយនៅពាក់កណ្តាលឆ្នាំ២០២៤។ ទោះបីជាមានការធ្លាក់ចុះយ៉ាងនេះក៏ដោយ ក៏អនុបាតឥណទានឯកជនធៀបនឹង ផ.ស.ស នៅតែកើនឡើងដោយស្ថិតក្នុងអត្រា ១២៦,៨ភាគរយ។ ប្រហែលមួយភាគបីនៃឥណទាននេះត្រូវបានផ្តល់ទៅឱ្យវិស័យអចលនទ្រព្យ សំណង់ និងកម្ចីផ្ទាល់ខ្លួន។ ការប្រឈមបែបប្រមូលផ្តុំទៅនឹងវិស័យអចលនវត្ថុដែលស្ថិតក្នុងស្ថានភាពធ្លាក់ចុះចាប់តាំងពីកើតមានជំងឺរាតត្បាតមក បង្កហានិភ័យកាន់តែខ្លាំងដល់ស្ថិរភាពហិរញ្ញវត្ថុ។ អនុបាតកម្ចីមិនដំណើរការបានកើនឡើងដល់ ៦,៨ភាគរយសម្រាប់វិស័យធនាគារ និង ៨,៣ភាគរយសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុនៅពាក់កណ្តាលឆ្នាំ២០២៤ រួមជាមួយនឹងការធ្លាក់ចុះប្រាក់ចំណេញក្នុងវិស័យហិរញ្ញវត្ថុ។

**ផ្ទុយទៅវិញ បំណុលគ្រួសារនៅក្នុងប្រទេសកម្ពុជាបាននិងកំពុងកើនឡើង ដូចដែលបានបង្ហាញដោយការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (CSES)។** បំណុលគ្រួសារដែលមិនទាន់សងជាមធ្យមក្នុងមួយគ្រួសារបានកើនឡើងយ៉ាងឆាប់រហ័សដោយកើនឡើងក្នុងអត្រាប្រចាំឆ្នាំ ២៣,២ភាគរយដល់ ២១,៣លានរៀលក្នុងឆ្នាំ២០២១ ពោលគឺកើនឡើងពី ១,៧លានរៀលក្នុងឆ្នាំ២០០៩ ដោយសារលទ្ធភាពទទួលបានហិរញ្ញវត្ថុមានភាពប្រសើរឡើង និងការថយចុះអត្រាការប្រាក់លើប្រាក់កម្ចី។ ក្នុងឆ្នាំ២០០៩ ប្រភពប្រាក់កម្ចីចម្បងគឺអ្នកឱ្យខ្ចីក្រៅផ្លូវការដូចជាសាច់ញាតិ មិត្តភក្តិ អ្នកចងការប្រាក់ និងពាណិជ្ជករ ដោយមានអត្រាការប្រាក់ជាមធ្យម ៣៤,៨ភាគរយក្នុងមួយឆ្នាំ។ នៅឆ្នាំ២០២១ ប្រភពទាំងនេះភាគច្រើនត្រូវបានជំនួសដោយវិស័យហិរញ្ញវត្ថុផ្លូវការ រួមទាំងគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ដែលផ្តល់អត្រាការប្រាក់ជាមធ្យម ១៨ភាគរយក្នុងមួយឆ្នាំ។ ទោះបីជាប្រាក់ចំណូលគ្រួសារបានកើនឡើងក៏ដោយ ក៏ការកើនឡើងនេះមានអត្រាយឺតជាងអត្រាកំណើនបំណុលគ្រួសារ។ ប្រាក់ចំណូលគ្រួសារជាមធ្យមបានកើនឡើងក្នុងអត្រាប្រចាំឆ្នាំ ១០ភាគរយដល់ ២៧,៩លានរៀលក្នុងឆ្នាំ២០២១ កើនឡើងពី ៨,៨លានរៀលក្នុងឆ្នាំ២០០៩។ ជាលទ្ធផល អនុបាតបំណុលធៀបនឹងប្រាក់ចំណូលបានកើនឡើងយ៉ាងខ្លាំងដល់ ៧៦,៤ភាគរយ កើនឡើងពី ១៩,៧ភាគរយក្នុងឆ្នាំ២០០៩ (រូប B២.១)។

**លើសពីនេះ មានការផ្លាស់ប្តូរយ៉ាងខ្លាំងក្នុងការប្រើប្រាស់ប្រាក់កម្ចីគ្រួសារពីគោលបំណងផលិតកម្មទៅជាគោលបំណងមិនផលិតកម្ម។** ជាពិសេស ការអង្កេត CSES បានរកឃើញថា ចំណែកនៃប្រាក់កម្ចីដែលប្រើប្រាស់សម្រាប់សកម្មភាពផលិតកម្មដូចជាសកម្មភាពកសិកម្មនិងមិនមែនកសិកម្ម បានធ្លាក់ចុះមកត្រឹម ៣០ភាគរយក្នុងឆ្នាំ២០២១ ពីកម្រិតខ្ពស់បំផុត ៤២,៦ភាគរយក្នុងឆ្នាំ២០១២។ ផ្ទុយទៅវិញ ចំណែកនៃប្រាក់កម្ចីដែលបានប្រើប្រាស់សម្រាប់គោលបំណងប្រើប្រាស់ក្នុងគ្រួសារ រួមទាំងការទិញនិងការកែលម្អផ្ទះ ទំនិញប្រើប្រាស់អាយុកាលវែង តម្រូវការប្រើប្រាស់ក្នុងគ្រួសារ និងការថែទាំសុខភាព បានកើនឡើងយ៉ាងខ្លាំង។ ការកើនឡើងការខ្ចីប្រាក់សម្រាប់ការប្រើប្រាស់ជាជាងសម្រាប់ការវិនិយោគក្នុងសកម្មភាពផលិតកម្ម អាចនាំទៅរកកម្រិតបំណុលច្រើនលើសលុបកាន់តែខ្ពស់ ដោយមិនត្រូវគ្នាទៅនឹងកំណើនប្រាក់ចំណូល ដោយហេតុនេះធ្វើឱ្យមានភាពងាយរងគ្រោះផ្នែកហិរញ្ញវត្ថុកាន់តែធ្ងន់ធ្ងរក្នុងចំណោមគ្រួសារដែលជំពាក់បំណុល។

**ទោះបីជារយៈពេលកំណត់កម្ចីជាមធ្យមកើនឡើងដល់ ២៧ខែក្នុងឆ្នាំ២០២១ កើនឡើងពី ៨,៧ខែក្នុងឆ្នាំ២០០៩ ក៏ដោយ ក៏ការទូទាត់សេវាបំណុលបានកើនឡើងយ៉ាងឆាប់រហ័សពោលគឺកើនឡើងក្នុងអត្រា ១៣ភាគរយក្នុងមួយឆ្នាំ។** ជាលទ្ធផល អនុបាតសេវាបំណុលធៀបនឹងប្រាក់ចំណូល (DTI) បានឡើងដល់កម្រិតខ្ពស់បំផុត ៤៨,៤ភាគរយក្នុងឆ្នាំ២០១៩/២០២០ មុនពេលធ្លាក់ចុះបន្តិចមកវិញមកនៅត្រឹម ៤៦,៥ភាគរយនៅឆ្នាំ២០២១ (រូប B២.២)។ កម្រិត DTI ខ្ពស់បំផុត ៤៨,៤ភាគរយដែលជិតដល់កម្រិតកំណត់ ៥០ភាគរយ[ក] បង្ហាញថា អ្នកខ្ចីកំពុងជួបការលំបាកក្នុងការបំពេញកាតព្វកិច្ចបំណុលទាំងអស់ឱ្យបានទៀងទាត់ ខណៈពេលដែលពួកគេអាចមិនមានប្រាក់ច្រើនដើម្បីសន្សំ ចំណាយ ឬដោះស្រាយការចំណាយដែលមិនបានរំពឹងទុកនានា។ នៅខែសីហា ឆ្នាំ២០២៤ ធនាគារកណ្តាលកម្ពុជាបានដាក់ចេញវិធានការអនុគ្រោះបទប្បញ្ញត្តិដែលអនុញ្ញាតឱ្យមានការរៀបចំឥណទានឡើងវិញ ដែលស្រដៀងទៅនឹងវិធានការដែលបានអនុវត្តសម្រាប់ជាផ្នែកមួយនៃការឆ្លើយតបនឹងជំងឺរាតត្បាតកូវីដ-១៩។ គំនិតផ្តួចផ្តើមនេះមានគោលបំណងជួយសម្រាលបន្ទុករបស់អ្នកខ្ចី និងរក្សាស្ថិរភាពហិរញ្ញវត្ថុតាមរយៈការអនុញ្ញាតឱ្យលក្ខខណ្ឌកម្ចីដែលកាន់តែមានភាពបត់បែនបន្ថែមទៀតក្នុងអំឡុងពេលមានការលំបាក។

**រូប B២.១ ៖ បំណុលគ្រួសារមិនទាន់សងជាមធ្យម**
*(% នៃប្រាក់ចំណូល)*




*ប្រភព៖ ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា។*

**រូប B២.២ ៖ ការទូទាត់សេវាបំណុល**
*(% នៃប្រាក់ចំណូល)*




*ប្រភព៖ ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា។*

ក. "តើអនុបាតបំណុលធៀបនឹងប្រាក់ចំណូលដែលល្អមានអត្រាប៉ុន្មាន?" https://www.wellsfargo.com/goals-credit/smarter-credit/credit-101/debt-to-income-ratio/understanding-dti។

## ប្រអប់ ៣ ៖ របាយការណ៍ Business-Ready ឆ្នាំ២០២៤

**ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងកែលម្អបរិយាកាសអាជីវកម្មក៏ដោយ ក៏ការធ្វើការអង្កេតសហគ្រាសឆ្នាំ២០២៣ និងរបាយការណ៍ថ្មីៗនេះរបស់ធនាគារពិភពលោកសម្រាប់ខែតុលា ឆ្នាំ២០២៤ (របាយការណ៍ B-READY) បានបង្ហាញពីបញ្ហាប្រឈមសំខាន់ៗ ដោយពិន្ទុភាគច្រើនបានធ្លាក់ចូលទៅក្នុងកម្រិត ទី៤ ឬកម្រិតក្រោមគេ ដូចដែលបានបង្ហាញក្នុងរូប B.៣.១។**

**ទាក់ទងនឹងការដាក់ពិន្ទុលើផ្នែកផ្សេងវិញ កម្ពុជាទទួលបានពិន្ទុ ១៩,៦៣ ក្នុងផ្នែកអសាធនភាពអាជីវកម្ម ដោយស្ថិតនៅកម្រិតក្រោមគេបង្អស់។ សម្រាប់ផ្នែកការប្រកួតប្រជែងទីផ្សារ កម្ពុជាទទួលបានពិន្ទុ ៣៣,១ ដែលធ្លាក់ចូលទៅក្នុងកម្រិតទី៤។** ផ្នែកការបង្កើតអាជីវកម្មទទួលបានពិន្ទុ ៤៣,៨ ដែលក៏ស្ថិតនៅក្នុងកម្រិតទី៤ ផងដែរ ខណៈពេលដែលផ្នែកទីតាំងធ្វើអាជីវកម្មទទួលបានពិន្ទុ ៤៩ ដែលក៏ស្ថិតនៅកម្រិតទី៤ ដដែល។ លើកលែងតែផ្នែកសេវាកម្មហិរញ្ញវត្ថុ ដែលកម្ពុជាទទួលបានពិន្ទុ ៨៦ ដែលស្ថិតនៅកម្រិតខ្ពស់បំផុត។ បើប្រៀបធៀបទៅនឹងប្រទេសជាសមាជិកអាស៊ានផ្សេងទៀតដែលត្រូវបានរួមបញ្ចូលក្នុងរបាយការណ៍នេះ (កម្ពុជា ហ្វីលីពីន ឥណ្ឌូណេស៊ី វៀតណាម និងសិង្ហបុរី) លទ្ធផលរបស់កម្ពុជាគឺទាបជាងប្រទេសជិតខាងរបស់ខ្លួនលើផ្នែកភាគច្រើន លើកលែងតែសេវាកម្មហិរញ្ញវត្ថុប៉ុណ្ណោះ ដូចបង្ហាញក្នុងរូប B.៣.២។

**រូប B.៣.១ ៖ លទ្ធផលរបស់កម្ពុជាតាមប្រធានបទនិងសសរស្តម្ភ**
*(ភាគរយ)*




*ប្រភព៖ *ធនាគារពិភពលោក* ២០២៤d។

**រូប B.៣.២ ៖ ការប្រៀបធៀបក្នុងតំបន់**
*(ភាគរយ)*




*ប្រភព៖ *ធនាគារពិភពលោក* ២០២៤d។

ដូចជាការនាំចេញ កសិកម្ម និងការកែច្នៃកសិផលនៅតែមានភាពស្ទប់ស្ទាត់ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីបញ្ហាប្រឈម ដែលកំពុងកើតមានចំពោះភាពងាយស្រួលនៃការធ្វើអាជីវកម្ម។ ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ Business-Ready ឆ្នាំ២០២៤ (សូមមើលប្រអប់ ៣) បញ្ហាប្រឈមបំផុតគឺកម្ពុជាខ្វះសេវាសាធារណៈដែលមានគុណភាព ដើម្បីគាំទ្រអាជីវកម្ម ជាពិសេសក្នុងវិស័យដូចជាអសាធនភាពអាជីវកម្ម ការប្រកួតប្រជែងទីផ្សារ និងការបង្កើតអាជីវកម្ម។ អាស្រ័យហេតុនេះ វិស័យឯកជន (គ្រួសារ និងក្រុមហ៊ុន) នៅតែយល់ឃើញថា អត្រាការប្រាក់បញ្ញើទាបមានភាពទាក់ទាញ។ ទោះបីជាមានការបន្ធូរបន្ថយគោលនយោបាយរូបិយវត្ថុ និងការកើនឡើងប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសក៏ដោយ ក៏កំណើនឥណទានដែលធ្លាក់ចុះ នៅតែបន្តកើតមានដោយសារបញ្ហាប្រឈមដែលកំពុងបន្តកើតមាននៅក្នុងភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម។

**ការកើនឡើងប្រាក់បញ្ញើ របស់វិស័យឯកជនបានជំរុញឱ្យអនុបាតប្រាក់បញ្ញើ ធៀបនឹងផលិតផលក្នុងស្រុកសរុបនាមកើនឡើងដល់ ១០៤,៥ភាគរយនៅក្នុងខែសីហា ឆ្នាំ២០២៤ កើនឡើងពី ៩៧,២ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៣។** ការថយចុះកំណើនឥណទាន និងការកើនឡើងកំណើនប្រាក់បញ្ញើ បានជួយកាត់បន្ថយអនុបាតកម្ចីធៀបនឹងប្រាក់បញ្ញើមកនៅត្រឹម ១២០,៦ភាគរយក្នុងខែសីហា ឆ្នាំ២០២៤ ពី ១៣៥ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុង ឆ្នាំ២០២៣។

## ការប្រមូលប្រាក់ចំណូលក្នុងស្រុក នៅតែយឺត

**ទិន្នន័យថ្មីៗ ស្ដីពីការប្រមូលប្រាក់ចំណូលរបស់កម្ពុជាក្នុងរយៈពេលប្រាំបីខែដំបូងនៅក្នុងឆ្នាំ២០២៤ បង្ហាញឱ្យឃើញថា ការប្រមូលប្រាក់ចំណូលក្នុងស្រុករបស់រដ្ឋាភិបាលថ្នាក់កណ្ដាល បានកើនឡើងតិចតួចពោលគឺកើនឡើង ៤,២ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ពីកំណើន ០,៤ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៣ (រូប ១៧)។** កំណើននេះមានភាពស្របគ្នាទៅនឹងការស្ទុះងើបឡើងវិញជាបឋមនៃការប្រើប្រាស់ឯកជន ដោយសារប្រព័ន្ធពន្ធរបស់កម្ពុជា ពឹងផ្អែកយ៉ាងខ្លាំងលើពន្ធលើការប្រើប្រាស់ (ពន្ធលើទំនិញ និងសេវាកម្ម ឬចំណូលមិនផ្ទាល់)។ ក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ស្របតាមការស្ទុះងើបឡើងវិញនៃការប្រើប្រាស់ឯកជន ពន្ធលើទំនិញ និងសេវាកម្មបានកើនឡើង ៣,៧ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ជាមួយនឹងការកើនឡើងការនាំចូលទំនិញ ពន្ធលើពាណិជ្ជកម្មអន្តរជាតិបានកើនឡើង ៦,៤ភាគរយ។ ប្រាក់ចំណូលមិនមែនសារពើពន្ធ (និងប្រាក់ចំណូលផ្សេងទៀត) បានកើនឡើង ៤៣,៧ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដោយសារសកម្មភាពធ្វើដំណើរ និងទេសចរណ៍មានភាពប្រសើរឡើង។

**ទោះជាយ៉ាងណា ក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ប្រាក់ចំណូលផ្ទាល់បានធ្លាក់ចុះ ៦,៤ភាគរយ ដោយសារការធ្លាក់ចុះការប្រមូលពន្ធលើប្រាក់ចំណូលសាជីវកម្ម។** ប្រាក់ចំណូលផ្ទាល់ ដែលរាប់បញ្ចូលទាំងពន្ធលើប្រាក់ចំណេញ និងពន្ធលើប្រាក់ចំណូល នៅតែមានកម្រិតទាប ដែលស្មើនឹងប្រហែលមួយភាគបីនៃចំណូលសារពើពន្ធសរុប។ កត្តានេះ ត្រូវបានរារាំងកាន់តែខ្លាំងដោយសារការលើកទឹកចិត្តផ្នែកពន្ធរបស់កម្ពុជា ហើយអវត្តមានពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួនដាក់កម្រិតបន្ថែមទៀតលើកំណើនប្រាក់ចំណូលផ្ទាល់។

**រូប ១៧ ៖ ការប្រមូលចំណូលក្នុងស្រុកមានភាពប្រសើរ ប្រាក់ចំណូលក្នុងស្រុករបស់រដ្ឋាភិបាលថ្នាក់កណ្ដាល**

*(ប្រែប្រួលជាភាគរយ y/y)*




*ប្រភព៖ អាជ្ញាធរកម្ពុជា*

*សម្គាល់៖ m = ខែ។*

**រូប ១៨ ៖ ការចំណាយត្រូវបានទប់ស្កាត់ ការចំណាយរបស់រដ្ឋាភិបាលថ្នាក់កណ្ដាល**

*(ប្រែប្រួលជាភាគរយ y/y)*




*ប្រភព៖ អាជ្ញាធរកម្ពុជា*

*សម្គាល់៖ m = ខែ។*

# កិច្ចប្រឹងប្រែងពង្រឹងថវិកាបាន ចាប់ផ្តើមទប់ស្កាត់ការចំណាយ

**កិច្ចខិតខំប្រឹងប្រែងពង្រឹងថវិកា បានទប់ស្កាត់ការចំណាយរបស់រដ្ឋាភិបាល ដែលនាំមុខដោយការកាត់បន្ថយចំណាយលើការវិនិយោគ និងប្រាក់ខែ។** ក្នុងរយៈពេលប្រាំបីខែដំបូងនៅក្នុងឆ្នាំ២០២៤ ការចំណាយថវិការបស់រដ្ឋាភិបាលថ្នាក់កណ្តាលត្រូវបានទប់ស្កាត់ ដោយបានធ្លាក់ចុះ ០,៣ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនពី ១២,៧ភាគរយក្នុងឆ្នាំ២០២៣ (រូប ១៨) ។ ការណ៍នេះត្រូវបានជំរុញដោយការថយចុះការចំណាយមូលធន គួរឱ្យកត់សម្គាល់ ដែលបានធ្លាក់ចុះចំនួន ៣០ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ការចំណាយលើប្រាក់ខែ និងប្រាក់សំណង ក៏បានធ្លាក់ចុះផងដែរ ពោលគឺថយចុះចំនួន ១០,៧ភាគរយដែរ ដែលទំនងជាបណ្តាលមកពី ការពន្យារពេលជ្រើសរើសមន្ត្រីរាជការថ្មី។ ផ្ទុយទៅវិញ ការចំណាយលើទំនិញ និងសេវាកម្ម បានកើនឡើង ៣៩,៧ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដោយសារតែការកើនឡើងអត្ថប្រយោជន៍សង្គម និងការផ្ទេរប្រាក់ទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ។

# ឱនភាពសារពើពន្ធជារួមបានធ្លាក់ចុះ

**កិច្ចខិតខំប្រឹងប្រែងពង្រឹងថវិកា បានកាត់បន្ថយឱនភាពសារពើពន្ធជារួម ប្រកបដោយប្រសិទ្ធភាព។** គម្លាតរវាងប្រាក់ចំណូលសរុប (រួមទាំងជំនួយឥតសំណង) និងការចំណាយស្ថិតក្រោមប្រតិបត្តិការរបស់រដ្ឋាភិបាលកណ្តាលរបស់ប្រទេសកម្ពុជា បានរួមតូចមកត្រឹមឱនភាពចំនួន ១ភាគរយនៃផលិតផលក្នុងស្រុកសរុប ក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៤ ធ្លាក់ចុះពីឱនភាពចំនួន ១,៦ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២៣ ។

**ដោយសារតែ កិច្ចខិតខំប្រឹងប្រែងពង្រឹងថវិការបស់អាជ្ញាធរ ការថយចុះការចំណាយរបស់រដ្ឋាភិបាលទូទៅដែលត្រូវបានព្យាករ មានច្រើនជាងការធ្លាក់ចុះប្រាក់ចំណូលរបស់រដ្ឋាភិបាលទូទៅ (រួមទាំងជំនួយឥតសំណង)។** ការណ៍នេះបណ្តាលឱ្យមានការថយចុះឱនភាពសារពើពន្ធជារួម ដែលបង្ហាញពីប្រសិទ្ធភាពនៃគោលនយោបាយសារពើពន្ធ ដែលកំពុងអនុវត្ត ដើម្បីគ្រប់គ្រងនិងកាត់បន្ថយឱនភាព។ ឱនភាពសារពើពន្ធជារួម នៃប្រតិបត្តិការរដ្ឋាភិបាលទូទៅរបស់កម្ពុជា ត្រូវបានព្យាករថានឹងរួមតូចមកនៅត្រឹម ៣ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០២៤ ធ្លាក់ចុះពីប្រមាណ ៥,១ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០២៣ (រូប ១៩)។ ប្រាក់ចំណូល (រួមទាំងជំនួយឥតសំណង) ត្រូវបានរំពឹងថានឹងថយចុះតិចតួចមកនៅត្រឹម ១៥,៤ ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅក្នុងឆ្នាំ២០២៤ ដោយធ្លាក់ចុះពី ១៥,៩ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០២៣។ ទន្ទឹមនឹងនោះដែរ ការចំណាយរបស់រដ្ឋាភិបាល ត្រូវបានព្យាករថានឹងធ្លាក់ចុះមកនៅត្រឹម១៨,៤ភាគរយ នៃផលិតផលក្នុងស្រុកសរុបពី ២១ ភាគរយនៃផលិតផលក្នុងស្រុកសរុប។

**មូលនិធិខាងក្រៅ នៅតែមានសារៈសំខាន់ក្នុងការផ្តល់ហិរញ្ញប្បទានដល់ឱនភាពសារពើពន្ធ។** ដើម្បីផ្តល់ហិរញ្ញប្បទានដល់ឱនភាពសារពើពន្ធជារួម ដែលបានព្យាករថានឹងមាន ៣ភាគរយ នៃផលិតផលក្នុងស្រុកសរុប ហិរញ្ញប្បទានខាងក្រៅរួមទាំងការគាំទ្រផ្នែកគម្រោងនិងថវិកាត្រូវបានរំពឹងថានឹងគ្របដណ្តប់ពាក់កណ្តាលនៃចំនួនសរុប (រូប ២០) ។ ពាក់កណ្តាលដែលនៅសល់ត្រូវបានរំពឹងថានឹងត្រូវបានផ្តល់ហិរញ្ញប្បទានដោយការដកប្រាក់បញ្ញើរបស់រដ្ឋាភិបាល (ទុនបម្រុងសារពើពន្ធ) មកប្រើប្រាស់ដែលមានចំនួន ១១,៦ភាគរយនៃផលិតផលក្នុងស្រុកសរុប (២១,៩ពាន់ពាន់លានរៀល) នៅខែកក្កដា ឆ្នាំ២០២៤ ធ្លាក់ចុះពី១២,៦ភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣។

**រូប ១៩ ៖ ប្រតិបត្តិការរបស់រដ្ឋាភិបាលទូទៅ**

*(ភាគរយនៃ ផ.ស.ស)*




*ប្រភព៖ ច្បាប់ស្តីពី* Budget Settlement, ការប៉ាន់ប្រមាណ និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក។

*សម្គាល់៖ e* = ការប៉ាន់ស្មាន, p = ការព្យាករ។

**រូប ២០ ៖ អតិរេក/ឱនភាពរបស់រដ្ឋាភិបាលទូទៅ និងការផ្តល់ហិរញ្ញប្បទាន**

*(ភាគរយនៃ ផ.ស.ស)*




ប្រភព៖ ច្បាប់ស្តីពី Budget Settlement, ការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក។

សម្គាល់៖ e = ការប៉ាន់ស្មាន, p = ការព្យាករ។

# ស្តុកបំណុលសាធារណៈបានកើនឡើងដល់ ២៤,៤ភាគរយនៃ ផ.ស.ស

**គិតត្រឹមពាក់កណ្តាលឆ្នាំ២០២៤ អនុបាតបំណុលសាធារណៈធៀបនឹង ផ.ស.ស របស់កម្ពុជាបានកើនឡើងដល់ ២៤,៤ភាគរយ ដែលស្មើនឹង ១១,២៧ពាន់លានដុល្លារអាមេរិក ដែលជាបំណុលមិនទាន់សង។** ក្នុងចំណោមបរិមាណបំណុលសរុបនេះ ៩៩ភាគរយឬស្មើនឹង ១១,១៦ពាន់លានដុល្លារ គឺជាបំណុលសាធារណៈខាងក្រៅ ខណៈដែលចំនួនដែលនៅសល់ ១ភាគរយឬស្មើនឹង ១១៣លានដុល្លារអាមេរិក គឺជាបំណុលសាធារណៈក្នុងស្រុក។ របាយបំណុលសាធារណៈខាងក្រៅបង្ហាញថា ៦៣ភាគរយជំពាក់ម្ចាស់បំណុលទ្វេភាគី និង ៣៧ភាគរយដល់ម្ចាស់បំណុលពហុភាគី។ ក្នុងកំឡុងឆមាសទីមួយឆ្នាំ២០២៤ ចំនួនប្រាក់កម្ចីដែលបានចុះហត្ថលេខារវាងកម្ពុជា និងម្ចាស់បំណុលផ្លូវការរបស់ខ្លួនបានកើនឡើងដល់ត្រឹមតែ ២៣៧,៥៥លានអេសឌីអ័រ (SDR) (៣១៣,៧លានដុល្លារអាមេរិក) ប៉ុណ្ណោះធៀបនឹងពិដានប្រចាំឆ្នាំដែលអនុញ្ញាតដោយច្បាប់ថវិកាឆ្នាំ២០២៤ ដែលមានចំនួន ១.៧០០លាន SDR។

## ចក្ខុវិស័យ

**ដោយប្រើប្រាស់ទិន្នន័យគណនីជាតិ ដែលបានរៀបចំមូលដ្ឋានគណនាជាថ្មី កំណើនសេដ្ឋកិច្ចនៅឆ្នាំនេះត្រូវបានព្យាករថានឹងកើនឡើងដល់ ៥,៣ភាគរយ (តារាងទី២) បើប្រៀបធៀបទៅនឹង ៥ភាគរយក្នុងឆ្នាំ២០២៣ ដែលជំរុញភាគច្រើនដោយការនាំចេញសេវាកម្ម និងទំនិញ។** ការកើនឡើងការនាំចេញជាពិសេសកំណើននាំចេញសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងផលិតផលស្បែកជើង ការស្ទុះងើបឡើងវិញនៃឧស្សាហកម្មទេសចរណ៍និងធ្វើដំណើរ និងលំហូរចូលការវិនិយោគផ្ទាល់ពីបរទេសជាបន្ត បានជួយទ្រទ្រង់ដល់ការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចនៅក្នុងឆ្នាំនេះ។

**ក្នុងរយៈពេលខ្លី កំណើន ផ.ស.ស ពិត របស់កម្ពុជាត្រូវបានព្យាករថា នឹងមានភាពប្រសើរឡើងបន្តិច ដោយកើនឡើងដល់ ៥,៥ភាគរយនៅឆ្នាំ ២០២៥ និងឆ្នាំ២០២៦។** ទោះបីជាតម្រូវការក្នុងស្រុកត្រូវបានរំពឹងថា នឹងប្រសើរឡើងបន្ថែមទៀតក្នុងរយៈពេលពីរឆ្នាំខាងមុខ ដែលគាំទ្រដោយភាពប្រសើរឡើងនៃទីផ្សារការងារ និងការរំពឹងទុកអតិផរណាយ៉ាងល្អក៏ដោយ ក៏ការស្ទុះងើបសេដ្ឋកិច្ចឡើងវិញនៅតែមិនទាន់មានភាពពេញលេញនៅឡើយ។ កត្តានេះគឺដោយសារតែការស្ទុះងើបឡើងវិញ នៃការប្រើប្រាស់ក្នុងស្រុក ដែលមានប្រហែលពីរភាគបីនៃផលិតផលក្នុងស្រុកសរុប នឹងត្រូវបានបង្អាក់ដោយការថមថយកំណើនឥណទានក្នុងស្រុក ដែលបណ្តាលមកពីការធ្លាក់ចុះរយៈពេលយូរនៅក្នុងវិស័យសំណង់ និងអចលនទ្រព្យ។ លើសពីនេះឥទ្ធិពលទ្រព្យសម្បត្តិអវិជ្ជមានដែលបណ្តាលមកពីការធ្លាក់ចុះតម្លៃផ្ទះ និងជាពិសេសបំណុលគ្រួសារខ្ពស់ ដោយត្រូវទូទាត់សេវាបំណុលជិត ៥០% នៃប្រាក់ចំណូល ទំនងជានឹងរារាំងដល់ការប្រើប្រាស់បន្តទៅមុខទៀត។

**ខាងផ្នែកផលិតកម្មវិញ ឧស្សាហកម្មទេសចរណ៍និងបដិសណ្ឋារកិច្ច ទំនងជានឹងមានភាពប្រសើរឡើងបន្ថែមទៀតដោយមានការព្យាករថា ភ្ញៀវទេសចរអន្តរជាតិនឹងកើនឡើង។** ខណៈពេលដែលការនាំចេញទំនិញកម្មន្តសាល ជាពិសេសសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងផលិតផលស្បែកជើងនឹងនៅតែងាយរងគ្រោះ ទៅនឹងតម្រូវការខាងក្រៅ ផលិតកម្មកសិកម្ម និងឧស្សាហកម្មកែច្នៃកសិកម្ម បន្តទទួលបានការជំរុញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគី។ ឧស្សាហកម្មធ្វើដំណើរ ដឹកជញ្ជូន និងឡូជីស្ទិក គួរតែទទួលបានអត្ថប្រយោជន៍ពីការវិនិយោគឯកជនខ្លាំង នៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗមួយចំនួន ដូចជាផ្លូវល្បឿនលឿនទើបសាងសង់ថ្មី ដែលតភ្ជាប់ពីរាជធានីភ្នំពេញទៅកាន់ខេត្តព្រះសីហនុដែលជាទីតាំងរបស់កំពង់ផែទឹកជ្រៅ គម្រោងអភិវឌ្ឍន៍កំពង់ផែពហុមុខងារនិងទីតាំងឡូជីស្ទិកថ្មីនៅខេត្តកំពត និងរាជធានីភ្នំពេញ និងគម្រោងផ្លូវល្បឿនលឿនថ្មីដែលតភ្ជាប់រាជធានីភ្នំពេញទៅកាន់ក្រុងបាវិតនៅព្រំដែនកម្ពុជា-វៀតណាម និងគម្រោងផ្សេងៗទៀត។

**ជាមួយនឹង ការធ្លាក់ចុះការប្រើប្រាស់ឯកជន ដោយសារតែការធ្លាក់ចុះរយៈពេលយូរ នៅក្នុងវិស័យអចលនទ្រព្យ អតុល្យភាពខាងក្រៅត្រូវបានរំពឹងថានឹងកើនឡើងនៅក្នុងរយៈពេលខ្លីដល់មធ្យម។** ខណៈពេលដែលប្រាក់បញ្ញើពីបរទេស និងប្រាក់ចំណូលពីទេសចរណ៍ នឹងបន្តជំរុញប្រាក់ចំណូលសុទ្ធ និងសេវាកម្មការវិនិយោគផ្ទាល់ពីបរទេសគួរតែបន្តផ្តល់ហិរញ្ញប្បទានដល់ឱនភាពគណនីចរន្ត ដែលព្យាករថានឹងកើតមានតិចតួចនាពេលខាងមុខ។ ក្នុងរយៈពេលខ្លីដល់មធ្យម កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរក្នុងការធ្វើឱ្យប្រសើរឡើងនូវការប្រមូលចំណូល អនុវត្តការពង្រឹងសារពើពន្ធ និងពង្រឹងប្រសិទ្ធភាពចំណាយស្ថិតក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គួរតែធ្វើឱ្យឱនភាពសារពើពន្ធសរុបរួមតូច ដែលត្រូវបានកំណត់គោលដៅឱ្យស្មើនឹង ឬក្រោម ៥ភាគរយនៃ ផ.ស.ស។

## បញ្ហាប្រឈមនិងហានិភ័យ

**ទោះបីជាសេដ្ឋកិច្ច មានភាពប្រសើរឡើងជាបន្តក៏ដោយ ក៏សេដ្ឋកិច្ចកំពុងប្រឈមមុខនឹងហានិភ័យធ្លាក់ចុះ រួមទាំងការធ្លាក់ចុះតម្រូវការសកលលោកជាងការរំពឹងទុក ក្នុងគ្រាដែលបំណុលនិងអត្រាប្រាក់កម្ចីកើនឡើង និងការថមថយកំណើនសេដ្ឋកិច្ចខ្លាំងជាងការរំពឹងទុកនៅក្នុងប្រទេសចិន។** សេដ្ឋកិច្ចដែលបើកចំហរនិងមានទំហំតូចរបស់កម្ពុជា ដែលមានអនុបាត

**តារាង ២ ៖ ចក្ខុវិស័យម៉ាក្រូបង្ហាញពីភាពប្រសើរឡើងនៃសេដ្ឋកិច្ចជាបន្ត**

| **ចក្ខុវិស័យម៉ាក្រូ** | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | **2019** | **2020** | **2021** | **2022** | **2023e** | **2024p** | **2025p** | **2026p** |
| **គណនីជាតិ និងតម្លៃ** | | | | | | | | |
| ផ.ស.ស ក្នុងមនុស្សម្នាក់ (US$, ណូមីណល) | 2,258.5 | 2,131.5 | 2,217.1 | 2,357.6 | 2,524.6 | 2,696.2 | 2,886.2 | 3,089.0 |
| ផ.ស.ស នៅតម្លៃទីផ្សារថេរ (% ប្រែប្រួល) | 7.9 | -3.6 | 3.1 | 5.1 | 5.0 | 5.3 | 5.5 | 5.5 |
| កសិកម្ម | -0.4 | 0.6 | 1.5 | 0.6 | 1.6 | 1.6 | 1.4 | 1.5 |
| ឧស្សាហកម្ម | 13.0 | -2.2 | 8.4 | 8.2 | 7.6 | 7.2 | 7.1 | 6.9 |
| សេវាកម្ម | 6.6 | -6.7 | -1.8 | 3.6 | 3.4 | 4.5 | 5.2 | 5.4 |
| សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ (ឆ្នាំ, ជាមធ្យម) | 1.9 | 2.9 | 2.8 | 5.5 | 2.1 | 2.2 | 2.2 | 2.2 |
| **រដ្ឋាភិបាលទូទៅ** (% នៃ ផ.ស.ស) | | | | | | | | |
| ប្រាក់ចំណូល និងជំនួយឥតសំណង | 20.0 | 17.9 | 16.2 | 17.2 | 15.9 | 15.4 | 15.4 | 15.3 |
| ប្រាក់ចំណូលពន្ធ | 14.8 | 13.6 | 12.3 | 13.8 | 12.4 | 12.2 | 12.3 | 12.5 |
| ពន្ធលើទំនិញ និងសេវាកម្ម | 9.5 | 8.0 | 6.9 | 7.7 | 6.5 | 6.3 | 6.5 | 6.7 |
| ពន្ធផ្ទាល់ | 3.4 | 4.1 | 3.9 | 4.5 | 4.5 | 4.6 | 4.6 | 4.7 |
| ពន្ធលើពាណិជ្ជកម្មអន្តរជាតិ | 2.0 | 1.6 | 1.4 | 1.6 | 1.5 | 1.3 | 1.2 | 1.1 |
| ជំនួយឥតសំណង | 1.4 | 1.4 | 1.1 | 0.5 | 0.8 | 0.4 | 0.3 | 0.1 |
| ការចំណាយ និងការផ្តល់កម្ចីសុទ្ធ | 18.8 | 21.3 | 21.3 | 20.4 | 21.0 | 18.4 | 18.7 | 18.5 |
| សមតុល្យរួម (មិនរួមទាំងជំនួយឥតសំណង) | -0.3 | -4.8 | -6.3 | -3.8 | -5.9 | -3.4 | -3.6 | -3.3 |
| សមតុល្យរួម (រួមទាំងជំនួយឥតសំណង) | 1.1 | -3.4 | -5.1 | -3.2 | -5.1 | -3.0 | -3.3 | -3.2 |
| ហិរញ្ញប្បទានបរទេស | 2.3 | 3.5 | 3.1 | 3.9 | 4.0 | 1.6 | 2.7 | 2.7 |
| ហិរញ្ញប្បទានក្នុងស្រុកសុទ្ធ (ពីការសន្សំចរន្ត) | -2.8 | 0.7 | 2.8 | 0.2 | 2.1 | 2.3 | 1.4 | 1.5 |
| ការរំលស់ថ្លៃ | -0.6 | -0.8 | -0.8 | -0.9 | -0.9 | -0.9 | -0.9 | -1.0 |
| **រូបិយវត្ថុ និងឥណទាន** | | | | | | | | |
| រូបិយវត្ថុទូទៅ (% ប្រែប្រួល) | 18.2 | 15.3 | 16.4 | 8.2 | 12.5 | 15.0 | 16.5 | 17.0 |
| ឥណទានដល់វិស័យឯកជន (% ប្រែប្រួល) | 1.5 | 1.5 | 1.5 | 1.5 | 1.5 | 1.5 | 1.5 | 1.5 |
| **វិស័យខាងក្រៅ** (លានដុល្លារអាមេរិក លុះត្រាមានការបញ្ជាក់ផ្សេងពីនេះ) | | | | | | | | |
| ការនាំចេញ (ទំនិញ និងសេវាកម្ម) | 16,351 | 16,692 | 18,566 | 24,494.7 | 28,570.2 | 31,599.6 | 35,950.2 | 38,193.9 |
| ការនាំចូល (ទំនិញ និងសេវាកម្ម) | 18,198 | 19,955 | 29,489 | 40,467.1 | 32,468.2 | 34,155.1 | 37,747.8 | 39,889.0 |
| វិនិយោគផ្ទាល់ពីបរទេស លំហូរចូលសុទ្ធ | -3,561 | -3,498 | -3,391 | -3,425 | -3,639 | -4,080 | -4,351 | -4,620 |
| ទុនបម្រុងផ្លូវការដុល | 18,733 | 16,237 | 17,675 | 17,764.8 | 19,895.6 | 20,978.4 | 22,180.8 | 23,502.7 |
| (ចំនួនខែនៃការនាំចូល) | 9.7 | 10.4 | 8.1 | 7.0 | 6.0 | 5.5 | 5.0 | 5.0 |
| គណនីចរន្ត (% នៃ ផ.ស.ស) | -5.9 | -5.5 | -29.1 | -18.8 | 1.3 | -1.0 | -1.5 | -1.8 |
| អត្រាប្តូរប្រាក់ (រៀល/១ដុល្លារជាមធ្យម) | 4,070 | 4,077 | 4,100 | 4,150 | 4,110 | 4,100 | 4,090 | 4,080 |
| បំណុលសាធារណៈសរុប (% of ផ.ស.ស) | 20.8 | 26.6 | 26.5 | 27.0 | 27.5 | 26.9 | 27.4 | 27.4 |
| ***ព័ត៌មានបន្ថែម៖*** | | | | | | | | |
| ផ.ស.ស ណូមីណល,លានដុល្លារអាមេរិក | 36,606 | 34,949 | 36,779 | 39,532 | 42,779 | 46,164 | 49,912 | 53,934 |

*ប្រភព៖ អាជ្ញាធរកម្ពុជា, ការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក។*

*សម្គាល់៖ e = ការប៉ាន់ស្មាន, p = ការព្យាករ។*

ពាណិជ្ជកម្មធៀបនឹង ផ.ស.ស ចំនួន ១១២ភាគរយក្នុងឆ្នាំ២០២៣ នេះ ប្រឈមមុខនឹងហានិភ័យនៃការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ច និងការកើនឡើងកិច្ចគាំពារនិយម។

**នៅក្នុងប្រទេសវិញ ការកើនឡើងខ្លាំងជាងរំពឹងទុកនៃកម្ចីមិនដំណើរការ អាចជះឥទ្ធិពលដល់ស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ ខណៈដែលការធ្លាក់ចុះទីផ្សារលំនៅឋានបន្តកើតមាន។** ការធ្លាក់តម្លៃផ្ទះកំពុងជះឥទ្ធិពលអវិជ្ជមានដល់សុខភាព និងស្ថិរភាពនៃវិស័យធនាគារ តាមរយៈការកើនឡើងហានិភ័យនៃការបរាជ័យបង់សងប្រាក់កម្ចី និងការធ្លាក់ចុះតម្លៃទ្រព្យបញ្ចាំដែលកាន់កាប់ដោយធនាគារ។ ទោះជាយ៉ាងណា ការធ្លាក់ចុះទីផ្សារលំនៅឋានក៏អាចត្រូវបានគេមើលឃើញថា ជាផ្នែកមួយនៃវដ្តឥណទានធម្មតាផងដែរ ដែលអាចផ្តល់លទ្ធភាពឱ្យគ្រួសារកម្ពុជាកាន់តែច្រើនមានលទ្ធភាពទិញលំនៅឋានក្នុងតម្លៃទាប។

## ជម្រើសគោលនយោបាយ

**ដោយផ្អែកលើការកែលម្អជាបន្តបន្ទាប់ ក្នុងការគ្រប់គ្រងសារពើពន្ធក្រោយជំងឺរាតត្បាត កំណែទម្រង់សារពើពន្ធ ដើម្បីជំរុញការកៀរគរប្រាក់ចំណូលក្នុងស្រុក គួរតែជាអាទិភាពកំពូល។** ការពង្រឹងសារពើពន្ធដែលកំពុងដំណើរការ ដោយសារតែការថមថយការប្រមូលប្រាក់ចំណូល នឹងទំនងជាប៉ះពាល់ដល់ការចំណាយសម្រាប់សង្គមនិងការអប់រំជាមូលដ្ឋាន និងសេវាសុខភាព លុះត្រាតែទំហំសារពើពន្ធត្រូវបានស្តារឡើងវិញក្នុងរយៈពេលខ្លី។ ទីមួយ ការធ្វើអន្តរាគមន៍សារពើពន្ធ និងការលើកទឹកចិត្តផ្នែកពន្ធ ដែលជំរុញដោយជំងឺរាតត្បាត គួរតែត្រូវបានបញ្ឈប់។ ទីពីរ ការដាក់ចេញអភិបាលកិច្ចកាន់តែតឹងរ៉ឹងទៅលើវិធានការលើកទឹកចិត្តផ្នែកពន្ធ គួរតែជួយកាត់បន្ថយការខាតបង់ប្រាក់ចំណូលមិនចាំបាច់ ដែលវិធានការទាំងនោះអាចបង្កឡើង។ ក្នុងន័យនេះ ការអភិវឌ្ឍសមត្ថភាពតាមដាន គ្រប់គ្រង និងត្រួតពិនិត្យមើលការចំណាយផ្នែកពន្ធដារ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តសារពើពន្ធ និងថវិការយៈពេលមធ្យម មានសារៈសំខាន់ខ្លាំង។ ទីបី ពន្ធលើទំនិញនិងសេវាកម្ម គួរតែត្រូវបានពង្រឹងតាមរយៈការពិនិត្យមើលឡើងវិញទៅលើអត្រាអាករលើតម្លៃបន្ថែម ការលើកលែងពន្ធ និងការកំណត់ពន្ធក្នុងអត្រាសូន្យ ខណៈពេលដែលដាក់ចេញវិធានការដំឡើងពន្ធគយ ប្រកបដោយមហ្ឈិតាលើគ្រឿងស្រវឹង និងថ្នាំជក់ ដោយកំណត់អត្រាពន្ធគយនេះធៀបទៅនឹងអត្រាពន្ធគយ ដែលអនុវត្តនៅក្នុងប្រទេសដែលមានចំណូលមធ្យមនានា។ ការដាក់ចេញវិធានការពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួន គួរតែជាគោលដៅរយៈពេលមធ្យមនៃយុទ្ធសាស្ត្រកៀរគរប្រាក់ចំណូលបន្ទាប់។ ទីបួន ខណៈពេលដែលអាជ្ញាធរកំពុងដាក់ចេញគោលនយោបាយពង្រឹងសារពើពន្ធសន្សឹមៗ ការពង្រឹងប្រសិទ្ធភាពចំណាយ ឬតម្លៃសាច់ប្រាក់គឺជាការងារចាំបាច់។

**ដើម្បីការពារស្ថិរភាពហិរញ្ញវត្ថុ ការផ្តោតការយកចិត្តទុកដាក់ជាបន្ទាន់ គួរតែធ្វើឡើងទៅលើការត្រួតពិនិត្យធនាគារកាន់តែខ្លាំង៖ ការធ្វើស្ត្រេសតេស្តរបស់គ្រឹះស្ថាននីមួយៗ ការត្រួតពិនិត្យនៅនឹងកន្លែងជាប្រព័ន្ធ ការបន្ស៊ីបន្ថែមទៀតនៃក្របខ័ណ្ឌបទប្បញ្ញត្តិជាមួយនឹងស្តង់ដារអន្តរជាតិ និងការវាយតម្លៃយ៉ាងម៉ត់ចត់ទៅលើគុណភាពផលប័ត្រប្រាក់កម្ចី និងកិច្ចការផ្សេងៗទៀត។** ចំនួនគ្រឹះស្ថានហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា កំពុងកើនឡើងយ៉ាងឆាប់រហ័សរហូតដល់ឆ្នាំ២០២២។ ដូច្នេះ ការពង្រឹងវិស័យហិរញ្ញវត្ថុតាមរយៈការច្របាច់បញ្ចូលគ្នា និងការទិញយក (M&A) គួរតែជួយរក្សាប្រាក់ចំណេញ តាមរយៈការកែលម្អប្រសិទ្ធភាព និងការបង្កើនចំណែកទីផ្សារ។ ដើម្បីត្រៀមខ្លួនសម្រាប់ការកើនឡើងកម្រិតឥណទានមិនដំណើរការ វាមានសារៈសំខាន់ណាស់ក្នុងការធានាថា ជម្រើសដំណោះស្រាយត្រូវត្រៀមរួចជាស្រេច ដើម្បីដាក់ឱ្យប្រើប្រាស់តាមតម្រូវការ និងដើម្បីពង្រឹងរបបអសាធនភាពរបស់កម្ពុជា។ កិច្ចខិតខំប្រឹងប្រែងរៀបចំច្បាប់ស្តីពីការធានារ៉ាប់រងប្រាក់បញ្ញើ និងដំណោះស្រាយធនាគារត្រូវតែបន្តធ្វើ។

**ជាចុងក្រោយ ដើម្បីបញ្ចៀសការថមថយកំណើនសេដ្ឋកិច្ចកម្ពុជាគួរតែផ្លាស់ប្តូរទៅរកគំរូកំណើនប្រកបដោយនិរន្តរភាពជាងនេះ តាមរយៈការធ្វើកំណែទម្រង់រចនាសម្ព័ន្ធបន្ថែមទៀតដើម្បីជំរុញ និងធ្វើពិពិធកម្មការនាំចេញទំនិញ ជាពិសេសផលិតផលកម្មន្តសាល និងការកែច្នៃកសិផល ក៏ដូចជាសេវាកម្ម ជាពិសេសការធ្វើដំណើរ និងបដិសណ្ឋារកិច្ច។** កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតត្រូវធ្វើជាចាំបាច់ ដើម្បីពន្លឿនការធ្វើកំណែទម្រង់ភាពងាយស្រួលនៃការអាជីវកម្ម។ ដូចដែលមានបង្ហាញនៅក្នុងរបាយការណ៍ Business-Ready ឆ្នាំ២០២៤ បញ្ហាប្រឈមបំផុតគឺថា ប្រទេសកម្ពុជាខ្វះសេវាកម្មសាធារណៈដែលមានគុណភាពដើម្បីគាំទ្រដល់អាជីវកម្ម ជាពិសេសក្នុងវិស័យដូចជាអសាធនភាពអាជីវកម្ម ការប្រកួតប្រជែងទីផ្សារ និងការបង្កើតអាជីវកម្មជាដើម។ ដូច្នេះ ការពង្រឹងគ្រឹះស្ថានរបស់កម្ពុជា ដើម្បីធានាថា បទប្បញ្ញត្តិ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពនឹងជួយបង្កើតបរិយាកាសធុរកិច្ច ដែលអាចព្យាករបាន និងមានស្ថិរភាព ដែលមានសារៈសំខាន់សម្រាប់ការលើកកម្ពស់ពាណិជ្ជកម្ម និងការវិនិយោគ។ នោះគឺជាការផ្តោតរបស់អត្ថបទផ្តោតពិសេស នៃរបាយការណ៍នេះ។

# ផ្នែកទី២ ៖

## ឧបសគ្គរចនាសម្ព័ន្ធ ក្រុមហ៊ុន និងធុរកិច្ចចំពោះ ផលិតភាពការងារ



# I. សេចក្តីផ្តើម[13]

**ការចូលរួមចំណែកចំពោះកំណើនសេដ្ឋកិច្ចពីផលិតភាពការងារក្នុងប្រទេសកម្ពុជា នៅមានកម្រិតក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ មួយផ្នែកដោយសារតែបរិយាកាសធុរកិច្ចមិនអំណោយផល។** ការស្រាវជ្រាវកន្លងមករបស់ធនាគារពិភពលោកបានបង្ហាញថា អត្រាកំណើនសេដ្ឋកិច្ចដ៏គួរឱ្យចាប់អារម្មណ៍របស់កម្ពុជាក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ភាគច្រើនត្រូវបានជំរុញដោយកត្តាប្រមូលផ្តុំ (ជាពិសេសពីមូលធន) និងថា ការផ្លាស់ប្តូររចនាសម្ព័ន្ធរបស់ប្រទេសកម្ពុជាពីកសិកម្មទៅជាកម្មន្តសាលនិងសេវាកម្ម បាននៅទ្រឹងក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ[14]។ លទ្ធផលមួយនៃគំរូកំណើននេះ គឺកម្រិតផលិតភាពការងារទាបខ្លាំងនៅប្រទេសកម្ពុជា បើប្រៀបធៀបទៅនឹងប្រទេសក្នុងតំបន់នៅគ្រប់វិស័យនៃសេដ្ឋកិច្ច។ ការស្រាវជ្រាវកន្លងមកបានរកឃើញថា ដំណើរការផលិតភាពការងារខ្សោយរបស់កម្ពុជាកើតមានឡើងដោយសារបរិយាកាសធុរកិច្ចមិនល្អ និងការប្រកួតប្រជែងសេដ្ឋកិច្ច ធនធានមនុស្ស និងអភិបាលកិច្ចមានកម្រិតទាប។

**កម្ពុជានឹងចាំបាច់ត្រូវធ្វើឱ្យដំណើរការផលិតភាពការងាររបស់ខ្លួន មានភាពប្រសើរឡើងឱ្យបានខ្លាំងនៅក្នុងទសវត្សរ៍ខាងមុខ ដើម្បីរក្សាបានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ និងសម្រេចបានចក្ខុវិស័យរបស់ខ្លួនក្នុងការក្លាយជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ឱ្យបានឆាប់រហ័ស។** ការក្លាយជាប្រទេសមានប្រាក់ចំណូលខ្ពស់ទាមទារឱ្យមានកំណើនប្រាក់ចំណូលក្នុងមនុស្សម្នាក់ ៦ដងពោលគឺពីប្រហែល ២.២០០ដុល្លារអាមេរិកនៅថ្ងៃនេះដល់ប្រហែល ១៣.៨០០ដុល្លារ។ ការសម្រេចបានគោលដៅនេះ តម្រូវឱ្យប្រទេសកម្ពុជារក្សាបានអត្រាកំណើនខ្ពស់ក្នុងរយៈពេលទសវត្សរ៍ខាងមុខ និងត្រូវជៀសវាងឱ្យផុតពី “អន្ទាក់ចំណូលមធ្យម” ពោលគឺមានន័យថាជាស្ថានភាពដែលផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់របស់ប្រទេសមួយឈានដល់កម្រិតប្រាក់ចំណូលមធ្យម ប៉ុន្តែប្រទេសនោះមិនអភិវឌ្ឍទៅមុខបន្ថែមទៀតដើម្បីក្លាយជាប្រទេសមានប្រាក់ចំណូលខ្ពស់ឡើយ ដែលទំនងជានឹងតម្រូវឱ្យមានការផ្លាស់ប្តូរទៅជាគំរូកំណើនដែលដឹកនាំដោយផលិតភាពការងារដែលមាននិរន្តរភាពជាងមុន។ ការសម្រេចបានឋានៈជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅក្នុងពេលវេលាកំណត់ដែលលឿនណាមួយ ទំនងជាតម្រូវឱ្យប្រទេសកម្ពុជាសម្រេចបានដំណើរការផលិតភាពការងារដូចទៅនឹងផលិតភាពកាងារជាប្រវត្តិសាស្ត្រឈានមុខគេក្នុងពិភពលោករបស់សាធារណរដ្ឋកូរ៉េនៅក្នុងដំណាក់កាលអភិវឌ្ឍន៍យ៉ាងឆាប់រហ័សរបស់ប្រទេសនេះ។ ប្រទេសកូរ៉េខាងត្បូងនៅក្នុងឆ្នាំ១៩៦៨ ស្ថិតក្នុងកម្រិតអភិវឌ្ឍន៍នាពេលបច្ចុប្បន្នរបស់ប្រទេសកម្ពុជា ហើយប្រទេសនេះបានរក្សាកំណើនកត្តាផលិតភាពការងារសរុបចំនួន ២,២ ភាគរយ ក្នុងមួយឆ្នាំក្នុងរយៈពេល ២៥ឆ្នាំបន្ទាប់ (ពីឆ្នាំ ១៩៦៨ ដល់ឆ្នាំ ១៩៩៣)។ អត្រាកំណើនផលិតភាពការងារនេះមានកម្រិតខ្ពស់ជាងជិតពីរដងធៀបនឹងអត្រាជា មធ្យមជាប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ១,៣ភាគរយនៅចន្លោះឆ្នាំ២០០០ ដល់ឆ្នាំ២០១៩។

**ផ្នែកអត្ថបទផ្តោតពិសេសនៃរបាយការណ៍ស្តីពីបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះ ផ្តល់ការយល់ដឹងលម្អិតថ្មីបន្ថែមទៀតអំពីអ្វីដែលតម្រូវឱ្យមាន ដើម្បីគាំទ្រដល់ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សឆ្ពោះទៅកាន់គំរូកំណើនសេដ្ឋកិច្ចដែលដឹកនាំដោយផលិតភាពការងារ។** អត្ថបទផ្តោតពិសេសនេះ ស្វែងយល់ពីកត្តាជំរុញរចនាសម្ព័ន្ធជាមូលដ្ឋាននៃផលិតភាពការងារកម្រិតក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជា ក៏ដូចជាបរិយាកាសខាងក្រៅ និងឧបសគ្គការិយាធិបតេយ្យដែលរារាំងដល់ការកើនឡើងផលិតភាពឱ្យខ្ពស់ជាងនេះ។ គោលបំណងនៃការងារនេះគឺដើម្បីជួយអភិវឌ្ឍ និងផ្តល់អាទិភាពដល់អនុសាសន៍គោលនយោបាយដែលអាចអនុវត្តបាន ដែលអាចជូនដំណឹងដល់តួអង្គនានានៅក្នុងវិស័យរបស់រដ្ឋាភិបាល និងក្នុងវិស័យឯកជន។

# II. មូលដ្ឋានគ្រឹះរចនាសម្ព័ន្ធ និង ផលិតភាពការងារកម្រិតក្រុមហ៊ុន

**ទិន្នន័យដែលទទួលបានពីការធ្វើអង្កេតសហគ្រាសបង្ហាញថា កម្រិតផលិតភាពការងារក្នុងចំណោមក្រុមហ៊ុនកម្ពុជាមានកម្រិតទាបជាងប្រទេសក្នុងតំបន់ទាំងនៅផ្នែកផលិតកម្ម និងសេវាកម្ម (រូប S.១)។** ផលិតភាពការងារជាមធ្យមក្នុងចំណោមក្រុមហ៊ុនទាំងអស់នៅកម្ពុជា ត្រូវបានប៉ាន់ស្មានថាមានចំនួន ៦.៨៩៩ដុល្លារអាមេរិកសម្រាប់កម្មករនិយោជិតម្នាក់ ហើយខ្ពស់ជាងនេះនៅក្នុងចំណោមក្រុមហ៊ុនសេវាកម្ម (៨.៥៥៥ ដុល្លារអាមេរិក) ធៀបទៅនឹងក្រុមហ៊ុនកម្មន្តសាល (៤.៧៨៤ ដុល្លារអាមេរិក)។ កម្រិតផលិតភាពនេះទាបជាងក្រុមហ៊ុននៅក្នុងប្រទេសក្នុងតំបន់ជារួម (ទាបជាង ៤១ភាគរយ) ក៏ដូចជានៅទូទាំងវិស័យកម្មន្តសាល (ទាបជាង ២៨ភាគរយ) និងវិស័យសេវាកម្ម (ទាបជា ៤៣ភាគរយ)[15]។

13 ផ្នែកអត្ថបទផ្តោតពិសេសត្រូវបានសរសេរដោយ Faya Hayati, Hassan Noura និង Aka Kyaw Min Maw។

14 របាយការណ៍ស្តីពី បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា (ខែវិច្ឆិកា ឆ្នាំ២០២៣) និងរបាយការណ៍ស្តីពី បច្ចុប្បន្នភាពការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ ជំនាន់ទីពីរ របស់ប្រទេសកម្ពុជា (ធនាគារពិភពលោក ឆ្នាំ២០២៤)។

15 ចំណាំថា ការប៉ាន់ស្មានអំពីផលិតភាពការងារដោយផ្អែកលើទិន្នន័យអង្កេតសហគ្រាសខុសពីការប៉ាន់ស្មានដោយផ្អែកលើគណនីជាតិ ហើយជាធម្មតាខ្ពស់ជាងខ្លាំង។ ការប៉ាន់ស្មានខ្ពស់ជាងនេះគឺដោយសារតែការដកចេញពីការធ្វើអង្កេតសហគ្រាសនូវវិស័យ និងក្រុមហ៊ុនដែលជាធម្មតាមានផលិតភាពទាបជាង រួមទាំងវិស័យកសិកម្ម រដ្ឋាភិបាល ក្រុមហ៊ុនក្រៅផ្លូវការ និងសហគ្រាសរដ្ឋ។

## រូប S.១ ៖ ផលិតភាពការងារក្នុងចំណោមក្រុមហ៊ុនកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់ តាមវិស័យ




*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសបង់ក្លាដែស* (ឆ្នាំ២០២២) កម្ពុជា (ឆ្នាំ២០២៣) ហ្វីលីពីន (ឆ្នាំ២០២៣) និងវៀតណាម (ឆ្នាំ២០២៣), ធនាគារពិភពលោក។
*ចំណាំ៖ ការធ្វើអង្កេតសហគ្រាសគ្របដណ្តប់តែក្រុមហ៊ុនចុះបញ្ជីឯកជននៅក្នុងវិស័យកម្មន្តសាល* និងសេវាកម្មប៉ុណ្ណោះ។ ការធ្វើអង្កេតសហគ្រាសទាំងនេះមិនរាប់បញ្ចូលក្រុមហ៊ុនក្រៅផ្លូវការ និងសហគ្រាសរដ្ឋ ក៏ដូចជាវិស័យកសិកម្ម និងរដ្ឋាភិបាល។ ប្រទេសក្នុងតំបន់រួមមាន បង់ក្លាដែស ហ្វីលីពីន និងវៀតណាម។

## រូប S.២ ៖ ភាពខុសគ្នានៃផលិតភាពការងារក្នុងចំណោមក្រុមហ៊ុនកម្ពុជាផ្អែកតាមលក្ខណៈក្រុមហ៊ុន តម្លៃបន្ថែមជាមធ្យមក្នុងនិយោជិតម្នាក់ (ដុល្លារអាមេរិក) ឆ្នាំ២០២៣




*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសកម្ពុជា* (ឆ្នាំ២០២៣), ធនាគារពិភពលោក។
*ចំណាំ៖ ១.* តំបន់ទំនាបរួមមានខេត្តនៅភាគខាងត្បូងព័ទ្ធជុំវិញរាជធានី ដូចជាខេត្តកណ្តាល និងព្រៃវែង។ តំបន់បឹងទន្លេសាបរួមមានខេត្តមួយចំនួនដូចជាសៀមរាប និងបាត់ដំបង។ តំបន់ភ្នំរួមមានខេត្តខ្ពង់រាបនៅភាគខាងជើងនិងឦសាន ដូចជាក្រចេះ និងព្រះវិហារ។

**ជាងនេះទៅទៀត មានភាពខុសគ្នាខ្លាំងនៅផ្អែកផលិតភាពការងារក្នុងចំណោមក្រុមហ៊ុនកម្ពុជា ដោយផ្អែកលើលក្ខណៈនានាដូចជា ទីតាំង វិស័យ និងទំហំ (រូប S.២)។** ក្រុមហ៊ុនដែលមានមូលដ្ឋាននៅរាជធានីភ្នំពេញ មានផលិតភាពការងារជាមធ្យមខ្ពស់ជាង ៧៣ភាគរយធៀបនឹងក្រុមហ៊ុនដែលមានមូលដ្ឋាននៅតំបន់ដាច់ស្រយាល តំបន់ភ្នំភាគខាងជើង និងភាគឦសាន។ លើសពីនេះ ក្រុមហ៊ុនសេវាកម្មមានផលិតភាពជាមធ្យមខ្ពស់ជាង ៨៧ភាគរយ ធៀបនឹងក្រុមហ៊ុនកម្មន្តសាល ដោយ “ក្រុមហ៊ុនសេវាកម្មផ្សេងទៀត”[16] គឺជាអនុវិស័យដែលមានផលិតភាពការងារច្រើនបំផុត ហើយ “ក្រុមហ៊ុនកម្មន្តសាលផ្សេងទៀត” មានផលិតភាពតិចបំផុត។ ជាចុងក្រោយ មានទំនាក់ទំនង “រាងជាអក្សរ U” រវាងផលិតភាពការងារនិងទំហំ

16 សេវាកម្មផ្សេងទៀតរួមមានការសាងសង់ ការលក់និងជួសជុលយានយន្ត ការលក់ដុំ ការស្តុកទំនិញ ការដឹកជញ្ជូន និងបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន។

ក្រុមហ៊ុន ដោយទាំងក្រុមហ៊ុនតូច និងក្រុមហ៊ុនធំ ជាធម្មតាមានផលិតភាពច្រើនជាងក្រុមហ៊ុនធុនមធ្យម។ ការណ៍នេះបង្ហាញថា ក្រុមហ៊ុនធុនមធ្យមអាចប្រឈមនឹងឧបសគ្គចនាសម្ព័ន្ធប្លែកពីគេ ក្នុងការឈានទៅរកផលិតភាពការងារកាន់តែខ្ពស់។ លើសពីនេះ ការវិភាគសេដ្ឋកិច្ចបង្ហាញថា ទំនាក់ទំនងរវាងផលិតភាពការងារ និងទីតាំង វិស័យ និងទំហំមានសារៈសំខាន់ជាលក្ខណៈស្ថិតិ និងមានភាពរឹងមាំ[17]។ ផ្ទុយទៅវិញ ផលិតភាពការងារជាមធ្យមមានភាពខុសគ្នាតិចតួចផ្អែកតាមលក្ខណៈជាមូលដ្ឋានផ្សេងទៀត ដូចជាអាយុរបស់ក្រុមហ៊ុនជាដើម។ ទិន្នន័យទាំងនេះចង្អុលបង្ហាញឱ្យឃើញពីឱកាសផលិតភាពសម្រាប់ប្រទេសកម្ពុជាដោយចាប់ផ្តើមពីការពន្លឿនការផ្លាស់ប្តូររចនាសម្ព័ន្ធរបស់ប្រទេសឆ្ពោះទៅរកវិស័យ និងអនុវិស័យដែលមានផលិតភាពការងារកាន់តែខ្ពស់ ក៏ដូចជាពីការដោះស្រាយឧបសគ្គចនាសម្ព័ន្ធដែលប្រឈមដោយក្រុមហ៊ុនធុនមធ្យម និងក្រុមហ៊ុនដែលមានទីតាំងនៅតំបន់ជនបទ និងតំបន់អភិវឌ្ឍន៍តិចតួចនៃប្រទេសកម្ពុជា។

**ក៏មានភាពខុសគ្នាគួរឱ្យកត់សម្គាល់ផងដែរនៃផលិតភាពការងារក្នុងចំណោមក្រុមហ៊ុនកម្ពុជា ដោយផ្អែកលើការអនុវត្តទាក់ទងនឹងបុគ្គលិក ការប្រើប្រាស់បច្ចេកវិទ្យា និងការផ្តោតលើទីផ្សារ ទោះបីជាភាពខុសគ្នានេះមានតិចតួចក្តី (រូប S.៣)។** ក្រុមហ៊ុនកម្ពុជាដែលមានការអនុវត្តមុខងារបុគ្គលិកទំនើបជាង បើទោះបីជាមានតែក្រុមហ៊ុនតិចតួចក្តី ជាធម្មតាមានផលិតភាពខ្លាំងជាង។ ជាពិសេស ក្រុមហ៊ុនដែលគ្រប់គ្រងដោយនាយកប្រតិបត្តិឯករាជ្យ (CEO) (មានតែ ៥ភាគរយនៃក្រុមហ៊ុន) មានផលិតភាពការងារខ្ពស់ជាង ២០ភាគរយធៀបនឹងក្រុមហ៊ុនដែលមានម្ចាស់ក្រុមហ៊ុនគ្រប់គ្រងដោយខ្លួនឯង។ ក៏មានទំនាក់ទំនងវិជ្ជមានខ្លាំងផងដែររវាងការអនុវត្តការគ្រប់គ្រងកាន់តែប្រសើរ និងផលិតភាពការងារ។ ដូចគ្នានេះដែរ ក្រុមហ៊ុន ដែលផ្តល់កម្មវិធីបណ្តុះបណ្តាលបុគ្គលិកជាផ្លូវការ (មានតែ ១០ភាគរយនៃក្រុមហ៊ុន) មានផលិតភាពការងារខ្ពស់ជាង ២៩ភាគរយ។ លើសពីនេះ ក្រុមហ៊ុនដែលប្រើប្រាស់បច្ចេកវិទ្យា ដូចជាក្រុមហ៊ុនដែលមានគេហទំព័រ និងប្រើប្រាស់ការទូទាត់តាមអេឡិចត្រូនិកជាធម្មតាមានផលិតភាពខ្ពស់ជាង។ ការវិភាគម៉ាទ្រិចសេដ្ឋកិច្ចបង្ហាញថា ទំនាក់ទំនងទាំងនេះមានសារៈសំខាន់ជាលក្ខណៈស្ថិតិនៅក្នុងវិស័យភាគច្រើន[18]។ ជាចុងក្រោយ ក្រុមហ៊ុនកម្មន្តសាលដែលផ្តោតលើការនាំចេញជាមធ្យមមានផលិតភាពការងារខ្ពស់ជាង ២៩ភាគរយធៀបនឹងក្រុមហ៊ុនដែលផ្តោតលើទីផ្សារក្នុងស្រុក។ ទិន្នន័យទាំងនេះចង្អុលបង្ហាញឱ្យឃើញពីឱកាសផលិតភាពសម្រាប់ប្រទេសកម្ពុជា ដោយចាប់ផ្តើមពីការជំរុញឱ្យមានការពន្លឿនការអនុវត្តល្អបំផុតឱ្យបានទូលំទូលាយនៅទូទាំងក្រុមហ៊ុន ក៏ដូចជាការតម្រង់ទិសឆ្ពោះទៅរកអន្តរជាតិកាន់តែខ្លាំង។

**ជាចុងក្រោយ ក៏មានភាពខុសគ្នាខ្លាំងផងដែរនៃផលិតភាពការងារក្នុងចំណោមក្រុមហ៊ុនកម្ពុជា ដោយមានគម្លាតដ៏ធំរវាងក្រុមហ៊ុនឈានមុខគេ និងក្រុមហ៊ុនដំណើរការយឺតយ៉ាវ (រូប S.៤, ក្រាហ្វិក ក)។** ដោយអនុលោមតាមគំរូដែលសង្កេតឃើញមាននៅទូទាំងពិភពលោកនិងនៅក្នុងតំបន់អាស៊ី[19] ផលិតភាពរបស់ក្រុមហ៊ុនឈានមុខគេរបស់កម្ពុជា (ក្រុមហ៊ុនឈានមុខគេកំពូលទាំង១០) មានខ្លាំងជាងផលិតភាពរបស់ក្រុមហ៊ុនដំណើរការ

**រូប S.៣ ៖ ភាពខុសគ្នានៃផលិតភាពការងារក្នុងចំណោមក្រុមហ៊ុនកម្ពុជាផ្អែកតាមការអនុវត្ត**
(តម្លៃបន្ថែមជាមធ្យមក្នុងនិយោជិតម្នាក់គិតជាដុល្លារអាមេរិក)




*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសកម្ពុជា* (ឆ្នាំ២០២៣), ធនាគារពិភពលោក។ សម្គាល់៖ *សម្រាប់តែក្រុមហ៊ុនកម្មន្តសាលប៉ុណ្ណោះ។

17 ធនាគារពិភពលោក ដែលនឹងចេញផ្សាយនាពេលខាងមុខ(a)។
18 ធនាគារពិភពលោក ដែលនឹងចេញផ្សាយនាពេលខាងមុខ (a)។
19 សូមមើល ឧទាហរណ៍ ធនាគារពិភពលោក ឆ្នាំ២០២៤f។

**រូប S.៤ ៖ ភាពខុសគ្នានៃផលិតភាពការងារក្នុងចំណោមក្រុមហ៊ុនកម្ពុជាផ្អែកតាមកម្រិតអនុវត្ត និងធៀបនឹងប្រទេសក្នុងតំបន់**

*ក្រាហ្វិក ក*




*ក្រាហ្វិក ខ*




*ក្រាហ្វិក គ*




*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសបង់ក្លាដែស (ឆ្នាំ២០២២) កម្ពុជា (ឆ្នាំ២០១៦ និងឆ្នាំ២០២៣) ហ្វីលីពីន (ឆ្នាំ២០២៣) និងវៀតណាម (ឆ្នាំ២០២៣), ធនាគារពិភពលោក។*

*សម្គាល់៖ ក្រុមប្រទេសក្នុងតំបន់រួមមានប្រទេសបង់ក្លាដែស ហ្វីលីពីន និងវៀតណាម។*

យឺតយ៉ាវ (ក្រុមហ៊ុនដំណើរការយឺតយ៉ាវជាងគេទាំង១០) ជាមធ្យម ១៣ដង (និងមានផលិតភាពច្រើនជាងជិតបួនដងធៀបនឹងក្រុមហ៊ុនមធ្យម "ធម្មតា")។ គំរូនេះត្រូវបានសង្កេតឃើញនៅទូទាំងគ្រប់វិស័យ និងអនុវិស័យនៃសេដ្ឋកិច្ច ប៉ុន្តែមានភាពរឹងមាំជាងនៅទូទាំងវិស័យសេវាកម្ម ជាទីដែលជាធម្មតាក្រុមហ៊ុនឈានមុខគេមានផលិតភាពខ្លាំងជាង ១៨ដងធៀបនឹងក្រុមហ៊ុនដំណើរការយឺតយ៉ាវ (ខ្ពស់ជាង ៨ដងធៀបនឹងក្រុមហ៊ុនកម្មន្តសាល)។

**ជាងនេះទៀត ក្រុមហ៊ុនឈានមុខគេរបស់កម្ពុជា មានលក្ខណៈ និងការអនុវត្តខុសៗគ្នា។** នៅកម្រិតសេដ្ឋកិច្ចទាំងមូល ក្រុមហ៊ុនឈានមុខគេភាគច្រើនលើសលុបគឺជាក្រុមហ៊ុនសេវាកម្ម (៩៧ភាគរយ) ដោយជិតពាក់កណ្តាលនៅក្នុងអនុវិស័យ "សេវាកម្មផ្សេងទៀត" ដែលរួមមានទាំងវិស័យចំណេះដឹងនានាដូចជាបច្ចេកវិទ្យាព័ត៌មានវិទ្យា (IT) ជាដើម។ ក្រុមហ៊ុនទាំងណោះភាគច្រើនលើសលុបគឺជាក្រុមហ៊ុនខ្នាតតូចផងដែរ (៩១ភាគរយ) ដែលមានទីតាំងនៅភ្នំពេញ ឬតំបន់វាលទំនាប (៩០ភាគរយ) ដែលជាកម្មសិទ្ធិក្នុងស្រុកទាំងស្រុង (៩៦ភាគរយ) និងផ្តោតលើទីផ្សារក្នុងស្រុក (៩៧ភាគរយ)។ ទោះជាយ៉ាងណា នៅក្នុងវិស័យកម្មន្តសាល ក្រុមហ៊ុនឈានមុខគេទំនងជាមានចំនួនច្រើនខ្លាំង (៦៨ភាគរយ) ដែលមួយចំនួនជាកម្មសិទ្ធិរបស់បរទេស (៦០ភាគរយ) និងផ្តោតលើការនាំចេញ (៦៤ភាគរយ)។ ជាងនេះទៀត ក្រុមហ៊ុនឈានមុខគេក៏ទំនងជាបានទទួលយកការអនុវត្តល្អបំផុតដូចជាការមាននាយកប្រតិបត្តិឯករាជ្យ (១០ភាគរយធៀបនឹង ៥ភាគរយនៅទូទាំងប្រទេស) និងកម្មវិធីបណ្តុះបណ្តាលបុគ្គលិក (១៥ភាគរយធៀបនឹង ១០ភាគរយ) និងប្រើប្រាស់បច្ចេកវិទ្យា។ លក្ខណៈទាំងនេះមានភាពស៊ីសង្វាក់គ្នាយ៉ាងទូលំទូលាយជាមួយនឹងការស្រាវជ្រាវក្នុងតំបន់ ដែលបានរកឃើញថា ក្រុមហ៊ុននាំមុខគេក្នុងតំបន់អាស៊ីជាធម្មតាត្រូវបានប្រមូលផ្តុំនៅក្នុងវិស័យដែលពឹងផ្អែកខ្លាំងលើឌីជីថល ហើយទំនងកាន់តែខ្លាំងប្រើប្រាស់បច្ចេកវិទ្យាទំនើប[20]។ ទិន្នន័យទាំងអស់នេះចង្អុលបង្ហាញឱ្យឃើញឱកាសផលិតភាពសម្រាប់ប្រទេសកម្ពុជាដោយចាប់ផ្តើមពីការជំរុញនិងលើកទឹកចិត្តដល់ក្រុមហ៊ុនដំណើរការយឺតយ៉ាវនិងក្រុមហ៊ុនមធ្យមឱ្យខិតខំប្រឹងប្រែងរៀនសូត្រ និងតាមឱ្យទាន់ក្រុមហ៊ុនឈានមុខគេនៅក្នុងវិស័យនិងនៅថ្នាក់ជាតិលើការអនុវត្តល្អផ្សេងៗ។

**ទោះបីជាទទួលបានជោគជ័យនៅថ្នាក់ជាតិក៏ដោយ ក៏ក្រុមហ៊ុនឈានមុខគេរបស់កម្ពុជានៅតែមានកម្រិតទាបខ្លាំងធៀបនឹងកម្រិតផលិតភាពក្នុងតំបន់ ដែលរារាំងការច្នៃប្រឌិតជាតិ និងទាញទម្លាក់កម្រិតផលិតភាពជាតិ។** ទោះបីជាក្រុមហ៊ុនឈានមុខគេមានចំនួនតិចតួចក៏ដោយ ក៏ក្រុមហ៊ុនទាំងនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការច្នៃប្រឌិតជាតិ ព្រមទាំងជួយបង្កើតនិងបន្តជំរុញកម្រិតផលិតភាពជាតិ[21]។ ទោះជាយ៉ាងណា ក្រុមហ៊ុនឈានមុខគេរបស់កម្ពុជាមិននាំមុខក្រុមហ៊ុនដំណើរការយឺតយ៉ាវឆ្ងាយ ដូចទៅនឹងក្រុមហ៊ុនឈានមុខគេនៅក្នុងប្រទេសផ្សេងទៀតទេ ដែលនៅក្នុងប្រទេសទាំងនោះគម្លាតផលិតភាពមានទំហំធំជាង (រូប S.៤, ក្រាហ្វិក ខ)។ ជាងនេះទៅទៀត ក្រុមហ៊ុនឈានមុខគេជាតិរបស់កម្ពុជានៅមានកម្រិតផលិតភាពទាបជាងឆ្ងាយធៀបនឹងកម្រិតផលិតភាពក្នុងតំបន់ (ដែលកម្រិតផលិតភាពក្នុងតំបន់នេះក៏នៅទាបជាងកម្រិតផលិតភាពសកលដែលកំណត់ដោយក្រុមហ៊ុនក្នុងប្រទេសមានសេដ្ឋកិច្ចជឿនលឿនទៀតផង)។ ឧទាហរណ៍ កម្រិតផលិតភាពជាមធ្យមនៃក្រុមហ៊ុនឈានមុខគេរបស់កម្ពុជា (ប្រហែល ២៥.០០០ដុល្លារអាមេរិកក្នុងកម្មករម្នាក់) គឺប្រហាក់ប្រហែលនឹងក្រុមហ៊ុនធម្មតា ឬមធ្យមនៅក្នុងប្រទេសវៀតណាម និងទាបជាងកម្រិតផលិតភាពមធ្យមរបស់ក្រុមហ៊ុនឈានមុខគេក្នុងតំបន់ ៨៣ភាគរយ (រូប S.៤, ក្រាហ្វិក គ)។ ហេតុផលមួយដែលបណ្តាលឱ្យមានគម្លាតកម្រិតផលិតភាពនេះគឺថា កម្រិតផលិតភាពទាបរបស់កម្ពុជា ត្រូវបានជំរុញដោយភាពដំណើរការមិនល្អនៃក្រុមហ៊ុនឈានមុខគេរបស់កម្ពុជា។ ទិន្នន័យទាំងនេះចង្អុលបង្ហាញឱ្យឃើញឱកាសផលិតភាពសម្រាប់ប្រទេសកម្ពុជាដោយចាប់ផ្តើមពីការជំរុញ និងលើកទឹកចិត្តក្រុមហ៊ុនឈានមុខគេរបស់ខ្លួនឱ្យធ្វើប្រឹងប្រែងបន្ថែមទៀត និងខិតខំឱ្យកាន់តែខ្លាំងដើម្បីឈានទៅដល់កម្រិតផលិតភាពក្នុងតំបន់ និងពិភពលោក។

## III. ទិដ្ឋភាពទូទៅអំពីឧបសគ្គចំពោះការធ្វើអាជីវកម្ម

**ឧបសគ្គចម្បងក្នុងការធ្វើអាជីវកម្មដែលលើកឡើងដោយក្រុមហ៊ុនកម្ពុជាសព្វថ្ងៃ គឺជាក្រុមហ៊ុនក្រៅផ្លូវការ ពន្ធដារ អំពើពុករលួយ តុលាការ និងការដឹកជញ្ជូន (រូប S.៥)។** ក្រុមហ៊ុននៅកម្ពុជាភាគច្រើនបានលើកឡើងពីការអនុវត្តរបស់ក្រុមហ៊ុនជាគូប្រកួតប្រជែងក្រៅផ្លូវការ (៧៨ភាគរយនៃក្រុមហ៊ុន) ថាជា "ឧបសគ្គ" ក្នុងការធ្វើអាជីវកម្ម បន្ទាប់មកដោយអត្រាពន្ធដារ (៦៨ភាគរយ) អំពើពុករលួយ (៥៧ភាគរយ) និងតុលាការ (៥៧ភាគរយ)។ ដូចគ្នានេះដែរ ក្រុមហ៊ុននៅកម្ពុជាភាគច្រើនបានលើកឡើងពីវិស័យក្រៅប្រព័ន្ធ (៤២ភាគរយនៃក្រុមហ៊ុន) ថាជា "ឧបសគ្គដ៏ធំបំផុត" ក្នុងការធ្វើអាជីវកម្ម បន្ទាប់មកដោយអត្រាពន្ធដារ (៣២ភាគរយ) រដ្ឋបាលសារពើពន្ធ (៩ភាគរយ) និងការដឹកជញ្ជូន (៦ភាគរយ)។ ផ្ទុយទៅវិញ លទ្ធភាពទទួលបានហិរញ្ញវត្ថុ ការអប់រំកម្លាំងពលកម្ម និងបទប្បញ្ញត្តិការងារស្ថិតនៅក្នុងចំណោមឧបសគ្គតូចជាងគេទាំងប្រាំដែលត្រូវបានលើកឡើងដោយក្រុមហ៊ុននៅកម្ពុជា។

20 ធនាគារពិភពលោក ឆ្នាំ២០២៤f។

21 ធនាគារពិភពលោក ឆ្នាំ២០២៤f។

**ជារួម បរិយាកាសធុរកិច្ចនៅកម្ពុជានៅតែមានបញ្ហាប្រឈមខ្លាំងជាងប្រទេសក្នុងតំបន់ បើទោះជាមានការកែលម្អគួរឱ្យកត់សម្គាល់ពីពេលមួយទៅពេលមួយក៏ដោយ។** ប្រធានបទភាគច្រើនបានប្រែក្លាយជាកង្វល់តិចជាងមុនសម្រាប់ក្រុមហ៊ុនកម្ពុជាក្នុងរយៈពេលពីឆ្នាំ២០១៦ និងឆ្នាំ២០២៣ លើកលែងតែក្រុមហ៊ុនក្រៅផ្លូវការ និងបញ្ហាអគ្គិសនីដែលនៅតែជាកង្វល់។ ទោះជាយ៉ាងណា ការប្រៀបធៀបក្រុមហ៊ុននៅកម្ពុជាជាមួយប្រទេសក្នុងតំបន់បង្ហាញឱ្យឃើញថា ក្រុមហ៊ុនកម្ពុជាមានការព្រួយបារម្ភច្រើនជាងស្ទើរតែលើប្រធានបទទាំងអស់ ដែលបង្ហាញថា ពួកគេជួបប្រទះបរិយាកាសធុរកិច្ចដែលមានបញ្ហាប្រឈមខ្លាំងជាង។ លទ្ធផលនេះមានស្របគ្នាទៅនឹងការរកឃើញនៃ របាយការណ៍ B-Ready របស់ធនាគារពិភពលោក[22] ដែលរកឃើញថា ប្រទេសកម្ពុជាមានបរិយាកាសធុរកិច្ចជារួមអាក្រក់ខ្លាំងធៀបនឹងប្រទេសសិង្ហបុរីដែលជាប្រទេសនាំមុខក្នុងតំបន់ ឬអាក្រក់ជាងប្រទេសវៀតណាម ហ្វីលីពីន ឬបង់ក្លាដែស។ របាយការណ៍នោះក៏បានរកឃើញផងដែរថា ប្រទេសកម្ពុជាអនុវត្តមិនបានល្អជាពិសេសទាក់ទងនឹងការផ្តល់សេវាសាធារណៈ និងអំពីប្រធានបទនានាដូចជា អសាធនភាពធុរកិច្ច ការប្រកួតប្រជែងទីផ្សារ និងការបង្កើតក្រុមហ៊ុន។

**ជាងនេះទៅទៀត មានភាពខុសគ្នាខ្លាំងទាក់ទងនឹងក្តីបារម្ភក្នុងចំណោមក្រុមហ៊ុនកម្ពុជា ដោយផ្អែកលើលក្ខណៈនានាដូចជាទីតាំង ទំហំ វិស័យ និងកម្រិតប្រតិបត្តិការ (រូប S.៦)។** ក្រុមហ៊ុនដែលមានទីតាំងនៅតំបន់ភ្នំ (និងដែលមានផលិតភាពទាបបំផុត) មានការព្រួយបារម្ភអំពីប្រធានបទទាំងអស់ខ្លាំងជាងក្រុមហ៊ុននៅក្នុងរាជធានីភ្នំពេញ (ដែលមានផលិតភាពខ្ពស់បំផុត) ដែលបង្ហាញឱ្យឃើញបញ្ហាប្រឈមខ្លាំងជាងក្នុងបរិយាកាសអាជីវកម្មនៅក្នុងតំបន់ទីក្រុងតូចជាង និងដាច់ស្រយាលជាងក្នុងប្រទេសកម្ពុជា។ ដូចគ្នានេះដែរ ក្រុមហ៊ុនធុនមធ្យម (ដែលមានផលិតភាពទាបបំផុត) មានការព្រួយបារម្ភអំពីប្រធានបទទាំងអស់ខ្លាំងជាងក្រុមហ៊ុនតូចៗ (ដែលមានផលិតភាពខ្ពស់បំផុត)។ ការណ៍នេះបង្ហាញថា ក្រុមហ៊ុនធុនមធ្យមប្រឈមមុខនឹងឧបសគ្គធំជាងក្នុងការធ្វើអាជីវកម្ម មិនសូវមានសមត្ថភាពក្នុងការជម្នះឧបសគ្គអាជីវកម្ម ឬប្រឈមនឹងបញ្ហាទាំងពីរ។ ឧទាហរណ៍ វាអាចមានការលំបាកកាន់តែខ្លាំងក្នុងការដោះស្រាយឧបសគ្គនានា ខណៈពេលដែលក្រុមហ៊ុនពង្រីកខ្លួន និងលែងនៅតូចនិងលែងរហ័សរហួនដូចមុន ប៉ុន្តែមិនទាន់មានសមត្ថភាព និងដំណើរការស្ថាប័នជាលក្ខណៈក្រុមហ៊ុនធំៗនៅឡើយ។ លើសពីនេះ ក្រុមហ៊ុនកម្មន្តសាល និងក្រុមហ៊ុនឈានមុខគេមានការព្រួយបារម្ភខ្លាំងបន្តិចដែរអំពីពន្ធដារ និងអគ្គិសនីធៀបនឹងក្រុមហ៊ុនសេវាកម្ម និងក្រុមហ៊ុនដំណើរការយឺតយ៉ាវ ប៉ុន្តែមិនសូវមានការព្រួយបារម្ភអំពីក្រុមហ៊ុនក្រៅផ្លូវការទេ។

**ផ្អែកនៅលើផ្សេងទៀតនៃអត្ថបទផ្តោតពិសេសនេះ ពិនិត្យមើលយ៉ាងជិតដល់ទៅលើឧបសគ្គខាងក្រៅ និងការិយាធិបតេយ្យក្នុងការធ្វើអាជីវកម្ម។** ឧបសគ្គខាងក្រៅប៉ះពាល់ដល់ក្រុមហ៊ុនដោយប្រយោល ខណៈដែលឧបសគ្គការិយាធិបតេយ្យនិង

**រូប S.៥ ៖ ចំណាត់ថ្នាក់ឧបសគ្គក្នុងការធ្វើអាជីវកម្មក្នុងប្រទេសកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់**

ធំទាំង 5 | ក្រោមទាំង 5 | ខាងក្រៅ | ការិយាធិបតេយ្យ | អាក្រក់ | ប្រសើរ

| **ឧបសគ្គនៅថ្ងៃនេះ** ចំណែកក្រុមហ៊ុនកម្ពុជាដែលជ្រើសរើសប្រធានបទនេះថាជាឧបសគ្គ ( % ), ឆ្នាំ2023 | | **ឧបសគ្គធំបំផុតនៅថ្ងៃនេះ** ចំណែកក្រុមហ៊ុនកម្ពុជាដែលជ្រើសរើសប្រធានបទនេះថាជាឧបសគ្គធំបំផុត ( % ), ឆ្នាំ2023 | | **ប្រៀបធៀបឧបសគ្គកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់** ភាពខុសគ្នានៃចំណែកក្រុមហ៊ុនដែលជ្រើសរើសប្រធានបទនេះថាជាឧបសគ្គ, ពិន្ទុភាគរយ, ឆ្នាំ2022/23 | | **ឧបសគ្គទៅតាមពេលវេលា** ភាពខុសគ្នានៃចំណែកក្រុមហ៊ុនកម្ពុជាដែលជ្រើសរើសនេះជាឧបសគ្គ, ពិន្ទុភាគរយ, ឆ្នាំ2023 ធៀបឆ្នាំ2016 | |
|---|---|---|---|---|---|---|---|
| វិស័យក្រៅប្រព័ន្ធ | 78% | វិស័យក្រៅប្រព័ន្ធ | 42% | តុលាការ | 39% | វិស័យក្រៅប្រព័ន្ធ | 6% |
| អត្រាពន្ធដារ | 68% | អត្រាពន្ធដារ | 32% | អំពើពុករលួយ | 26% | អត្រាពន្ធដារ | 6% |
| អំពើពុករលួយ | 57% | រដ្ឋបាលសារពើពន្ធ | 9% | អត្រាពន្ធដារ | 21% | តុលាការ | 2% |
| តុលាការ | 57% | ដឹកជញ្ជូន | 6% | វិស័យក្រៅប្រព័ន្ធ | 18% | អគ្គិសនី | 1% |
| រដ្ឋបាលសារពើពន្ធ | 52% | បទឧក្រិដ្ឋ | 4% | បទឧក្រិដ្ឋ | 17% | បទប្បញ្ញត្តិការងារ | -2% |
| ដឹកជញ្ជូន | 48% | អគ្គិសនី | 2% | បទប្បញ្ញត្តិពាណិជ្ជកម្ម | 15% | អំពើពុករលួយ | -9% |
| ឯកសារអាជីវកម្ម | 48% | បទប្បញ្ញត្តិពាណិជ្ជកម្ម | 2% | រដ្ឋបាលសារពើពន្ធ | 14% | រដ្ឋបាលសារពើពន្ធ | -9% |
| អស្ថិរភាពនយោបាយ | 45% | តុលាការ | 1% | ឯកសារអាជីវកម្ម | 14% | ការអប់រំរបស់កម្លាំងពលកម្ម | -10% |
| បទឧក្រិដ្ឋ | 45% | ដីធ្លី | 1% | អស្ថិរភាពនយោបាយ | 14% | អស្ថិរភាពនយោបាយ | -14% |
| អគ្គិសនី | 43% | ឯកសារអាជីវកម្ម | 1% | បទប្បញ្ញត្តិការងារ | 10% | ឯកសារអាជីវកម្ម | -18% |
| បទប្បញ្ញត្តិពាណិជ្ជកម្ម | 41% | បទប្បញ្ញត្តិការងារ | 0% | ដឹកជញ្ជូន | 4% | ដឹកជញ្ជូន | -18% |
| ការអប់រំរបស់កម្លាំងពលកម្ម | 39% | ការអប់រំរបស់កម្លាំងពលកម្ម | 0% | ការអប់រំរបស់កម្លាំងពលកម្ម | 1% | បទប្បញ្ញត្តិពាណិជ្ជកម្ម | -21% |
| បទប្បញ្ញត្តិការងារ | 38% | ហិរញ្ញវត្ថុ | 0% | ដីធ្លី | 1% | បទឧក្រិដ្ឋ | -23% |
| ដីធ្លី | 38% | អំពើពុករលួយ | 0% | ហិរញ្ញវត្ថុ | -8% | ដីធ្លី | -28% |
| ហិរញ្ញវត្ថុ | 37% | អស្ថិរភាពនយោបាយ | 0% | បទប្បញ្ញត្តិអគ្គិសនី | -13% | ហិរញ្ញវត្ថុ | -28% |

*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសបង់ក្លាដែស* (ឆ្នាំ២០២២) កម្ពុជា (ឆ្នាំ២០១៦ និងឆ្នាំ២០២៣) ហ្វីលីពីន (ឆ្នាំ២០២៣) និងវៀតណាម (ឆ្នាំ២០២៣), ធនាគារពិភពលោក។

*ចំណាំ៖ ក្រុមប្រទេសក្នុងតំបន់រួមមានប្រទេសបង់ក្លាដែស* ហ្វីលីពីន និងវៀតណាម។

22 ធនាគារពិភពលោក ឆ្នាំ២០២៤d។

អភិបាលកិច្ចវិញ ប៉ះពាល់ដោយផ្ទាល់ដល់ក្រុមហ៊ុននៅពេលពួកគេប្រាស្រ័យទាក់ទងជាមួយមន្ត្រីរដ្ឋាភិបាល និងរៀបចំដំណើរការនិងអនុលោមតាមច្បាប់។ ឧបសគ្គធំៗចំនួនបីក្នុងចំណោម “ឧបសគ្គធំៗ” ទាំងប្រាំក្នុងការធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជាគឺជាឧបសគ្គខាងក្រៅ (រូប S.៥ ខាងលើ) ខណៈដែលឧបសគ្គធំទាំងបួនក្នុងចំណោម “ឧបសគ្គ” ធំទាំងប្រាំគឺការិយាធិបតេយ្យ។ ផ្នែកពីរបន្ទាប់នៃអត្ថបទផ្តោតពិសេសនេះ ស្វែងយល់ពីឧបសគ្គខាងក្រៅ និងឧបសគ្គការិយាធិបតេយ្យនៅក្នុងការធ្វើអាជីវកម្មនៅកម្ពុជាឱ្យបានលម្អិតបន្ថែមទៀត។

# IV. ឧបសគ្គខាងក្រៅចំពោះការធ្វើអាជីវកម្ម

**ផ្នែកនេះស្វែងយល់ពីឧបសគ្គខាងក្រៅចំនួនបួនចំពោះការធ្វើអាជីវកម្ម៖** (ក) ការប្រកួតប្រជែងជាមួយក្រុមហ៊ុនក្រៅផ្លូវការ (ខ) ហេដ្ឋារចនាសម្ព័ន្ធ (ដឹកជញ្ជូន អគ្គិសនី និងសេវាអ៊ិនធឺណិត) (គ) លទ្ធភាពទទួលបានជំនាញ និង (ឃ) លទ្ធភាពទទួលបានហិរញ្ញវត្ថុ។

## *ក. ក្រុមហ៊ុនក្រៅផ្លូវការ*

**ក្រុមហ៊ុននៅកម្ពុជាភាគច្រើន កំពុងប្រកួតប្រជែងជាមួយក្រុមហ៊ុនក្រៅផ្លូវការ ហើយចាត់ទុកបញ្ហានេះថាជាឧបសគ្គចម្បងរបស់ពួកគេក្នុងការធ្វើអាជីវកម្ម។** នៅឆ្នាំ២០២៣ ក្រុមហ៊ុនកម្ពុជាចំនួន ៨៥ភាគរយបានរាយការណ៍ថា ពួកគេកំពុងប្រកួតប្រជែងជាមួយនឹងក្រុមហ៊ុនក្រៅផ្លូវការឬក្រុមហ៊ុនមិនចុះបញ្ជី ដែលមានចាប់ពី ៧២ភាគរយក្នុងចំណោមក្រុមហ៊ុន “កម្មន្តសាលផ្សេងទៀត” ដល់ ៩៦ភាគរយក្នុងចំណោមក្រុមហ៊ុនកាត់ដេរ ដែលវាមិនគួរឱ្យភ្ញាក់ផ្អើលទេដោយសារភាពមិនផ្លូវការរីករាលដាលនៅទូទាំងសេដ្ឋកិច្ចកម្ពុជា។ ជាងនេះទៅទៀត ក្រុមហ៊ុនកម្ពុជាមើលឃើញយ៉ាងលើសលុបថាការប្រកួតប្រជែងជាមួយក្រុមហ៊ុនក្រៅផ្លូវការថាជារឿងអយុត្តិធម៌ ដោយ “ការអនុវត្តរបស់ក្រុមហ៊ុនជាគូប្រកួតប្រជែងមកពីវិស័យក្រៅប្រព័ន្ធ” គឺជាឧបសគ្គដែលត្រូវបានលើកឡើងច្រើនបំផុត (៧៨ភាគរយនៃក្រុមហ៊ុន) និងឧបសគ្គដ៏ធំបំផុត (៤២ភាគរយ) ក្នុងការធ្វើអាជីវកម្ម (រូប S.៥ ខាងលើ)។ លើសពីនេះ ក្តីបារម្ភអំពីវិស័យក្រៅប្រព័ន្ធ បានកើនឡើងពីពេលមួយទៅពេលមួយ និងបានក្លាយជាក្តីកង្វល់កាន់តែខ្លាំងសម្រាប់ក្រុមហ៊ុនកម្ពុជាបើធៀបនឹងក្រុមហ៊ុននៅក្រៅប្រទេស។

**ក្រៅពីនេះ ការព្រួយបារម្ភអំពីក្រុមហ៊ុនក្រៅផ្លូវការជាធម្មតាមានភាពស្រួចស្រាលខ្លាំងជាងចំពោះក្រុមហ៊ុនតូច និងមិនសូវទំនើប ដែលទំនងជាមានការប្រកួតប្រជែងដោយផ្ទាល់ជាមួយពួកគេ (រូប S.៧)។** ការអនុវត្តរបស់ក្រុមហ៊ុនក្រៅផ្លូវការ បង្កឱ្យមានការព្រួយបារម្ភកាន់តែខ្លាំងសម្រាប់ក្រុមហ៊ុនដែលមានទីតាំងនៅខាងក្រៅរដ្ឋធានីភ្នំពេញ ជាពិសេសសម្រាប់ក្រុមហ៊ុនដែលមានទីតាំងនៅតំបន់វាលទំនាប (៥៣ភាគរយ)។ វិស័យក្រៅប្រព័ន្ធក៏ជាការព្រួយបារម្ភខ្លាំងផងដែរចំពោះក្រុមហ៊ុនដំណើរការយឺតយ៉ាវ (៦៨ភាគរយ) ក្រុមហ៊ុនបដិសណ្ឋារកិច្ច (៥១ភាគរយ) ក្រុមហ៊ុនលក់រាយ (៥០ភាគរយ) ក្រុមហ៊ុនធុនតូច (៤៧ភាគរយ) និងក្រុមហ៊ុនផ្តោតលើទីផ្សារក្នុងស្រុក (៤៥ភាគរយ) ។ ផ្ទុយទៅវិញ ក្រុមហ៊ុនក្រៅផ្លូវការមិនសូវមានការព្រួយបារម្ភលើយសម្រាប់ក្រុមហ៊ុនកម្មន្តសាល (ជាពិសេសក្រុមហ៊ុនកាត់ដេរ) ក្រុមហ៊ុនកាន់

**រូប S.៦ ៖ ចំណាត់ថ្នាក់ឧបសគ្គក្នុងការធ្វើអាជីវកម្មនៅកម្ពុជាផ្អែកតាមលក្ខណៈក្រុមហ៊ុន**

អាក្រក់ ប្រសើរ

| **ក្រុមហ៊ុនមានតាំងនៅតំបន់ភ្នំ** ភាពខុសគ្នានៃចំណែកក្រុមហ៊ុនដែលជ្រើសរើសថាជាឧបសគ្គធៀបនឹងក្រុមហ៊ុននៅភ្នំពេញ, ពិន្ទុភាគរយ | | **ក្រុមហ៊ុនធុនមធ្យម** ភាពខុសគ្នានៃចំណែកក្រុមហ៊ុនដែលជ្រើសរើសថាជាឧបសគ្គធៀបនឹងក្រុមហ៊ុនតូច, ពិន្ទុភាគរយ | | **ក្រុមហ៊ុនកម្មន្តសាល** ភាពខុសគ្នានៃចំណែកក្រុមហ៊ុនដែលជ្រើសរើសថាជាឧបសគ្គធៀបនឹងក្រុមហ៊ុនសេវាកម្ម, ពិន្ទុភាគរយ | | **ក្រុមហ៊ុនឈានមុខគេ** ភាពខុសគ្នានៃចំណែកក្រុមហ៊ុនដែលជ្រើសរើសថាជាឧបសគ្គធៀបនឹងក្រុមហ៊ុនដំណើរការយឺតយ៉ាវ, ពិន្ទុភាគរយ | |
|---|---|---|---|---|---|---|---|
| អស្ថិរភាពនយោបាយ | 36% | បទឧក្រិដ្ឋ | 31% | រដ្ឋបាលសារពើពន្ធ | 20% | រដ្ឋបាលសារពើពន្ធ | 9% |
| អគ្គិសនី | 33% | លទ្ធភាពទទួលបានដីធ្លី | 26% | អគ្គិសនី | 17% | អគ្គិសនី | 5% |
| ឯកសារអាជីវកម្ម | 30% | លទ្ធភាពទទួលបានហិរញ្ញវត្ថុ | 26% | អត្រាពន្ធដារ | 10% | បទឧក្រិដ្ឋ | 4% |
| រដ្ឋបាលសារពើពន្ធ | 29% | រដ្ឋបាលសារពើពន្ធ | 25% | អស្ថិរភាពនយោបាយ | 8% | អត្រាពន្ធដារ | 2% |
| លទ្ធភាពទទួលបានហិរញ្ញវត្ថុ | 28% | អគ្គិសនី | 25% | បទឧក្រិដ្ឋ | 7% | ដឹកជញ្ជូន | 1% |
| ការអប់រំរបស់កម្លាំងពលកម្ម | 27% | បទប្បញ្ញត្តិការងារ | 25% | ដឹកជញ្ជូន | 7% | បទប្បញ្ញត្តិពាណិជ្ជកម្ម | 1% |
| លទ្ធភាពទទួលបានដីធ្លី | 27% | ការអប់រំរបស់កម្លាំងពលកម្ម | 24% | ឯកសារអាជីវកម្ម | 5% | ដីធ្លី | 1% |
| បទប្បញ្ញត្តិពាណិជ្ជកម្ម | 27% | ដឹកជញ្ជូន | 24% | ការអប់រំរបស់កម្លាំងពលកម្ម | 4% | អស្ថិរភាពនយោបាយ | 0% |
| បទឧក្រិដ្ឋ | 26% | ឯកសារអាជីវកម្ម | 23% | លទ្ធភាពទទួលបានដីធ្លី | 4% | បទប្បញ្ញត្តិការងារ | 0% |
| អត្រាពន្ធដារ | 26% | បរិយាកាសបទប្បញ្ញត្តិ | 22% | លទ្ធភាពទទួលបានហិរញ្ញវត្ថុ | 4% | អំពើពុករលួយ | 0% |
| បទប្បញ្ញត្តិការងារ | 26% | អំពើពុករលួយ | 21% | បទប្បញ្ញត្តិការងារ | 4% | ឯកសារអាជីវកម្ម | 0% |
| ដឹកជញ្ជូន | 21% | តុលាការ | 19% | បរិយាកាសបទប្បញ្ញត្តិ | 4% | តុលាការ | 0% |
| អំពើពុករលួយ | 18% | អស្ថិរភាពនយោបាយ | 18% | អំពើពុករលួយ | 4% | ហិរញ្ញវត្ថុ | 0% |
| តុលាការ | 16% | អត្រាពន្ធដារ | 12% | តុលាការ | -1% | ការអប់រំរបស់កម្លាំងពលកម្ម | -2% |
| ក្រុមហ៊ុនក្រៅផ្លូវការ | 12% | វិស័យក្រៅប្រព័ន្ធ | 1% | ក្រុមហ៊ុនក្រៅផ្លូវការ | -12% | ក្រុមហ៊ុនក្រៅផ្លូវការ | -22% |

*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសកម្ពុជា* (ឆ្នាំ២០២៣), ធនាគារពិភពលោក។

តែធំនិងក្រុមហ៊ុនផ្តោតលើការនាំចេញ និងក្រុមហ៊ុនដែលមានមូលដ្ឋាននៅទីក្រុងភ្នំពេញ។ តួរទាំងនេះបង្ហាញថា អត្ថប្រយោជន៍នៃការចុះបញ្ជីអាចមិនមានតម្លៃសម្រាប់ក្រុមហ៊ុនតូចៗ និងមិនសូវទំនើបជាច្រើនដែលស្ថិតក្នុងការប្រកួតប្រជែងដោយផ្ទាល់ជាមួយក្រុមហ៊ុនក្រៅផ្លូវការ ដែលទំនងជាបង្កើតឱ្យមានការមិនលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនក្នុងការបង្កើតជាក្រុមហ៊ុនផ្លូវការ។

## ខ. ហេដ្ឋារចនាសម្ព័ន្ធ

**ក្រុមហ៊ុនកម្ពុជាមានការព្រួយបារម្ភគួរសមអំពីហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដោយការដឹកជញ្ជូនគឺជាក្តីបារម្ភខ្លាំងបំផុត (រូប S.៩ ខាងលើ)។** ការដឹកជញ្ជូនគឺជាឧបសគ្គដែលត្រូវបានលើកឡើងច្រើនបំផុតទីប្រាំមួយក្នុងការធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា (៤៨ភាគរយនៃក្រុមហ៊ុន) ហើយនៅតែជាកង្វល់ធំជាងធៀបនឹងប្រទេសក្នុងតំបន់ បើទោះបីជាមានភាពប្រសើរឡើងក៏ដោយ។ លើសពីនេះ អគ្គិសនីគឺជាឧបសគ្គដែលត្រូវបានលើកឡើងច្រើនបំផុតទីដប់ សម្រាប់ក្រុមហ៊ុនកម្ពុជា (៤៣ភាគរយ) ប៉ុន្តែមានការព្រួយបារម្ភតិចជាងខ្លាំងធៀបនឹងប្រទេសក្នុងតំបន់។ សេវាអ៊ិនធឺណេតក្នុងប្រទេសកម្ពុជាហាក់ដូចជាអាចប្រៀបធៀបទៅនឹងប្រទេសក្នុងតំបន់បាន ដោយក្រុមហ៊ុនកម្ពុជាចំនួន ៨៨ភាគរយមានអ៊ិនធឺណិតប្រើប្រាស់ (ធៀបនឹង ៨៤ភាគរយក្នុងចំណោមប្រទេសក្នុងតំបន់) ហើយ ៣៦ភាគរយជួបប្រទះការអាក់ខានសេវាអ៊ិនធឺណិត (ដូចទៅនឹងប្រទេសក្នុងតំបន់ដែរ)។ កត្តាជំរុញសំខាន់ៗដែលបង្កឱ្យមានការបារម្ភអំពីហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានទាំងនេះ រួមមានការតភ្ជាប់ផ្លូវថ្នល់និងផ្លូវដែកក្នុងស្រុកនិងអន្តរជាតិមិនល្អ ការកកស្ទះចរាចរណ៍កាន់តែខ្លាំងក្នុងរាជធានីភ្នំពេញ តម្លៃអគ្គិសនីខ្ពស់ ល្បឿនអ៊ិនធឺណិតយឺត និងសេវាឌីជីថលមិនល្អសម្រាប់សេវាសាធារណៈ[23]។

**ទោះជាយ៉ាងណា ក្តីបារម្ភអំពីហេដ្ឋារចនាសម្ព័ន្ធជាធម្មតាមានភាពធ្ងន់ធ្ងរជាងសម្រាប់ក្រុមហ៊ុនដែលមានទីតាំងនៅខេត្តតំបន់ភ្នំនៃប្រទេសកម្ពុជា និងសម្រាប់ក្រុមហ៊ុនស្ថិតនៅទីតាំងដែលហេដ្ឋារចនាសម្ព័ន្ធគឺជាធាតុចូលផលិតកម្មដ៏សំខាន់។** ការដឹកជញ្ជូនទំនងជាត្រូវបានលើកឡើងថាជាឧបសគ្គដោយក្រុមហ៊ុនដែលមានទីតាំងនៅតំបន់ភ្នំនៃប្រទេសកម្ពុជា (៧៩ភាគរយ) និងក្រុមហ៊ុនធុនមធ្យម (៦៨ភាគរយ) និងក្រុមហ៊ុនដែលត្រូវតែផ្លាស់ទីទំនិញរូបវន្តដូចជាក្រុមហ៊ុនលក់រាយ (៥៦ភាគរយ) និងក្រុមហ៊ុនកាត់ដេរ (៥៦ភាគរយ)។ មានខុសគ្នាកាន់តែខ្លាំងទាក់ទងនឹងការព្រួយបារម្ភអំពីអគ្គិសនី (រូប S.៨)។ អគ្គិសនីទំនងជាត្រូវបានលើកឡើងថាជាឧបសគ្គដោយក្រុមហ៊ុនដែលមានទីតាំងនៅតំបន់ភ្នំនៃប្រទេសកម្ពុជា (៨០ភាគរយ) ជាទីដែលសេវាអគ្គិសនីនៅខ្សោយជាង។ ទោះជាយ៉ាងណា អគ្គិសនីក៏ជាកង្វល់សម្រាប់ក្រុមហ៊ុនកម្មន្តសាល (៥៧ភាគរយ) ជាពិសេសក្រុមហ៊ុនកាត់ដេរសម្លៀកបំពាក់ (៧៥ភាគរយ) ដែលពឹងផ្អែកលើអគ្គិសនីដើម្បីដំណើរការប្រតិបត្តិការរបស់ពួកគេ និងជាធម្មតាជាក្រុមហ៊ុនធំជាង និងផ្តោតលើការនាំចេញ[24]។ ជាចុងក្រោយ ក្រុមហ៊ុនកាត់ដេរក៏ទំនងកាន់តែខ្លាំងក្នុងការរាយការណ៍ពីការអាក់ខានសេវាកម្មអ៊ិនធឺណិត (៥១ភាគរយ)។

**រូប S.៧ ៖ ឧបសគ្គវិស័យក្រៅប្រព័ន្ធនៅកម្ពុជាផ្អែកតាមលក្ខណៈក្រុមហ៊ុន**

**ចំណែកក្រុមហ៊ុនកម្ពុជាដែលជ្រើសរើសអគ្គិសនីថាជាឧបសគ្គក្នុងការធ្វើអាជីវកម្ម (%), ឆ្នាំ2023**




*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសកម្ពុជា* (ឆ្នាំ២០២៣), ធនាគារពិភពលោក។

23 របាយការណ៍ស្តីពី បច្ចុប្បន្នភាពការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ ជំនាន់ទីពីររបស់ប្រទេសកម្ពុជា (ធនាគារពិភពលោក ឆ្នាំ២០២៤) និង របាយការណ៍ B-Ready (ធនាគារពិភពលោក ឆ្នាំ២០២៤d)។

24 មានទំនាក់ទំនងខ្លាំងរវាងក្រុមហ៊ុនកាត់ដេរ សហគ្រាសធំៗ និងក្រុមហ៊ុនផ្តោតលើការចេញនៅកម្ពុជា។

## គ. លទ្ធភាពទទួលបានជំនាញ

**ខណៈពេលដែលក្រុមហ៊ុនកម្ពុជាភាគច្រើនមិនមានការព្រួយបារម្ភខ្លាំងអំពីជំនាញកម្លាំងពលកម្ម (និងព្រួយបារម្ភតិចជាងប្រទេសក្នុងតំបន់) ជំនាញកម្លាំងពលកម្មក៏ជាក្តីបារម្ភធំមួយនៅក្នុងចំណោមក្រុមហ៊ុនធំៗ និងក្រុមហ៊ុនផ្តោតលើការនាំចេញរបស់កម្ពុជាផងដែរ (រូប S.៩)។** កម្លាំងការងារដែលមានការអប់រំមិនគ្រប់គ្រាន់គឺជាកង្វល់មួយក្នុងចំណោមកង្វល់តិចបំផុតទាំងប្រាំក្នុងចំណោមក្រុមហ៊ុនកម្ពុជា (៣៩ភាគរយនៃក្រុមហ៊ុនទាំងអស់លើកឡើងកត្តានេះថាជាឧបសគ្គ) ហើយការព្រួយបារម្ភទាំងនេះបានធ្លាក់ចុះ និងមានកម្រិតទាបជាងប្រទេសក្នុងតំបន់ភាគច្រើន (រូប S.៥ ខាងលើ)។ ទោះយ៉ាងណា មានភាពខុសគ្នាខ្លាំងទាក់ទងនឹងការព្រួយបារម្ភអំពីកម្រិតអប់រំកម្លាំងពលកម្មក្នុងចំណោមក្រុមហ៊ុននៅកម្ពុជា ដោយផ្អែកលើលក្ខណៈរបស់ក្រុមហ៊ុនទាំងនោះ។ ឧទាហរណ៍ ជំនាញកម្លាំងពលកម្មទំនងជាត្រូវបានចាត់ទុកថាជាឧបសគ្គមួយដោយក្រុមហ៊ុនដែលមានទីតាំងនៅតំបន់កាន់តែដាច់ស្រយាល តំបន់ភ្នំនៃប្រទេសកម្ពុជា (៧៣ភាគរយ) ជាទីដែលលទ្ធភាពទទួលបានការសិក្សាមានភាពខ្សត់ខ្សោយជាង។ ជាងនេះទៅទៀត ជំនាញក៏ទំនងជាខ្លាំងត្រូវបានចាត់ទុកថាជាឧបសគ្គដោយក្រុមហ៊ុនធុនមធ្យម (៥៩ភាគរយ) ក្រុមហ៊ុនកាត់ដេរ (៥៧ភាគរយ) ក្រុមហ៊ុនផ្តោតលើការនាំចេញ (៥០ភាគរយ) ក្រុមហ៊ុនធំ (៤៨ភាគរយ) និងក្រុមហ៊ុនដែលមានទីតាំងនៅក្នុងរាជធានី (៤៦ភាគរយ)។ ភាពចម្រុះនៃការយល់ឃើញរបស់ក្រុមហ៊ុននេះបង្ហាញថា ជំនាញពិតជាក្តីបារម្ភខ្លាំងមួយសម្រាប់ក្រុមហ៊ុនមួយចំនួនដែលទំនងជាស្ថិតនៅក្នុងចំណោមក្រុមហ៊ុនទំនើបជាងនៅក្នុងប្រទេសកម្ពុជា។ ការរកឃើញនេះក៏មានភាពស្របគ្នាជាមួយនឹងការស្រាវជ្រាវកន្លងមកផងដែរដែលបានរកឃើញថាក្រុមហ៊ុនធំៗនៅកម្ពុជា (ក៏ដូចជាមន្ត្រីរដ្ឋាភិបាល) ចាត់ទុកការអប់រំនិងជំនាញថាជាកង្វល់កាន់តែខ្លាំង និងជាឧបសគ្គធំបំផុតចំពោះការអភិវឌ្ឍរបស់ប្រទេសកម្ពុជាក្នុងរយៈពេលប្រាំឆ្នាំខាងមុខ[25]។

**ក្រៅពីនេះ ជាក់ស្តែងក្រុមហ៊ុននៅកម្ពុជាទំនងជាមិនសូវមានកម្មករជំនាញទេធៀបនឹងប្រទេសក្នុងតំបន់ (រូប S.១០) ដោយសារតែតួនាទីរបស់ក្រុមហ៊ុនទាំងនេះស្ថិតនៅចំណុចដែលមានជំនាញទាបនៃខ្សែច្រវាក់តម្លៃ។** ចំណែកជាមធ្យមនៃបុគ្គលិកពេញម៉ោងក្នុងចំណោមក្រុមហ៊ុនកម្ពុជា ដែលបានបញ្ចប់ថ្នាក់វិទ្យាល័យគឺ ៦៩ភាគរយ ដែលមានភាពប្រសើរឡើងធៀបនឹងឆ្នាំ២០១៦ (៦១ភាគរយ) ប៉ុន្តែនៅតែទាបជាងប្រទេសវៀតណាម (៩០ភាគរយ) និងហ្វីលីពីន (៨៧ភាគរយ) ។ លើសពីនេះ បុគ្គលិកជនជាតិកម្ពុជាតែ ៣៣ភាគរយប៉ុណ្ណោះត្រូវបានចាត់ថ្នាក់ថាមាន "ជំនាញខ្ពស់" ពោលគឺទាបជាងកម្រិតមធ្យមនៃប្រទេសក្នុងតំបន់ដែលមាន ៤៤ភាគរយ។ គម្លាតរវាងការយល់ឃើញនិងការពិតក្នុងចំណោមក្រុមហ៊ុននៅកម្ពុជាឆ្លុះបញ្ចាំងថាក្រុមហ៊ុនភាគច្រើនស្ថិតនៅក្នុងផ្នែកនិងខ្សែច្រវាក់តម្លៃ ដែលពឹងផ្អែកជាចម្បងលើកម្មករជំនាញទាប។ ម៉្យាងវិញទៀត ក្រុមហ៊ុននៅកម្ពុជាភាគច្រើនជាប់គាំងនៅក្នុងស្ថានភាពមួយដែលមានជំនាញទាបនិងប្រាក់ឈ្នួលទាប ហើយវិនិយោគិនបរទេសជាច្រើនគ្រាន់តែមកកម្ពុជាដើម្បីទាញយកអត្ថប្រយោជន៍ពីស្ថានភាពនេះតែប៉ុណ្ណោះ (ជាពិសេសផ្នែកកម្មន្តសាល)។ ទីបំផុត កម្ពុជាចាំបាច់ត្រូវផ្លាស់ប្តូរទៅជាប្រទេសដែលមានជំនាញខ្ពស់ និងប្រាក់ខែខ្ពស់ ដើម្បីក្លាយជាប្រទេសមានប្រាក់ចំណូលខ្ពស់។

**រូប S.៨ ៖ ឧបសគ្គអគ្គិសនីនៅកម្ពុជាផ្អែកតាមលក្ខណៈក្រុមហ៊ុន**

**ចំណែកក្រុមហ៊ុនកម្ពុជាដែលជ្រើសរើសអគ្គិសនីថាជាឧបសគ្គក្នុងការធ្វើអាជីវកម្ម (%), ឆ្នាំ2023**




*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសកម្ពុជា* (ឆ្នាំ២០២៣), ធនាគារពិភពលោក។

25 របាយការណ៍ស្តីពី បច្ចុប្បន្នភាពការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ ជំនាន់ទីពីររបស់ប្រទេសកម្ពុជា (ធនាគារពិភពលោក ឆ្នាំ២០២៤)

**រូប ៦.៩ ៖ ឧបសគ្គជំនាញក្នុងចំណោមក្រុមហ៊ុនកម្ពុជាផ្អែកតាមលក្ខណៈក្រុមហ៊ុន**

**ចំណែកក្រុមហ៊ុនកម្ពុជាដែលជ្រើសរើសកម្លាំងពលកម្មដែលមានការអប់រំមិនគ្រប់គ្រាន់ថាជាឧបសគ្គក្នុងការធ្វើអាជីវកម្ម (%), ឆ្នាំ2023**




*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសកម្ពុជា (ឆ្នាំ២០២៣), ធនាគារពិភពលោក។*

**រូប ៦.១០ ៖ សង្ខេបអំពីលក្ខណៈអប់រំរបស់កម្លាំងពលកម្មក្នុងចំណោមក្រុមហ៊ុនកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់**




*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសបង់ក្លាដែស (ឆ្នាំ២០២២) កម្ពុជា (ឆ្នាំ២០១៦ និងឆ្នាំ២០២៣) ហ្វីលីពីន (ឆ្នាំ២០២៣) និងវៀតណាម (ឆ្នាំ២០២៣), ធនាគារពិភពលោក។*

*ចំណាំ៖ ក្រុមប្រទេសក្នុងតំបន់រួមមានប្រទេសបង់ក្លាដែស ហ្វីលីពីន និងវៀតណាម។*

## ឃ. លទ្ធភាពទទួលបានហិរញ្ញវត្ថុ

**ក្រុមហ៊ុននៅកម្ពុជាភាគច្រើនក៏មិនមានការព្រួយបារម្ភខ្លាំងទេអំពីលទ្ធភាពទទួលបានហិរញ្ញវត្ថុ (និងបារម្ភតិចជាងប្រទេសក្នុងតំបន់) បើទោះបីជាកត្តានេះគឺជាក្ដីបារម្ភធំមួយក្នុងចំណោមក្រុមហ៊ុនធំៗ និងក្រុមហ៊ុនទំនើបនៅកម្ពុជាក៏ដោយ។** លទ្ធភាពទទួលបានហិរញ្ញវត្ថុគឺជាក្ដីបារម្ភទាបបំផុតសម្រាប់ក្រុមហ៊ុនកម្ពុជា (ក្រុមហ៊ុន ៣៧ភាគរយលើកឡើងថាជាឧបសគ្គ) ហើយការព្រួយបារម្ភទាំងនេះបានធ្លាក់ចុះយ៉ាងខ្លាំង និងមានកម្រិតទាបជាងប្រទេសក្នុងតំបន់ (រូប ៦.៥ ខាងលើ)។ កង្វះក្ដីបារម្ភអំពីលទ្ធភាពទទួលបានហិរញ្ញវត្ថុ ប្រហែលជាមិនគួរឱ្យភ្ញាក់ផ្អើលទេ ដោយសារការកើនឡើងឥណទាននៅក្នុងប្រទេសកម្ពុជាក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធភាពទទួលបានហិរញ្ញវត្ថុទំនងជាត្រូវបានលើកឡើងថាជាឧបសគ្គមួយដោយក្រុមហ៊ុនដែលមានទីតាំងនៅតំបន់កាន់តែដាច់ស្រយាល តំបន់ភ្នំនៃប្រទេសកម្ពុជា (៧៣ភាគរយ) ជាទីដែលសេវាហិរញ្ញវត្ថុនៅមានកម្រិត។ ជាងនេះ

ទៀត សេវាហិរញ្ញវត្ថុក៏ទំនងកាន់តែខ្លាំងត្រូវបានលើកឡើងថាជាឧបសគ្គមួយដោយក្រុមហ៊ុនធុនមធ្យម (៥៩ភាគរយ) ក្រុមហ៊ុនកាត់ដេរ (៥៤ភាគរយ) ក្រុមហ៊ុនផ្តោតលើការនាំចេញ (៤៧ភាគរយ) ក្រុមហ៊ុនធំ (៤៥ភាគរយ) និងក្រុមហ៊ុនដែលមានទីតាំងនៅរាជធានីភ្នំពេញ (៤៥ភាគរយ)។ ភាពចម្រុះនៃការយល់ឃើញរបស់ក្រុមហ៊ុននេះបង្ហាញថា លទ្ធភាពទទួលបានហិរញ្ញវត្ថុតាមពិតអាចជាកង្វល់ដ៏ធំមួយសម្រាប់ក្រុមហ៊ុនមួយចំនួនដែលទំនងជាស្ថិតក្នុងចំណោមក្រុមហ៊ុនទំនើបជាងនេះរបស់ប្រទេសកម្ពុជា។

**លើសពីនេះទៀត ក្រុមហ៊ុនកម្ពុជាជាក់ស្តែងទំនងជាប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុទាបជាងប្រទេសក្នុងតំបន់ ហើយជាលទ្ធផលមានអនុបាតបំណុលទាបជាង (រូប S.១១, ក្រាហ្វិក ក)។** មានតែក្រុមហ៊ុនកម្ពុជាចំនួន ១៤ភាគរយប៉ុណ្ណោះដែលមានកម្រិតបន្ទាត់ឥណទាន ឬកម្ចីពីគ្រឹះស្ថានហិរញ្ញវត្ថុ ពោលគឺទាបជាង ១៩ពិន្ទុភាគរយធៀបនឹងកម្រិតជាមធ្យមនៃប្រទេសក្នុងតំបន់ដែលមាន ៣៣ភាគរយ។ ជាលទ្ធផល ក្រុមហ៊ុនកម្ពុជាក៏មានអនុបាតបំណុលជាមធ្យមត្រឹមតែ ៣ភាគរយប៉ុណ្ណោះ ពោលគឺទាបជាង ១៤ពិន្ទុភាគរយធៀបនឹងកម្រិតជាមធ្យមដែលមាន ១៧ភាគរយ។ ករណីនេះហាក់មានភាពផ្ទុយគ្នាបន្តិចបន្តួចក្នុងពេលមានកំណើនឥណទាន និងដោយសារថា

**រូប S.១១ ៖ ភាពខុសគ្នានៃលទ្ធភាពទទួលហិរញ្ញវត្ថុក្នុងចំណោមក្រុមហ៊ុនកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់ តាមវិស័យ**

*ក្រាហ្វិក ក*




*ក្រាហ្វិក ខ*




*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសបង់ក្លាដែស* (ឆ្នាំ២០២២) កម្ពុជា (ឆ្នាំ២០១៦ និងឆ្នាំ២០២៣) ហ្វីលីពីន (ឆ្នាំ២០២៣) និងវៀតណាម (ឆ្នាំ២០២៣), ធនាគារពិភពលោក។

*ចំណាំ៖ ក្រុមប្រទេសក្នុងតំបន់រួមមានប្រទេសបង់ក្លាដែស* ហ្វីលីពីន និងវៀតណាម។

ក្រុមហ៊ុនភាគច្រើននិយាយថា ពួកគេមិនមានការព្រួយបារម្ភអំពីលទ្ធភាពទទួលបានហិរញ្ញវត្ថុនោះទេ។ ក៏មានភាពខុសគ្នាខ្លាំងផងដែរក្នុងការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ (និងអនុបាតបំណុល) តាមវិស័យ (រូប S.១១, ក្រាហ្វិក ខ) ហើយដូចដែលបានរំពឹងទុក មានទំនាក់ទំនងអវិជ្ជមានរវាងក្តីបារម្ភអំពីអត្រាលទ្ធផលទទួលបាន និងអត្រាប្រើប្រាស់។ ឧទាហរណ៍ ក្រុមហ៊ុនកាត់ដេរដែលមានការព្រួយបារម្ភខ្លាំងបំផុតអំពីលទ្ធភាពទទួលបានហិរញ្ញវត្ថុទំនងថាមានកម្រិតបន្ទាត់ឥណទានតិចតួចបំផុត (២ភាគរយ) និងមានអនុបាតបំណុលជាមធ្យមទាបបំផុត (០,៥ភាគរយ)។

# V. ឧបសគ្គការិយាល័យធិបតេយ្យចំពោះការធ្វើអាជីវកម្ម

**ផ្នែកនេះស្វែងយល់ពីកត្តាការិយាធិបតេយ្យ និងអភិបាលកិច្ចចំនួនបួន៖** (ក) ពន្ធដារ ទាំងអត្រាពន្ធ និងរដ្ឋបាលពន្ធដារ (ខ) អំពើពុករលួយនិងការចំណាយក្រៅផ្លូវការ (គ) តុលាការ រួមទាំង ឯករាជ្យភាពក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម និង (ឃ) ភាពទាន់ពេលវេលានៃការរៀបចំឯកសារអាជីវកម្មសំខាន់ៗ និងដំណើរការដែលផ្តល់ជូនដោយរដ្ឋាភិបាល។

## ក. ពន្ធដារ

**ក្រុមហ៊ុននៅកម្ពុជាភាគច្រើនចាត់ទុកពន្ធដារ រួមទាំងអត្រាពន្ធសារ និងរដ្ឋបាលពន្ធដារថាជាឧបសគ្គកំពូលក្នុងការធ្វើអាជីវកម្ម ជាពិសេសសម្រាប់ក្រុមហ៊ុនធំៗ ក្រុមហ៊ុនផ្តោតលើការនាំចេញ និងក្រុមហ៊ុនកម្មន្តសាល។** អត្រាពន្ធដារនិងរដ្ឋបាលពន្ធដារគឺជា “ឧបសគ្គធំជាងគេ” ទីពីរ និងទីបីសម្រាប់ការធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា និងបានក្លាយជាក្តីបារម្ភកាន់តែធំ ហើយអត្រាពន្ធដារគឺជាកង្វល់កាន់តែធំមួយសម្រាប់ក្រុមហ៊ុនកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់របស់ពួកគេ (រូប S.5, ខាងលើ)។ លើសពីនេះទៀត រដ្ឋបាលពន្ធដារទំនងជាខ្លាំងត្រូវបានចាត់ទុកថាជាឧបសគ្គក្នុងការធ្វើអាជីវកម្មដោយក្រុមហ៊ុនដែលស្ថិតនៅឆ្ងាយពីរាជធានីភ្នំពេញ (រូបភាព S.១២) និងក្រុមហ៊ុនកម្មន្តសាល (៦៧ភាគរយ) ជាពិសេសសម្លៀកបំពាក់ (៧៥ភាគរយ) ក្រុមហ៊ុនផ្តោតលើការនាំចេញ (៧៧ភាគរយ) ក្រុមហ៊ុនធំ (៧៤ភាគរយ) និងក្រុមហ៊ុនធុនមធ្យម (៧១ភាគរយ)។ ជាងនេះទៅទៀត រដ្ឋបាលពន្ធដារមានក្តីបារម្ភកាន់តែខ្លាំងសម្រាប់ ក្រុមហ៊ុនឈានមុខគេ (ដោយមាន ១៦ភាគរយលើកឡើងថា វាជាឧបសគ្គធំបំផុត)។ ផ្ទុយទៅវិញ រដ្ឋបាលពន្ធដារមិនសូវជាក្តីបារម្ភទេចំពោះក្រុមហ៊ុនសេវាកម្ម (ក្រៅពីក្រុមហ៊ុនលក់រាយ) ក្រុមហ៊ុនផ្តោតលើទីផ្សារក្នុងស្រុក និងក្រុមហ៊ុនធុនតូច។ ភាពខុសគ្នាប្រហាក់ប្រហែលគ្នាមួយពាក់ព័ន្ធនឹងអត្រាពន្ធក៏ត្រូវបានសង្កេតឃើញមានផងដែរក្នុងចំណោមក្រុមហ៊ុន។

**ក្តីបារម្ភអំពីគោលនយោបាយ និងរដ្ឋបាលពន្ធដារនៅក្នុងប្រទេសកម្ពុជា ហាក់ដូចជាត្រូវបានជំរុញដោយបន្ទុកនៃការអនុលោមតាមច្បាប់ដ៏ធ្ងន់និងចំណាយច្រើន រួមជាមួយនឹងការកើតមានខ្លាំងនៃការចំណាយក្រៅផ្លូវការជាជាង “អត្រាពន្ធដារ” ខ្លួនឯងផ្ទាល់។** អត្រាពន្ធលើប្រាក់ចំណូលសាជីវកម្មស្តង់ដារនៅកម្ពុជាមានអត្រា ២០ភាគរយ ដែលមានលក្ខណៈស្របគ្នាយ៉ាងទូលំទូលាយទៅនឹងអត្រាជាមធ្យមក្នុងតំបន់អាស៊ាន (២១ភាគរយ) វៀតណាម (២០ភាគរយ) បង់ក្លាដែស (២២,៥

**រូប S.១២ ៖ ឧបសគ្គរដ្ឋបាលពន្ធដារក្នុងចំណោមក្រុមហ៊ុនកម្ពុជាផ្អែកតាមលក្ខណៈក្រុមហ៊ុន**

**ចំណែកក្រុមហ៊ុនកម្ពុជាដែលជ្រើសរើសរដ្ឋបាលសារពើពន្ធថាជាឧបសគ្គក្នុងការធ្វើអាជីវកម្ម (%), ឆ្នាំ2023**




*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសកម្ពុជា* (ឆ្នាំ២០២៣), ធនាគារពិភពលោក។

*ចំណាំ៖ *តួលេខសម្រាប់ឧបសគ្គ* ៉ធំបំផុត៉ ក្នុងការធ្វើអាជីវកម្មត្រូវបានបង្ហាញ (ជំនួសឱ្យតួលេខសម្រាប់ឧបសគ្គ ៉មួយ៉) ។

ភាគរយ) និងហ្វីលីពីន (២៥ភាគរយ)[26]។ ផ្ទុយទៅវិញ រដ្ឋបាលសារពើពន្ធមានភាពស្មុគស្មាញនិងចំណាយច្រើន (ទាក់ទងនឹងពេលវេលា និងថវិកា) នៅក្នុងប្រទេសកម្ពុជា (រូប S.១៣)។ ការណ៍នេះមិនមែនដោយសារការចំណាយផ្ទាល់ទៅលើការបង់វិភាគទានពន្ធកាតព្វកិច្ចនោះទេ ប៉ុន្តែជាបន្ទុកផ្នែករដ្ឋបាលដ៏ធំ និងភាពកើតមានជាធម្មតានៃការចំណាយក្រៅផ្លូវការ។ បើប្រៀបធៀបទៅនឹងប្រទេសក្នុងតំបន់ ក្រុមហ៊ុននៅកម្ពុជារាយការណ៍ថា (i) ការមកជួបឬមកត្រួតពិនិត្យពីសំណាក់មន្ត្រីពន្ធដារអាចកើតមានខ្លាំងជាង ហើយការណ៍នេះបានកើនឡើង (ii) ការមកជួបពីសំណាក់មន្ត្រីពន្ធដារមានចំនួនច្រើនដងជាង បើទោះបីជាមានការធ្លាក់ចុះតាមក៏ដោយ (iii) ការរំពឹងទុកឬសំណើសុំការចំណាយក្រៅផ្លូវការ ឬអំណោយសម្រាប់មន្ត្រីក្នុងអំឡុងកិច្ចប្រជុំពាក់ព័ន្ធនឹងពន្ធទំនងមានកម្រិតខ្ពស់ជាង ទោះបីជាវាបានធ្លាក់ចុះក៏ដោយ (iv) ការចំណាយលើសវនករខាងក្រៅឱ្យចូលរួមក្នុងកិច្ចប្រជុំពាក់ព័ន្ធនឹងពន្ធទាំងនេះទំនងជាមានកម្រិតខ្ពស់ជាង (v) ការជួលភ្នាក់ងារខាងក្រៅឱ្យរាយការណ៍ពន្ធទំនងកើតមានខ្លាំងជាង និង (vi) ការបំពេញទម្រង់បែបបទពន្ធតាមអេឡិចត្រូនិកទំនងមានកម្រិតទាបជាង។ ក៏មានភាពខុសគ្នាគួរឱ្យកត់សម្គាល់ផងដែរក្នុងចំណោមក្រុមហ៊ុនកម្ពុជាដោយផ្អែកលើលក្ខណៈរបស់ក្រុមហ៊ុនទាំងនោះ។ ឧទាហរណ៍ ក្រុមហ៊ុនកាត់ដេរ (៩០ភាគរយ) និងក្រុមហ៊ុនធំ (៩៥ភាគរយ) ទំនងជាត្រូវបានត្រួតពិនិត្យដោយមន្ត្រីពន្ធដារ ហើយទំនងកាន់តែខ្លាំងនឹងរាយការណ៍អំពីការចំណាយក្រៅផ្លូវការ។ កត្តារួមចំណែកផ្សេងទៀតដល់ដំណើរការរដ្ឋបាលសារពើពន្ធមិនល្អរួមមានភាពទន់ខ្សោយជុំវិញសវនកម្មពន្ធ និងវិវាទដែលពាក់ព័ន្ធក៏ដូចជាតម្លាភាពជាដើម[27]។ ឧទាហរណ៍ មានការខ្វះខាតមុខងារធានាគុណភាពសវនកម្មច្បាស់លាស់ដោយមិនមានការវាយតម្លៃជាប្រចាំនូវផលជះសវនកម្មលើការអនុលោមតាមច្បាប់។

## ខ. អំពើពុករលួយ

**អំពើពុករលួយនៅតែជាកង្វល់កាន់តែទូលំទូលាយសម្រាប់ក្រុមហ៊ុនកម្ពុជា បើធៀបទៅនឹងប្រទេសក្នុងតំបន់ បើទោះបីជាមានការកែលម្អគួរឱ្យកត់សម្គាល់ក៏ដោយ ដែលឆ្លុះបញ្ចាំងឱ្យឃើញថា នៅតែមានការចំណាយក្រៅផ្លូវការយ៉ាងទូលំទូលាយ និងច្រើននៅឡើយ។** សកម្មភាពអំពើពុករលួយជាច្រើននៅក្នុងប្រទេសកម្ពុជាបានធ្លាក់ចុះ (មានភាពប្រសើរឡើង) ខ្លាំងនៅចន្លោះពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២៣ តែនៅតែបញ្ហាដ៏ទូលំទូលាយធៀបនឹងប្រទេសក្នុងតំបន់។ ទោះជាយ៉ាងណា អំពើពុករលួយនៅតែជា "ឧបសគ្គ" ធំបំផុតទីបីសម្រាប់ការធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា និងជាក្ដីបារម្ភធំជាងសម្រាប់ក្រុមហ៊ុនកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់ (រូប S.៥ ខាងលើ)។ ជាងនេះទៅទៀត ការចំណាយក្រៅផ្លូវការផ្ដល់ទៅឱ្យមន្ត្រីរដ្ឋាភិបាល "ដើម្បីជួយសម្រេចកិច្ចការអ្វីមួយ" នៅតែកើតមានខ្លាំងនៅក្នុងប្រទេសកម្ពុជាគឺប្រហែលប្រាំមួយដងច្រើនជាងប្រទេសក្នុងតំបន់ និងមានទំហំធំជាងប្រហែលបីដង បើទោះបីជាមានការថយចុះក៏ដោយ (រូប S.១៤)។ សរុបមក ក្រុមហ៊ុនកម្ពុជាចំនួន ៤៥ភាគរយបានរាយការណ៍ពីការចំណាយក្រៅផ្លូវការក្នុងឆ្នាំ២០២៣ ធៀបនឹងត្រឹមតែ ៨ភាគរយប៉ុណ្ណោះដែលរាយការណ៍ដោយក្រុមហ៊ុន

**រូប S.១៣ ៖ កត្តាបង្កឱ្យមានការព្រួយបារម្ភអំពីពន្ធក្នុងចំណោមក្រុមហ៊ុនកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់**




*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសបង់ក្លាដែស* (ឆ្នាំ២០២២) កម្ពុជា (ឆ្នាំ២០១៦ និងឆ្នាំ២០២៣) ហ្វីលីពីន (ឆ្នាំ២០២៣) និងវៀតណាម (ឆ្នាំ២០២៣), ធនាគារពិភពលោក។

*ចំណាំ៖ ក្រុមប្រទេសក្នុងតំបន់រួមមានប្រទេសបង់ក្លាដែស* ហ្វីលីពីន និងវៀតណាម។

---

26 ធនាគារពិភពលោក ដែលនឹងចេញផ្សាយនាពេលខាងមុខ (b)។

27 របាយការណ៍ B-Ready (ធនាគារពិភពលោក 2024d)។

**រូប ទ.១៤ ៖ កត្តាជំរុញឱ្យមានការបារម្ភអំពីអំពើពុករលួយក្នុងចំណោមក្រុមហ៊ុនកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់**




*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសបង់ក្លាដែស* (ឆ្នាំ២០២២) កម្ពុជា (ឆ្នាំ២០១៦ និងឆ្នាំ២០២៣) ហ្វីលីពីន (ឆ្នាំ២០២៣) និងវៀតណាម (ឆ្នាំ២០២៣), ធនាគារពិភពលោក។

*ចំណាំ៖ ក្រុមប្រទេសក្នុងតំបន់រួមមានប្រទេសបង់ក្លាដែស* ហ្វីលីពីន និងវៀតណាម។

**រូប ទ.១៥ ៖ ការកើតមានការចំណាយក្រៅផ្លូវការក្នុងចំណោមក្រុមហ៊ុនកម្ពុជាផ្អែកតាមលក្ខណៈក្រុមហ៊ុន**

**ចំណែកក្រុមហ៊ុនកម្ពុជាដែលរាយការណ៍ការចំណាយក្រៅផ្លូវការទៅឱ្យមន្ត្រីរដ្ឋាភិបាលថាជាឧបសគ្គក្នុងការធ្វើអាជីវកម្ម (%), ឆ្នាំ2023**




*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសកម្ពុជា* (ឆ្នាំ២០២៣), ធនាគារពិភពលោក។

ក្នុងប្រទេសក្នុងតំបន់។ ជាងនេះទៅទៀត ក្រុមហ៊ុននៅកម្ពុជារាយការណ៍ពីការបង់ប្រាក់ជាមធ្យម ១,៦ភាគរយនៃការលក់សរុបធៀបនឹងត្រឹមតែ ០,៣ភាគរយនៅប្រទេសក្នុងតំបន់។ ក្រុមហ៊ុននៅកម្ពុជាទំនងជាធ្វើការចំណាយក្រៅផ្លូវការក្នុងអំឡុងកិច្ចប្រជុំជាមួយមន្ត្រីពន្ធដារ (៣៦ភាគរយរាយការណ៍ពីការបង់ប្រាក់) បន្ទាប់មកគឺកិច្ចប្រជុំទាក់ទងនឹងការអនុញ្ញាតនាំចូល (១៥ភាគរយ)។ អាជ្ញាប័ណ្ណអាជីវកម្មកើតមានការចំណាយក្រៅផ្លូវការទាបបំផុត (១ភាគរយ) ដែលថយចុះយ៉ាងខ្លាំងពី ៥០ភាគរយក្នុងឆ្នាំ២០១៦។ ការធ្លាក់ចុះគួរឱ្យចាប់អារម្មណ៍នេះទំនងជាកើតមានឡើងដោយសារដំណើរការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណអាជីវកម្មភាគច្រើន ត្រូវបានប្តូរទៅធ្វើតាមអ៊ិនធឺណិតនៅក្នុងអំឡុងពេលកើតមានជំងឺរាតត្បាតកូវីដ-១៩ ដែលបានលុបបំបាត់ឱកាសភាគច្រើនដែលបណ្តាលឱ្យការចំណាយក្រៅផ្លូវការ។ ទិន្នន័យនេះចង្អុលបង្ហាញឱ្យឃើញពីការប្រឆាំងនឹងអំពើពុករលួយ ក៏ដូចជាឱកាសផលិតផលិតភាពសម្រាប់ប្រទេសកម្ពុជាតាមរយៈការធ្វើឌីជីថលនីកម្មសេវាកម្មរបស់រដ្ឋាភិបាលឱ្យកាន់តែលឿនរហ័សជាងនេះ។

**ក្រៅពីនេះ ការចំណាយក្រៅផ្លូវការជាធម្មតាមានភាពទូលំ**

**រូប S.16 ៖ ការយល់ឃើញអំពីឯករាជ្យភាពរបស់តុលាការក្នុងវិវាទពាណិជ្ជកម្មក្នុងចំណោមក្រុមហ៊ុនកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់**




*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសបង់ក្លាដែស* (ឆ្នាំ២០២២) កម្ពុជា (ឆ្នាំ២០២៣) ហ្វីលីពីន (ឆ្នាំ២០២៣) និងវៀតណាម (ឆ្នាំ២០២៣), ធនាគារពិភពលោក។

*ចំណាំ៖ ក្រុមប្រទេសក្នុងតំបន់រួមមានប្រទេសបង់ក្លាដែស* ហ្វីលីពីន និងវៀតណាម។

**ទូលាយ និងធំជាងក្នុងចំណោមក្រុមហ៊ុនដែលមានទីតាំងនៅតំបន់ភ្នំនៃប្រទេសកម្ពុជា ក៏ដូចជាក្រុមហ៊ុនថ្មីថ្មោង ក្រុមហ៊ុនធំជាង និងក្រុមហ៊ុនកាត់ដេរ។** អំពើពុករលួយទំនងជាត្រូវបានលើកឡើងថាជាឧបសគ្គក្នុងការធ្វើអាជីវកម្មដោយក្រុមហ៊ុនដែលមានទីតាំងនៅតំបន់ភ្នំនៃប្រទេសកម្ពុជា ក៏ដូចជាក្រុមហ៊ុនលក់រាយ ក្រុមហ៊ុនកាត់ដេរ និងក្រុមហ៊ុនធុនមធ្យម ហើយការព្រួយបារម្ភទាំងនេះមានទំនាក់ទំនងប្រហាក់ប្រហែលនឹងភាពខុសគ្នានៃភាពកើតមាននិងទំហំនៃការចំណាយក្រៅផ្លូវការ (រូប S.១៥)។ ឧទាហរណ៍ ក្រុមហ៊ុនដែលមានទីតាំងនៅតំបន់ភ្នំនៃប្រទេសកម្ពុជាទំនងខ្លាំងជាងក្នុងការចំណាយក្រៅផ្លូវការ (៨៨ភាគរយ) រួមជាមួយនឹងក្រុមហ៊ុនថ្មីថ្មោង (៦៧ភាគរយ) ក្រុមហ៊ុនដំណើរការយឺតយ៉ាវ (៦៧ភាគរយ) ក្រុមហ៊ុនធុនមធ្យម (៦៦ភាគរយ) និងក្រុមហ៊ុនកាត់ដេរ (៦៤ភាគរយ) ។ ភាពខុសគ្នាប្រហាក់ប្រហែលគ្នានេះទាក់ទងនឹងទំហំចំណាយក្រៅផ្លូវការនៅក្នុងចំណោមក្រុមហ៊ុន ក៏ត្រូវបានសង្កេតឃើញកើតមានផងដែរ ដោយការចំណាយធំបំផុតធ្វើឡើងដោយក្រុមហ៊ុនកាត់ដេរនៅតំបន់ភ្នំ (៣,៥ភាគរយនៃការលក់) ក្រុមហ៊ុនធុនមធ្យម (២,៤ភាគរយ) ក្រុមហ៊ុនថ្មីថ្មោង (២,៣ភាគរយ) ក្រុមហ៊ុនកាត់ដេរ (២,៣ភាគរយ) និងក្រុមហ៊ុនធំ (២,១ភាគរយ)។

## គ. តុលាការ

**តុលាការក៏នៅតែជាការព្រួយបារម្ភកាន់តែខ្លាំងឡើងសម្រាប់ក្រុមហ៊ុនកម្ពុជា ធៀបនឹងប្រទេសក្នុងតំបន់ ដែលឆ្លុះបញ្ចាំងពីការយល់ឃើញកាន់តែទូលំទូលាយអំពីភាពលំអៀងនៅក្នុងជម្លោះពាណិជ្ជកម្ម និងបញ្ហាប្រតិបត្តិការផ្សេងៗ។** តុលាការគឺជា “ឧបសគ្គ” ខ្ពស់បំផុតទីបួនសម្រាប់ការធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា (ដែលត្រូវបានលើកឡើងដោយក្រុមហ៊ុនចំនួន ៥៧ភាគរយ) បានក្លាយជាក្តីបារម្ភកាន់តែធំ និងជាក្តីបារម្ភធំខ្លាំងសម្រាប់ក្រុមហ៊ុនកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់ (រូប S.១៥ ខាងលើ។ ) ជាងនេះទៅទៀត តុលាការគឺជាកង្វល់ដ៏ទូលំទូលាយសម្រាប់ក្រុមហ៊ុនលក់រាយ (៧៨ភាគរយ) និងសម្រាប់ក្រុមហ៊ុនធុនមធ្យម (៧៤ភាគរយ)។ ក្រុមហ៊ុនកម្ពុជាក៏ទំនងខ្លាំងជាងប្រទេសក្នុងតំបន់ដែលគិតថា តុលាការមិនមានភាបឯករាជ្យ ឬមានភាពលំអៀងនៅពេលដោះស្រាយវិវាទពាណិជ្ជកម្ម (រូប S.១៦)។ នៅឆ្នាំ២០២៣ ក្រុមហ៊ុនកម្ពុជាចំនួន ២៥ភាគរយមិនយល់ស្របថា “តុលាការមានភាពឯករាជ្យនិងមិនលំអៀងក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម” (ធៀបទៅនឹងកម្រិតមធ្យម ១៩ភាគរយនៅប្រទេសក្នុងតំបន់)។ ក៏មានការយល់ឃើញខុសគ្នាផងដែរអំពីឯករាជ្យភាពរបស់តុលាការក្នុងចំណោមក្រុមហ៊ុនកម្ពុជា ដោយក្រុមហ៊ុនឈានមុខគេ (មាន ៤០ភាគរយ) ក្រុមហ៊ុន “សេវាកម្មផ្សេងទៀត” (៣៨ភាគរយ) ក្រុមហ៊ុន “កម្មន្តសាលផ្សេងទៀត” (៣៣ភាគរយ) ហើយក្រុមហ៊ុនតូច (២៩ភាគរយ) ទំនងកាន់តែខ្លាំងគិតថា តុលាការមានភាពលំអៀង។ កត្តារួមចំណែកផ្សេងទៀតដល់ការយល់ឃើញមិនល្អអំពីតុលាការ រួមមានកង្វះតុលាការពាណិជ្ជកម្មនៅកម្ពុជា និងការធ្វើឌីជីថលនីយកម្មនិងតម្លាភាពក្នុងកិច្ចដំណើរការនីតិវិធីតុលាការនៅមានកម្រិត[28]។

## ឃ. ឯកសារអាជីវកម្មនិងដំណើរការ

**ឯកសារអាជីវកម្មនិងដំណើរការក៏នៅតែជាក្តីបារម្ភកាន់តែខ្លាំងសម្រាប់ក្រុមហ៊ុនកម្ពុជា ធៀបនឹងប្រទេសក្នុងតំបន់ ដោយ**

28 របាយការណ៍ B-Ready (ធនាគារពិភពលោក 2024d)។

**រូប S.១៧ ៖ ពេលវេលាផ្តល់សេវាកម្មអាជីវកម្មសម្រាប់ក្រុមហ៊ុនក្នុងប្រទេសកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់**




*ប្រភព៖ ការធ្វើអង្កេតសហគ្រាសសម្រាប់ប្រទេសបង់ក្លាដែស* (ឆ្នាំ២០២២) កម្ពុជា (ឆ្នាំ២០២៣) ហ្វីលីពីន (ឆ្នាំ២០២៣) និងវៀតណាម (ឆ្នាំ២០២៣), ធនាគារពិភពលោក។

*ចំណាំ៖ ក្រុមប្រទេសក្នុងតំបន់រួមមានប្រទេសបង់ក្លាដែស* ហ្វីលីពីន និងវៀតណាម។

**មួយផ្នែកឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈពេលវេលារង់ចាំយូរជាងសម្រាប់សេវាកម្ម។** ឯកសារពាណិជ្ជកម្ម គឺជា "ឧបសគ្គ" ធំបំផុតទីប្រាំពីរក្នុងការធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា (ដែលត្រូវបានលើកឡើងដោយក្រុមហ៊ុនចំនួន ៤៨ភាគរយ) ហើយនៅតែជាក្តីបារម្ភធំកាន់តែខ្លាំងសម្រាប់ក្រុមហ៊ុនកម្ពុជាធៀបនឹងប្រទេសក្នុងតំបន់ទោះបីជាមានភាពប្រសើរឡើងក៏ដោយ (រូប S.៥ ខាងលើ)។ ជាងនេះទៀត ឯកសារអាជីវកម្មគឺជាកង្វល់ដ៏ទូលំទូលាយសម្រាប់ក្រុមហ៊ុនធុនមធ្យម (៦៧ភាគរយ) ក្រុមហ៊ុនលក់រាយ (៦៤ភាគរយ) និងក្រុមហ៊ុនកាត់ដេរ (៥៩ភាគរយ) ។ កង្វល់ទាំងនេះមួយផ្នែកឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈពេលវេលារង់ចាំយូរកាន់តែនៅទូទាំងសេវាសំខាន់ៗដែលផ្តល់ដោយរដ្ឋាភិបាល (រូប S.១៧)។ បើប្រៀបធៀបទៅនឹងប្រទេសក្នុងតំបន់ ក្រុមហ៊ុននៅកម្ពុជារាយការណ៍ពីការរង់ចាំយូរជាងដើម្បី (i) ទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការអាជីវកម្ម (៣០ថ្ងៃធៀបនឹង ២២ថ្ងៃ ធ្លាក់ចុះពី ៣៣ថ្ងៃក្នុងឆ្នាំ២០១៦) (ii) ទទួលបានលិខិតអនុញ្ញាតនាំចូល (២៨ថ្ងៃធៀបនឹង ២០ថ្ងៃ កើនឡើងខ្លាំងពី ១៦ថ្ងៃក្នុងឆ្នាំ ២០១៦) (iii) បំពេញបែបបទបញ្ចេញទំនិញនាំចូលតាមរយៈភ្នាក់ងារត្រួតពិនិត្យព្រំដែន (២២ថ្ងៃធៀបនឹង ១៧ ថ្ងៃ) និង (iv) បំពេញបែបបទបញ្ចេញទំនិញនាំចេញ (២០ថ្ងៃធៀបនឹង ១២ថ្ងៃ)។ ក្រុមហ៊ុននៅកម្ពុជាត្រូវរង់ចាំរយៈពេលប្រាំពីរថ្ងៃជាមធ្យមយូរជាងប្រទេសក្នុងតំបន់នៅទូទាំងសេវាកម្មទាំងអស់នេះ។ មានភាពខុសគ្នាតិចតួចក្នុងចំណោមក្រុមហ៊ុននៅកម្ពុជា ទាក់ទងនឹងចំនួនថ្ងៃដើម្បីទទួលបានឯកសារអាជីវកម្ម ដោយសារដំណើរការតាមអ៊ិនធឺណិតដែលមានស្តង់ដារ។ ទោះយ៉ាងណា មានភាពខុសគ្នាខ្លះទាក់ទងនឹងពេលវេលាបំពេញទម្រង់បែបបទដើម្បីបញ្ចេញទំនិញនាំចេញនិងនាំចូល។ ឧទាហរណ៍ ក្រុមហ៊ុនឈានមុខគេនិងក្រុមហ៊ុនសេវាកម្មត្រូវចំណាយពេលយូររហូត ៣៤ថ្ងៃ និង ២៤ថ្ងៃរៀងគ្នា ដើម្បីបំពេញទម្រង់បែបបទនាំចូលរបស់ពួកគេតាមរយៈភ្នាក់ងារទាំងអស់ ដែលរយៈពេលនេះយូរជាងក្រុមហ៊ុនកម្មន្តសាលនិងក្រុមហ៊ុនដំណើរការយឺតយ៉ាវ។ ក្រុមហ៊ុនតូចៗត្រូវចំណាយពេលយូរជាង (២៦ថ្ងៃ) ក្រុមហ៊ុនធំ (១៩ថ្ងៃ)។ កត្តារួមចំណែកផ្សេងទៀតដែលនាំឱ្យទទួលបានពិន្ទុមិនល្អទាក់ទងនឹងឯកសារអាជីវកម្មរួមមានភាពទន់ខ្សោយខាងផ្នែកសេវាកម្មឌីជីថលមានអន្តរប្រតិបត្តិការនៃប្រព័ន្ធសេវាកម្ម (នៅទូទាំងទីភ្នាក់ងាររដ្ឋាភិបាល) តម្លាភាព និងការចំណាយក្នុងការចុះបញ្ជីអាជីវកម្ម។ សម្រាប់ពាណិជ្ជកម្មអន្តរជាតិ បញ្ហារួមមានហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្មមិនល្អ (ឧទាហរណ៍ ឧបករណ៍ ទីតាំង និងបរិក្ខារ) ការគ្រប់គ្រងព្រំដែន និងពេលវេលាដែលត្រូវចំណាយក្នុងការអនុលោមតាមតម្រូវការពាណិជ្ជកម្ម[29]។

# VI. ភាពជំពាក់ជំពិនផ្នែកគោលនយោបាយនិងអនុសាសន៍

**ផ្នែកនេះបង្ហាញអំពីវិស័យកំណែទម្រង់ជាអាទិភាពចំនួនបួន ដើម្បីគាំទ្រដល់ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សឆ្ពោះទៅកាន់គំរូកំណើនសេដ្ឋកិច្ចដែលដឹកនាំដោយផលិតភាពកាន់តែខ្លាំងនៅក្នុងប្រទេសកម្ពុជា៖** (១) ពន្លឿនការផ្លាស់ប្តូររចនាសម្ព័ន្ធទាំងក្នុងនិងទូទាំងវិស័យឆ្ពោះទៅរកផលិតផល ខ្សែច្រវាក់តម្លៃ និងសកម្មភាពដែលបន្ថែមតម្លៃកាន់តែខ្ពស់ (២) ដោះស្រាយឧបសគ្គ

29 របាយការណ៍ B-Ready (ធនាគារពិភពលោក 2024d)។

រចនាសម្ព័ន្ធ និង/ឬការបង្អាក់ទឹកចិត្តដែលប្រឈមដោយក្រុមហ៊ុនធុនមធ្យម ក្រុមហ៊ុនឈានមុខគេ និងក្រុមហ៊ុននៅក្នុងតំបន់ជនបទ/ទីក្រុងតូចៗ (៣) ជំរុញការធ្វើទំនើបកម្មក្រុមហ៊ុនឱ្យបានលឿនរហ័សជាងមុន និងការតម្រង់ទិសឆ្ពោះទៅរកទីផ្សារអន្តរជាតិ និង (៤) ដោះស្រាយឧបសគ្គធំបំផុតដែលបង្កឱ្យមានសម្ពាធក្នុងការធ្វើអាជីវកម្មដែលលើកឡើងដោយក្រុមហ៊ុនកម្ពុជា។ វិស័យកំណែទម្រង់ទាំងបួននេះពឹងផ្អែកគ្នាទៅវិញទៅមក និងជួយពង្រឹងគ្នាទៅវិញទៅមក។

**កម្ពុជាចាំបាច់ត្រូវពន្លឿនការផ្លាស់ប្តូររចនាសម្ព័ន្ធទាំងក្នុងនិងទូទាំងវិស័យឆ្ពោះទៅរកផលិតផល ខ្សែច្រវាក់តម្លៃ និងសកម្មភាពដែលបន្ថែមតម្លៃកាន់តែខ្ពស់។** អត្ថបទផ្តោតពិសេសនេះបានរំលេចពីភាពខុសគ្នាយ៉ាងទូលំទូលាយនៃផលិតភាពការងារក្នុងចំណោមក្រុមហ៊ុនកម្ពុជាទាំងក្នុងនិងទូទាំងវិស័យ ដោយវិស័យមួយចំនួន (ដូចជាសេវាកម្ម) និងអនុវិស័យ (ដូចជាសេវាកម្មផ្សេងទៀត) មានផលិតភាពច្រើនជាងវិស័យនិងអនុវិស័យផ្សេងទៀត (ដូចជាវិស័យកាត់ដេរ)។ ការកែលម្អដំណើរការផលិតភាពរបស់កម្ពុជាទាមទារឱ្យមានការរុះរើ និងពន្លឿនការផ្លាស់ប្តូររចនាសម្ព័ន្ធរបស់ប្រទេសឆ្ពោះទៅរកសកម្មភាពនិងក្រុមហ៊ុនដែលបន្ថែមតម្លៃកាន់តែខ្ពស់ ទាំងនៅក្នុងវិស័យ និងចាប់ពីវិស័យមានផលិតភាពទាបរហូតដល់វិស័យមានផលិតភាពខ្ពស់ និងចាប់ពីតំបន់ជនបទរហូតទៅតំបន់ទីក្រុង។ ការណ៍នេះមានភាពស្របតាមតម្រូវការដ៏ទូលំទូលាយ ដើម្បីបន្តធ្វើពិពិធកម្មសេដ្ឋកិច្ចកាន់តែខ្លាំងនៅក្នុងប្រទេសកម្ពុជា ដើម្បីកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងការប្រមូលផ្តុំខ្លាំងតែលើផលិតផលនិងទីផ្សារមួយចំនួន។ គំនិតគោលនយោបាយជាក់លាក់ដើម្បីពន្លឿនការផ្លាស់ប្តូររចនាសម្ព័ន្ធរួមមាន៖

- **បង្កភាពកាន់តែងាយស្រួល និងកាន់តែលឿនរហ័សសម្រាប់ក្រុមហ៊ុនថ្មីក្នុងការបើកដំណើរការ និងសម្រាប់ក្រុមហ៊ុនដែលដំណើរការមិនល្អក្នុងការបិទដំណើរការ** រួមទាំងតាមរយៈការធ្វើឌីជីថលពេញលេញនូវវិបផតថលចុះបញ្ជីអាជីវកម្ម ការកាត់បន្ថយការចំណាយនិងពេលវេលារង់ចាំនៅក្នុងសេវាកម្មអាជីវកម្មទាំងអស់ដែលអាចធ្វើទៅបានតាមរយៈការកំណត់ស្តង់ដារសេវាកម្មអប្បបរមា និងបង្កភាពងាយស្រួលក្នុងការបង្កើនសមត្ថភាពដើម្បីឆ្លើយតបទៅនឹងស្តង់ដារទាំងនេះ និងការបង្កើនការផ្តល់ (និងប្រសិទ្ធភាព) សេវាកម្មសាធារណៈទាក់ទងនឹងអសាធនភាព និងការក្ស័យធនអាជីវកម្ម[30]។ សូមមើល (ឆ) សេវាកម្មអាជីវកម្មខាងក្រោមសម្រាប់ព័ត៌មានលម្អិតបន្ថែម។
- **លើកទឹកចិត្តឱ្យមានការអភិវឌ្ឍន៍ឧស្សាហកម្មថ្មី និងការបំប្លែងឧស្សាហកម្មដែលមានស្រាប់ទៅជាផ្នែកបន្ថែមតម្លៃកាន់តែខ្ពស់** រួមទាំងតាមរយៈការផ្តល់ការលើកទឹកចិត្តដែលបានបង្កើតឡើងយ៉ាងល្អសម្រាប់ការវិនិយោគនៅក្នុងឧស្សាហកម្មដែលកំពុងរីកចម្រើន និងការគាំទ្រដល់ការរីកចម្រើន និងកិច្ចខិតខំប្រឹងប្រែងច្នៃប្រឌិតរបស់សហគ្រាសធុនតូច និងមធ្យម (SMEs)។ ការណ៍នេះអាចត្រូវបានគាំទ្រដោយកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងឧស្សាហកម្មដែលស្ថិតក្នុងផែនទីបង្ហាញផ្លូវរយៈពេលវែងសម្រាប់វិស័យសំខាន់ៗ។ ឧទាហរណ៍ នៅក្នុងវិស័យកាត់ដេរ មានតម្រូវការច្បាស់លាស់ក្នុងការអភិវឌ្ឍស្តង់ដារមួយសម្រាប់ប្រទេសកម្ពុជា ដើម្បីធ្វើដំណើរឱ្យហួសពីផលិតកម្មតម្លៃបន្ថែមទាបសម្រាប់ផលិតផលិតផលសម្លៀកបំពាក់តម្លៃសមរម្យដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនម៉ាកយីហោបរទេស ជាពិសេសក្នុងពេលដែលកម្ពុជាកំពុងរៀបចំខ្លួនចាកចេញពីឋានៈជាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ដែលនឹងបណ្តាលឱ្យកម្ពុជាបាត់បង់សិទ្ធិទទួលបានការអនុគ្រោះផ្នែកពាណិជ្ជកម្ម។ ផែនទីបង្ហាញផ្លូវរយៈពេលវែងអាចដាក់ចេញរបៀបដែលវិស័យនេះអាចទាញយកអត្ថប្រយោជន៍ពីនិន្នាការពិភពលោក (ឧទាហរណ៍ ការផ្លាស់ប្តូររបស់អ្នកប្រើប្រាស់ឆ្ពោះទៅកាន់សម្លៀកបំពាក់សរីរាង្គ និងមាននិរន្តរភាពជាពេលបច្ចុប្បន្ន) និងជំនាញដែលមានស្រាប់របស់កម្ពុជា ដើម្បីឈានទៅរកផលិតផលដែលមានគុណភាពខ្ពស់ កាន់តែមាននិរន្តរភាព និងមានតម្លៃថ្លៃ ដែលអាចត្រូវបានរចនានិងជាកម្មសិទ្ធិជាអ្នកក្នុងស្រុក។

**កម្ពុជាក៏ចាំបាច់ត្រូវដោះស្រាយឧបសគ្គរចនាសម្ព័ន្ធជាក់លាក់ និង/ឬការបង្អាក់ទឹកចិត្តដែលប្រឈមដោយក្រុមហ៊ុនធុនមធ្យម ក្រុមហ៊ុននៅតំបន់ជនបទ/ដាច់ស្រយាល និងក្រុមហ៊ុនឈានមុខគេផងដែរ។** អត្ថបទផ្តោតពិសេសនេះបានគូសបញ្ជាក់ថា ក្រុមហ៊ុនធុនមធ្យមនិងក្រុមហ៊ុនដែលមានទីតាំងនៅតំបន់ភ្នំនៃប្រទេសកម្ពុជា (និងនៅបឹងទន្លេសាប) មានផលិតភាពការងារទាបជាង ហើយមានការព្រួយបារម្ភខ្លាំងជាងអំពីប្រធានបទទាំងអស់ក្នុងការធ្វើអាជីវកម្ម។ ជាងនេះទៅទៀត ក្រុមហ៊ុនឈានមុខគេនៅកម្ពុជាកំពុងដើរយឺតជាងប្រទេសក្នុងតំបន់។ ការវិភាគផ្នែកឆ្លងវិស័យនៅក្នុងផ្នែកទី IV និងផ្នែកទី V ក៏បង្ហាញផងដែរថា ក្រុមហ៊ុនទាំងនេះមានក្តីបារម្ភផ្សេងគ្នាដែលអំពាវនាវឱ្យការធ្វើអន្តរាគមន៍គោលនយោបាយសមស្រប។ គោលនយោបាយគាំទ្រក្រុមហ៊ុនទាំងនេះរួមមាន៖

- **កំណត់គោលដៅគាំទ្រក្រុមហ៊ុនធុនមធ្យម ដើម្បីជួយពួកគេឱ្យជម្នះឧបសគ្គអាជីវកម្មបានកាន់តែប្រសើរ។** ក្រុមហ៊ុនធុនមធ្យមរបស់កម្ពុជាមានផលិតភាពតិចបំផុត មានការព្រួយបារម្ភច្រើនលើប្រធានបទអាជីវកម្មទាំងអស់ ទំនងខ្លាំងជាង

30 ក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយនេះ សំណុំរឿងអសាធនភាពល្បីមួយចំនួនតូចប៉ុណ្ណោះត្រូវបានដោះស្រាយដោយតុលាការក្រុងនានានៅកម្ពុជា។ សំណុំរឿងទាំងអស់ដែលបានដំណើរការនៅក្នុងតុលាការកម្ពុជារហូតមកដល់បច្ចុប្បន្ន បានបណ្តាលឱ្យមានការជម្រះបញ្ជីទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនបានតិចតួចប៉ុណ្ណោះ ដែលនាំឱ្យអត្រាស្តារឡើងវិញមានកម្រិតទាបសម្រាប់ម្ចាស់បំណុល (១៤,៦សេនក្នុងមួយប្រាក់ដុល្លារក្នុងប្រទេសកម្ពុជា ធៀបនឹង ៣៥,៥សេនជាមធ្យមនៅក្នុងតំបន់អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក (EAP) និង ៧០,២សេននៅក្នុងប្រទេសជាសមាជិករបស់អង្គការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD)។ លើសពីនេះទៀត មានការខ្វះខាតការយល់ដឹងអំពីអត្ថប្រយោជន៍នៃការរៀបចំបំណុលឡើងវិញក្នុងចំណោមអាជីវកម្ម និងចៅក្រម ហើយអ្នកគ្រប់គ្រងផ្នែកអសាធនភាពខ្វះការបណ្តុះបណ្តាលជំនាញឯកទេសក្នុងបញ្ហាអសាធណភាពនេះ។

ក្នុងការចំណាយក្រៅផ្លូវការទៅឱ្យមន្ត្រីរដ្ឋាភិបាលដើម្បី “សម្រេចកិច្ចការអ្វីមួយ” និងមានសមត្ថភាពគ្រប់គ្រងទាបជាង (ដែលជាកត្តាជំរុញផលិតភាពដ៏សំខាន់)។ ដូច្នេះហើយ ក្រុមហ៊ុនធុនមធ្យមនឹងទទួលបានអត្ថប្រយោជន៍ពីការគាំទ្រពីរដ្ឋាភិបាលកាន់តែខ្លាំង ដើម្បីជម្នះឧបសគ្គអាជីវកម្ម និងកសាងសមត្ថភាពរបស់ពួកគេ។ អន្តរាគមន៍ប្រកបដោយសក្តានុពលអាចរួមមានទាំងការបង្កើត (i) “ការិយាល័យច្រកចេញចូលតែមួយ (One-stop shop)” សម្រាប់ក្រុមហ៊ុនដោយផ្តោយការយកចិត្តទុកដាក់លើសហគ្រាសធុនតូច និងមធ្យម និង (ii) កម្មវិធីបណ្តុះបណ្តាល វគ្គបណ្តុះបណ្តាល និងជំនួយឥតសំណងដើម្បីជួយសហគ្រាសធុនតូចនិងមធ្យមក្នុងការកសាងសមត្ថភាពគ្រប់គ្រងនិងអាជីវកម្មរបស់ពួកគេនៅពេលដែលអាជីវកម្មរបស់ពួកគេរីកចម្រើន[31]។

- **កំណត់គោលដៅកម្មវិធីពង្រីកសេវាហេដ្ឋារចនាសម្ព័ន្ធ និងអាជីវកម្មនៅតំបន់ជនបទ/តំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា។** ក្រុមហ៊ុនដែលមានទីតាំងនៅតាមតំបន់ជនបទ/តំបន់ដាច់ស្រយាលកាន់តែឆ្ងាយនៃប្រទេសកម្ពុជា មិនសូវមានផលិតភាពទេ និងបារម្ភច្រើនអំពីប្រធានបទអាជីវកម្មទាំងអស់ រួមទាំងអគ្គិសនី និងការដឹកជញ្ជូនផងដែរ។ អន្តរាគមន៍ប្រកបដោយសក្តានុពលដើម្បីគាំទ្រក្រុមហ៊ុនទាំងនេះឱ្យកាន់តែប្រសើរឡើងអាចរួមមានទាំងគម្រោង និងគំនិតផ្តួចផ្តើមមូលធនថ្មីៗ ដើម្បីកាត់បន្ថយវិសមភាពខាងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងស្តង់ដារសេវាកម្មជាមួយនឹងតំបន់ទីក្រុង។ ឧទាហរណ៍រួមមាន (i) ការកែលម្អផ្លូវខេត្ត និងផ្លូវជនបទ ដែលទាបជាងស្តង់ដារជាតិ (ii) ការកែលម្អលទ្ធភាពទទួលបានសេវាអ៊ិនធឺណេតល្បឿនលឿននៅតំបន់ជនបទ និង (iii) ការបើកមជ្ឈមណ្ឌលថ្មីៗសម្រាប់សេវាកម្មធុរកិច្ចរដ្ឋាភិបាលនៅក្នុងតំបន់ទាំងនេះ ដើម្បីគាំទ្រក្រុមហ៊ុនក្នុងស្រុកឱ្យកាន់តែប្រសើរឡើង[32]។
- **បង្កើតបរិយាកាសសម្រាប់ក្រុមហ៊ុនឈានមុខគេថ្នាក់ជាតិដើម្បីខិតខំប្រឹងប្រែងបង្កើនផលិតភាពឱ្យដល់កម្រិតផលិតភាពថ្នាក់តំបន់។** ក្រុមហ៊ុនឈានមុខគេរបស់កម្ពុជាកំពុងប្រតិបត្តិការជាមួយនឹងផលិតភាពទាបជាងកម្រិតផលិតភាពថ្នាក់តំបន់។ កំណែទម្រង់ដែលបង្កើនការប្រកួតប្រជែងអាចជួយជំរុញឱ្យក្រុមហ៊ុនឈានមុខគេថ្នាក់ជាតិកាន់តែប្រសើរឡើង ដើម្បីបង្កើនផលិតភាពរបស់ពួកគេក្នុងការប្រកួតប្រជែងកាន់តែប្រសើរជាមួយក្រុមហ៊ុនឈានមុខគេក្នុងតំបន់ និងពិភពលោក។ ប្រទេសកម្ពុជាបានចាត់វិធានការលើវិស័យនេះរួចហើយ ដោយបានអនុម័តច្បាប់ស្តីពីការប្រកួតប្រជែងថ្មីនៅឆ្នាំ២០២១ និងបានបង្កើតគណៈកម្មការប្រកួតប្រជែង ហើយវាអាចត្រូវការពេលវេលាបន្ថែមទៀតដើម្បីឱ្យលទ្ធផលនៃការធ្វើកំណែទម្រង់ទាំងនេះមានប្រសិទ្ធភាព។ ទោះបីជាយ៉ាងណា កម្ពុជាអាចពិចារណាលើការធ្វើកំណែទម្រង់បន្ថែមទៀតដើម្បីបង្កើនការប្រកួតប្រជែង (ជាពិសេសក្នុងវិស័យសេវាកម្ម និងឌីជីថល) ដូចជាការកាត់បន្ថយរបាំងពាណិជ្ជកម្ម បើកវិស័យបន្ថែមទៀតដល់ការវិនិយោគបរទេស និងកាត់បន្ថយឥទ្ធិពលរបស់សហគ្រាសរដ្ឋ ជាពិសេសក្នុងវិស័យដែលការប្រកួតប្រជែងមានកម្រិតទាប។

  លើសពីនេះ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងរូបវ័ន្ត ជាពិសេសការកែលម្អលទ្ធភាពទទួលបានអ៊ិនធឺណិតល្បឿនលឿន គឺជាកត្តាសំខាន់ដើម្បីផ្តល់លទ្ធភាពឱ្យក្រុមហ៊ុននានាទទួលយកបច្ចេកវិទ្យាទំនើប។ ជាចុងក្រោយ ការកែលម្អការអប់រំ និងជំនាញកម្លាំងពលកម្ម ជាពិសេសផ្នែកឌីជីថល និងបច្ចេកទេស មានភាពចាំបាច់ណាស់ដើម្បីជួយក្រុមហ៊ុនឱ្យមានការច្នៃប្រឌិត និងរក្សាការប្រកួតប្រជែង[33]។ ក្រុមហ៊ុនឈាន មុខគេក៏អាចត្រូវបានជំរុញនិងលើកទឹកចិត្តឱ្យវិនិយោគលើបច្ចេកវិទ្យាទំនើប (ឧទាហរណ៍ ការវិភាគទិន្នន័យ កុំព្យូទ័រខ្លោដ) ផ្តោតលើការអភិវឌ្ឍជំនាញ (ឧទាហរណ៍ តាមរយៈកម្មវិធីបណ្តុះបណ្តាល និងភាពជាដៃគូជាមួយស្ថាប័នអប់រំ ដើម្បីធានាថា បុគ្គលិករបស់ពួកគេមានជំនាញចាំបាច់ដើម្បីជំរុញនវានុវត្តន៍) និងដើម្បីពង្រីកបណ្តាញសកលរបស់ពួកគេ (ឧទាហរណ៍ ដើម្បីទទួលបានចំណេះដឹងអំពីការអនុវត្តល្អបំផុតក្នុងពិភពលោក ការទទួលយកបច្ចេកវិទ្យាមកប្រើប្រាស់ និងយុទ្ធសាស្ត្រប្រកួតប្រជែង)។

  **លើសពីនេះ កម្ពុជាគួរតែលើកទឹកចិត្តឱ្យមានការធ្វើទំនើបកម្ម និងឌីជីថលភាវូបនីយកម្មក្រុមហ៊ុនរបស់ខ្លួនកាន់តែខ្លាំងនិងលឿនជាងមុន ក៏ដូចជាផ្តោតលើទីផ្សារអន្តរជាតិឱ្យកាន់តែប្រសើរឡើង។** អត្ថបទផ្តោតពិសេសនេះបានបានគូសបញ្ជាក់ថា ក្រុមហ៊ុនដែលមានការអនុវត្តមុខងារបុគ្គលិកទំនើបជាងមុន (ឧទាហរណ៍ នាយកប្រតិបត្តិដែលមានជំនាញវិជ្ជាជីវៈ ការគ្រប់គ្រងកាន់តែប្រសើរ ការផ្តល់កម្មវិធីបណ្តុះបណ្តាលបុគ្គលិកផ្លូវការ) និងដែលប្រើប្រាស់បច្ចេកវិទ្យា (ឧទាហរណ៍ មានគេហទំព័រ ប្រើប្រាស់ការទូទាត់តាមអេឡិចត្រូនិក) ក៏ដូចជាក្រុមហ៊ុនផ្តោតលើការនាំចេញ ជាធម្មតាមានផលិតភាពការងារខ្ពស់ជាង។ វានឹងមានអត្ថប្រយោជន៍ផលិតភាពពីការលើកកម្ពស់ការផ្សព្វផ្សាយយ៉ាងឆាប់រហ័សនូវការអនុវត្តល្អបំផុតទាំងនេះនៅទូទាំងក្រុមហ៊ុនក្នុងប្រទេសកម្ពុជា។
- **គាំទ្រ និងលើកទឹកចិត្តដល់ក្រុមហ៊ុនឱ្យធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការអភិវឌ្ឍស្ថាប័ន ការគ្រប់គ្រង និងកម្លាំងការងាររបស់ពួកគេ។** គំនិតជាក់លាក់រួមមាន (i) ជំរុញឱ្យមានការទទួលយកការអនុវត្តការគ្រប់គ្រងដែលទទួលស្គាល់ជាសាកល តាមរយៈភាពជាដៃគូសាធារណៈនិងឯកជន ដែលជួយឱ្យក្រុមហ៊ុនក្នុងស្រុកចូលរួមក្នុងការអនុវត្តល្អបំផុត និងវិធីសាស្ត្រគ្រប់គ្រងជាអន្តរជាតិ ជាពិសេសនៅក្នុងវិស័យ

31 មានឧទាហរណ៍ជាច្រើនអំពីកម្មវិធីបែបនេះនៅទូទាំងតំបន់អាស៊ី ដូចជាកម្មវិធី ASEAN SME Academy ជាដើម។
32 របាយការណ៍ស្តីពី បច្ចុប្បន្នភាពការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ ជំនាន់ទីពីររបស់ប្រទេសកម្ពុជា (ធនាគារពិភពលោក ឆ្នាំ២០២៤)
33 ធនាគារពិភពលោក ឆ្នាំ២០២៤f។

ដែលគួរប្រកួតប្រជែងសកលលោកពូកែ (ii) គាំទ្រកម្មវិធីបណ្តុះបណ្តាលផ្នែកគ្រប់គ្រងតាមរយៈការផ្តល់ជូនកម្មវិធីបណ្តុះបណ្តាលដែលគាំទ្រដោយរដ្ឋាភិបាល ឬការលើកទឹកចិត្តឱ្យក្រុមហ៊ុនវិនិយោគលើការអភិវឌ្ឍន៍ជំនាញគ្រប់គ្រង (iii) លើកទឹកចិត្តឱ្យមានកម្មវិធីបណ្តុះបណ្តាលកម្រិតក្រុមហ៊ុនតាមរយៈឥណទានពន្ធ ឬការឧបត្ថម្ភធនផ្ទាល់ដល់ក្រុមហ៊ុនដែលបង្កើតកម្មវិធីបណ្តុះបណ្តាលក្នុងស្ថាប័នដោយផ្តោតលើការលើកកម្ពស់មត្ថភាពបច្ចេកទេស និងការគ្រប់គ្រង និង (iv) ផ្តល់ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ឬជំនួយឥតសំណងសម្រាប់ក្រុមហ៊ុនដែលផ្តោតលើការកែលម្អដំណើរការ ការគ្រប់គ្រង lean management និងការច្នៃប្រឌិតជាបន្ត។

- **គាំទ្រនិងលើកទឹកចិត្តក្រុមហ៊ុនឱ្យប្រើប្រាស់បច្ចេកវិទ្យាដែលជួយបង្កើនផលិតភាព។** គំនិតជាក់លាក់រួមមាន (i) ធ្វើឱ្យប្រសើរឡើងនូវជំនាញបច្ចេកវិទ្យាកម្លាំងពលកម្មតាម រយៈការបង្កើត ឬកែលម្អកម្មវិធីអភិវឌ្ឍជំនាញ និងភាពជាដៃគូបណ្តុះបណ្តាលសាធារណៈនិងឯកជនក្នុងគោលបំណងជំរុញជំនាញឌីជីថល និងបច្ចេកទេស (ឧទាហរណ៍ បញ្ញាសិប្បនិម្មិត និងការវិភាគទិន្នន័យធំ) (ii) ផ្តល់ការបន្ធូរបន្ថយពន្ធតាមគោលដៅ ឬកម្មវិធីផ្តល់ជំនួយឥតសំណងដើម្បីលើកទឹកចិត្តដល់ក្រុមហ៊ុន ជាពិសេសសហគ្រាសធុនតូច និងមធ្យម (SMEs) ឱ្យវិនិយោគលើការប្រើប្រាស់បច្ចេកវិទ្យានិងការផ្លាស់ប្តូរទៅជាឌីជីថល (iii) បង្កើតកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍន៍សាធារណៈ និងមជ្ឈមណ្ឌលផ្ទេរបច្ចេកវិទ្យា ដើម្បីជួយក្រុមហ៊ុនឱ្យមានលទ្ធភាពទទួលបានបច្ចេកវិទ្យាទំនើបៗ និងការច្នៃប្រឌិតដែលពួកគេអាចអនុវត្តដើម្បីបង្កើនផលិតភាព និង (iv) គាំទ្រការអភិវឌ្ឍ និងការសាយភាយវេទិកាឌីជីថលដែលអាចមានឥទ្ធិពលវិជ្ជមានទៅលើផលិតភាព (ឧទាហរណ៍ វេទិកាពាណិជ្ជកម្មអេឡិចត្រូនិក ឬសេវាកម្មផ្អែកលើពពក)។
- **គាំទ្រក្រុមហ៊ុនឱ្យបង្កើនការផ្តោតលើទីផ្សារអន្តរជាតិរបស់ពួកគេរួមទាំងការដោះស្រាយឧបសគ្គផ្នែកហេដ្ឋារចនាសម្ព័ន្ធចំពោះពាណិជ្ជកម្ម និងការកែលម្អប្រសិទ្ធភាពដំណើរការពាណិជ្ជកម្ម (សូមមើល "ខ. ហេដ្ឋារចនាសម្ព័ន្ធ" ខាងក្រោមសម្រាប់ព័ត៌មានលម្អិតបន្ថែម) និងការកែលម្អសេវាកម្មដើម្បីជួយឱ្យក្រុមហ៊ុនទទួលបានទីផ្សារថ្មី។** ឧទាហរណ៍ កម្ពុជាអាចធ្វើឱ្យប្រសើរឡើងនូវការលើកកម្ពស់ការនាំចេញ ការធ្វើពិពិធកម្ម និងសេវាកម្មតភ្ជាប់របស់ខ្លួន ដើម្បីជួយក្រុមហ៊ុនកម្ពុជាឱ្យកាន់តែខិតចូល និងរួមបញ្ចូលជាមួយទីផ្សារអាស៊ីប៉ូព៌ា និងខ្សែច្រវាក់ផ្គត់ផ្គង់ (ពាណិជ្ជកម្មរបស់កម្ពុជាផ្តោតលើសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប)។

**ជាចុងក្រោយ កម្ពុជាគួរតែផ្តល់អាទិភាព និងដោះស្រាយឧបសគ្គដ៏ធ្ងន់ធ្ងរបំផុតដែលបានលើកឡើងដោយក្រុមហ៊ុនរបស់ខ្លួន។** អត្ថបទផ្តោតពិសេសនេះបានរំលេចថា តម្រូវការចាំបាច់បំផុតរួមមាន (ក) ការធានាថា អត្ថប្រយោជន៍ នៃការចុះបញ្ជីក្រុមហ៊ុនមានលើសពីការចំណាយ ជាពិសេសសម្រាប់ ក្រុមហ៊ុនតូចៗ។ ខ) ការកែលម្អហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (គ) ការកែលម្អលទ្ធភាពទទួលបានជំនាញ និងហិរញ្ញវត្ថុក្នុង ចំណោមក្រុមហ៊ុនទំនើបៗ (ឃ) សម្រួលរបបសារពើពន្ធដ៏ស្មុគស្មាញ និងចំណាយច្រើន (ង) កាត់ បន្ថយអំពើពុករលួយ (ច) ធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព និងភាពមិនលំអៀងនៃមជ្ឈត្តកម្មតុលាការក្នុងកិច្ចការពាណិជ្ជកម្ម និង (ឆ) លើកកម្ពស់ ការផ្តល់ និងប្រសិទ្ធភាពនៃសេវាកម្មអាជីវកម្ម។ គំនិតគោល នយោបាយជាក់លាក់ដើម្បីដោះស្រាយបញ្ហានីមួយៗក្នុងចំណោម បញ្ហាទាំងនេះរួមមាន៖

ក. **ក្រុមហ៊ុនក្រៅផ្លូវការ៖ ធានាថា អត្ថប្រយោជន៍នៃការចុះបញ្ជីក្រុមហ៊ុនមានលើសពីការចំណាយ** ហើយទម្រង់បែបបទនោះផ្តល់ជាផ្លូវមួយឆ្ពោះទៅកាន់ផលិតភាពខ្ពស់ និងឱកាសអាជីវកម្មកាន់តែប្រសើរ[34]។

- **កាត់បន្ថយឧបសគ្គ និងការចំណាយលើការចុះបញ្ជីក្រុមហ៊ុន។** ខណៈពេលដែលដំណើរការចុះបញ្ជីអាជីវកម្មភាគច្រើនបានដំណើរការលើអ៊ីនធឺណិតក្នុងអំឡុងពេលកើតមានជំងឺរាតត្បាតកូវីដ-១៩ (ដែលជួយកាត់បន្ថយការចំណាយក្រៅផ្លូវការ និងថ្លៃដើមបានច្រើន) ការទទួលបានអាជ្ញាប័ណ្ណអាជីវកម្មនៅក្នុងប្រទេសកម្ពុជានៅតែបន្តចំណាយកាន់តែច្រើននិងចំណាយពេលកាន់តែយូរក្នុង បើធៀបនឹងប្រទេសក្នុងតំបន់ ដែលបន្តចបង្អាក់ក្រុមហ៊ុនពីការចុះបញ្ជី។ ប្រទេសកម្ពុជាគួរតែស្វែងរកឱកាសបន្ថែមទៀតដើម្បីសម្រួល និងពន្លឿនដំណើរការ និងកាត់បន្ថយការចំណាយ (សូមមើល "ឆ. ឯកសារពាណិជ្ជកម្មខាងក្រោម)។ ប្រទេសកម្ពុជាក៏អាចពិចារណាលើការពង្រីកមជ្ឈមណ្ឌលចុះបញ្ជីអាជីវកម្ម និងសេវាកម្មនៅតំបន់ជនបទ និងតំបន់ទីក្រុងតូចៗផងដែរ ដើម្បីបង្កលក្ខណៈងាយស្រួលសម្រាប់ក្រុមហ៊ុនក្រៅផ្លូវការដែលប្រតិបត្តិការនៅក្នុងតំបន់ទាំងនោះក្នុងការចុះបញ្ជីដោយលុបបំបាត់ចោលឧបសគ្គភូមិសាស្ត្រចំពោះប្រែក្លាយទៅជាក្រុមហ៊ុនផ្លូវការ។
- **ការបង្កើនអត្ថប្រយោជន៍នៃការចុះឈ្មោះ។** កម្ពុជាអាចពិចារណាផ្តល់វិធានការលើកទឹកចិត្តជាច្រើន ដើម្បីលើកទឹកចិត្តក្រុមហ៊ុនក្រៅផ្លូវការឱ្យចុះឈ្មោះ និងធ្វើឱ្យការចុះឈ្មោះនោះមានតម្លៃ។ ឧទាហរណ៍ ប្រទេសកម្ពុជាអាចផ្តល់ការបន្ធូរបន្ថយពន្ធបណ្តោះអាសន្ន ឬកាត់បន្ថយថ្លៃសេវាសម្រាប់ក្រុមហ៊ុនដែលបានចុះបញ្ជីថ្មី។ លើសពីនេះ ក្រុមហ៊ុនដែលបានចុះបញ្ជីអាចត្រូវបានផ្តល់ភាពកាន់តែងាយស្រួលក្នុងការទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ រួមទាំងកម្ចីធនាគារ កម្រិតបន្ទាត់ឥណទាន និងការគាំទ្រផ្នែកហិរញ្ញវត្ថុពីកម្មវិធីរដ្ឋាភិបាល។ កម្ពុជាក៏ អាច

34 ទិដ្ឋភាពក្រុមហ៊ុនក្រៅផ្លូវការនៅក្នុងប្រទេសកម្ពុជា និងឧបសគ្គរបស់ពួកគេនឹងត្រូវបានពិនិត្យមើលយ៉ាងលម្អិតសម្រាប់ជាផ្នែកមួយនៃឯកសារការងារជាសេរីស្តីពី "ការប្រើប្រាស់ការអង្កេតលើក្រុមហ៊ុនក្រៅផ្លូវការ" ដែលនឹងចេញផ្សាយនាពេលខាងមុខ។

ផ្តល់ជំនួយឥតសំណងឬឧបត្ថម្ភធន (ឧទាហរណ៍ សម្រាប់ការប្រើប្រាស់បច្ចេកវិទ្យា និងការកសាងសមត្ថភាព និងកម្មវិធីបណ្តុះបណ្តាលកម្លាំងពលកម្ម និងការគ្រប់គ្រង) ដែលមានសម្រាប់តែក្រុមហ៊ុនដែលបានចុះបញ្ជីប៉ុណ្ណោះ។ នៅទីបំផុត រដ្ឋាភិបាលអាចផ្តល់ការអនុគ្រោះដល់ក្រុមហ៊ុនតូចៗដែលបានចុះបញ្ជីនូវសិទ្ធិពិសេសក្នុងការទទួលបានកិច្ចសន្យាលទ្ធកម្មរបស់រដ្ឋាភិបាល។

**ខ. ហេដ្ឋារចនាសម្ព័ន្ធ៖ ដោះស្រាយអាទិភាពសំខាន់ៗ[35]។**

- **ក្នុងការដឹកជញ្ជូន** អាទិភាពគឺត្រូវដោះស្រាយភាពខ្វះខាតនៅតាមច្រករបៀងដឹកជញ្ជូនក្នុងតំបន់អាទិភាព ដើម្បីជួយសម្រួលដល់ការតភ្ជាប់ និងពាណិជ្ជកម្មក្នុងតំបន់ប្រកបដោយប្រសិទ្ធភាព ធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់ក្នុងស្រុកដែលមានភាពធន់ (ផ្លូវខេត្ត និងជនបទ) និងបង្កើនមូលនិធិសម្រាប់ការថែទាំទ្រព្យសម្បត្តិដើម្បីធានានិរន្តរភាពនៃការវិនិយោគ។ គំនិតផ្តួចផ្តើមជាអាទិភាពរួមមានការកែលម្អ (i) ច្រករបៀងខាងកើត-ខាងលិចរវាងប្រទេសថៃ កម្ពុជា និងវៀតណាម (និងច្រករបៀងផ្លូវតភ្ជាប់ប្រទេសកម្ពុជាជាមួយប្រទេសឡាវដែលជាច្រករបៀងតែមួយគត់រវាងប្រទេសទាំងពីរ) (ii) ការតភ្ជាប់ផ្លូវទឹកនៃដីគោកជាមួយវៀតណាម និង (ii) ប្រតិបត្តិការផ្លូវដែកដែលមានស្រាប់ និងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធជាមួយប្រទេសថៃ។
- **ក្នុងផ្នែកឡូជីស្ទិក** ចាំបាច់ត្រូវកែលម្អលំហូរឡូជីស្ទិកដែលមានភាពធន់និងប្រកបដោយប្រសិទ្ធភាពតាមរយៈការលើកកម្ពស់ប្រតិបត្តិការដឹកជញ្ជូនចម្រុះ និងជំរុញកិច្ចខិតខំប្រឹងប្រែងលើការសម្របសម្រួលពាណិជ្ជកម្មឆ្លងដែន ដូចជាស្វ័យប្រវត្តិកម្មពេញលេញនិងតម្លាភាពក្នុងការបំពេញទម្រង់បែបបទបញ្ចេញទំនិញពីគយក្នុងទម្រង់ជាប្រព័ន្ធច្រកព្រំដែនតែមួយ (OSBPs) ដោយផ្តោតលើការត្រួតពិនិត្យតែនៅមួយកន្លែង (SSI)/តំបន់ត្រួតពិនិត្យរួម (CCA) ជាមួយប្រទេសថៃ និងវៀតណាម ដើម្បីសម្រួលដល់ការឆ្លងកាត់ព្រំដែន និងការដឹកជញ្ជូន។
- **ក្នុងវិស័យទូរគមនាគមន៍** ចាំបាច់ត្រូវជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធអ៊ិនធឺណិតមានខ្សែ ជាពិសេសនៅតំបន់ជនបទ ធ្វើឱ្យប្រសើរឡើងនូវល្បឿន និងគុណភាពនៃការតភ្ជាប់ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធសន្តិសុខអ៊ិនធឺណិត ដើម្បីស្វែងរកការគំរាមកំហែងតាមអ៊ិនធឺណិតឱ្យកាន់តែប្រសើរ ការពារហេដ្ឋារចនាសម្ព័ន្ធព័ត៌មានសំខាន់ៗ និងការពារទ្រព្យសម្បត្តិឌីជីថលរបស់ប្រទេស។

**គ. លទ្ធភាពទទួលបានជំនាញ និងហិរញ្ញវត្ថុ៖ ធ្វើឱ្យប្រសើរឡើងនូវការទទួលយក/ការប្រើប្រាស់ក្នុងចំណោមក្រុមហ៊ុនដែលមានជំនាញខ្ពស់/ទំនើប៖**

- **លទ្ធភាពទទួលបានជំនាញ ជាពិសេសសម្រាប់ក្រុមហ៊ុនធំៗនិងទំនើបជាង អាចត្រូវបានពង្រឹងតាមរយៈការពង្រឹងភាពជាដៃគូរវាងវិស័យអប់រំ ជាពិសេសការអប់រំវិជ្ជាជីវៈ និងឧស្សាហកម្ម។** ក៏មានភាពចាំបាច់ផងដែរក្នុងការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើការផ្តល់ជំនាញទំនើបនិងជំនាញពាក់ព័ន្ធឆ្លងវិស័យដល់សិស្សនិស្សិត (ឌីជីថល បច្ចេកវិទ្យា សង្គមអារម្មណ៍ បៃតង និងជំនាញផ្នែកស្មារតីកម្រិតខ្ពស់)។
- **កម្ពុជាអាចធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានហិរញ្ញវត្ថុ និងការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ ក៏ដូចជាការប្រើប្រាស់កាន់តែច្រើននូវការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈការអនុវត្តវិធីសាស្ត្រដ៏ទូលំទូលាយប្រកបដោយយុទ្ធសាស្ត្រក្នុងការលើកកម្ពស់ភាពជាម្ចាស់គណនីប្រតិបត្តិការ និងការប្រើប្រាស់ការទូទាត់តាមឌីជីថល, ធ្វើឱ្យមានភាពងាយស្រួលនូវហេដ្ឋារចនាសម្ព័ន្ធទូទាត់រួមទាំងតាមរយៈការផ្សព្វផ្សាយនិងពង្រីកប្រព័ន្ធបាគង សេវាផ្ទេរប្រាក់ពីបុគ្គលទីបុគ្គល (P2P), ពង្រីកបណ្តាញទទួលយកសម្រាប់ការទូទាត់ឌីជីថល, ធ្វើឌីជីថលនីយកម្មការទូទាត់របស់រដ្ឋាភិបាល, ឃ្លាំផ្តល់ធនធានក្នុងវិស័យសាធារណៈនិងឯកជនឱ្យបានគ្រប់គ្រាន់សម្រាប់ការអប់រំផ្នែកឌីជីថល និងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងរចនាផលិតផលដែលបំពេញតាមតម្រូវការនៃផ្នែកទីផ្សារផ្សេងៗគ្នា។**

**ឃ. រដ្ឋបាលសារពើពន្ធ៖ កាត់បន្ថយការចំណាយ និងបន្ទុកនៃអនុលោមភាពពន្ធដារ** ជាពិសេសតាមរយៈការកាត់បន្ថយការប្រជុំដោយផ្ទាល់មុខ និងដំណើរការប្រើប្រាស់ក្រដាសសរសេរដោយដៃដែលងាយនាំឱ្យមានការចំណាយក្រៅផ្លូវការយ៉ាងខ្លាំង។ គំនិតជាក់លាក់រួមមាន (i) ផ្តល់ការពន្យល់និង/ឬកំណត់ដែនកំណត់លើចំនួននៃការមកជួប/ការត្រួតពិនិត្យ និងការផ្លាស់កិច្ចការទាំងនេះទៅធ្វើតាមអ៊ិនធឺណិតតាមឱ្យបានច្រើនតាមដែលអាចធ្វើបាន (ដែលអាចធ្វើការត្រួតពិនិត្យ និងសវនកម្មបានកាន់តែងាយស្រួល) (ii) បង្កើនប្រសិទ្ធភាពការប្រើប្រាស់ភ្នាក់ងារពន្ធដារដែលត្រូវបានលើកទឹកចិត្តតាមរយៈកម្រៃជើងសារ ដើម្បីធ្វើសវនកម្មឱ្យបានយ៉ាងខ្លាំងក្លា ដែលបង្កើតការលើកទឹកចិត្តឱ្យមានការចំណាយក្រៅផ្លូវការ។ (iii) ធ្វើស្វ័យប្រវត្តិកម្មនិងឌីជីថលនីយកម្មប្រព័ន្ធពន្ធដារ និងធ្វើកិច្ចការបន្ថែមទៀតក្រៅពីការពង្រីកការបង់ពន្ធដារតាមអេឡិចត្រូនិច និងការទូទាត់តាមអេឡិចត្រូនិកដោយធ្វើឱ្យក្លាយជាកាតព្វកិច្ចចំពោះការបង់ពន្ធដារតាម

35 សូមមើល របាយការណ៍ស្តីពី បច្ចុប្បន្នភាពការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ ជំនាន់ទីពីររបស់ប្រទេសកម្ពុជា (ធនាគារពិភពលោក ឆ្នាំ២០២៤)

អេឡិចត្រូនិចនិងការទូទាត់តាមអេឡិចត្រូនិក និងដាក់ឱ្យប្រើប្រាស់ការប្រកាសពន្ធដែលបំពេញជាមុន (prefilled declarations) សម្រាប់អ្នកជាប់ពន្ធ (iv) ធ្វើឱ្យប្រសើរឡើងនូវដំណើរការចុះបញ្ជីពន្ធ រួមទាំងធ្វើឡើងតាមរយៈការពង្រីកឬសូម្បីតែធ្វើឱ្យក្លាយជាកាតព្វកិច្ចនូវការប្រើប្រាស់លេខអត្តសញ្ញាណអ្នកជាប់ពន្ធ (TINs) (v) ពង្រឹងការអនុវត្តសវនកម្មពន្ធ រួមទាំងតាមរយៈការអនុវត្តសវនកម្មខាងក្នុងនិងខាងក្រៅដោយចៃដន្យ ដើម្បីទប់ស្កាត់អាកប្បកិរិយាពុករលួយ ការបង្កើតយន្តការជម្លោះសមស្រប ដើម្បីប្រជែងជាមួយនឹងលទ្ធផលសវនកម្ម ការពិនិត្យមើលគុណភាពសវនកម្មតាមដំណាក់កាល និងការវាយតម្លៃផលជះសវនកម្មលើអនុលោមភាពពន្ធ (vi) បង្កើតប្រព័ន្ធនានា (ដូចជាខ្សែទូរស័ព្ទទាន់ហេតុការណ៍ អង្គភាពស៊ើបអង្កេតឯករាជ្យ) សម្រាប់ក្រុមហ៊ុនដើម្បីរាយការណ៍អំពីការស្នើសុំការចំណាយក្រៅផ្លូវការ និងការប្រព្រឹត្តខុសផ្សេងៗទៀត (vii) បង្កើតផែនការកែលម្អអនុលោមភាពទូលំទូលាយ (CIP) និង (viii) បង្កើនប្រសិទ្ធភាពនីតិវិធីពន្ធដារ និងឯកសារដើម្បីកាត់បន្ថយភាពស្មុគស្មាញដើម្បីកាត់បន្ថយតម្រូវការឱ្យមានការជួបប្រជុំ ក៏ដូចជាការពឹងផ្អែកខ្លាំងលើទីប្រឹក្សាពន្ធដារ សវនករ និងភ្នាក់ងារខាងក្រៅ[36]។

ង. **អំពើពុករលួយ៖ កាត់បន្ថយការកើតមានការចំណាយក្រៅផ្លូវការក្នុងចំណោមក្រុមហ៊ុននៅកម្ពុជាតាមរយៈ** (i) ការរៀបចំប្រព័ន្ធ (ឧទាហរណ៍ ខ្សែទូរស័ព្ទទាន់ហេតុការណ៍) និងលើកទឹកចិត្តក្រុមហ៊ុនឱ្យរាយការណ៍អំពីការស្នើសុំការចំណាយក្រៅផ្លូវការ។ (ii) ការបង្កើនការពិន័យសម្រាប់មន្ត្រីសាធារណៈដែលចាប់បានការទារប្រាក់ក្រៅផ្លូវការ (iii) ការធ្វើឌីជីថលការទូទាត់ថ្លៃសេវាសាធារណៈដើម្បីកាត់បន្ថយឱកាសសម្រាប់ការចំណាយក្រៅផ្លូវការ ដែលជាជំហានដំបូងនៅក្នុងការផ្លាស់ប្តូរទៅជាឌីជីថលរបស់រដ្ឋាភិបាលកាន់តែទូលំទូលាយ និង (iv) ការពង្រឹងស្ថាប័នដែលសម្របសម្រួលកិច្ចសន្ទនាក្នុងន័យស្ថាបនារវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការចូលរួម។

ច. **តុលាការ៖ កែលម្អការអនុវត្តកិច្ចសន្យាពាណិជ្ជកម្ម**តាមរយៈការបង្កើតតុលាការពាណិជ្ជកម្មឯកទេស និងការបង្កើនតម្លាភាពនិងឌីជីថលនីយកម្មតុលាការ។ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតត្រូវការជាចាំបាច់ដើម្បីកាត់បន្ថយពេលវេលានិងធនធាន ដែលត្រូវការដើម្បីដោះស្រាយរឿងក្តីនៅតុលាការសាលាដំបូង តុលាការឧទ្ធរណ៍ ឬនៅមជ្ឈត្តកម្ម។ ប្រព័ន្ធគ្រប់គ្រងសំណុំរឿងអេឡិចត្រូនិកសម្រាប់ទំនាក់ទំនងជាមួយតុលាការគួរតែត្រូវបានបង្កើតឡើង។ ការអនុញ្ញាតឱ្យដាក់ជូនឯកសារតុលាការតាមអេឡិចត្រូនិក និងលទ្ធភាពធ្វើសវនាការតាមអ៊ិនធឺណិតនឹងជួយសម្រួលដល់ការទទួលបានប្រសិទ្ធភាព។ ការសម្រុះសម្រួលពាណិជ្ជកម្មក្រៅប្រព័ន្ធតុលាការគួរតែត្រូវបានលើកកម្ពស់ជាមួយនឹងការបង្កើតមូលដ្ឋានច្បាប់មួយសម្រាប់ការដាក់ពាក្យស្នើសុំ។

ឆ. **ការអនុញ្ញាតអាជីវកម្ម៖ កាត់បន្ថយការចំណាយដោយផ្ទាល់និងដោយប្រយោល និងពេលវេលា**សម្រាប់ឯកសារអាជីវកម្មដូចជាការទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការ ឬលិខិតអនុញ្ញាតនាំចូលតាមរយៈការបង្កើនតម្លាភាព និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថលកាន់តែច្រើន។ គំនិតជាក់លាក់រួមមាន៖

- **ធ្វើឌីជីថលពេញលេញនៃវិបផតថលចុះបញ្ជីអាជីវកម្មនិងបន្តពង្រីកបញ្ជីស្ថាប័នដែលតភ្ជាប់។** ការបញ្ចប់ការអនុវត្តវិបផតថលចុះបញ្ជីអាជីវកម្មនឹងធានាបាននូវដំណើរការអនឡាញពេញលេញ។ មុខងារថ្មីៗដែលអាចត្រូវបានបន្ថែមទៅវិបផតថល រួមមានហត្ថលេខាអេឡិចត្រូនិកនិងការផ្ទៀងផ្ទាត់ ក៏ដូចជាការផ្ទៀងផ្ទាត់ឯកសារអត្តសញ្ញាណ។ វិបផតថលគួរតែត្រូវបានពង្រីកផងដែរដើម្បីរួមបញ្ចូលស្ថាប័នផ្សេងទៀតដូចជា បេឡាជាតិសន្តិសុខសង្គម (ដែលអាចត្រូវបានប្រើដើម្បីចុះឈ្មោះបុគ្គលិក) និងអង្គភាពថ្នាក់ក្រោមជាតិដែលមានសក្តានុពលនានា (ដើម្បីចុះឈ្មោះក្រុមហ៊ុនតូចៗ និងកាត់បន្ថយភាពមិនផ្លូវការ)។ លើសពីនេះ ការអនុញ្ញាតឱ្យការដោះដូរព័ត៌មានដោយស្វ័យប្រវត្តិក្នុងចំណោមភ្នាក់ងារវិស័យសាធារណៈដែលភ្ជាប់ទៅវិបផតថលនឹងកាត់បន្ថយសំណើសុំព័ត៌មានដដែលៗច្រើនដង។
- **ការបង្កើតបញ្ជីសារពើភណ្ឌអាជ្ញាប័ណ្ណនិងការអនុញ្ញាតពេញលេញ ការដាក់ចេញ និងការអនុវត្តវិធីសាស្ត្រផ្អែកលើហានិភ័យក្នុងការផ្តល់អាជ្ញាបណ្ណ និងការបង្កើនប្រសិទ្ធភាពអាជ្ញាប័ណ្ណតាមវិស័យ។** សារពើភ័ណ្ឌអាជ្ញាប័ណ្ណដែលមានព័ត៌មានអំពីដំណើរការ តម្រូវការឯកសារ និងថ្លៃសេវា នឹងបង្កើនតម្លាភាព និងកាត់បន្ថយការចំណាយរដ្ឋបាលទៅលើការអនុលោមតាមច្បាប់សម្រាប់អាជីវកម្ម។ ទោះជាយ៉ាងណា វិធានការបែបនេះជារឿយៗបង្ហាញឱ្យឃើញពីបញ្ហាប្រឈមនៃការសម្របសម្រួលដោយសារមានភ្នាក់ងារច្រើនពាក់ព័ន្ធក្នុងការផ្តល់អាជ្ញាប័ណ្ណសម្រាប់ប្រតិបត្តិការអាជីវកម្ម។ ប្រទេសកម្ពុជាក៏អាចពិចារណាផ្លាស់ប្តូរឆ្ពោះទៅរកវិធីសាស្ត្រផ្អែកលើហានិភ័យក្នុងការផ្តល់អាជ្ញាប័ណ្ណផងដែរ ដែលនឹងជួយកាត់បន្ថយបន្ទុកអនុលោមភាពទៅលើក្រុមហ៊ុនដែលមានហានិភ័យទាប និងជួយដឹកនាំធនធានរបស់រដ្ឋាភិបាលមានកម្រិតឆ្ពោះទៅរកការគ្រប់គ្រង និងការត្រួតពិនិត្យក្រុមហ៊ុនពាក់ព័ន្ធនឹងសកម្មភាពនានាដែលបង្កហានិភ័យខ្ពស់ (បរិស្ថាន សុខភាពសាធារណៈ សុវត្ថិភាព ជាដើម)។

36 ធនាគារពិភពលោក ដែលនឹងចេញផ្សាយនាពេលខាងមុខ (b)។

# ឧបសម្ព័ន្ធ៖ កម្ពុជា-សូចនាករសំខាន់ៗ

| សូចនាករសំខាន់ៗ* | A ១០-១៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤F |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ប្រាក់ចំណូលនិងកំណើនសេដ្ឋកិច្ច** | | | | | | | | | | | | | | | | |
| កំណើន ផ.ស.ស (ប្រចាំឆ្នាំ %) | ៧,៦ | ៥,១ | ៧,៣ | ៧,៧ | ៧,៩ | ៨,០ | ៧,២ | ៧,៩ | ៨,១ | ៨,៨ | ៧,៩ | -៣,៦ | ៣,១ | ៥,១ | ៥,០ | ៥,៣ |
| កំណើន ផ.ស.ស ក្នុងមនុស្សម្នាក់ (ប្រចាំឆ្នាំ %, ពិត) | ៦,១ | ៣,៦ | ៥,៧ | ៦,១ | ៦,៣ | ៦,៥ | ៥,៨ | ៦,៥ | ៦,៧ | ៧,៥ | ៦,៧ | -៤,៧ | ១,៩ | ៤,០ | ៣,៩ | ៤,២ |
| កំណើន ផ.ស.ស ក្នុងមនុស្សម្នាក់ (ដុល្លារអាមេរិក, ណូនីណល) | ១.៥៥៤ | ៩៩៥ | ១.១១២ | ១.២០៦ | ១.៣២១ | ១.៤៥២ | ១.៥៨៥ | ១.៧០០ | ១.៨៤៩ | ២.០៦០ | ២.២៥៩ | ២.១៣១ | ២.២១៧ | ២.៣៥៨ | ២.៥២៥ | ២.៦៩៦ |
| កំណើនប្រើប្រាស់ឯកជន (ប្រចាំឆ្នាំ %) | ៦,៤ | ៩,៣ | ១០,៨ | ៦,០ | ៦,៨ | ៥,៤ | ៥,៧ | ៤,៦ | ៦,៧ | ៥,៥ | ៣,៤ | -១,៩ | -២,៤ | ៥,២ | -០,២ | ០,៧ |
| ការវិនិយោគដុល (% នៃ ផ.ស.ស ណូមីណល) | ២៧ | ២១,៣ | ២១,៤ | ២៣,៧ | ២៥,៩ | ២៩,១ | ២៩,០ | ២៩,៥ | ២៩,៨ | ៣០,០ | ៣០,៧ | ៣០,៦ | ២៩,៧ | ៣៤,០ | ២០,៤ | ១៧,៥ |
| ការវិនិយោគដុល-សាធារណៈ (% នៃ ផ.ស.ស ណូមីណល)[2] | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | |
| **រូបិយវត្ថុនិងតម្លៃ** | | | | | | | | | | | | | | | | |
| អតិផរណា តម្លៃទំនិញប្រើប្រាស់ (ប្រចាំឆ្នាំ %, EOP ឬ MRV)[1] | ២,៩ | ២,៩ | ៤,៦ | ២,៣ | ៤,៥ | ០,៩ | ២,៨ | ៣,៨ | ២,២ | ១,៦ | ៣,១ | ៣,០ | ៣,៨ | ៣,០ | ២,៨ | ០,៧ |
| អតិផរណា តម្លៃទំនិញប្រើប្រាស់ (ប្រចាំឆ្នាំ %, រយៈពេលមធ្យម) | ២,៩ | ២,៦ | ៥,៥ | ៣,០ | ២,៩ | ៣,៩ | ១,២ | ៣,០ | ២,៩ | ២,៥ | ១,៩ | ២,៩ | ២,៨ | ៥,៥ | ២,១ | ២,២ |
| រូបិយវត្ថុមូលដ្ឋាន (% នៃ ផ.ស.ស) | ៥៤ | ៣៣,៩ | ៣១,៣ | ៣៩,៥ | ៤៣,៣ | ៥១,១ | ៥៤,១ | ៥៩,៧ | ៦៦,៦ | ៧៤,៧ | ៨៥,៩ | ១០៦,៥ | ៩៥,៨ | ៦៦,២ | ៦៣,០ | ៦២,៨ |
| ឥណទានក្នុងស្រុកផ្តល់ឱ្យវិស័យឯកជន (% នៃ ផ.ស.ស)[2] | ៦៦,៦ | ២៧,៦ | ២៨,៣ | ៣៨,៧ | ៥២,០ | ៦២,៧ | ៧៤,៣ | ៨១,៧ | ៨៦,៧ | ៩៩,៦ | ១១៤,២ | ១៣៩,៦ | ១៦៦,៣ | ១៨០,០ | .. | .. |
| អត្រាការប្រាក់រយៈពេល ១០ឆ្នាំ (ជាមធ្យមប្រចាំឆ្នាំ)[1] | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| អត្រាប្តូរប្រាក់ណូមីណល (រូបិយប័ណ្ណក្នុងស្រុកក្នុងមួយដុល្លារ) | ៤.០៤៣ | ៤.០៤៤ | ៤.០១៦ | ៤.០៣៣ | ៤.០២៧ | ៤.០៣០ | ៤.០២៥ | ៤.០៥៨ | ៤.០៦២ | ៤.០៦៧ | ៤.០៧០ | ៤.០៧៧ | ៤.១០០ | ៤.១៥០ | ៤.១១០ | ៤.១០០ |
| សន្ទស្សន៍អត្រាប្តូរប្រាក់ពិត (២០១៥ =១០០) | ៩៧,៧ | ៩១,៨ | ៩១,១ | ៩០,៧ | ៩១,៧ | ៩៣,១ | ១០០ | ១០៥,២ | ១០៣,១ | ១០៥,៤ | ១០៥,១ | ៩៨,៤ | ១០០,៤ | ៩៤,០ | ៧៩,៦ | ៧៨,០ |
| **សារពើពន្ធ** | | | | | | | | | | | | | | | | |
| ប្រាក់ចំណូល (% នៃ ផ.ស.ស) | ១៥,៦ | ១៤,៤ | ១៤,១ | ១៣,៩ | ១៤,២ | ១៥,២ | ១៤,៧ | ១៥,៧ | ១៦,៥ | ១៧,៧ | ២០,០ | ១៧,៩ | ១៦,២ | ១៧,២ | ១៥,៩ | ១៥,៤ |
| ការចំណាយ (% នៃ ផ.ស.ស) | ១៧,០ | ១៧,១ | ១៨,០ | ១៧,១ | ១៦,៧ | ១៦,៦ | ១៥,១ | ១៥,៩ | ១៧,១ | ១៧,៤ | ១៨,៨ | ២១,៣ | ២១,៣ | ២០,៤ | ២១,០ | ១៨,៤ |
| ការបង់សងការប្រាក់ (% នៃ ផ.ស.ស) | ០,៣ | ០,២ | ០,២ | ០,៤ | ០,៦ | ០,៥ | ០,២ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៤ |
| ការចំណាយមិនមែនការប្រាក់ (% នៃ ផ.ស.ស) | ១៦,៦ | ១៦,៩ | ១៧,៧ | ១៦,៧ | ១៦,១ | ១៦,១ | ១៤,៨ | ១៥,៦ | ១៦,៨ | ១៧,១ | ១៨,៥ | ២០,៩ | ២០,៩ | ២០,១ | ២០,៧ | ១៨,១ |
| សមតុល្យសារពើពន្ធសរុប (% នៃ ផ.ស.ស) | -១,៣ | -២,៧ | -៣,៩ | -៣,២ | -២,៥ | -១,៣ | -០,៣ | -០,២ | -០,៦ | ០,៣ | ១,១ | -៣,៤ | -៥,១ | -៣,២ | -៥,១ | -៣,០ |
| សមតុល្យសារពើពន្ធចម្បង (% នៃ ផ.ស.ស) | -១,០ | -២,៥ | -៣,៦ | -២,៨ | -១,៩ | -០,៨ | -០,១ | -០,១ | -០,៣ | ០,៦ | ១,៤ | -៣,១ | -៤,៨ | -២,៩ | -៤,៨ | -២,៦ |
| បំណុលរដ្ឋាភិបាលទូទៅ (% នៃ ផ.ស.ស) | ២៣,១ | ២៣,៤ | ២៣,៨ | ២៤,៩ | ២៤,៤ | ២៤,២ | ២៣,៣ | ២២,០ | ២២,៩ | ២១,០ | ២០,៨ | ២៦,៦ | ២៦,៥ | ២៧,០ | ២៧,៥ | ២៦,៩ |
| បំណុលសាធារណៈបរទេស (% នៃ ផ.ស.ស)[2] | ២៩,៤ | ២៧,២ | ២៧,០ | ៣០,៥ | ៣១,៦ | ៣១,៥ | ៣១,៣ | ២៩,២ | ២៩,៧ | ២៨,៥ | ២៨,០ | ៣៤,០ | ៣៥,២ | ៣៤,១ | .. | .. |

| សូចនាករសំខាន់ៗ* | A ១០-១៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤F |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **គណនីខាងក្រៅ** | | | | | | | | | | | | | | | | |
| កំណើននាំចេញ, G&S (ដុល្លារអាមេរិកល្អមីណល, % ប្រចាំឆ្នាំ) | ១២,៤ | ២២.៩ | ១១,៤ | ១៦,០ | ១៦,៨ | ១០,៣ | ៧,៥ | ៩,០ | ៩,៤ | ១២,៣ | ៨,៣ | ២,១ | ១១,២ | ៣១,៩ | ១៦,៦ | ១០,៦ |
| កំណើននាំចូល, G&S (ដុល្លារអាមេរិកល្អមីណល, % ប្រចាំឆ្នាំ) | ១២,២ | ១៩,១ | ១១,៤ | ១៤,២ | ១៦,៩ | ៨,៨ | ៧,៦ | ៩.០ | ៧,៨ | ៩,៣ | ១៧,៤ | ៩,៧ | ៤៧,៨ | ៣៧,២ | -១៩,៨ | ៥,២ |
| ការនាំចេញទំនិញ (% នៃ ផ.ស.ស) | ៣៣,៥ | ៣១,១ | ៣១,១ | ៣២,៨ | ៣៤,៨ | ៣៤,៦ | ៣៣,៩ | ៣៤,៤ | ៣៤,១ | ៣៤,១ | ៣៣,៩ | ៣៨,៥ | ៤៦,០ | ៥២,៧ | ៥៤,៧ | ៥៧,០ |
| ការនាំចូលទំនិញ (% នៃ ផ.ស.ស) | ៤២,១ | ៤១,១ | ៤០,៤ | ៤២,៣ | ៤៤,៩ | ៤៣,៧ | ៤២,៨ | ៤២,៩ | ៤២,០ | ៤០,៩ | ៤០,៣ | ៤៨,៩ | ៦៧,៧ | ៦៨,៦ | ៥៤,៨ | ៥៨,៤ |
| សេវាកម្ម, សុទ្ធ (% នៃ ផ.ស.ស) | ៥,១ | ៥,៥ | ៥,០ | ៥,៧ | ៦,១ | ៥,៨ | ៥,៦ | ៥,៣ | ៥,៣ | ៥,៥ | ១,៣ | ១,០ | -៨,០ | -២៤,៥ | -៩,០ | -៤,២ |
| សមតុល្យគណនីចរន្ត (លានដុល្លារអាមេរិកចរន្ត) | -១.៦០២,១ | -១.១៦៥,៣ | -១.៣០៩,៣ | -១.៣៩០,៧ | -១.៨៨៩,៣ | -១.៨៩៩,៧ | -១.៦៨០,៦ | -១.៧៥៦,៥ | -១.៦៣៤,៤ | -១.៥៤០,៥ | -២.១៥៥,០ | -១.៩៣៨,៣ | -១០.៧១១,១ | -៧.៤៣៧,៥ | -៥៦១,៤ | -៤៥០,១ |
| សមតុល្យគណនីចរន្ត (% នៃ ផ.ស.ស) | -៧,០ | -៨,២ | -៨,១ | -៧,៨ | -៧,៥ | -៨,៦ | -៦,៩ | -៦,៦ | -៥,៦ | -៤,៧ | -៥,៩ | -៥,៥ | -២៩,១ | -១៨,៨ | ១,៣ | -១,០ |
| ការវិនិយោគផ្ទាល់ពីបរទេស, លំហូរចូលសុទ្ធ (% នៃ ផ.ស.ស) | ៩,៣ | ៩.៦ | ៩,៤ | ១១,០ | ១០,១ | ៨,០ | ៧,១ | ៩,០ | ៩,១ | ៩,៤ | ៩,៧ | ១០,០ | ៩,២ | ៨,៧ | ៨,៥ | ៨,៨ |
| បំណុលពហុភាគី (% នៃបំណុលបរទេសសរុប)[2] | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | |
| **ប្រជាជន ការងារ និងភាពក្រីក្រ** | | | | | | | | | | | | | | | | |
| ចំនួនប្រជាជនសរុប (លាន) | ១៥,៣ | ១៤,៤ | ១៤,៦ | ១៤,៨ | ១៥,០ | ១៥,២ | ១៥,៤ | ១៥,៦ | ១៥,៨ | ១៦,០ | ១៦,២ | ១៦,៤ | ១៦,៦ | ១៦,៨ | ១៦,៩ | ១៧,១ |
| កំណើនប្រជាជន (% ប្រចាំឆ្នាំ) | ១,៤ | ១,៥ | ១,៥ | ១,៥ | ១,៤ | ១,៤ | ១,៤ | ១,៣ | ១,៣ | ១,២ | ១,១ | ១,២ | ១,២ | ១,១ | ១,១ | ១,០ |
| អត្រាគ្មានការងារធ្វើ[2] | ០,៤ | ០,៨ | ០,៦ | ០,៥ | ០,៤ | ០,៧ | ០,៤ | ០,៧ | ០,១ | ០,១ | ០,១ | ០,២ | ០,៤ | ០,២ | ០,២ | .. |
| វិសមភាព - មេគុណ Gini[2] | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| អាយុរស់រំពឹងទុក[2] | ៦៩,៦ | ៦៧,៧ | ៦៨,៤ | ៦៨,៩ | ៦៩,៣ | ៦៩,៧ | ៦៩,៩ | ៧០,២ | ៧០,៥ | ៧០,៦ | ៧០,៧ | ៧០,៤ | ៦៩,៦ | ៦៩,៩ | .. | .. |
| **ផ្សេងៗ** | | | | | | | | | | | | | | | | |
| ផ.ស.ស (ពាន់លាន, LCU ចរន្ត) | ៩៧.១៨០.២៧៦ | ៥៧.៧៨៨.១៤៧ | ៦៥.០៦៨.៣៩៦ | ៧១.៨៩៤.៤២៣ | ៧៩.៧៦៨.២៨៥ | ៨៨.៩៩២.៤១១ | ៩៨.៣៣៤.៤៨២ | ១០៧.៧៨៤.៩០៦ | ១១៨.៩០៧.៤៧៣ | ១៣៤.២៧៩.៥៤១ | ១៤៨.៩៨៤.៦៩៧ | ១៤២.៥០២.៨២៩ | ១៥០.៧៩២.៦៨៣ | ១៦៤.០៥៩.០៨៩ | ១៧៥.៨២២.៥៨០ | ១៨៩.២៧០.៩២៩ |
| ផ.ស.ស (លានដុល្លារអាមេរិក ចរន្ត) | ២៤.០១០ | ១៤.២៩០ | ១៦.២០២ | ១៧.៨២៧ | ១៩.៨០៨ | ២២.០៨២ | ២៤.៤៣១ | ២៦.៥៦១ | ២៩.២៧៣ | ៣៣.០១៧ | ៣៦.៦០៦ | ៣៤.៩៤៩ | ៣៦.៧៧៩ | ៣៩.៥៣២ | ៤២.៧៧៩ | ៤៦.១៦៤ |
| ផ.ស.ស ក្នុងមនុស្សម្នាក់ LCU (ពិត) | ៦.១៩០.២៨៣ | ៤.៦០៥.២៧៥ | ៤.៨៦៩.៥៣១ | ៥.១៦៦.៦៣៩ | ៥.៤៩៣.៤៥៨ | ៥.៨៥០.៦០០ | ៦.១៨៨.១៦២ | ៦.៥៨៨.៨៧៧ | ៧.០២៨.២២១ | ៧.៥៥២.២២២ | ៨.០៥៩.៨៤៦ | ៧.៦៨៣.៦០៧ | ៧.៨២៩.២៦៣ | ៨.១៤១.០៦៤ | ៨.៤៥៨.៨៣៥ | ៨.៨១៥.១២៥ |
| ចំណាត់ថ្នាក់សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស[3] | ១៥០,០ | ១៤៩ | ១៥០ | ១៥០ | ១៥១ | ១៥១ | ១៥០ | ១៥០ | ១៤៩ | ១៥០ | ១៥០ | ១៤៩ | ១៤៧ | ១៤៨ | .. | .. |
| CPIA (ចំណាត់ថ្នាក់សរុប)[2] | ៣,៤ | ៣,៤ | ៣,៤ | ៣,៥ | ៣,៤ | ៣,៤ | ៣,៤ | ៣,៤ | ៣,៤ | ៣,៤ | ៣,៤ | ៣,៤ | ៣,៥ | ៣,៦ | ៣,៦ | .. |
| ការគ្រប់គ្រងសេដ្ឋកិច្ច[2] | ៤,០ | ៤,០ | ៣,៨ | ៣,៨ | ៣,៨ | ៣,៨ | ៤,០ | ៤,០ | ៤,០ | ៤,២ | ៤,២ | ៤,២ | ៤,២ | ៤,២ | ៤,២ | .. |
| គោលនយោបាយរចនាសម្ព័ន្ធ[2] | ៣,៥ | ៣,៣ | ៣,៥ | ៣,៧ | ៣,៧ | ៣,៧ | ៣,៥ | ៣,៥ | ៣,៣ | ៣,៣ | ៣,៣ | ៣,៣ | ៣,៥ | ៣,៥ | ៣,៥ | .. |
| គោលនយោបាយសម្រាប់បរិយាបន្នសង្គម និងសមធម៌[2] | ៣,៤ | ៣,៤ | ៣,៥ | ៣,៥ | ៣,៤ | ៣,៤ | ៣,៤ | ៣,៤ | ៣,៤ | ៣,៤ | ៣,៥ | ៣,៥ | ៣,៦ | ៣,៨ | ៣,៨ | .. |
| ការគ្រប់គ្រងវិស័យសាធារណៈ និងស្ថាប័ន[2] | ២,៧ | ២,៧ | ២,៨ | ២,៨ | ២,៨ | ២,៨ | ២,៧ | ២,៧ | ២,៧ | ២,៦ | ២,៦ | ២,៧ | ២,៨ | ២,៨ | ២,៨ | .. |

សម្គាល់៖ ´..ª បង្ហាញថា ទិន្នន័យមិនអាចរកបាន, E = ប៉ាន់ស្មាន, F = ព្យាករ។ ទិន្នន័យទទួលបានពី MFMOD លុះត្រាតែមានកំណត់សម្គាល់ផ្សេងពីនេះ។
១/ មូលដ្ឋានទិន្នន័យ Haver Analysis, MRV = តម្លៃបច្ចុប្បន្នបំផុត។
២/ មូលដ្ឋានទិន្នន័យសូចនាករការអភិវឌ្ឍពិភពលោក និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក។
៣/ ចំណាត់ថ្នាក់ HDI ឆ្នាំ២០០១ ដែលមានប្រទេសចំនួន ១៧៥ប្រទេស និងក្នុងឆ្នាំ២០១០ ដែលមានប្រទេសចំនួន ១៦៩ប្រទេស។ ការពង្រឹងវិធីសាស្ត្រក្នុងការគណនា HDI បានបណ្តាលឱ្យមានការកើនឡើងគួរឱ្យកត់សម្គាល់នូវចំណាត់ថ្នាក់របស់ប្រទេសនានា។
ប្រភព៖ មូលដ្ឋានទិន្នន័យ MFMOD, WDI របស់ធនាគារពិភពលោក និងមូលដ្ឋានទិន្នន័យ Haver Analysis, មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។

# គន្ថនិទ្ទេស

Angkor Enterprise. 2024. "Monthly Revenue from Angkor Entrance Fees 2024." Angkor Enterprise, Phnom Penh. https://www.angkorenterprise.gov.kh/.

Devadas, S. and N. Loayza. 2018. "When Is a Current Account Deficit Bad?" *Research & Policy Briefs, From the World Bank Malaysia Hub* No. 17, October. World Bank, Washington, DC. https://documents1.worldbank.org/curated/en/507731538487989157/pdf/130415-BRI-PUBLIC-ADD-SERIES-When-is-a-current-account-deficit-bad.pdf.

Food and Agriculture Organization of the United Nations. 2022. Rome. https://www.fao.org/faostat/en/#data.

International Monetary Fund. 2016. "Managing Government Compensation and Employment – Institutions, Policies, and Reform Challenges." Volume 2016, Issue 047. International Monetary Fund, Washington, DC. https://doi.org/10.5089/9781498345774.007.

———. 2024. "Cambodia: 2023 Article IV Consultation" Press Release and Staff Report. International Monetary Fund, Washington, DC. https://www.imf.org/en/Publications/CR/Issues/2024/01/29/Cambodia-2023-Article-IV-Consultation-Press-Release-and-Staff-Report-544276.

Ministry of Agriculture, Forestry and Fisheries. 2023. "Annual report for 2023 and target for 2024." Ministry of Agriculture, Forestry and Fisheries, Phnom Penh.

Ministry of Economy and Finance. 2024a. *Public Debt Statistical Bulletin*, Volume 23, 2024. Ministry of Economy and Finance, Phnom Penh. https://gdicdm.mef.gov.kh/en/2024/08/21/11204.html.

———. 2024b. Government Finance Statistics (GFS) and Tableau des Opérations Financières de l'Etat (TOFE). Ministry of Economy and Finance, Phnom Penh. https://mef.gov.kh/documents-category/publication/tofe/.

Ministry of Planning. 2014. Cambodia Socio-Economic Survey (CSES) 2014. National Institute of Statistics, Ministry of Planning, Ministry of Planning, Phnom Penh. https://nis.gov.kh/index.php/km/.

———. 2019. Cambodia Socio-Economic Survey 2019. National Institute of Statistics Ministry of Planning, Phnom Penh. https://nis.gov.kh/index.php/km/.

———. 2019/20. Cambodia Socio-Economic Survey Reports. 2019/20. https://nis.gov.kh/index.php/km/.

———. 2021. Cambodia Socio-Economic Survey 2021. National Institute of Statistics, Ministry of Planning, Phnom Penh.

———. 2024. Monthly Consumer Price Index 2024. Ministry of Planning, Phnom Penh.

———. 2024. National Accounts 2024. "The Result of the Rebased National Accounts Base Year 2014." Ministry of Planning, Phnom Penh. https://www.nis.gov.kh/index.php/km/21-na/150-national-account-new.

Ministry of Tourism. 2023. "Cambodia Tourism Statistics Report, 2023." Ministry of Tourism, Phnom Penh.

———. 2024. "Monthly Cambodia Tourism Statistics Report," August 2024. Ministry of Tourism, Phnom Penh.

National Bank of Cambodia. 2024. Monetary and Financial Statistics Data 2024. National Bank of Cambodia, Phnom Penh. https://www.nbc.gov.kh/english/economic_research/monetary_and_financial_statistics_data.php.

———. 2024a. "Semi-Annual Report, 2024." National Bank of Cambodia, Phnom Penh. https://www.nbc.gov.kh/download_files/publication/annual_rep_kh/Semi_Final_Report_2024.pdf

———. 2024b. Cambodia Balance of Payments Fourth Quarter 2024. National Bank of Cambodia, Phnom Penh. https://www.nbc.gov.kh/economic_research/balance_of_payment_data.php.

Royal Government of Cambodia. 2023. The 2022 Budget Settlement Law. Royal Government of Cambodia, Phnom Penh. http://www.treasury.gov.kh/document/5.

———. 2024. The 2024 Annual Budget Law. Royal Government of Cambodia, Phnom Penh. https://mef.gov.kh/documents-category/law-and-regulation/.

United States Federal Reserve. 2024. "Federal Reserve issues FOMC statement," Press Release, September 18, Washington, DC. https://www.federalreserve.gov/newsevents/pressreleases/monetary20240918a.htm.

World Bank. 2009. "Cambodia – Rural electrification strategy and implementation plan – final report." World Bank Washington, DC. https://documents1.worldbank.org/curated/en/635301468014998063/pdf/701160ESW0P1140gy0Impl0Plan0P114368.pdf.

———. 2016. Enterprise Survey for Cambodia. World Bank, Washington, DC. https://microdata.worldbank.org/index.php/catalog/2802.

———. 2019. *"Cambodia Economic Update – November 2019: Upgrading Cambodia in Global Value Chains" (English).* Washington, DC: World Bank. https://documents.worldbank.org/en/publication/documents-reports/documentdetail/707971575947227090.

———. 2020. "Lasting Scars of the COVID-19 Pandemic." *Global Economic Prospects,* June 2020. Washington, DC: World Bank. https://elibrary.worldbank.org/doi/epdf/10.1596/978-1-4648-1553-9_ch3.

———. 2022a. "Expecting the Unexpected: Tools and Policy Considerations to Support the Recovery and Resilience of the Tourism Sector." World Bank, Washington, DC. https://documents1.worldbank.org/curated/en/099145008082285386/pdf/P17482108c6d290f809f390a957e71245ac.pdf.

———. 2022b. *Cambodia Economic Update – June 2022: Weathering the Oil Price Shock.* "Special Focus – Post-Pandemic Supply Chain Disruptions: Strategies to Reduce Logistics Costs." (English). Washington, DC: World Bank. https://documents.worldbank.org/en/publication/documents-reports/documentdetail/099315006282226217/p1773400c74b8e06308c8a00ff3a41dd50c.

———. 2023a. Enterprise Survey for Cambodia. World Bank, Washington, DC. https://www.enterprisesurveys.org/content/dam/enterprisesurveys/documents/country/Cambodia-2023.pdf.

———. 2024. "Cambodia: Second-Generation Systematic Country Diagnostic Update." World Bank, Washington, DC, March. https://www.worldbank.org/en/country/cambodia/publication/cambodia-systematic-country-diagnostic-update.

———. 2024a. *Global Economic Prospects, June 2024.* Washington, DC: World Bank. https://www.worldbank.org/en/publication/global-economic-prospects.

———. 2024b. *Commodity Markets Outlook.* Washington, DC: World Bank, April 25. https://www.worldbank.org/en/research/commodity-markets.

———. 2024c. "Cambodia Public Finance Review (PFR) – From Spending More to Spending Better," Chapter 2. World Bank, Washington, DC.

———. 2024d. *Business Ready 2024.* Washington, DC: World Bank. doi:10.1596/978-1-4648-2021-2. License: Creative Commons Attribution CC BY 3.0 IGO. https://openknowledge.worldbank.org/server/api/core/bitstreams/131b6383-30a1-44b3-8e66-f425d715503d/content.

———. 2024e. *Jobs and Technology.* World Bank East Asia and Pacific Economic Update (October 2024). Washington, DC: World Bank. doi: 10.1596/978-1-4648-2175-2. License: Creative Commons Attribution CC BY 3.0 IGO. https://www.worldbank.org/en/publication/east-asia-and-pacific-economic-update.

———. 2024f. *Firm Foundations of Growth: East Asia and Pacific Economic Update, April 2024.* Washington, DC: World Bank. https://openknowledge.worldbank.org/server/api/core/bitstreams/9bf0f0aa-bd08-4c91-b665-caee561fb5d3/content.

———. Forthcoming (a). "The structural foundations of firm productivity in Cambodia." Working Paper, World Bank, Washington, DC.

———. Forthcoming (b). "Domestic Revenue Mobilization in Cambodia: Assessment of major taxes, administration, and options for reform." World Bank, Washington, DC.

THE WORLD BANK
IBRD • IDA | WORLD BANK GROUP
East Asia & Pacific